# សៀវភៅណែនាំសហគមន៍ស្តីពីគោលនយោបាយ ការពារការផ្លាស់ប្តូរទីលំនៅដោយបង្ខំរបស់ ធនាគារអភិវឌ្ឍន៍អាស៊ី

*សៀវភៅណែនាំសម្រាប់បណ្តាសហគមន៍ខ្មែរដែលទទួលរងផលប៉ះពាល់ដោយសារ*
*គម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី*




## សៀវភៅសម្រាប់អ្នកសម្របសម្រួល

បោះពុម្ពផ្សាយដោយអង្គការស្ពានទៅកាន់សន្តិភាពកម្ពុជា

រក្សាសិទ្ធិគ្រប់បែបយ៉ាងដោយអង្គការស្ពានទៅកាន់សន្តិភាព កម្ពុជា ឆ្នាំ២០១១

*សៀវភៅណែនាំសហគមន៍ស្តីពីគោលនយោបាយការពារការផ្លាស់ប្តូរទីលំនៅដោយបង្ខំរបស់ធនាគារអភិវឌ្ឍន៍អាស៊ី*

សៀវភៅណែនាំសម្រាប់អ្នកសម្របសម្រួល

បោះពុម្ពលើកទី១: ខែឧសភា ឆ្នាំ២០១១

យើងលើកទឹកចិត្តឱ្យថតចម្លងផលិតឡើងវិញ ឬក៏យកលំនាំតាមផ្នែកខ្លះ ឬផ្នែកទាំងស្រុងនៃសៀវភៅនេះ ប្រសិនបើផ្នែកដែលបានផលិតឡើងវិញនោះត្រូវបានយោងដល់ការបោះពុម្ពច្បាប់ដើម និងចែកចាយជូនប្រជាពលរដ្ឋប្រើប្រាស់ដោយមិនយកប្រាក់ចំណេញ។ អង្គការ ឬបុគ្គលណាដែលចង់ថតចំលងផលិតឡើងវិញឬយកលំនាំតាមផ្នែកណាមួយ ឬផ្នែកទាំងស្រុងនៃសៀវភៅនេះក្នុងគោលបំណងធ្វើពាណិជ្ជកម្មត្រូវតែសុំការអនុញ្ញាតពីអ្នកនិពន្ធជាមុនសិន។

មុននឹងចាប់ផ្តើមបកប្រែឬយកលំនាំតាមសៀវភៅនេះ ឬខ្លឹមសារនៃសៀវភៅនេះសូមទាក់ទងមកអ្នកនិពន្ធសៀវភៅនេះដើម្បីស្នើសុំយោបល់ ក្នុងការធ្វើបច្ចុប្បន្នភាពព័ត៌មាន ដែលមានក្នុងសៀវភៅនេះ និងដើម្បីចៀសវាងការបកប្រែជាន់គ្នា។ សូមផ្ញើជូនអ្នកនិពន្ធមួយច្បាប់ផងចំពោះឯកសារថតចម្លងទាំងឡាយណា ដែលមានយកអត្ថបទពីសៀវភៅនេះទៅប្រើប្រាស់។

អង្គការស្ពានទៅកាន់សន្តិភាព កម្ពុជា
ផ្ទះលេខ ២៦១AB ផ្លូវលេខ ៣៧១
សង្កាត់បឹងទំពុន ខណ្ឌមានជ័យ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
អ៊ីមែល: office@babcambodia.org
គេហទំព័រ: www.babcambodia.org

គាំទ្រផ្នែកហិរញ្ញវត្ថុដោយ:

Oxfam Australia
THE McKNIGHT FOUNDATION
NORWEGIAN PEOPLE'S AID
OPEN SOCIETY INSTITUTE

## សេចក្តីថ្លែងអំណរគុណ

*សៀវភៅណែនាំសហគមន៍ស្តីពីគោលនយោបាយការពារការផ្លាស់ប្តូរទីលំនៅ ដោយបង្ខំរបស់ធនាគារអភិវឌ្ឍន៍អាស៊ី* នេះជាស្នាដៃស្រាវជ្រាវនិពន្ធ និងបានធ្វើតេស្តនៅមូលដ្ឋាន នៅឆ្នាំ២០១០។ គម្រោងនេះត្រូវបានគាំទ្រដោយអង្គការ Oxfam Australia មូលនិធិ McKnight Foundation ជំនួយនៃប្រជាពលរដ្ឋន័រវេស្សន៍ (NPA) និងវិទ្យាស្ថានសង្គមបើកទូលាយ (OSI)។ យើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះដៃគូទាំងអស់ដែលបានគាំទ្រ និងបង្ក លទ្ធភាពងាយស្រួលដល់យើងខ្ញុំក្នុងការ អនុវត្តគម្រោងនេះឱ្យកើតចេញជាការពិត។

**អ្នកនិពន្ធ:**

ណាតាលី ប៊ូហ្គាស្គី (Natalie Bugalski)

**ប្រធានកែសម្រួល**

ដេវីត ព្រេត (David Pred)

**ក្រុមត្រួតពិនិត្យ:**

សៅ សុធារី

អៀង វុទ្ធី (ភូ លី)

ប៊ុន មករា

ចាន់ វិចិត្រ

ណាតាលី ប៊ូហ្គាស្គី

ជូសលីន មីដាឡូ

**ក្រុមធ្វើតេស្ត**

សៅ សុធារី

អៀង វុទ្ធី (ភូ លី)

ប៊ុន មករា

ចាន់ វិចិត្រ

អាស៊ីសះ

សៀ ភារម្យ

អ៊ី សារ៉ុម

ណើប លី

**រូបភាព:**

រូបភាពសម្រាប់សៀវភៅនេះបានផ្តល់ជូនដោយវិចិត្រករ

**សៀវភៅយើង**

(http://www.siewphewyeung.org.kh/)

សឿន ខូ (អ្នកសម្របសម្រួល)

ម៉ើឌីយ៉ា ដារ៉ាវុធ

ចាន់ នី

តិក ទេវិន

ចាន់ ពិសី

ម៉ើឌីយ៉ា ដារ៉ាវុធ (ជំនួយការផ្នែកក្រាហ្វិក)

**រចនាក្រាបដោយ:**

ចាន់ វិចិត្រ

**បកប្រែដោយ:**

សេក សុខា

អៀង វុទ្ធី (ភូ លី)

# មាតិកា

សេចក្តីផ្តើម------------------------------------------------------ ១
សេចក្តីណែនាំពីការប្រើប្រាស់សៀវភៅ------------------------------------i
១.　ការរៀបចំវគ្គបណ្តុះបណ្តាល ------------------------------------------i
២.　ការចាប់ផ្តើមវគ្គបណ្តុះបណ្តាល------------------------------------------ iv
៣.　ការបង្រៀនបែបអន្តរសកម្ម--------------------------------------------- v
៤.　វិធីសាស្ត្របង្រៀន -------------------------------------------------- vii
៥.　កិច្ចតែងការបង្រៀន ----------------------------------------------- xiii
៦.　ជំនាញសម្របសម្រួល --------------------------------------------------xv
៧.　ការវាយតម្លៃ -------------------------------------------------------xx
៨.　ការរក្សាកំណត់ហេតុ -------------------------------------------------xxi
តារាងពេលវេលា ---------------------------------------------------xxii

ធនាគារអភិវឌ្ឍន៍អាស៊ី ------------------------------------------------- ១
១.　តើធនាគារអភិវឌ្ឍន៍អាស៊ីជាអ្វី?~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ១
២.　តើគម្រោងប្រភេទអ្វីខ្លះដែលធនាគារអភិវឌ្ឍន៍អាស៊ីគាំទ្រ? ~~~~~~~~~~~~~~~~~~~~~~~~~~~~~ ២
៣.　ធនាគារអភិវឌ្ឍន៍អាស៊ីនៅក្នុងប្រទេសកម្ពុជា~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ៣
　លំហាត់ទី១:　តើធនាគារអភិវឌ្ឍន៍អាស៊ីជាអ្វីនិងធ្វើអ្វី?---------------------------------------- ៥

ផលប៉ះពាល់ពីគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ------------------------------------ ៩
១.　គម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី　និងបេសកកម្មរបស់ធនាគារនេះ ----------------------- ៩
២.　ការបង្កើតគោលនយោបាយការពារ-----------------------------------------១២
៣.　ហេតុអ្វីបានជាយើងចាំបាច់ត្រូវដឹងអំពីគោលនយោបាយការពារទាំងនេះ? ---------------------១៣
　លំហាត់ទី២:　ផលប៉ះពាល់ពីគម្រោងគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី----------------------- ១៥

**គោលនយោបាយការពារការផ្លាស់ប្តូរទីលំនៅដោយបង្ខំ ------------------------------ ២៣**

**១.** គម្រោងគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី និងការផ្លាស់ប្តូរទីលំនៅ ---------------------- ២៣

**២.** គោលនយោបាយស្តីពីការតាំងទីលំនៅថ្មីដោយបង្ខំ ------------------------------------ ២៤

**៣.** ការផ្លាស់ប្តូរទីលំនៅថ្មីប្រភេទណាខ្លះ ដែលត្រូវការពារដោយគោលនយោបាយនេះ? -------------- ២៥

**៤.** ការបញ្ចៀសការផ្លាស់ប្តូរទីលំនៅ ---------------------------------------------- ២៧

លំហាត់ទី៣: ការបញ្ចៀសការផ្លាស់ប្តូរទីលំនៅ ----------------------------------- ២៩

**ការតាំងទីលំនៅថ្មីដោយបង្ខំ និង សិទ្ធិទទួលសំណង ----------------------- ៣៥**

**១.** មិនត្រូវធ្វើឱ្យប្រជាពលរដ្ឋធ្លាក់កាន់តែក្រជាងមុនឡើយ ------------------------------ ៣៥

**២.** សិទ្ធិទទួលសំណងខុសៗគ្នា សម្រាប់ម្ចាស់កម្មសិទ្ធិ អ្នកកាន់កាប់ស្របច្បាប់ និងអ្នកកាន់កាប់ខុសច្បាប់--- ៣៦

**៣.** សំណងជារបស់ជំនួស ឬសំណងជាសាច់ប្រាក់? ------------------------------------ ៣៨

លំហាត់ទី៤: សិទ្ធិទទួលសំណង ដី ឬ ប្រាក់? ------------------------------------- ៤០

**៤.** តើប្រជាពលរដ្ឋគប្បីទទួលសំណងចំនួនប៉ុន្មាន? --------------------------------------- ៤៦

**៥.** តើប្រជាពលរដ្ឋត្រូវទទួលបានអ្វីខ្លះ ប្រសិនបើពួកគាត់ត្រូវតាំងទីលំនៅថ្មី? ------------------- ៤៧

**៦.** ការចរចាជាមួយរដ្ឋាភិបាល ------------------------------------------------- ៤៨

លំហាត់ទី៥: សំណង និងការតាំងទីលំនៅថ្មី --------------------------------------- ៤៩

**៧.** តើប្រជាពលរដ្ឋត្រូវទទួលបានអ្វី ប្រសិនបើពួកគាត់បាត់បង់ឱកាសប្រកប អាជីវកម្ម បាត់បង់ការងារ ឬការប្រកបរបរ ចិញ្ចឹមជីវិតផ្សេងៗទៀត? ----------------------------------- ៥៦

លំហាត់ទី៦: សំណងសម្រាប់ការបាត់បង់មុខរបរចិញ្ចឹមជីវិត ---------------------------- ៥៩

**៨.** ការគាំទ្រការប្រកបរបរចិញ្ចឹមជីវិត --------------------------------------------- ៧០

**៩.** ការទទួលផលប្រយោជន៍រួមពីគម្រោង ------------------------------------------ ៧២

លំហាត់ទី៧: ការគាំទ្រការប្រកបរបរចិញ្ចឹមជីវិត ------------------------------------ ៧៣

**ព័ត៌មាន និង ការពិគ្រោះយោបល់ ------------------------------------- ៧៩**

**១.** កាតព្វកិច្ចរបស់រដ្ឋាភិបាលក្នុងការផ្តល់ព័ត៌មាន និងពិគ្រោះយោបល់ជាមួយ ប្រជាពលរដ្ឋ ----------- ៧៩

**២.** តើព័ត៌មានអ្វីខ្លះដែលចាំបាច់ត្រូវតែមានសម្រាប់ប្រជាពលរដ្ឋ? ------------------------------ ៨១

**៣.** ព័ត៌មានត្រូវតែមានលក្ខណៈងាយយល់ ------------------------------------------ ៨២

**៤.** ការពិនិត្យព័ត៌មាននៅក្នុងផែនការតាំងទីលំនៅថ្មី ------------------------------------ ៨៣

លំហាត់ទី៨: ការរៀបចំព័ត៌មានដែលប្រជាពលរដ្ឋងាយយល់ ---------------------------------- ៨៥
៥. តើការពិគ្រោះយោបល់ត្រឹមត្រូវមានន័យដូចម្តេច? ------------------------------------------៩០
៦. តើត្រូវពិគ្រោះយោបល់ជាមួយអ្នកណា? ---------------------------------------------------- ៩១
៧. តើរដ្ឋាភិបាលត្រូវតែពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ នៅពេលណា? -----------------------៩២
លំហាត់ទី៩: តើការពិគ្រោះយោបល់ត្រឹមត្រូវមានន័យដូចម្តេច? ----------------------------- ៩៤

ការទទួលខុសត្រូវរបស់រដ្ឋាភិបាល និង ធនាគារអភិវឌ្ឍន៍អាស៊ី---------------------- ១០៣
១. គោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីមិនត្រូវបានគេគោរពជានិច្ចនោះទេ---------------- ១០៣
២. ការធ្វើឱ្យរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ីមានការទទួលខុសត្រូវ ----------------------១០៤
៣. ការតាមដានគម្រោង-------------------------------------------------------------------១០៥
លំហាត់ទី១០: ការតាមដានគម្រោង ---------------------------------------------------១០៨
៤. ការដោះស្រាយបញ្ហានានានៅមូលដ្ឋាន --------------------------------------------------១១២
លំហាត់ទី១១: ការធ្វើឱ្យរដ្ឋាភិបាលនិងធនាគារអភិវឌ្ឍន៍អាស៊ីទទួលខុសត្រូវ: យន្តការនៅមូលដ្ឋាន ------១១៧
៥. ការប្រើប្រាស់យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី---------------------------១២១
លំហាត់ទី១២: យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី -------------------------១២៨
៦. ទម្រង់ផ្សេងៗនៃការតស៊ូមតិ --------------------------------------------------------- ១៣៣
លំហាត់ទី១៣: ការប្រើប្រាស់ទម្រង់ផ្សេងៗនៃការតស៊ូមតិដើម្បីធ្វើឱ្យធនាគារអភិវឌ្ឍន៍អាស៊ីមានការទទួលខុសត្រូវ ១៤០

សទ្ទានុក្រម--------------------------------------------------------------------------១៤៩
ព័ត៌មានសម្រាប់ទាក់ទង ---------------------------------------------------------------១៥៥
សំណួរស្ទាបស្ទង់ចំណេះដឹងអ្នកចូលរួម មុន និង ក្រោយវគ្គបណ្តុះបណ្តាល -------------១៦៣

# សេចក្តីផ្តើម

ធនាគារអភិវឌ្ឍន៍អាស៊ី ធ្វើការជាមួយរដ្ឋាភិបាលនៅទូទាំងតំបន់ ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ធ្វើសេចក្តីព្រាងច្បាប់ និងគោលនយោបាយនានា និងកសាងសមត្ថភាពបច្ចេកទេសរបស់បុគ្គលិករដ្ឋ។ ធនាគារនេះបានបញ្ជាក់យ៉ាងច្បាស់ថា បេសកកម្មរបស់ខ្លួនគឺ ដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់គុណភាពនៃជីវភាពរស់នៅ។ ប៉ុន្តែប្រជាជនជាង ១០០.០០០នាក់នៅក្នុងតំបន់អាស៊ីបានទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរក្នុងមួយឆ្នាំៗដោយសារគម្រោងដែលផ្តល់មូលនិធិដោយធនាគារអភិវឌ្ឍន៍អាស៊ី។ ការបណ្តេញចេញពីលំនៅដ្ឋាន ដីធ្លី និងពីកន្លែងប្រកបរបរចិញ្ចឹមជីវិត ដើម្បីយកដីសម្រាប់ "គម្រោងអភិវឌ្ឍន៍" គឺជាផលប៉ះពាល់មួយយ៉ាងធ្ងន់ធ្ងរក្នុងចំណោមផលប៉ះពាល់នានា ដែលកើតមានលើប្រជាជននៅតាមសហគមន៍។

មានប្រជាជនជាច្រើននៅក្នុងពិភពលោកបានធ្លាក់ខ្លួនកាន់តែក្រ និងមានការលំបាកយ៉ាងធ្ងន់ធ្ងរ ដោយសារតែការផ្លាស់ប្តូរទីលំនៅ។ ផ្ទុយពីការទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍ ប្រជាជនទាំងនោះបែរជាអ្នកខាតបង់ រីឯជីវភាពរបស់ពួកគាត់ក៏កាន់តែដុនដាបដោយសារតែគម្រោងដែលផ្តល់មូលនិធិដោយធនាគារអភិវឌ្ឍន៍អាស៊ីទៅវិញ បើទោះបីជាធនាគារនេះបានបញ្ជាក់អំពីបេសកកម្មរបស់ខ្លួនយ៉ាងច្បាស់យ៉ាងណាក៏ដោយ។ ជាទូទៅ គេមិនបានផ្តល់ឱកាសជូនសហគមន៍ទាំងនោះ ដើម្បីចូលរួមក្នុងការសម្រេចចិត្តថា តើគប្បីត្រូវអនុវត្តគម្រោងអភិវឌ្ឍន៍នោះ និងថាតើពួកគាត់ត្រូវទទួលរងផលប៉ះពាល់ក្នុងកម្រិតណា។

ដោយមានការទទួលស្គាល់អំពីបញ្ហាទាំងអស់នេះ ធនាគារអភិវឌ្ឍន៍អាស៊ីបានរៀបចំឡើងវិញនូវគោលនយោបាយរបស់ខ្លួន ស្តីពីការតាំងទីលំនៅដោយបង្ខំ នៅឆ្នាំ២០០៩។ គោលបំណងធំៗនៃគោលនយោបាយនេះគឺដើម្បីបញ្ចៀស និងបន្ថយការផ្លាស់ប្តូរទីលំនៅឱ្យនៅតិចបំផុត ព្រមទាំងដើម្បីធានាថា គ្មានប្រជាពលរដ្ឋណាម្នាក់ត្រូវធ្លាក់ខ្លួនកាន់តែដុនដាបជាងមុន ដោយសារតែគម្រោង ដែលផ្តល់មូលនិធិដោយធនាគារអភិវឌ្ឍន៍អាស៊ីទេ។

សៀវភៅណែនាំនេះ ព្យាយាមធ្វើឱ្យប្រជាពលរដ្ឋខ្មែរដែលទទួលរងផលប៉ះពាល់ដោយសារតែគម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី អាចយល់ និងអាចប្រើប្រាស់គោលនយោបាយនេះបាន។ សៀវភៅណែនាំនេះក៏ព្យាយាមផ្ទេរជំនាញនានាដែលជាការចាំបាច់ដើម្បីឱ្យសហគមន៍ក្លាយជាអ្នកចេះតាមដានគម្រោងទាំងនេះ។ សៀវភៅណែនាំនេះនឹងពន្យល់ប្រជាពលរដ្ឋខ្មែរអំពីយន្តការបណ្តឹងនៅមូលដ្ឋាន យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍ និងពិភាក្សាអំពីការប្រើប្រាស់ទម្រង់ផ្សេងៗនៃការតស៊ូមតិ ដើម្បីឱ្យសហគមន៍អាចប្រើប្រាស់ព័ត៌មានដើម្បីការពារសិទ្ធិរបស់គាត់ និងដើម្បីធ្វើឱ្យធនាគារអភិវឌ្ឍន៍អាស៊ី និងរដ្ឋាភិបាលមានការទទួលខុសត្រូវ។

សៀវភៅសម្រាប់អ្នកសម្របសម្រួលនេះមានប្រើសកម្មភាពអន្តរសកម្មនានា ដើម្បីជួយឱ្យប្រជាពលរដ្ឋយល់ព័ត៌មាន ចូលរួមពិភាក្សា និងអាចរៀនចេះជំនាញសំខាន់ៗ ទោះបីជាពួកគាត់មិនចេះអាន និងសរសេរអក្សរក៏ដោយ។ តាមវិធីនេះ ម្នាក់ៗសុទ្ធតែអាចចូលរួមក្នុងការតាមដានគម្រោង ដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីឱ្យដឹងថា តើគេគោរពតាមគោលនយោបាយស្តីពីការតាំងទីលំនៅដោយបង្ខំដែរឬទេ និងដើម្បីចាត់វិធានការការពារសិទ្ធិរបស់ពួកាគាត់ នៅពេលដែលមានការរំលោភគោលនយោបាយទាំងនេះ។

# សេចក្ដីណែនាំពីការប្រើប្រាស់សៀវភៅ

*សៀវភៅណែនាំសហគមន៍ស្ដីពីគោលនយោបាយការពារការផ្លាស់ប្ដូរទីលំនៅ ដោយបង្ខំរបស់ធនាគារអភិវឌ្ឍន៍អាស៊ី* ត្រូវបានរៀបចំ និងសរសេរឡើង ដើម្បីឱ្យមានភាពងាយស្រួលយល់ដល់សហគមន៍នានា រួមទាំងអ្នកទាំងឡាយដែលរៀនបានតិចតួច និងមានចំណេះដឹងតិចតួច ឬគ្មានចំណេះដឹងសោះអំពីប្រធានបទទាំងនោះ។ ភាសាដែលប្រើក្នុងសៀវភៅនេះ ជាភាសាសាមញ្ញ និងងាយយល់ ចំណែកឯលំហាត់វិញក៏ប្រើវិធីសាស្ត្រអន្តរសកម្ម និងគួរឱ្យចង់រៀន។

សៀវភៅណែនាំនេះ អាចប្រើប្រាស់សម្រាប់អ្នក ដែលចង់សម្របសម្រួលវគ្គសិក្ខាសិលាបណ្ដុះបណ្ដាល និងអ្នកដែលចង់ប្រើប្រាស់ព័ត៌មាននៅក្នុងសៀវភៅនេះតាមលក្ខណៈសាមញ្ញ។ សៀវភៅណែនាំនេះ បានបង្កើតឡើងសម្រាប់អ្នកសម្របសម្រួល និងអ្នកចូលរួម។ សៀវភៅសម្រាប់អ្នកសម្របសម្រួលមានបញ្ចូលគ្រប់ការណែនាំ និងព័ត៌មានសំខាន់ៗទាំងអស់ ដែលអ្នកត្រូវការដើម្បីធ្វើឱ្យវគ្គបណ្ដុះបណ្ដាលនេះមានដំណើរការទៅយ៉ាងល្អ ។ សៀវភៅសម្រាប់អ្នកចូលរួមមានត្រឹមតែព័ត៌មាន នៅលើប្រធានបទនិមួយៗតែប៉ុណ្ណោះ ដោយគ្មានការណែនាំរបស់អ្នកសម្របសម្រួលទេ។ វាមានអត្ថប្រយោជន៍ណាស់ ក្នុងការផ្ដល់ឯកសារចម្លងនៃសៀវភៅសម្រាប់អ្នកចូលរួមទៅមនុស្ស ដែលបានមកចូលរួមនូវវគ្គបណ្ដុះបណ្ដាលរបស់អ្នក។

ជំពូកបន្តទៅនេះមានសេចក្ដីពន្យល់ពីរបៀបងាយៗដើម្បីប្រើប្រាស់សៀវភៅនេះ និងពីរបៀបរៀបចំកិច្ចតែងការបង្រៀន ព្រមទាំងពីរបៀបនៃការបើកវគ្គបណ្ដុះបណ្ដាលដោយប្រើប្រាស់សៀវភៅណែនាំនេះជាឧបករណ៍សំរាប់បង្រៀន និងសំរាប់រៀន។

## ១. ការរៀបចំវគ្គបណ្ដុះបណ្ដាល

ជំហានដំបូង អ្នកត្រូវរៀបចំវគ្គបណ្ដុះបណ្ដាល។ ក្នុងជំហាននេះ អ្នកត្រូវត្រៀមឱ្យបានល្អិតល្អន់ ចាប់ពីការរកកន្លែងសំរាប់បើកវគ្គបណ្ដុះបណ្ដាល ការជ្រើសរើសយកជំពូក និងប្រធានបទដើម្បីបង្រៀនឱ្យបានរួចស្រេចទុកជាមុន ហើយត្រូវពិនិត្យមើលឱ្យដឹងច្បាស់ថា សព្វបែបយ៉ាងត្រូវបានត្រៀមរួចរាល់តាមសេចក្ដីត្រូវការ និងស៊ីសង្វាក់គ្នា។ ប្រសិនបើកិច្ចការ និងសម្ភារៈទាំងអស់នោះរៀបចំមិនបានល្អទុកជាមុនទេ នោះការបណ្ដុះបណ្ដាលក៏មិនអាចទទួលបានលទ្ធផលល្អដែរ។ អ្នករៀបចំត្រូវពិចារណា និងគិតឱ្យបានដិតដល់នៅពេលរៀបចំបើកវគ្គបណ្ដុះបណ្ដាលនូវចំណុចដូចមានរាយខាងក្រោមនេះ:

### ១.១. ការជ្រើសរើសកន្លែងសំរាប់វគ្គបណ្ដុះបណ្ដាល

ពេលខ្លះអ្នកអាចបើកវគ្គបង្រៀននៅឯមូលដ្ឋាន។ តែពេលខ្លះអ្នកត្រូវរក ឬ ជួលកន្លែងណាមួយដែលសមរម្យល្មម ដើម្បីងាយស្រួលក្នុងការបណ្ដុះបណ្ដាលនេះ ។ ត្រូវចាំថា អ្នកត្រូវធ្វើយ៉ាងណាឱ្យកន្លែងរៀនមានភាពស្ងប់ស្ងាត់ល្អ

មានពន្លឺគ្រប់គ្រាន់ និងទូលាយល្មមដើម្បីឱ្យអ្នកចូលរួមអាចអង្គុយរៀន និងធ្វើកិច្ចការនានាបានស្រួល។ ត្រូវរក ឬ ជួល កន្លែងឱ្យបានយ៉ាងតិចពីរសប្តាហ៍មុនថ្ងៃបើកវគ្គបណ្តុះបណ្តាល។

## ១.២. អ្នកចូលរួម

អ្នកចាំបាច់ត្រូវកំណត់ឱ្យបានច្បាស់ថា តើអ្នកណាខ្លះគួរមកចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ។ អ្នកចូលរួមនេះអាចជាក្រុមពលរដ្ឋ ឬតំណាងប្រជាពលរដ្ឋដែលកំពុងទទួលរងផលប៉ះពាល់ដោយសារគម្រោងណាមួយ ដែលផ្តល់មូលនិធិដោយធនាគារអភិវឌ្ឍន៍អាស៊ី។ គោលបំណងយ៉ាងសំខាន់នៃសិក្ខាសាលានេះជាទូទៅគឺដើម្បីបង្រៀនអ្នកតាមដាន ដែលជាសមាជិកសហគមន៍ ដើម្បីជ្រើសរើសតំណាងសហគមន៍ដែលចំណាយពេលវេលាសមស្រប និងគោរពសហគមន៍របស់ខ្លួន។

អ្នកត្រូវប្រាកដថា ស្ត្រីនឹងត្រូវបានអញ្ជើញឱ្យមកចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងប្រសិនបើអាចធ្វើបានត្រូវមានស្ត្រីចូលរួមយ៉ាងតិចបំផុតពាក់កណ្តាល។ ប្រសិនបើមានក្រុមជនជាតិនានាដែលទទួលរងផលប៉ះពាល់ដោយសារគម្រោងនោះ ដូចជា ជនជាតិចាម ឬជនជាតិដើមភាគតិច អ្នកត្រូវលើកទឹកចិត្តពួកគាត់ឱ្យចូលរួម។ ត្រូវប្រាកដថា ម្នាក់ៗមានសិទ្ធិទទួលបានការគោរពស្មើៗគ្នានៅពេលចូលរួមវគ្គបណ្តុះបណ្តាល។

អ្នកក៏គប្បីត្រូវពិចារណាដែរថា តើអ្នកណាអាចចូលរួមវគ្គបណ្តុះបណ្តាលនេះតាំងពីដើមវគ្គរហូតដល់ចប់។ សូមគិតថា តើប្រជាពលរដ្ឋប៉ុន្មានអ្នកដែលត្រូវមកចូលរួម ដែលជាទូទៅចំនួនអ្នកចូលរួមគឺរវាងពី២០ ទៅ៣០នាក់។ សូមព្យាយាមស្វែងយល់ឱ្យបានកាន់តែច្រើនកាន់តែល្អ អំពីស្ថានភាពរបស់សហគមន៍ទាំងនេះ និងអំពីគម្រោងដែលធ្វើឱ្យប៉ះពាល់ដល់ពួកគាត់។ ឧទាហរណ៍ សូមព្យាយាមរក និងអានឯកសារអំពីផែនការតាំងទីលំនៅថ្មី សម្រាប់សហគមន៍ ដែលនឹងត្រូវមកចូលរួមក្នុងវគ្គបណ្តុះបណ្តាល។

## ១.៣. ការជូនដំណឹង និង ការអញ្ជើញ

ត្រូវប្រាកដថា អ្នកបានជូនដំណឹងដល់អ្នកចូលរួមអំពីកាលបរិច្ឆេទ នៃវគ្គបណ្តុះបណ្តាលនេះច្បាស់លាស់ជាមុន។ នៅពេលជិតដល់ថ្ងៃកំណត់ អ្នកគប្បីរំឭកពួកគាត់ផងតាមរយៈទូរស័ព្ទ ឬ តាមមធ្យោបាយណាដែលអាចធ្វើទៅបាន។

## ១.៤. របៀបវារៈ

របៀបវារៈត្រូវកំណត់ផែនការសម្រាប់ដំណើរការនៃវគ្គបណ្តុះបណ្តាលមួយថ្ងៃៗ។ ជាទូទៅ ដើម្បីធ្វើលំហាត់ទាំងអស់ ដែលមាននៅក្នុងសៀវភៅណែនាំនេះ អ្នកនឹងត្រូវការរយៈពេលបួនថ្ងៃ។ នេះគិតទាំងពេលសម្រាប់ការពិភាក្សាទូទៅ និងសម្រាប់ការធ្វើផែនការ នៅពេលចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល។

អ្នកត្រូវលៃពេលវេលាឱ្យបានគ្រប់គ្រាន់ សម្រាប់បង្រៀនមេរៀនគ្រប់មេរៀន។ អ្នកក៏ត្រូវគិតដែរ អំពីពេលសម្រាក ពេលអាហារថ្ងៃត្រង់ និងពេលលេងល្បែងបង្កើនថាមពល (នឹងមានសេចក្តីពន្យល់លំអិតនៅខាងក្រោម)។ សូមកុំព្យាយាមធ្វើច្រើនពេកក្នុងមួយថ្ងៃៗ។

## ១.៥. ការផ្តល់ដំណឹងដល់អាជ្ញាធរ

ត្រូវពិចារណាឱ្យបានហ្មត់ចត់ថាគួរប្រាប់ដំណឹងពីវគ្គបណ្តុះបណ្តាលនេះដល់អាជ្ញាធរដែរឬទេ។

## ១.៦. សៀវភៅសម្រាប់អ្នកចូលរួម

វាជាគំនិតមួយល្អដែលត្រូវផ្តល់ឯកសារព័ត៌មានទាំងអស់ដែលបានបង្រៀនជូនអ្នកចូលរួម នៅចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាលនីមួយៗ។ ដូច្នេះអ្នកត្រូវមានសៀវភៅសម្រប់អ្នកចូលរួម ឱ្យបានគ្រប់គ្រាន់សម្រាប់អ្នកចូលរួមម្នាក់ៗ។ សៀវភៅនេះមាននៅអង្គការស្ពានទៅកាន់សន្តិភាពកម្ពុជា។

## ១.៧. ត្រូវត្រៀមមេរៀនឱ្យបានល្អិតល្អន់

ត្រូវប្រាកដថា អ្នកយល់ និងដឹងឱ្យបានល្អិតល្អន់ពីមេរៀន ដែលខ្លួននឹងបង្រៀននិងត្រូវប្រាកដថា មុនថ្ងៃចាប់ផ្តើមវគ្គបណ្តុះបណ្តាល អ្នកមានសម្ភារៈចាំបាច់ៗទាំងអស់ សំរាប់ប្រើការក្នុងមេរៀននីមួយៗ រួមទាំងត្រូវមានឯកសារសម្រាប់ចែកជូនអ្នកចូលរួមផង។ ប្រសិនបើមានអ្នកសម្របសម្រួលច្រើន អ្នកត្រូវប្រាកដថា អ្នកបានសម្រេចរួចហើយថា អ្នកណាជាអ្នកទទួលខុសត្រូវបង្រៀនមេរៀនណា និងធ្វើសកម្មភាពណាខ្លះសំរាប់មេរៀននីមួយៗ។

| តារាងផ្ទៀងផ្ទាត់កិច្ចការមុនពេលបណ្តុះបណ្តាល |
|---|
| មុននឹងបើកវគ្គបណ្តុះបណ្តាលណាមួយអ្នកត្រូវពិនិត្យមើល តើអ្នកបានធ្វើគ្រប់ចំណុចខាងក្រោមនេះហើយឬនៅ: |
| រៀបចំកន្លែងសំរាប់វគ្គបណ្តុះបណ្តាល ☑ |
| កំណត់ថា អ្នកណាខ្លះត្រូវចូលរួម ហើយត្រូវយកមនុស្សប៉ុន្មាននាក់ ☑ |
| អញ្ជើញអ្នកចូលរួមឱ្យបានមុនពេលបើកវគ្គ និងត្រូវរំឭកពួកគាត់ពេលជិតដល់ថ្ងៃកំណត់ ។ ☑ |
| ព្យាយាមស្វែងយល់អំពីប្រវត្តិស្ថានភាពរបស់អ្នកចូលរួម និងគម្រោងដែលផ្តល់មូលនិធិដោយធនាគារអភិវឌ្ឍន៍អាស៊ី ដែលធ្វើឱ្យប៉ះពាល់ដល់ពួកគាត់។ ☑ |
| រៀបចំរបៀបវារៈ ☑ |
| ជូនដំណឹងដល់អាជ្ញាធរ ប្រសិនបើចាំបាច់ ☑ |
| មានសៀវភៅសម្រាប់អ្នកចូលរួម (សៀវភៅមេរៀន) ឱ្យបានគ្រប់គ្រាន់សម្រាប់អ្នកចូលរួម ☑ |
| រៀបចំសម្ភារៈសម្រាប់បង្រៀនឱ្យបានគ្រប់គ្រាន់ ឧទាហរណ៍ដូចជា ក្រដាស ប៊ិច និងមេរៀនសម្រាប់ចែក ☑ |
| កែសំរួល និងហាត់អនុវត្តមេរៀនដើម្បីឱ្យអ្នកមានទំនុកចិត្តក្នុងការបង្រៀន ☑ |

## ២. ការចាប់ផ្តើមវគ្គបណ្តុះបណ្តាល

នៅថ្ងៃបើកវគ្គ អ្នកសម្របសម្រួលត្រូវមកកន្លែងបណ្តុះបណ្តាលឱ្យបានមុនគេ ដើម្បីពិនិត្យមើលឱ្យប្រាកដប្រជាថាអ្វីៗសព្វបែបយ៉ាងដែលត្រូវការសម្រាប់ដំណើរការមានគ្រប់គ្រាន់ និងរួចរាល់អស់ហើយ ។ រៀបចំសំភារៈសំរាប់បង្រៀនឱ្យមានលំដាប់លំដោយ និងឱ្យនៅជិតៗខ្លួន ដើម្បីងាយស្រួលឈោងយកមកប្រើប្រាស់នៅពេលកំពុងបង្រៀន។ បើនៅកន្លែងនោះមានតុ និងកៅអី ត្រូវគិតមើលថារៀបយ៉ាងដូចម្តេច។ ជួនកាលវាអាចផ្តល់ភាពងាយស្រួលដល់ដំណើរការរៀនសូត្រ បើសិនជារៀបចំតុកៅអីជារង្វង់ដើម្បីឱ្យអ្នកចូលរួមគ្រប់គ្នាអាចមើលឃើញមុខគ្នាទៅវិញទៅមក និងជៀសវាងការអង្គុយមើលខ្នងគ្នា។ អង្គុយជារង្វង់យ៉ាងនេះ អាចជួយឱ្យវគ្គបណ្តុះបណ្តាលកាន់តែមានលក្ខណៈអន្តរសកម្ម ហើយគ្រប់គ្នាមានអារម្មណ៍ថាបានចូលរួមទាំងអស់គ្នា ។

នៅពេលអ្នកចូលរួមបានមកដល់ និងបានចូលអង្គុយតាមកន្លែងស្រួលបួលហើយ ជំហានដំបូងគឺអ្នកសំរបសំរួលត្រូវធ្វើការណែនាំខ្លួនឯងឱ្យពួកគាត់បានស្គាល់ជាមុនសិន ហើយចាំឱ្យពួកគាត់ណែនាំខ្លួនឱ្យអ្នកស្គាល់វិញ។ ពិធីស្វាគមន៍នេះត្រូវធ្វើឡើងរាល់ពេលចាប់ផ្តើមបើកវគ្គបណ្តុះបណ្តាល។ ដើម្បីឱ្យការបើកវគ្គមានភាពប្រសើរ និងជៀសវាងការធុញថប់ ត្រូវលៃយ៉ាងណាកុំឱ្យដំណើរនៃការណែនាំខ្លួននោះវែងហួសហេតុពេក ត្រូវធ្វើឱ្យខ្លីល្មមបានហើយ ឬ ក៏ប្រើវិធីណែនាំខ្លួនដោយលេងជាល្បែង ឬ ប្រើវិធីណាមួយដែលបង្កឱ្យមានការសើចសប្បាយក៏បាន ។ ការណែនាំខ្លួននេះអាចធ្វើតាមរបៀបសាមញ្ញ ដូចជាឱ្យម្នាក់ៗប្រាប់ឈ្មោះរបស់ខ្លួនមកពីស្រុក ឬ ភូមិណា ឬ ចូលចិត្តម្ហូបអីជាងគេ ឬ ក៏ចូលចិត្តបទចម្រៀងណាជាងគេជាដើម ។



វាក៏ជាគំនិតល្អដែរបើចាប់ផ្ដើមបើកវគ្គ ដោយពន្យល់អំពីគោលបំណងសំខាន់ៗនៃវគ្គបណ្ដុះបណ្ដាល ដល់អ្នកចូលរួមឱ្យបានយល់គ្រប់ៗគ្នា ។ ឆ្លៀតឱកាសនេះដើម្បីពន្យល់ថ្នាក់ទាំងមូលពីបទបញ្ជាខ្លះៗនៅក្នុងថ្នាក់ ដូចជា គ្រប់គ្នាត្រូវបិទទូរស័ព្ទដៃទាំងអស់ ឬ ក៏ត្រូវបន្ថយសម្លេងទូរស័ព្ទ កុំឱ្យរំខានដល់អ្នកឯទៀតពេលកំពុងរៀន គួរគិតគ្រែងអ្នកដទៃនៅជុំវិញខ្លួន និង ផ្ដល់ឱកាសឱ្យអ្នកជិតខាងខ្លួនបានឡើងនិយាយផងជាដើម។ នេះក៏ជាឱកាសល្អសំរាប់សាកសួរពីការរំពឹងទុករបស់ពួកគាត់ដូចជា តើពួកគាត់សង្ឃឹមថានឹងបានរៀនសូត្រពីអ្វីខ្លះនៅក្នុងវគ្គបណ្ដុះបណ្ដាលនេះ។ អ្នកអាចចុចសួរអ្នកចូលរួម ម្នាក់ ឬពីរនាក់ ឬក៏ឱ្យក្រុមទាំងមូលប្រាប់ពីចំណេះដឹងមួយដែលពួកគាត់សង្ឃឹមថា នឹងបានរៀនក្នុងវគ្គបណ្ដុះបណ្ដាលនេះ។ នៅចុងវគ្គអ្នកអាចរំលឹកពីការរំពឹងទុករបស់ពួកគាត់ ហើយឱ្យពួកគាត់ថ្លឹងថ្លែងមើល ថាតើពួកគាត់សម្រេចបាននូវចំណេះ ដឹង (វិជ្ជា) ដែលពួកគាត់ចង់រៀនកាលពីផ្ដើមវគ្គនោះដែរឬទេ។

## ៣. ការបង្រៀនបែបអន្តរសកម្ម

វិធីសាស្ត្របង្រៀន ដែលទទួលបានផលល្អជាងគេបំផុតគឺការបង្រៀនបែបលក្ខណៈអន្តរសកម្មដែលមានសកម្មភាពផ្ដោតការយកចិត្តទុកដាក់មកលើអ្នកចូលរួមជាជាងអ្នកសម្របសម្រួល។ ការប្រើប្រាស់វិធីនេះ អាចជួយឱ្យអ្នកចូលរួមរៀនឆាប់ចេះ និងចងចាំបានល្អជាងវិធីដទៃៗទៀត ដូចជាបទឧទ្ទេសជាដើម។

គេបានធ្វើការពិសោធន៍ជាច្រើនហើយដែលបង្ហាញថា អ្នកចូលរួមអាចរៀនចេះចាំបានតិច ឬច្រើនអាស្រ័យលើវិធីសាស្ត្របង្រៀនដែលអ្នកសម្របសម្រួលយកមកប្រើ ។ លទ្ធផលពីការស្រាវជ្រាវខ្លះក៏បានបញ្ជាក់ថាការធ្វើបទបង្ហាញជាវិធីសាស្ត្រដែលមិនមានប្រសិទ្ធភាពក្នុងការផ្ទេរចំណេះដឹងដល់អ្នកចូលរួមឡើយ ។ ខាងក្រោមនេះ គឺជាឧទាហរណ៍ខ្លះៗនៃវិធីសាស្ត្របង្រៀនដែលមានអន្តរសកម្ម :

- ការសម្ដែងតួ
- ការពន្យល់បង្ហាញ
- ការនិទានរឿង
- ការពិភាក្សាជាក្រុម

វិធីសាស្ត្រប្រសើរបំផុតមួយដែលអាចជួយឱ្យអ្នកយល់ពីព័ត៌មាន និង ជំនាញថ្មីៗគឺការឡើងបង្រៀនអ្នកដទៃ។ ការឡើងបង្រៀនអ្នកដទៃ អាចជួយឱ្យអ្នកយល់ពីប្រធានបទកាន់តែច្បាស់ជាងមុនចេះរករបៀបពន្យល់អ្នកដទៃដោយប្រើប្រាស់ពាក្យពេចន៍ងាយស្ដាប់ងាយយល់ ព្រមទាំងអាចបង្ហាញអ្នកដទៃអំពីរបៀបប្រើប្រាស់ព័ត៌មាន ឬ ជំនាញថ្មីទាំងនោះថែមទៀតផង។ ពេលអ្នកឡើងបង្រៀនកាន់តែច្រើន អ្នកក៏កាន់តែមានទំនុកចិត្តក្នុងការបង្រៀន និង កើនការយល់ដឹងពីប្រធានបទ ដែលខ្លួនបង្រៀននោះកាន់តែច្រើនដែរ ហើយក្នុងពេលដំណាលគ្នានេះដែរអ្នកក៏មានឱកាសរៀនសូត្រពីបទពិសោធន៍ និងរឿងរ៉ាវទាំងឡាយរបស់អ្នកចូលរួមដែរ ។

| តើអ្នកចូលរួមអាចចាំបានប៉ុន្មានភាគរយក្រោយពីបានរៀនមួយឆ្នាំមក? |
| --- |
| • បើសិនបង្រៀនតាមបទបង្ហាញ អ្នកចូលរួមអាចចាំបានប្រហែល ៥ % ។<br>• បើសិនអ្នកចូលរួមអានមេរៀនដោយខ្លួនឯងពួកគាត់អាចចាំបានប្រហែល ១០% ។<br>• បើបង្រៀនតាមវិធីសាស្ត្រដោយមានសំលេង និងរូបភាព (វីដេអូ បទបង្ហាញជាដើម) អ្នកចូលរួមអាចចាំបានប្រហែល ២០% ។<br>• បើសិនអ្នកចូលរួមមើលការពន្យល់បង្ហាញ នោះពួកគាត់អាចចាំប្រហែល ៣០% ។<br>• បើសិនអ្នកចូលរួមពិភាក្សាអំពីបញ្ហាតាមក្រុមតូចនោះពួកគាត់អាចចាំបានប្រហែល ៥០% ។<br>• បើសិនអ្នកចូលរួមបានមើលការពន្យល់បង្ហាញ រួចបានអនុវត្តសកម្មភាពជាក់ស្តែង ពួកគាត់អាចចាំបានប្រហែល ៧៥% ។<br>• បើសិនអ្នកចូលរួមបានឡើងបង្រៀនអ្នកដទៃពួកគាត់អាចចាំបានប្រហែល ៩០% ។<br> |

# ៤. វិធីសាស្ត្របង្រៀន

មានវិធីសាស្ត្រផ្សេងៗជាច្រើន ដែលមានសារៈប្រយោជន៍ដល់ការបង្រៀន។ វិធីសាស្ត្របង្រៀនភាគច្រើនមានគោលបំណងធ្វើឱ្យអ្នកចូលរួមក្លាយទៅជា *អ្នកចូលរួមយ៉ាងសកម្ម* ហើយវិធីសាស្ត្រទាំងនេះទទួលស្គាល់ថា អ្នកដែលមកចូលរួមក្នុងវគ្គបណ្តុះបណ្តាលសុទ្ធតែមានចំណេះដឹង និងបទពិសោធន៍ក្នុងជីវិតរបស់ខ្លួននិងអាចចែករំលែក ជាមួយអ្នកដទៃនៅក្នុងក្រុមបាន។ ខាងក្រោមនេះជាឧទាហរណ៍ខ្លះនៃវិធីសាស្ត្របង្រៀនបែបលក្ខណៈអន្តរសកម្ម។

## ៤.១. ការបំផុសគំនិត

ការបំផុតគំនិតជាវិធីមួយ ដែលផ្តល់ឱកាសឱ្យអ្នកចូលរួមបានថ្លែងពីគំនិតយោបល់ផ្ទាល់ខ្លួនតាមចិត្តនឹកឃើញ។ ជាធម្មតា ការបំផុសគំនិតទទួលស្គាល់ថាគ្មានគំនិតយោបល់ណាត្រូវ ឬខុសទេ ហើយម្នាក់ៗអាចបញ្ចេញគំនិតយោបល់របស់ខ្លួនតាមចិត្តនឹកឃើញដូច្នេះម្នាក់ៗគិតឃើញអីថាហ្នឹង។

ពេលធ្វើការបំផុសគំនិតពីប្រធានបទណាមួយ គេអាចលើកសួរសំណួរខ្លះៗដូចជា "តើយើងអាចប្រើវិធីអ្វីខ្លះដើម្បីបង្រៀន?" ទុកពេលឱ្យអ្នកចូលរួមលើកយកគំនិតខុសៗគ្នាឱ្យបានច្រើនតាមលទ្ធភាពដែលពួកគាត់អាចនឹកឃើញ ហើយត្រូវកត់ត្រាគំនិតយោបល់ទាំងនេះនៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ ។ ពេលរួចរាល់អស់ហើយ យើងអាចចាប់ផ្តើមលើកយកគំនិតនីមួយៗមកពិភាក្សាឱ្យបានស៊ីជម្រៅ។



## ៤.២. ការពិភាក្សាក្រុមតូច

ត្រូវគ្រោងការពិភាក្សាក្រុមតូចឱ្យបានហ្មត់ចត់។ សូមពន្យល់ពីវិធាន និង សេចក្តីណែនាំនៃការពិភាក្សាឱ្យបានច្បាស់លាស់ ព្រមទាំងទុកពេលសម្រាប់ធ្វើការពិភាក្សាឱ្យបានគ្រប់គ្រាន់ ។ បើអាចធ្វើទៅបានត្រូវរៀបចំក្រុមនីមួយៗឱ្យមានសមាជិកមិនលើសពី ៥ នាក់ ដើម្បីផ្តល់ឱ្យសមាជិកក្រុមបានបញ្ចេញយោបល់គ្រប់ៗគ្នា។

## ៤.៣. ករណីសិក្សា

ករណីសិក្សា (អាចជាសាច់រឿង) ឬជាសេចក្តីពណ៌នាពីព្រឹត្តិការណ៍មួយដែលអាចមានប្រភពពីរឿងពិត ឬដោយការប្រឌិត ហើយដែលអាចយកមកប្រើប្រាស់ក្នុងពេលបង្រៀនដើម្បីជួយឱ្យអ្នកចូលរួមយល់ថាពួកគាត់អាចប្រើវិជ្ជា និងជំនាញទាំងនោះតាមរបៀបណា។ យើងក៏អាចយកករណីសិក្សាមកប្រើក្នុងការពិភាក្សា ក្រុមតូចដើម្បីជួយឱ្យអ្នកចូលរួមចេះវិភាគ និងពិចារណាឱ្យបានល្អិតល្អន់ពីរបៀបប្រើប្រាស់ព័ត៌មាន និងជំនាញថ្មីៗតាមស្ថានភាពជាក់ស្តែងនៃជីវិតប្រចាំថ្ងៃ ។



## ៤.៤. ការសម្តែងតួ

នៅក្នុងការសម្តែងតួ អ្នកចូលរួម (ឬពេលខ្លះអ្នកសម្របសម្រួល) សម្តែងតាមសាច់រឿងនៃព្រឹត្តិការណ៍ណាមួយតាមការពិត ឬដោយការប្រឌិត។ ពេលសំដែងសាច់រឿង គេអាចប្រើប្រាស់វត្ថុសព្វបែបយ៉ាងនៅក្នុងបរិវេណនៃកន្លែងរៀនដើម្បីឱ្យសាច់រឿងមានភាពកំប្លែង ល្អមើលល្អសើច។ ការសម្តែងរឿងមានសារៈប្រយោជន៍ ព្រោះអ្នកចូលរួមអាច

សំដែងដោយការខំប្រឹងប្រែង និង ភាពប៉ិនប្រសប់ក្នុងការសំដែងរបស់គាត់ ដែលធ្វើឱ្យពួកគាត់មានអារម្មណ៏ថាបានចូលរួមយ៉ាង ស្វាហាប់ក្នុងវគ្គបណ្តុះបណ្តាល ព្រមទាំងអាចធ្វើឱ្យពួកគាត់សកម្ម និងចាប់អារម្មណ៏ក្នុងការរៀនសូត្ររបស់ខ្លួន។

## ៤.៥. សំណួរ ចម្លើយ

ជំនួសឱ្យការធ្វើបទឧទ្ទេស គេច្រើនប្រើការពិភាក្សាតាមរយៈសំណួរចម្លើយ។ ការប្រើវិធីនេះ អាចធ្វើឱ្យក្រុមទាំងមូលមានឱកាសឆ្លើយឆ្លងគ្នា និង តម្រូវឱ្យពួកគាត់ត្រិះរិះពីបញ្ហាឱ្យបានស៊ីជំរៅ មិនមែនឱ្យតែអ្នកសម្របសម្រួលរិះគិតតែម្នាក់ឯងនោះទេ ។ ត្រូវចងចាំថា អ្នកចូលរួមក៏អាចដឹងទោះតិចក្តីច្រើនក្តីពីរឿងរ៉ាវ ឬ ព័ត៌មានដែលកំពុងលើកឡើង ឬ ប្រធានបទដែលលើកមកបង្រៀន និង យល់ដឹងថារឿងរ៉ាវនោះវាពាក់ព័ន្ធនឹងជីវិតរបស់ពួកគាត់បែបណាខ្លះរួចមកហើយ។ អ្នកសម្របសម្រួល ដែលយល់ពីវិធីបង្រៀនតាមបែបអន្តរសកម្ម នឹងប្រឹងប្រែងធ្វើយ៉ាងណាឱ្យអ្នកចូលរួមបញ្ចេញចំណេះដឹង និងបទពិសោធន៏របស់ពួកគាត់ឱ្យបានច្រើន ហើយកសាងចំណេះដឹងថ្មី និងបទពិសោធន៏ទាំងនោះ។ ការសួរសំណួរដោយប្រើពាក្យសំដីទន់ភ្លន់ទៅកាន់អ្នកចូលរួមដែលស្ងៀមស្ងាត់ អាចជាវិធីមួយដ៏ល្អដើម្បីលើកទឹកចិត្តពួកគាត់ឱ្យហ៊ាននិយាយ និងឱ្យហ៊ានចូលប្រឡូកក្នុងសកម្មភាពរៀនសូត្រឱ្យកាន់តែសកម្មជាងមុន ។

វិធីដ៏ល្អមួយពេលលើកយកប្រធានបទថ្មីស្រឡាងមួយមកបង្រៀន គឺការសួរទៅក្រុមទាំងមូលនូវសំណួរងាយៗខ្លះ អំពីប្រធានបទនោះ។ នេះជាការស្ទាបស្ទង់មើលជាទូទៅថា តើអ្នកណាខ្លះដឹងអ្វីខ្លះពីប្រធានបទថ្មីនេះ។ សួរថ្លឹងថ្លែងមើលនៅចុងមេរៀន ក៏ជាវិធីល្អមួយក្នុងការស្ទាបស្ទង់មើលថា តើក្រុមទាំងមូលយល់ពីប្រធានបទបានកំរិតណា ហើយអាចឱ្យយើងដឹងថាយើងបានសម្រេចតាមគោលបំណងមេរៀនដែរឬទេ ។



## ៤.៦. ល្បែងស្ទាងគំនិត

ល្បែងស្ទាងគំនិតក្នុងន័យនេះជាវិធីបង្កើនចំណេះដឹងដោយការលេងសប្បាយសម្រាប់មនុស្សទាំងក្មេង ទាំងចាស់។ ល្បែងស្ទាងគំនិតប្រភេទនេះក៏អាចត្រូវយកមកលេងដើម្បី "បំបែកបរិយាកាសខ្មាស់អៀន" ហើយជាសកម្មភាពកំប្លែង ដើម្បីជួយឱ្យអ្នកចូលរួមបានរីករាយ និង ស្គាល់គ្នាកាន់តែច្បាស់ និងអាចជួយកាត់បន្ថយភាពធុញថប់ និង ងងុយគេងនៅក្នុងវគ្គរៀនសូត្រនេះផងដែរ។ ជួនកាលគេលេងល្បែងស្ទាងគំនិត ដើម្បី "បន្ថែមកម្លាំងកាយចិត្ត" ឬដើម្បីប្តូរបរិយាកាសឱ្យអ្នកចូលរួមស្វាហាប់ឡើងវិញ ជាពិសេសនៅពេលឃើញអ្នកចូលរួមលែងចាប់អារម្មណ៍នឹងការរៀនសូត្រ។ វិធីបង្រៀននេះក៏សមស្របសំរាប់បង្រៀនប្រធានបទពិបាកៗ ដូចជាច្បាប់ និង ប្រើប្រាស់ដើម្បីជួយអ្នកចូលរួមងាយរៀនចំណេះដឹងថ្មីៗ។ ល្បែងស្ទាងគំនិតនេះអាចលេងជាក្រុម ឬ លេងជាលក្ខណៈប្រកួតប្រជែងគ្នា ប៉ុន្តែត្រូវប្រយ័ត្នកុំបង្កឱ្យអ្នកចូលរួមណាម្នាក់អាម៉ាស់មុខដោយសារមិនពូកែលេងល្បែងណាមួយ។ ការលេងល្បែងស្ទាងគំនិតអាចជួយលើកកម្លាំងចិត្តច្រើន បើគ្មានអ្នកចាញ់ ដូច្នេះហើយគួរជៀសវាងស្ថានភាពម្នាក់នេះឈ្នះ ម្នាក់នោះចាញ់ ឬក្រុមនេះឈ្នះឯក្រុមនោះចាញ់។

## ៤.៧. ការធ្វើបទបង្ហាញរបស់អ្នកចូលរួម

នៅពេលពិភាក្សាជាក្រុម យើងអាចចែកប្រធានបទមួយ ឬ ករណីសិក្សាមួយ ឬ ឱ្យសំណួរមួយដើម្បីពិភាក្សានៅក្នុងក្រុមតូច រួចហើយពួកគាត់ឡើងធ្វើបទបង្ហាញដល់ក្រុមទាំងមូល។ យើងអាចសុំឱ្យក្រុមនីមួយៗរៀបចំបទបង្ហាញដូចជាតាមរយៈការច្រៀងចំរៀងប្រជាប្រិយ៍ ឆ្លើយនឹងសំណួរ ការឡើងសម្តែងឆាកខ្លី ឬ ការគូររូបជាដើម ។ អ្នកចូលរួមអាចឡើងធ្វើបទបង្ហាញជាក្រុម ឬ ជ្រើសរើសអ្នកតំណាងក្រុមម្នាក់ឱ្យឡើងបង្ហាញក៏បាន។ ក្រោយពីធ្វើបទបង្ហាញរួចហើយ ទាំងក្រុមធ្វើបទបង្ហាញ និងក្រុមទាំងមូលអាចពិភាក្សាគ្នាអំពីបទបង្ហាញនេះបាន ។

## ៤.៨. សំភារៈឧបទ្ទេស (ឧបករណ៍ជំនួយ)

វត្ថុ រូបថត រូបភាព រូបគំនូរ ផ្ទាំងរូបភាពធំៗ និងភាពយន្តជាដើម ទាំងអស់នេះគឺជាឧទាហរណ៍នៃសំភារៈឧបទ្ទេស។ សំភារៈឧបទ្ទេសជួយដាស់អារម្មណ៍អ្នកចូលរួម ហើយក៏ជាវិធីមួយក្នុងការនាំយកបទពិសោធន៍ជីវិតពិតៗពីក្នុងស្រុក និង ពីជុំវិញពិភពលោកមកបង្ហាញក្នុងក្រុមទាំងមូលយ៉ាងមានប្រសិទ្ធភាព។ ការប្រើប្រាស់សំភារៈឧបទ្ទេស ក៏អាចផ្តល់ការងាយស្រួលក្នុងការបញ្ចេញគំនិតយោបល់ និង ផែនការណ៍ផ្សេងៗ ។ នៅក្នុងពេលប្រើសំភារៈឧបទ្ទេស ឬឧបករណ៍ជំនួយនោះ គេអាចសួរឱ្យអ្នកចូលរួមរៀបរាប់ និង វិភាគនូវខ្លឹមសារនៃរឿងដែលពួកគាត់ទើបបានមើល និងឱ្យពួកគាត់គិតឬប្រៀបធៀបបទពិសោធន៍ទៅនឹងស្ថានភាពរបស់ខ្លួនផ្ទាល់ ។ ឧបករណ៍ជំនួយខ្លះ ដូចជាភាពយន្តជាដើម អាចមានប្រយោជន៍ខ្លាំងណាស់ ពេលធ្វើការពន្យល់បង្ហាញពីការអនុវត្ត ឬ របៀបប្រើប្រាស់ជំនាញថ្មីៗ។ (ចូរចាំថា យើងក៏អាចប្រើប្រាស់ការសម្តែងរឿងដើម្បីសំរេចគោលដៅបានដូចគ្នា) ។



មានក្រុមប្រជាពលរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល និង ស្ថាប័ននៃអង្គការសហប្រជាជាតិជាច្រើនបានផលិតវីដេអូអំពីបញ្ហាទាក់ទិននឹងច្បាប់សិទ្ធិមនុស្សនៅកម្ពុជា ។ អ្នកក៏អាចព្យាយាមរកវីឌីអូ ទាក់ទងនឹងធនាគារអភិវឌ្ឍន៍អាស៊ី និងគម្រោងផ្សេងៗទៀត ដែលធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់មូលនិធិ នៅតាមបណ្តាប្រទេសនានានៅអាស៊ី។ អ្នកអាចនឹងរកវីឌីអូទាំងនេះបាននៅតាមអ៊ីនធើរណិត ឬអ្នកអាចសួរអង្គការមួយចំនួនដែលមានរាយឈ្មោះ នៅផ្នែកចុងនៃសៀវភៅនេះ។ សូមប្រាកដថា អ្នកអាចមានភ្លើងអគ្គិសនី និងមានក្បាលវីដេអូ ប្រសិនបើអ្នកមានគម្រោង ចាក់វីឌីអូ។

## ៤.៩. បទចម្រៀង

ពលរដ្ឋខ្មែរចូលចិត្តការច្រៀងរាំកំសាន្តណាស់។ ដូច្នេះ អ្នកអាចទាញប្រយោជន៍ពីចំណូល ចិត្តបែបនេះបាននៅពេលធ្វើសិក្ខាសាលា ។ ជួនកាលអ្នកអាចឱ្យក្រុមសម្រាកមួយភ្លែតពីភាពមមាញឹកនៅក្នុងពេលកំពុងរៀន ហើយនាំគ្នាច្រៀងរាំ ដើម្បីបំបាត់ភាពងងុយ។ អ្នកក៏អាចប្រើបទចម្រៀងជាផ្នែកមួយនៃមេរៀន។ ឧទាហរណ៍ នៅចុងមេរៀនណាមួយអ្នកអាចសុំឱ្យអ្នកចូលរួមតែងចម្រៀងមួយបទពីអ្វីដែលពួកគាត់បានរៀនមកនោះ ។ ប្រសិនបើអាចធ្វើបានគួរប្រើទំនុកភ្លេងណាមួយដែលកំពុងពេញនិយម នោះវាកាន់តែធ្វើឱ្យពួកគាត់ងាយចាំនូវអ្វីដែលទើបបានរៀនថែមទៀតផង។




## អ្នកចូលរួមដែលមានបញ្ហាពិបាកក្នុងការអាន

ជួនកាលអាចមានអ្នកចូលរួមខ្លះមានការលំបាកក្នុងការអាន និងសរសេរ។ អ្នកចាំបាច់ត្រូវយល់អំពីបញ្ហានេះ ព្រោះថា វាអាចមិនមែនជាគំនិតល្អទេដែលយើងសួរនាំពួកគាត់ត្រង់ៗនៅក្នុងថ្នាក់ទាំងមូលយ៉ាងនេះ ព្រោះវាធ្វើឱ្យពួកគាត់អៀនខ្មាស។

លំហាត់ជាច្រើនតម្រូវឱ្យយើងប្រើប្រាស់ករណីសិក្សា និងវិធីសាស្ត្រផ្សេងៗដែលទាមទារឱ្យមានការអាន និងការសរសេរខ្លះៗ ។ ប្រសិនបើមានអ្នកចូលរួមណាមានការពិបាកអាន និង សរសេរ នោះនៅមានជំរើសពីរបី ផ្សេងទៀតដែលគេអាចយកមកប្រើដូចជា ជំរើសមួយគឺត្រូវដាក់សមាជិកយ៉ាងតិច ម្នាក់ក្នុងក្រុមនីមួយៗ ដែលចេះអាន និងសរសេរ ដើម្បីធានាថាពេលធ្វើលំហាត់ដែលប្រើករណីសិក្សា ឬ សំណួរគាត់អាចជួយអានឱ្យក្រុមរបស់គាត់ស្តាប់ និងជួយសរសេរគំនិតយោបល់ ឬ ចម្លើយរបស់ក្រុមគាត់ ប្រសិនបើជាចាំបាច់ ។

បើសិនគ្មានអ្នកចេះអាន និង ចេះសរសេរគ្រប់គ្រាន់ក្នុងចំណោមអ្នកចូលរួមទេនោះ ខ្លួនអ្នកផ្ទាល់ ឬក៏អ្នកសំរបសំរួលដទៃទៀតអាចជួយអានករណីសិក្សាឱ្យឮខ្លាំងៗនិងជួយកត់ត្រាចំលើយឱ្យពួកគាត់ ។ អ្នកអាចរិះរកវិធីផ្សេងៗទៀតដើម្បីបង្កលទ្ធភាពដល់ក្រុមទាំងអស់បានកត់ត្រានូវគំនិតនិងចំលើយ ដូចជាគូររូបភាព ឬកាត់ក្រដាសជារូបភាព ឬក៏ពួកគាត់ទន្ទិញសំនួរ និង ចំលើយឱ្យរត់មាត់ក៏បាន។

សកម្មភាពទាំងអស់នៅក្នុងសៀវភៅនេះ ងាយស្រួលនឹងកែសម្រួលទៅតាមស្ថានរបស់អ្នកចូលរួមគ្រប់រូបណាស់ដូច្នេះ សូម្បីតែអ្នកចូលរួមដែលមានការលំបាកក្នុងការអាន ក៏អាចចូលរួមក្នុងសកម្មភាពរៀនបានពេញលេញដែរ។

# ៥. កិច្ចតែងការបង្រៀន

*កិច្ចតែងការបង្រៀន* ជាផែនទីដែលជួយតម្រង់ទិសដៅយើង ។ ឧទាហរណ៍ថា បើយើងចង់ទៅកន្លែងមួយ តែយើងស្គាល់ផ្លូវមិនច្បាស់យើងអាចរកមើលផ្លូវដោយប្រើផែនទី។ យើងត្រូវរកមើលកន្លែងចាប់ផ្តើម និងកន្លែង ដែលយើងត្រូវទៅ ហើយយើងក៏ត្រូវរកមើលកន្លែងដែលយើងត្រូវឆ្លងកាត់មុនទៅដល់កន្លែងគោលដៅផងដែរ។ យើងអាចចាត់ទុកថា កន្លែងចាប់ផ្តើមជាគោលបំណងមេរៀន ឯកន្លែងគោលដៅជាអ្វីដែលយើងនឹងទទួលបានពីមេរៀន។ ប៉ុន្តែដើម្បីទៅឱ្យដល់គោលដៅនោះ មានជំហានជាច្រើនដែលយើងត្រូវឈានដើម្បីឱ្យបានដល់កន្លែងនោះ ។

កិច្ចតែងការបង្រៀនប្រើប្រាស់នៅក្នុងសៀវភៅនេះ មាន៨ផ្នែក។ ផ្នែកទី១គឺ **អត្ថបទមេរៀន** បន្ទាប់មក **លំហាត់** ដែលបំបែកចេញជា ៧ ផ្នែកតូចៗថែមទៀត។ ផ្នែកដទៃទៀតគឺ : គោលបំណង សម្ភារ:/ឯកសារ វិធីសាស្ត្រប្រើប្រាស់ ដំណើរការ/រយ:ពេលគិតជានាទី ការណែនាំសម្រាប់អ្នកសម្របសម្រួល ចម្លើយទទួលយកបាននិងការសង្ខេប ជាដើម ។ ខាងក្រោមនេះគឺជាសេចក្តីពន្យល់ត្រួសៗអំពីគោលបំណងនៃផ្នែកនីមួយៗនៃមេរៀន ។

## ៥.១. អត្ថបទមេរៀន

នៅក្នុងផ្នែកអត្ថបទមេរៀនមានព័ត៌មានអំពីប្រធានបទសំរាប់មេរៀននីមួយៗ។ ឧទាហរណ៍ បើសិនមេរៀននោះនិយាយពីសិទ្ធិមនុស្ស ដូច្នេះអត្ថបទមេរៀនត្រូវមានព័ត៌មាន ដូចជានិយមន័យរបស់សិទ្ធិមនុស្ស សិទ្ធិមនុស្សមានឫសគល់មកពីណា និងមានឧទាហរណ៍ខ្លះៗស្តីពីសិទ្ធិមនុស្ស ។ ជាធម្មតា ក្នុងផ្នែកអត្ថបទមេរៀន មានរូបភាពខ្លះៗពីប្រធានបទក្នុង មេរៀន។ ផ្នែកអត្ថបទមេរៀននេះ មានលំហាត់ខ្លះ និងការណែនាំសំរាប់ធ្វើលំហាត់ទាំងនោះ។

## ៥.២. មេរៀន

### ៥.២.១.គោលបំណង

គោលបំណងនៃមេរៀនគឺជាអ្វីដែលអ្នកចូលរួម គួរបានរៀន និង បានយល់ដឹងពីប្រធានបទដោយការធ្វើតាមជំហាននៃមេរៀននោះ។

ឧទាហរណ៍ :

| |
|---|
| **គោលបំណង : អ្នកចូលរួមនឹងបានយល់ដឹងថាតើសិទ្ធិមនុស្សជាអ្វីមានឫសគល់មកពីណា និងហេតុអ្វីបានជាយើងត្រូវយល់ដឹងពីសិទ្ធិមនុស្ស។** |

### ៥.២.២.សម្ភារៈ

នេះគឺជាបញ្ជីសម្ភារៈដែលយើងត្រូវការចាំបាច់សម្រាប់បង្រៀន ។ ដូច្នេះអ្នកត្រូវត្រៀមឱ្យមានសម្ភារៈទាំងអស់នេះមុននឹងចាប់ផ្តើមបង្រៀនមេរៀន។

ឧទាហរណ៍ :

| |
|---|
| **សម្ភារៈ:** ក្រដាសផ្ទាំងធំ ឬ ក្តារខៀន ហ្វឺតសម្រាប់សរសេរ កូនបាល់ ឯកសារមេរៀន។ |

### ៥.២.៣.វិធីសាស្ត្រប្រើប្រាស់

ជាវិធីសាស្ត្របង្រៀនតាមបែបអន្តរសកម្មមួយចំនួន ដែលត្រូវយកមកប្រើប្រាស់ក្នុងការបង្រៀន សំរាប់មេរៀននិមួយៗ ។

ឧទាហរណ៍:

| |
|---|
| **វិធីសាស្ត្រប្រើប្រាស់:** ការបំផុសគំនិត ការពិភាក្សាជាក្រុមធំ ការគូររូប |

### ៥.២.៤.ដំណើរការ/ពេលវេលា

កូឡោនខាងឆ្វេងដៃនៃតារាងនេះ មានកំណត់នូវជំហានទីមួយៗ ដើម្បីយកមកអនុវត្តតាមក្នុងពេលបង្រៀនមេរៀន ។ កូឡោនខាងស្តាំ បង្ហាញនូវរយៈពេលដែលត្រូវការចាំបាច់សម្រាប់ជំហានទីមួយៗ ។ រយៈពេលសរុបដើម្បីបង្រៀនមេរៀនមានបង្ហាញនៅខាងចុងតារាង។ តារាងនេះមានសារៈសំខាន់ណាស់សម្រាប់រៀបចំពេលវេលាក្នុងវគ្គបណ្តុះបណ្តាល ។

ឧទាហរណ៍

| ដំណើរការ | រយៈពេល(គិតជានាទី) |
|---|---|
| ១. ការបំផុសគំនិត និង ពិភាក្សាជាក្រុម | ១៥ |
| ២. ណែនាំព័ត៌មានក្នុងផ្នែកទី ១ និង ២ | ២០ |

| | | |
|---|---|---|
| ៣. | ការពិភាក្សាក្រុមតូច | ១៥ |
| ៤. | ការឡើងបង្ហាញរបស់ក្រុមនីមួយៗ | ២០ |
| ៥. | ការសង្ខេប | ១០ |
| **សរុបៈ** | | **៨០** |

### ៥.២.៥.ការណែនាំសម្រាប់អ្នកសម្របសម្រួល

នៅក្នុងផ្នែកនេះ មានការណែនាំលំអិតអំពីរបៀបបង្រៀនមេរៀននីមួយៗ និងគ្រប់ដំណាក់កាលនៃមេរៀន ដូចដែលបានកំណត់នៅក្នុងតារាងដំណើរការខាងលើ ។ ក្នុងនោះមានទាំងព័ត៌មានសំខាន់ៗ និងការប្រាប់អំពីរបៀបដែលអាចជួយអ្នកក្នុងការបង្រៀនមេរៀនឱ្យទទួលបានលទ្ធផលល្អ ។

### ៥.២.៦.ចម្លើយទទួលយកបាន

បើសិនមានសំណួរនៅក្នុងមេរៀនដែលទាមទារឱ្យអ្នកចូលរួមផ្តល់ជាព័ត៌មាន ជាជាងផ្តល់យោបល់ផ្ទាល់ខ្លួន។ នៅក្នុងផ្នែកនេះមានចម្លើយទទួលយកបានសំរាប់សំណួរខាងលើ។

### ៥.២.៧.ការសង្ខេប

ផ្នែកនេះមានគោលដៅវាយតម្លៃ ឬ ស្ទាបស្ទង់មើលថា តើគោលបំណងនៃមេរៀននេះបានសម្រេចដែរឬទេ ។ ចំណុចសំខាន់គឺយើងត្រូវចាំថា វាពុំមែនជាការសង្ខេបមេរៀន ឬការរំលឹកមេរៀនដូចដែលវិធីសាស្ត្របង្រៀនខ្លះតម្រូវឱ្យទេ ព្រោះការសង្ខេបមេរៀនមិនជួយអ្នកឱ្យបានដឹងថា តើអ្នកចូលរួមបានរៀន និងបានយល់ដឹងច្បាស់នូវចំណុចសំខាន់ក្នុងប្រធានបទនៃមេរៀន ឬមិនច្បាស់នៅឡើយទេ។ ដូច្នេះ អ្នកអាចធ្វើការស្ទាបស្ទង់មើលដោយប្រើវិធីខ្លះ ដូចសួរសំណួរទៅក្រុមទាំងមូល ឬ ឱ្យពួកគាត់សង្ខេបយកចំនុចដែលពួកគាត់គិតថាសំខាន់សំរាប់ពួកគាត់ ឬ ដោយការលេងល្បែងឆ្លើយសំណួរជាដើម ដើម្បីថ្លឹងថ្លែងថា តើគោលបំណងនៃមេរៀនបានសម្រេចហើយឬនៅ។

## ៦. ជំនាញសម្របសម្រួល

អ្នកសម្របសម្រួលត្រូវគិតឱ្យបានដិតដល់ពីមាតិកាមេរៀន ការណែនាំសំរាប់ធ្វើលំហាត់ និងពីសម្ភារៈចាំបាច់នានាសំរាប់ការបង្រៀន ។ ជាមួយគ្នានេះដែរ អ្នកសម្របសម្រួលត្រូវយល់ពីឥរិយាបថ ឬ អាកប្បកិរិយាខ្លួនឯងក្នុងពេលសម្របសម្រួល និង ស្វែងរកវិធីសមស្របសំរាប់បង្រៀនមេរៀន ។ ត្រូវចាំថាយើងត្រូវសំដែងអាកប្បកិរិយាដែលក្រុម

ទាំងមូលអាចគោរពបាន ហើយពួកគាត់ក៏មានអារម្មណ៍ថាពួកគាត់បានទទួលការគោរពពីអ្នកបង្រៀន និងមានអារម្មណ៍សប្បាយរីករាយក្នុងការចូលរួមសកម្មភាពក្នុងវគ្គបណ្ដុះបណ្ដាល។ ផ្នែកបន្តទៀតនេះមានប្រាប់ពីជំហាន និងជំនាញសំខាន់ៗខ្លះទៀត ដែលអាចជួយឱ្យអ្នកសម្របសម្រួលធ្វើការងារប្រកបដោយប្រសិទ្ធភាព ។ ដំបូង វាហាក់ដូចជាមានចំនុចច្រើនណាស់ដើម្បីត្រូវចងចាំឱ្យអស់ ប៉ុន្តែយូរៗទៅវានឹងក្លាយទៅជាជំនាញ ដែលអ្នកមាន និងទទួលបានមកពីការអនុវត្តដោយ ផ្ទាល់ដោយស្វ័យប្រវត្តិ។



## ៦.១. ការត្រៀមរៀបចំ

ប្រសិនបើអ្នកចេះចាំព័ត៌មានច្បាស់អស់ហើយ នោះអ្នកនឹងមានទំនុកចិត្តលើខ្លួនឯងខ្លាំងជាងមុនថាអ្នកនឹងអាចបង្រៀនបានកាន់តែល្អ ហើយអ្នកចូលរួមនឹងកាន់តែទុកចិត្តលើសមត្ថភាពក្នុងការបង្រៀនរបស់អ្នកច្រើនជាងមុនដែរ។ ត្រូវចាំថា យើងត្រូវស្វែងយល់ឱ្យបានច្បាស់លាស់ពីព័ត៌មាន ឬ ចំណេះដឹងណាដែលយើងជ្រើសរើសមកបង្រៀន ហើយត្រូវដឹងថាតើសម្ភារៈអ្វីខ្លះ ដែលយើងត្រូវការចាំបាច់សំរាប់ពេលបង្រៀន និងសេចក្ដីណែនាំណាខ្លះ ដែលអ្នកត្រូវផ្ដល់ដល់អ្នកចូលរួម។

ត្រូវធ្វើឱ្យប្រាកដថា កន្លែងរៀន អាហារសម្រន់ ឯកសារមេរៀន សម្ភារៈ និងឧបករណ៍សំរាប់បង្រៀនចាំបាច់នានាត្រូវបានរៀបចំរួចរាល់ជាមុនយ៉ាងហោចណាស់ក៏មួយសប្ដាហ៍មុនពេលបើកវគ្គបណ្ដុះបណ្ដាលដែរ។

## ៦.២. ការគ្រប់គ្រងពេលវេលា

ត្រូវចេះបត់បែនតាមស្ថានការណ៍ និង កាលៈទេសៈ។ បើសិនអ្នកចូលរួមយល់ថាមេរៀនពិបាកយល់ពេក អ្នកអាចផ្ដល់ពេលបន្ថែមឱ្យបានវែងជាងពេលកំណត់បន្តិច និង សមល្មមឱ្យពួកគាត់។ បើសិនពួកគាត់ថាមេរៀនស្រួលពេក ឬថាពួកគាត់ចេះដឹងច្រើនពីប្រធានបទនៃមេរៀននេះហើយ នោះអ្នកអាចបង្កើនល្បឿន និងបញ្ចប់មេរៀនមុនពេលកំណត់

ក៏បាន។ ប៉ុន្តែត្រូវចាំថាបើសិនអ្នករៀបចំកម្មវិធីបង្រៀនច្រើន និង ត្រូវបង្រៀនប្រធានបទជាច្រើន ពេលនោះ អ្នកត្រូវតែគោរពតាមកាលវិភាគដែលបានរៀបចំរួចមកតាមដែលអ្នកអាចធ្វើទៅបាន។

## ៦.៣. កាយវិការ

អ្នកសម្របសម្រួលត្រូវសំដែងឱ្យអ្នកចូលរួមដឹងថា អ្នកមានចិត្តសាទរ និងចង់បង្រៀន ។ ពេលឈរ ត្រូវឈរឱ្យត្រង់ខ្លួន និងទន់ភ្លន់។ ត្រូវដើរទៅមកនៅក្នុងថ្នាក់ទាំងមូលនៅពេលបង្រៀន។ ត្រូវរំពៃមើលទៅអ្នកចូលរួមឱ្យបានគ្រប់ៗគ្នា មិនត្រូវសំឡឹងទៅក្រោម ឬ សំឡឹងទៅក្រៅតាមបង្អួចឡើយ។ ហើយក៏មិនត្រូវរំពៃមើលតែអ្នកដែលនៅជួរខាងមុខប៉ុណ្ណោះទេ ត្រូវរំពៃមើលឱ្យបានគ្រប់ជ្រុងជ្រោយ។ កាយវិការរបស់អ្នក មិនគួរបង្កឱ្យអ្នកចូលរួមមានភាពទើសទាល់ឡើយ។ ឧទាហរណ៍ អ្នកមិនត្រូវចង្អុលមុខអ្នកមកចូលរួមណាម្នាក់ឡើយ ។ បើសិនអ្នកណាម្នាក់កំពុងឆ្លើយនឹងសំណួរកុំបន្ទុចបង្អាក់គាត់ ឬ សំលឹងគាត់ក្នុងន័យមើលស្រាលឡើយ។ ត្រូវសំដែងភាពសាទរ និងការលើកទឹកចិត្តឱ្យពួកគាត់វិញដោយពោលពាក្យសរសើរដោយសុទ្ធចិត្តហើយប្រសិនបើចាំបាច់ត្រូវកែតម្រូវចំឡើយត្រូវធ្វើដោយសុភាពរាបសារ និងប្រកបដោយសេចក្តីគោរព ។

## ៦.៤. ជៀសវាងការធ្វើបទឧទ្ទេស

យើងច្រើនច្រឡំថា បទឧទ្ទេសជាវិធីមានប្រសិទ្ធភាពជាងគេក្នុងការបង្រៀនចំណេះដឹងថ្មីៗ ។ តែវាមិនមែនដូច្នោះឡើយ។ ដូចដែលយើងបានពិភាក្សាមកពីខាងលើរួចមកហើយ បទឧទ្ទេសជាវិធីបង្រៀនដែលទទួលបានលទ្ធផលតិចតួចបំផុត ។ វិធីសាស្ត្របង្រៀនដែលយើងបានពិភាក្សាខាងលើ ជាវិធីយកមកបណ្តុះបណ្តាលចំណេះដឹងថ្មីដោយជៀសវាងការធ្វើបទឧទ្ទេសនេះ។ បើសិនក្នុងពេលបង្រៀន អ្នកចាប់អារម្មណ៍ថា អ្នកនិយាយច្រើនពេកលើផ្នែកណាមួយនៅពេលបង្រៀន ចូរឈប់បន្តិចសិន ហើយផ្លាស់របៀបបង្រៀនមកជាការសួរសំណួរ ឬលើកឱ្យថ្នាក់ធ្វើសកម្មភាពណាមួយដើម្បីប្តូរបរិយាកាស ។ ជាញឹកញាប់ណាស់ដែលគេអាចបំប្លែងមេរៀនតាមបែបបទឧទ្ទេស មកជាការបង្រៀនដែលមានអន្តរសកម្មវិញដោយលើកជាសំណួរដល់ក្រុមទាំងមូល និង បើកឱ្យមានការពិភាក្សាគ្នាក្នុងក្រុម។ ធ្វើយ៉ាងនេះ អ្នកចូលរួមអាចស្វែងយល់ពីព័ត៌មានដោយខ្លួនឯង មិនចាំបាច់យើងបកស្រាយច្រើនពេកទេ ។ បើទោះជាវិធីក្រោយនេះ ចំណាយពេលយូរបន្តិចមែន ប៉ុន្តែវាអាចធ្វើឱ្យមេរៀនមានការចាប់អារម្មណ៍ខ្លាំង និងមានប្រសិទ្ធភាពសំរាប់អ្នកមកចូលរួមជាងការព្រោកប្រាជ្ញ តែម្នាក់ឯងដូចជាការធ្វើបទឧទ្ទេស។

## ៦.៥. ត្រួតពិនិត្យការយល់ដឹងរបស់អ្នកចូលរួម

អ្នកសម្របសម្រួលល្អត្រូវចេះត្រួតពិនិត្យមើលការយល់ដឹងពីប្រធានបទរបស់អ្នកចូលរួម គ្រប់ដំណាក់កាលនៃការបង្រៀន។ កុំចាប់ដល់បង្រៀនអស់មួយម៉ោងហើយ ទើបសួរអ្នកចូលរួម "យល់ឬទេ?" អ្នកអាចផ្ទៀងផ្ទាត់ការយល់ដឹងរបស់អ្នកចូលរួមរៀងរាល់ពីរ-បីនាទីម្តង ដោយលើកជាសំណួរពីប្រធានបទកំពុងបង្រៀន ឬសុំឱ្យអ្នកណាម្នាក់ស្ម័គ្រចិត្ត

សង្ខេបមេរៀនដែលទើបបានរៀន។ ចូរចាំផងថា មិនត្រូវឱ្យតែអ្នកដែលមានសំលេងខ្លាំង (ច្បាស់) ឬអ្នកមានស្មារតីរឹងមាំ ឡើងសង្ខេបនោះទេ ។ ត្រូវចេះពិនិត្យថាអ្នកចូលរួមដែលមិនសូវបាននិយាយក៏បានយល់ដឹងពីមេរៀនផងដែរ ។

## ៦.៦. ការលើកទឹកចិត្តអ្នកចូលរួមដែលស្ងៀមស្ងាត់

ស្ទើរតែគ្រប់វគ្គបណ្តុះបណ្តាលតែងតែមានអ្នកចូលរួមខ្លះនៅស្ងៀមស្ងាត់ (មិនសូវនិយាយស្តី) ដោយសារភាពខ្មាសអៀន ឬដោយសារមិនសូវយល់មេរៀន។ មានករណីខ្លះ ស្ត្រី ឬជនជាតិភាគតិច ច្រើនតែនៅស្ងៀមស្ងាត់ ហើយមិនសូវហានឆ្លើយសំណួរទេបើទោះជាដឹងពីចំលើយហ្នឹងក៏ដោយ។

ត្រូវព្យាយាមធ្វើយ៉ាងណាដើម្បីឱ្យពួកគាត់មានអារម្មណ៍កក់ក្តៅ រីករាយ និងធូរស្រាលក្នុងអារម្មណ៍ ដោយឧស្សាហ៍ញញឹមរាក់ទាក់ដល់ពួកគាត់ និង យកចិត្តទុកដាក់នឹងពួកគាត់។ អ្នកអាចសាកល្បងលើកទឹកចិត្តពួកគាត់ ឱ្យឆ្លើយសំណួរ ឬឡើងធ្វើជាតំណាងក្នុងក្រុមរបស់ខ្លួន ហើយផ្តល់ការសាទរដល់ពួកគាត់នៅពេល ដែលពួកគាត់ចូលរួមយ៉ាងសកម្មក្នុងសកម្មភាពណាមួយ។ ពេលសំរាក បើអាចធ្វើទៅបាន ឆ្លៀតឱកាសសាកសួររាក់ទាក់ជាមួយនឹងពួកគាត់បន្ថែមទៀត ព្រោះពួកគាត់អាចមានអារម្មណ៍សន្ទនាជាមួយអ្នកពីអ្វី ដែលពួកគាត់ទើបបានរៀន ឬចង់សួរអ្នកពីអ្វីមួយទាក់ទិននឹងមេរៀន។

## ៦.៧. កសាងទំនាក់ទំនងល្អជាមួយអ្នកចូលរួម

អ្នកត្រូវព្យាយាមចងមិត្តភាពនឹងអ្នកចូលរួមទាំងឡាយ ដោយធ្វើតាមឧទាហរណ៍ដូចខាងក្រោមនេះ :

- ជម្រាបសួរពួកគាត់ ពេលចូលមកដល់បន្ទប់បណ្តុះបណ្តាល
- ហៅពួកគេឱ្យចំៗឈ្មោះ
- សួរសំណួរដល់ពួកគាត់ និង ប្រាប់ពួកគាត់ពីខ្លួនរបស់អ្នក
- លើកទឹកចិត្តអ្នកចូលរួមឱ្យសកម្មក្នុងមេរៀន
- និយាយទៅកាន់ពួកគាត់ម្នាក់ទល់ម្នាក់ មុនចាប់ផ្តើម និង ក្រោយពេលចប់មេរៀន ព្រមទាំងក្នុងពេលសម្រាក (ជាពិសេសជាមួយអ្នកដែលតែងតែស្ងៀមស្ងាត់)
- ផ្តល់ឱកាសឱ្យអ្នកចូលរួមបានចែករំលែកអំពីរឿងរ៉ាវផ្ទាល់ខ្លួននានា
- ចូលរួមពិសារអាហារថ្ងៃត្រង់ជាមួយអ្នកចូលរួម និង
- សរសើរចំពោះការខិតខំប្រឹងប្រែង និង ការចូលរួមចំណែក ព្រមទាំងលើកទឹកចិត្តអ្នកណាដែលតែងតែអៀនខ្មាសច្រើន ឬ មានការលំបាកក្នុងការយល់មេរៀន។

## ៦.៨. ល្បែងថាមពល

វាមានសារៈសំខាន់ណាស់ដែលអ្នកត្រូវធ្វើឱ្យអ្នកចូលរួមទាំងអស់មានការចាប់អារម្មណ៍។ ប្រសិនបើអ្នកចូលរួមមិនមានការចាប់អារម្មណ៍ នោះពួកគាត់នឹងមិនយកចិត្តទុកដាក់ស្តាប់ ហើយនឹងមិនចងចាំនូវអ្វីដែលគាត់បានរៀននោះទេ។

វិធីមួយដើម្បីជៀសវាងបញ្ហានេះអ្នកអាច "លេងល្បែងថាមពល" នៅចន្លោះមេរៀនណាមួយ ដើម្បីផ្លាស់ប្តូរបរិយាកាសឱ្យអ្នកចូលរួមស្វាហាប់ឡើងវិញ ឬ ជាពិសេស នៅពេលឃើញអ្នកចូលរួមលែងចាប់អារម្មណ៍នឹងការរៀនសូត្រ។ ជាទូទៅអ្នកអាចលេងល្បែងស្វាងថាមពលនៅចុងបញ្ចប់នៃថ្ងៃនីមួយៗ ឬ បន្ទាប់ពីអាហារថ្ងៃត្រង់ ពេលដែលគាត់មានអារម្មណ៍នឿយហត់។ ល្បែងនេះអាចជាការច្រៀងរាំកំសាន្ត ការលេងល្បែងផ្សេងទៀត ការនិទានរឿង និងសកម្មភាពផ្សេងៗ ដែលធ្វើយ៉ាងណាឱ្យអ្នកចូលរួមបានធ្វើចលនាចុះឡើង និង ឱ្យបានសើចសប្បាយខ្លះផង។



# ៧. ការវាយតម្លៃ

ក្រោយពីបង្រៀនចប់ យើងគួរតែធ្វើការវាយតម្លៃមួយដើម្បីចង់ដឹងថា តើអ្នកចូលរួមមានអារម្មណ៍យ៉ាងណាចំពោះវគ្គបណ្តុះបណ្តាល។ ដូច្នេះមានតែការវាយតម្លៃប៉ុណ្ណោះដែលអាចឱ្យយើងដឹងអំពីបញ្ហានេះបាន។ ការវាយតម្លៃអាចធ្វើតាមរបៀបផ្សេងៗគ្នាជាច្រើន និងអាចធ្វើបាននៅពេលខុសៗគ្នាដែរ។ ជាទូទៅអ្នកអាចធ្វើការវាយតម្លៃ នៅពេលចប់មេរៀនទីមួយៗ ប៉ុន្តែការធ្វើបែបនេះអាចនាំឱ្យអ្នកចូលរួមមានការធុញទ្រាន់បន្តិច ហើយអាចចំណាយពេលយូរ។ ការវាយតម្លៃដ៏ល្អបំផុតគឺនៅពេលចប់កម្មវិធីក្នុងថ្ងៃនីមួយៗ ។ នេះមានន័យថា យើងធ្វើការវាយតម្លៃ ជារៀងរាល់ថ្ងៃ ។ ពេលខ្លះអ្នកអាចធ្វើការវាយតម្លៃវគ្គបណ្តុះបណ្តាលពីរ ឬបីសប្តាហ៍ ក្រោយពីរៀនចប់ ឬអាច មួយខែក្រោយក៏បានដែរ ។ ការធ្វើបែបនេះ ជាវិធីមួយដែលអ្នកអាចធ្វើការស្ទាបស្ទង់ពីការចងចាំរបស់អ្នកចូលរួមផង ព្រមទាំងអាចដឹងថា តើពួកគាត់បានប្រើប្រាស់ចំណេះដឹង និងជំនាញដែលទើបបានរៀននៅក្នុងស្ថានភាពនៃជីវិតពួកគាត់ដែរឬទេ ។

អ្នកអាចធ្វើការវាយតម្លៃដោយការនិយាយ ដោយសួរសំណួរខ្លះៗយ៉ាងសាមញ្ញជាមួយអ្នកចូលរួម ។ ការធ្វើបែបនេះ អ្នកអាចធ្វើជាមួយក្រុមទាំងមូល ឬ ជាមួយក្រុមតូចៗក៏បាន។ ការធ្វើជាក្រុមបែបនេះ ល្អណាស់ចំពោះអ្នកចូលរួមដែលមិនសូវចេះអានអក្សរ ។វិធីសាស្រ្តក្នុងការវាយតម្លៃមួយទៀត គឺចែកទម្រង់វាយតម្លៃឱ្យអ្នកចូលរួមបំពេញ ។

វិធីមួយទៀតដើម្បីវាយតម្លៃនោះ គឺគួរសួរសំណួរដូចជា:

- តើអ្នកយល់មេរៀនដែរឬទេ?
- តើព័ត៌មានដែលផ្តល់ឱ្យនេះមានប្រយោជន៍ដែរឬទេ?
- តើមេរៀនណាដែលមានប្រយោជន៍ខ្លាំង ហើយមេរៀនណាដែលមិនសូវមានប្រយោជន៍? (អាចឱ្យអ្នកចូលរួមរៀបរាប់ពីលំដាប់នៃមេរៀនដែលមានសារៈសំខាន់ បំផុតពីលើចុះមកក្រោម)
- តើអ្នកសម្របសម្រួលរៀបចំ និងបង្រៀនបានល្អដែរឬទេ?

តាមរយៈការសួរសំណួរបែបនេះ អ្នកអាចកែលំអរ និងរៀបចំឱ្យបានកាន់តែប្រសើរឡើងនៅវគ្គក្រោយៗ ។

លើសពីនេះទៀត អ្នកសម្របសម្រួល និងអ្នកសង្កេតការណ៍ក៏អាចធ្វើការវាយតម្លៃវគ្គបណ្តុះបណ្តាលតាមរយៈការសង្កេតរបស់ខ្លួនបានដែរ ដោយស្មានមើលថាតើវគ្គបណ្តុះបណ្តាលនោះទទួលបានជោគជ័យត្រឹមកម្រិតណា ហើយអ្នកចូលរួមយល់បានប៉ុនណាដែរ។

## ៨. ការរក្សាកំណត់ហេតុ

ចុងក្រោយ អ្វីដែលសំខាន់គឺ អ្នកត្រូវរក្សាកំណត់ហេតុទុកនៅពេលដែលអ្នកបើកវគ្គបណ្តុះបណ្តាលម្តងៗ ។ កំណត់ហេតុនោះ វាពិតជាមានសារៈសំខាន់សម្រាប់អ្នកខ្លាំងណាស់ក្នុងការចែករំលែកទៅអ្នកដទៃទៀត ប្រសិនបើអ្នកជាសមាជិកបណ្តាញ ឬធ្វើការក្នុងអង្គការណាមួយ ។ ក្រោយពីបញ្ចប់វគ្គ អ្នកគួរកត់ត្រាទុកដូចខាងក្រោម៖

- មនុស្សដែលអ្នកបានបង្រៀន ( ចំនួនបុរស ចំនួនស្ត្រី )
- បង្រៀននៅកន្លែងណា ( ខេត្ត ស្រុក ឃុំ ភូមិ និង ទីតាំង)
- ប្រធានបទដែលអ្នកបានបង្រៀន
- តើអ្នកគិតថា វគ្គបណ្តុះបណ្តាលនោះដំណើរទៅយ៉ាងណា (ឧទាហរណ៍អ្នកចូលរួមយល់មេរៀនដែរឬទេ? តើមេរៀននោះ ធ្វើឱ្យមនុស្សចូលចិត្តដែរឬទេ? )
- តើអ្នកបានទទួលការឆ្លើយតបដូចម្តេចខ្លះពីអ្នកចូលរួម ( ការវាយតម្លៃវិជ្ជមាន ឬអវិជ្ជមាន)

## តារាងពេលវេលា

វគ្គសិក្សាស្តីពី *គោលនយោបាយការពារការផ្លាស់ប្តូរទីលំនៅដោយបង្ខំរបស់ធនាគារអភិវឌ្ឍន៍អាស៊ី* ត្រូវចំណាយពេលប្រមាណ ២០ម៉ោង។ វគ្គសិក្សាទាំងមូលនឹងត្រូវប្រព្រឹត្តទៅរយៈពេលបួនថ្ងៃ រាប់បញ្ចូលទាំងពេលវេលាសំរាប់ការពិភាក្សាទូទៅ និងការធ្វើផែនការ។

| **លេខរៀងមេរៀន** | **ចំណងជើងមេរៀន** | **ពេលវេលា (នាទី)** |
|---|---|---|
| ១ | តើធនាគារអភិវឌ្ឍន៍អាស៊ីជាអ្វី និងធ្វើអ្វី? | ៨០ |
| ២ | ផលប៉ះពាល់ដោយគម្រោងធនាគារអភិវឌ្ឍន៍អាស៊ី | ១០៥ |
| ៣ | ការបញ្ចៀសការផ្លាស់ប្តូរទីលំនៅ | ៨០ |
| ៤ | សិទ្ធិទទួលបានសំណង: ដី ឬ ផ្ទះ | ១១០ |
| ៥ | សំណង និងការតាំងទីលំនៅថ្មី | ៩០ |
| ៦ | សំណងសម្រាប់ការបាត់បង់មុខរបរចិញ្ចឹមជីវិត | ៨០ |
| ៧ | ការគាំទ្រមុខរបរចិញ្ចឹមជីវិត | ៩៥ |
| ៨ | ការរៀបចំព័ត៌មានដែលប្រជាពលរដ្ឋងាយយល់ | ១១០ |
| ៩ | តើការពិគ្រោះយោបល់ត្រឹមត្រូវមានន័យដូចម្តេច | ១០០ |
| ១០ | ការតាមដានគម្រោង | ៩០ |
| ១១ | ការធ្វើឱ្យធនាគារអភិវឌ្ឍន៍អាស៊ី និងរដ្ឋាភិបាលទទួលខុសត្រូវៈ យន្តការមូលដ្ឋាន | ៦០ |
| ១២ | ការប្រើប្រាស់យន្តការគណនេយ្យភាពរបស់ធនាគារ អភិវឌ្ឍន៍អាស៊ី | ៨០ |
| ១៣ | ការប្រើប្រាស់ទម្រង់ផ្សេងៗនៃការតស៊ូមតិដើម្បីធ្វើឱ្យធនាគារ អភិវឌ្ឍន៍អាស៊ី និងរដ្ឋាភិបាលទទួលខុសត្រូវ | ១១០ |
| **សរុបៈ ប្រមាណ ២០ ម៉ោង** | | |

# ធនាគារអភិវឌ្ឍន៍អាស៊ី

**លទ្ធផលទទួលបាន:**

ក្រោយពីបានរៀនចប់ជំពូកនេះ អ្នកចូលរួមនឹង:

១. យល់ថា តើធនាគារអភិវឌ្ឍន៍អាស៊ីជាអ្វី និងយល់ថា តើធនាគារនេះធ្វើអ្វី ឬមានបេសកកម្មអ្វី?

២. ដឹងអំពីប្រភេទនៃគម្រោងនានាដែលធនាគារនេះផ្តល់មូលនិធិគាំទ្រ។

៣. យល់ថា ធនាគារអភិវឌ្ឍន៍អាស៊ី មានឥទ្ធិពលធ្វើឱ្យប្រទេសកម្ពុជារីកចម្រើន។

## ១. តើធនាគារអភិវឌ្ឍន៍អាស៊ីជាអ្វី?

**ធនាគារអភិវឌ្ឍន៍អាស៊ី** ជាស្ថាប័នអន្តរជាតិមួយដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦៦។ ឥឡូវនេះ ធនាគារនេះត្រូវបានបង្កើតឡើងដោយមានបណ្តាប្រទេសចំនួន ៦៧ ជាសមាជិក។ ប្រទេសកម្ពុជាក៏ជាសមាជិកមួយនៃធនាគារនេះដែរ។ បេសកកម្មដែលធនាគារអភិវឌ្ឍន៍អាស៊ីបានបញ្ជាក់យ៉ាងច្បាស់គឺ "កាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់គុណភាពនៃជីវភាពរស់នៅ នៅតាមបណ្តាប្រទេសក្រីក្រនៅ តំបន់អាស៊ី។" ធនាគារនេះ មានការិយាល័យធំនៅទីក្រុងម៉ានីលនៃប្រទេសហ្វីលីពីន។ ធនាគារនេះ ក៏មានការិយាល័យនៅតាមប្រទេសនានាដែលខ្លួនធ្វើការដែរ។ ធនាគារអភិវឌ្ឍន៍អាស៊ីធ្វើការនៅក្នុង ប្រទេសកម្ពុជា និងមានការិយាល័យនៅរាជធានីភ្នំពេញ។



*ការិយាល័យធំនៃធនាគារអភិវឌ្ឍន៍អាស៊ី*

ធនាគារអភិវឌ្ឍន៍អាស៊ីធ្វើការនៅតាមប្រទេសនានា ដោយផ្តល់ប្រាក់ទៅរដ្ឋាភិបាលសម្រាប់គម្រោងជាច្រើនប្រភេទផ្សេងៗគ្នា ។ ធនាគារនេះក៏ផ្តល់ព័ត៌មាន យោបល់ និងជំនួយបច្ចេកទៅរដ្ឋាភិបាលដែរ ។

ធនាគារអភិវឌ្ឍន៍អាស៊ីផ្តល់ប្រាក់ទៅរដ្ឋាភិបាលជា **ប្រាក់កម្ចី** និង**ប្រាក់ជំនួយឥតសំណង** ។ នៅពេលដែលធនាគារនេះផ្តល់**ប្រាក់កម្ចី**ទៅរដ្ឋាភិបាល រដ្ឋាភិបាលនោះត្រូវតែសងប្រាក់នេះវិញដោយមានការប្រាក់ ។ ជាទូទៅ ការប្រាក់មិនខ្ពស់ទេសម្រាប់បណ្តាប្រទេសក្រីក្រ ។ នៅពេលដែលធនាគារផ្តល់ **ប្រាក់ជំនួយឥតសំណង**ទៅរដ្ឋាភិបាល រដ្ឋាភិបាលមិនចាំបាច់សងប្រាក់នេះវិញទេ ។

ធនាគារអភិវឌ្ឍន៍អាស៊ីក៏ផ្តល់មូលនិធិទៅក្រុមហ៊ុនឯកជន និងក្រុមអង្គការសង្គមស៊ីវិលសម្រាប់អនុវត្តគម្រោងជាក់លាក់ជាច្រើនទៀតដែរ ។

## ២. តើគម្រោងប្រភេទអ្វីខ្លះដែលធនាគារអភិវឌ្ឍន៍អាស៊ីគាំទ្រ ?

ធនាគារអភិវឌ្ឍន៍អាស៊ីផ្តល់មូលនិធិ ឬជំនួយសម្រាប់គម្រោងជាច្រើនប្រភេទផ្សេងៗគ្នា ដែលមានគោលបំណងកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់គុណភាពនៃជីវភាពរស់នៅ ។

ឧទាហរណ៍ ធនាគារអភិវឌ្ឍន៍អាស៊ីផ្តល់ជំនួយគាំទ្រគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដូចជាសាងសង់និងជួសជុលផ្លូវថ្នល់ ផ្លូវរថភ្លើង អាកាសយានដ្ឋាន រោងចក្រអគ្គិសនី ទំនប់វារីអគ្គិសនី សាលារៀន មណ្ឌលសុខភាព ប្រព័ន្ធប្រឡាយទឹក និងបណ្តាញទឹក និងអានាម័យ.



ធនាគារអភិវឌ្ឍន៍អាស៊ីក៏ផ្តល់ជំនួយបច្ចេកទេស និងផ្តល់យោបល់ទៅរដ្ឋាភិបាលផងដែរ។ ឧទាហរណ៍ ធនាគារនេះអាចនឹងផ្តល់ជំនួយបច្ចេកទេស ដោយជួយរដ្ឋាភិបាលក្នុងការរៀបចំ និងអនុវត្តគម្រោងនានា បណ្តុះបណ្តាលមន្ត្រីរាជការ ធ្វើការស្រាវជ្រាវ និងប្រមូលព័ត៌មាន ឬជួយតាក់តែងគោលនយោបាយ ឬច្បាប់នានា។ ជាក់ស្តែង នៅក្នុងប្រទេសកម្ពុជា ធនាគារអភិវឌ្ឍន៍អាស៊ី បានចូលរួមក្នុងការតាក់តែង ច្បាប់ភូមិបាលឆ្នាំ២០០១។



## ៣. ធនាគារអភិវឌ្ឍន៍អាស៊ីនៅក្នុងប្រទេសកម្ពុជា

នៅក្នុងប្រទេសកម្ពុជា គម្រោងខ្លះដែលធនាគារនេះចូលរួមមានដូចជា:

- គម្រោងសាងសង់ និងជួសជុលផ្លូវសំខាន់ៗនៅតាមតំបន់ជនបទ។
- គម្រោងសាងសង់ និងជួសជុលរោងចក្រអគ្គិសនី និងខ្សែបណ្តាញចែកចាយ។
- គម្រោងសាងសង់ និងអភិវឌ្ឍន៍សាលារៀននៅតាមតំបន់ជនបទ។
- គម្រោងសាងសង់ និងជួសជុលបំពង់ និងបណ្តាញចែកចាយទឹក។
- គម្រោងលើកទឹកចិត្តក្រុមហ៊ុនឯកជន និងការវិនិយោគទុនក្នុងវិស័យកសិកម្ម។
- គម្រោងជួលជុលផ្លូវរថភ្លើងពីប៉ោយប៉ែតកាត់រាជធានីភ្នំពេញទៅខេត្តព្រះសីហនុ។

គម្រោងទាំងអស់នេះមានផលល្អផង និងផលប៉ះពាល់ផង ដែលផលទាំងពីរនេះនឹងត្រូវលើកមកពិភាក្សានៅក្នុងផ្នែកបន្ទាប់។

ដោយសារធនាគារអភិវឌ្ឍន៍អាស៊ីផ្តល់ប្រាក់ ឬផ្តល់ប្រាក់កម្ចីទៅរដ្ឋាភិបាលជាច្រើន ក្នុងមួយឆ្នាំៗ និងដោយមានផ្តល់ព័ត៌មាន ជំនួយបច្ចេកទេស និងផ្តល់ការពិគ្រោះយោបល់ផងទៅក្រសួង មន្ទីរនានា ដូច្នេះ ធនាគារនេះមានឥទ្ធិពលធ្វើឱ្យប្រទេសកម្ពុជារីកចម្រើន។ ក្រុមសង្គមស៊ីវិលជាច្រើន បានលើកឡើង នូវកង្វល់អំពីប្រភេទនៃការអភិវឌ្ឍ ដែលធនាគារនេះកំពុងផ្តល់ជំនួយ និងបារម្ភថា មិនដឹងជាគម្រោង និងសកម្មភាពរបស់ធនាគារនេះផ្តល់ ឬមិនផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋក្រីក្រនោះឡើយ។ ដោយសារតែក្តីកង្វល់នេះហើយ ទើបប្រជាពលរដ្ឋកម្ពុជាគប្បីមានឱកាសចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តលើគម្រោងអភិវឌ្ឍន៍ផ្សេងៗ និងលើសកម្មភាពនានាទៀត ដែលធនាគារអភិវឌ្ឍន៍អាស៊ីចូលរួម។



## លំហាត់ទី១៖ តើធនាគារអភិវឌ្ឍន៍អាស៊ីជាអ្វី និងធ្វើអ្វី?

**គោលបំណង៖ អ្នកចូលរួមនឹងយល់ថា តើធនាគារអភិវឌ្ឍន៍អាស៊ីជាអ្វី និងមានបេសកកម្មអ្វី។ ពួកគាត់នឹងយល់ថា តើធនាគារអភិវឌ្ឍន៍អាស៊ីគាំទ្រគម្រោងប្រភេទអ្វីខ្លះ។ ពួកគាត់ក៏នឹងចូលរួមពិភាក្សាដែរ អំពីគម្រោងមួយចំនួននៅកម្ពុជា ដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី និងពិភាក្សាដែរ ថា តើធនាគារនេះបានទទួលជោគជ័យតាមបេសកកម្មរបស់ ខ្លួនដែរឬទេ។**

**សម្ភារបង្រៀន៖** ក្ដារខៀន ឬក្រដាសផ្ទាំងធំ និងហ្វឺត

**វិធីសាស្ត្រប្រើប្រាស់៖** ការបំផុសគំនិត ពិភាក្សារួម និទានរឿងផ្សេងៗ សំណួរល្បងចំណេះដឹង

| ដំណើរការ | រយៈពេល (គិតជានាទី) |
|---|---|
| ១. ការបង្ហាញព័ត៌មាននៅក្នុងផ្នែកទី១ | ១៥ |
| ២. ការបំផុសគំនិតអំពីបេសកកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី | ២០ |
| ៣. ការបង្ហាញព័ត៌មាននៅក្នុងផ្នែកទី២ និងផ្នែកទី៣ | ១៥ |
| ៤. ការពិភាក្សា និងនិទានរឿងនានា | ១៥ |
| ៥. សង្ខេបដោយមាន សំណួរល្បងចំណេះដឹង | ១៥ |
| **សរុប៖** | **៨០** |

## ការណែនាំសម្រាប់អ្នកសម្របសម្រួល

### ១. ការបង្ហាញព័ត៌មាននៅក្នុងផ្នែកទី១:

**ផ្នែកទី១:** សំខាន់នៅក្នុងផ្នែកនេះ អ្នកចូលរួមនឹងយល់:

- ថា តើធនាគារអភិវឌ្ឍន៍អាស៊ីជាអ្វី ។
- ថា បេសកកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ីគឺ ដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់គុណភាព នៃជីវភាពរបស់ប្រជាពលរដ្ឋនៅតាមបណ្តាប្រទេសក្រីក្រ ( ប្រទេសកំពុងអភិវឌ្ឍន៍) នានានៅក្នុង តំបន់អាស៊ី ។
- ថា ធនាគារអភិវឌ្ឍន៍ធ្វើការនៅតាមបណ្តាប្រទេសនានាដោយផ្តល់ប្រាក់ ការពិគ្រោះយោបល់ និងជំនួយបច្ចេកទេស ទៅរដ្ឋាភិបាលសម្រាប់អនុវត្តន៍គម្រោងជាច្រើនប្រភេទផ្សេងៗគ្នា ។
- អំពីអត្ថន័យខុសគ្នារវាង**ប្រាក់កម្ចី** និង**ប្រាក់ជំនួយឥតសំណង** ។

### ២. ការបំផុសគំនិតអំពីបេសកកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី

- សរសេរអំពីបេសកកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ីនៅលើក្រដាសផ្ទាំងធំ ឬនៅលើក្តារខៀន និងត្រូវប្រាកដថា អ្នកចូលរួមម្នាក់ៗយល់ថា វាមានន័យដូចម្តេច ដោយសួរអ្នកចូលរួម ក្រែងលោពួកគាត់នៅមិនទាន់យល់ច្បាស់អំពីអត្ថន័យនៃ **បេសកកម្ម**របស់ ធនាគារអភិវឌ្ឍន៍ អាស៊ី ។
- ស្នើសុំអ្នកចូលរួមឱ្យធ្វើការជាមួយគ្នាពីរៗរយៈ១០នាទី ដើម្បីពិភាក្សាគ្នា អំពីសួណួរដូចខាងក្រោមនេះ:
  - តើគម្រោងប្រភេទណាដែលពួកគាត់គិតថា ជួយឱ្យសម្រេចជោគជ័យបេសកកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី?
  - តើអ្នកនឹងទទួលផលប្រយោជន៍ពីគម្រោងទាំងនេះ?
- ក្រោយពីពួកគាត់បានពិភាក្សាគ្នាជាគូនេះចប់ ស្នើសុំឱ្យពួកគាត់ពីរ-បីនាក់ ចែករំលែកគំនិតរបស់គាត់ទៅអ្នកចូលរួមផ្សេងៗទៀត ។

## ៣. ការបង្ហាញព័ត៌មាននៅក្នុងផ្នែកទី២និងផ្នែកទី៣

**ផ្នែកទី២និងផ្នែកទី៣:** នៅក្នុងផ្នែកនេះ អ្នកចូលរួមចាំបាច់ត្រូវ:

- យល់អំពីប្រភេទនៃគម្រោងនានាដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី។
- យល់ថា គម្រោងទាំងនេះជាគម្រោងដែលត្រូវកាត់បន្ថយភាពក្រីក្រនិងលើកកម្ពស់គុណភាពនៃ ជីវភាពរបស់ប្រជាពលរដ្ឋ។
- យល់អំពី បណ្តាគម្រោងដែលធនាគារអភិវឌ្ឍន៍អាស៊ីគាំទ្រ។
- យល់ថា ប្រជាពលរដ្ឋកម្ពុជា គប្បីមានឱកាសចូលរួមពិភាក្សាថា តើធនាគារអភិវឌ្ឍន៍អាស៊ី ធ្វើអ្វីខ្លះនៅក្នុងប្រទេសកម្ពុជា ព្រោះធនាគារនេះ មានឥទ្ធិពលធ្វើឱ្យប្រទេសកម្ពុជារីកចម្រើន។

- មុននឹងពន្យល់ចំណុចចុងក្រោយទី២ អ្នកអាចសួរអ្នកចូលរួមមើលក្រែងលោពួកគាត់ធ្លាប់បានឮអំពីគម្រោង ឬកម្មវិធីណាមួយដែលធនាគារអភិវឌ្ឍន៍អាស៊ីធ្លាប់បានគាំទ្រ នៅក្នុង ប្រទេសកម្ពុជា។

## ៤. ការពិភាក្សានិងការនិទានរឿងផ្សេងៗ

- សួរអ្នកចូលរួមថា តើពួកគាត់យល់ដូចម្តេចចំពោះគម្រោងនានាដែលធនាគារអភិវឌ្ឍន៍អាស៊ី ធ្លាប់គាំទ្រនៅក្នុងប្រទេសកម្ពុជា។ តើពួកគាត់គិតថា គម្រោងទាំងអស់នោះជាគម្រោងល្អ និងបានសម្រេចបេសកកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងការកាត់បន្ថយភាពក្រីក្រ និងការលើកកម្ពស់គុណភាពនៃជីវភាពរបស់ ប្រជាពលរដ្ឋទេ? ហេតុអ្វីបានជាពួកគាត់គិតដូច្នោះ? ឬហេតុអ្វីបានជាពួកគាត់មិនគិតដូច្នោះ?
- សួរអ្នកចូលរួមមើលថា តើពួកគាត់មានប្រឈមប៉ះពាល់ដោយសារគម្រោងណាមួយក្នុងចំណោមគម្រោងទាំងនោះដោយផ្ទាល់ទេ ឬថាតើពួកគាត់ធ្លាប់បានឮអំពីផលប៉ះពាល់លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដោយសារគម្រោងទាំងនោះទេ?
- លើកទឹកចិត្ត អ្នកចូលរួមឱ្យចែករំលែកនូវយោបល់ គំនិត និងរឿងរ៉ាវផ្សេងៗអំពីគម្រោង ទាំងនោះ។

## ៥. សង្ខេប

- ស្នើសុំឱ្យអ្នកចូលរួមឈរជារង្វង់ជុំវិញអ្នក និងពន្យល់ថា អ្នកនឹងបោះបាល់ទៅអ្នកចូលរួមណាម្នាក់ និងសួរអ្នកចូលរួមដែលមានបាល់នៅក្នុងដៃ មួយសំណួរអំពីធនាគារអភិវឌ្ឍន៍អាស៊ី និង ការងារ ឬបេសកកម្មរបស់ធនាគារនោះ។ ក្រោយពីអ្នកចូលរួមនោះឆ្លើយសំណួររួច ត្រូវបោះបាល់នោះទៅអ្នកផ្សេងដែលអ្នកត្រូវសួរសំណួរមួយផ្សេងទៀត។ (ខាងក្រោមនេះជា សំណួរជាឧទាហរណ៍)។

**សំណួរជាឧទាហរណ៍:**

១. តើធនាគារអភិវឌ្ឍន៍អាស៊ីជាអ្វី?

**<u>ចម្លើយគ្រោងទុក</u>:** ធនាគារអភិវឌ្ឍន៍អាស៊ី ជាស្ថាប័នអន្តរជាតិមួយ ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៦៦ និងមានបណ្តាប្រទេសជាច្រើនជាសមាជិក។

២. តើធនាគារអភិវឌ្ឍន៍អាស៊ីមានបេសកកម្មអ្វី?

**<u>ចម្លើយគ្រោងទុក</u>:** បេសកកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី គឺដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់គុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមបណ្តាប្រទេសក្រីក្រនៅក្នុងតំបន់អាស៊ី។

៣. តើការិយាល័យធំរបស់ធនាគារអភិវឌ្ឍន៍អាស៊ីនៅឯណា?

**<u>ចម្លើយគ្រោងទុក</u>:** ក្រុងម៉ានីល ប្រទេសហ្វីលីពីន។

៤. តើ**ប្រាក់កម្ចី** និង**ប្រាក់ជំនួយឥតសំណង**របស់ធនាគារអភិវឌ្ឍន៍អាស៊ី ខុសគ្នាដូចម្តេច?

**<u>ចម្លើយគ្រោងទុក</u>:** រដ្ឋាភិបាលត្រូវសងប្រាក់កម្ចីដោយមានការប្រាក់ទៅធនគារអភិវឌ្ឍន៍អាស៊ីវិញ។

៥. សូមលើកឧទាហរណ៍បី អំពីប្រភេទគម្រោងដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី។ (អ្នកអាចសួរសំណួរនេះពីរដង)។

**<u>ចម្លើយគ្រោងទុក</u>:** ផ្លូវថ្នល់ ផ្លូវរថភ្លើង រោងចក្រអគ្គិសនី ទំនប់វារីអគ្គិសនី សាលារៀន មណ្ឌលសុខភាព ប្រព័ន្ធប្រឡាយទឹក និងបណ្តាញទឹកស្អាត និង អនាម័យ។

៦. តើជំនួយបច្ចេកទេសអ្វី ដែលធនាគារអភិវឌ្ឍន៍អាស៊ីអាចនឹងផ្តល់ជូនរដ្ឋាភិបាល?

**<u>ចម្លើយគ្រោងទុក</u>:** ធនាគារនេះអាចនឹងផ្តល់ជំនួយបច្ចេកទេសដូចជា ជួយរៀបចំ និងអនុវត្តគម្រោង បណ្តុះបណ្តាលជំនាញដល់មន្ត្រីរាជការ ចុះស្រាវជ្រាវ និងប្រមូលព័ត៌មាន ឬសរសេរគោលនយោបាយ និងច្បាប់នានា។

៧. តើហេតុអ្វីបានជាថា ប្រជាពលរដ្ឋខ្មែរចាំបាច់ត្រូវមានឱកាសចូលរួមក្នុងសេចក្តីសម្រេចចិត្តអំពីគម្រោង និងសកម្មភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី?

**<u>ចម្លើយគ្រោងទុក</u>:** ព្រោះធនាគារអភិវឌ្ឍន៍អាស៊ី មានឥទ្ធិពលធ្វើឱ្យប្រទេសកម្ពុជា រីកចម្រើន។

# ផលប៉ះពាល់ពីគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី



**លទ្ធផលទទួលបាន**

**ក្រោយពីបានរៀនចប់ជំពូកនេះ អ្នកចូលរួមនឹង:**

១. យល់ថា គម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ីមានផលល្អ (វិជ្ជមាន) ផង និងផលប៉ះពាល់ (អវិជ្ជមាន) ផង។

២. ដឹងថា គម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ីដែល ធ្វើឱ្យគុណភាពនៃជីវភាពរស់នៅកាន់តែអន់ជាង មុនមិនជួយឱ្យសម្រេចបេសកកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ីទេ។

៣. យល់ដឹងថា គោលនយោបាយការពាររបស់ធនាគារ ត្រូវបានបង្កើតឡើងដោយមានក្តីបារម្ភអំពីផលប៉ះពាល់ពីគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

៤. ដឹងថា តើគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ីមានអ្វីខ្លះ និងតើគោលនយោបាយនេះមានគោលបំណងអ្វីខ្លះ។

៥. យល់ដឹងថា ហេតុអ្វីបានជាចាំបាច់ត្រូវដឹងអំពីគោលនយោបាយនេះ។

## ១. គម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងបេសកកម្មរបស់ធនាគារនេះ

បេសកកម្មដែលធនាគារអភិវឌ្ឍន៍អាស៊ីបានបញ្ជាក់យ៉ាងច្បាស់គឺ "កាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់គុណភាពនៃជីវភាពរស់នៅរបស់ប្រជាជននៅតាមបណ្តាប្រទេសក្រីក្រនៅតំបន់អាស៊ី"។ គ្រប់គម្រោងទាំងអស់ ដែលធនាគារអភិវឌ្ឍន៍អាស៊ីផ្តល់មូលនិធិគាំទ្រ ត្រូវតែជួយសម្រេចបេសកកម្មនេះ។ នេះមានន័យថា មុននឹងធនាគារអភិវឌ្ឍន៍អាស៊ីយល់ព្រមផ្តល់មូលនិធិសម្រាប់គាំទ្រគម្រោងសង់ទំនប់វារីអគ្គិសនី ផ្លូវថ្នល់ ឬផ្លូវរថភ្លើង ឬគម្រោងផ្សេងៗជាដើម ធនាគារគប្បីត្រូវប្រាកដថា គម្រោងនោះនឹងជួយលើកកម្ពស់គុណភាពនៃជីវភាពរបស់ប្រជាពលរដ្ឋ។

ប៉ុន្តែ គម្រោងជាច្រើនដែលធនាគារអភិវឌ្ឍន៍អាស៊ី ផ្តល់ការគាំទ្រមានផលល្អផង និងផលប៉ះពាល់ផងទៅលើប្រជាពលរដ្ឋ និងបរិស្ថាន។ ជាពិសេស វាពិតជាមានផលយ៉ាងដូច្នោះសម្រាប់បណ្តាគម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗ។

| ករណីសិក្សាៈ គម្រោងធ្វើផ្លូវជាតិលេខ១នៅកម្ពុជា |
|---|
| នៅឆ្នាំ១៩៩៨ ធនាគារអភិវឌ្ឍន៍អាស៊ីបានឯកភាពផ្តល់ប្រាក់កម្ចីចំនួន៤០លានដុល្លារ ទៅរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីសាងសង់ និងជួសជុលផ្លូវមួយខ្សែដែលមានឈ្មោះថា ផ្លូវជាតិលេខ១ ពីភ្នំពេញ ទៅព្រំដែនវៀតណាម ។<br>ធនាគារអភិវឌ្ឍន៍អាស៊ីបានបញ្ជាក់អះអាងថា ផលល្អនៃគម្រោងសាងសង់ និងជួសជុលផ្លូវជាតិលេខ១ មានដូចខាងក្រោមនេះ:<br>• សហប្រតិបត្តិការសេដ្ឋកិច្ចរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម កើនឡើង ។<br>• ការធ្វើដំណើរតាមផ្លូវជាតិនេះ ពីភ្នំពេញទៅវៀតណាម និងពីវៀតណាមទៅភ្នំពេញ នឹងកាន់តែស្រួលកាន់តែថោក និងកាន់តែលឿន ។<br>• តម្លៃ និងការដឹកទំនិញនៅក្នុងប្រទេសកម្ពុជា និងការដឹកទំនិញទៅប្រទេសវៀតណាម និងដឹកទំនិញពីវៀតណាម ចូលមកកម្ពុជាកាន់តែលឿន និងថោកជាងមុន ។<br>• សុវត្ថិភាពធ្វើដំណើររបស់ប្រជាពលរដ្ឋតាមផ្លូវជាតិនេះកាន់តែល្អប្រសើរ ។<br>• ប្រជាពលរដ្ឋអាចបើកមុខរបររកស៊ីថ្មីៗ នៅតាមសងខាងផ្លូវជាតិនេះបាន ព្រោះនឹងមានអតិថិជនកាន់តែច្រើនដែលធ្វើដំណើរតាមផ្លូវនេះ ។[១]<br><br>ទោះជាមានផលល្អយ៉ាងនេះក្តី ក៏គម្រោងសាងសង់ និងជួសជុលផ្លូវជាតិលេខ១នេះ បានធ្វើឱ្យអ្នកភូមិជាង ៦០០០នាក់ដែលកំពុងរស់នៅតាមសងខាងផ្លូវនេះត្រូវគេបណ្តេញចេញពីទីលំនៅរបស់គាត់ ព្រោះដីរបស់គាត់ត្រូវរដ្ឋយកទៅធ្វើផ្លូវជាតិនេះ ។ ប្រជាពលរដ្ឋ មិនទទួលបានសំណងសមរម្យសម្រាប់ទីលំនៅ និងដីស្រែរបស់គាត់ដែលត្រូវបាត់បង់នោះទេ ។ ហេតុដូច្នេះហើយ គម្រោងធ្វើផ្លូវជាតិនេះ បានបណ្តាលឱ្យប្រជាពលរដ្ឋ មានបញ្ហាជាច្រើនដូចខាងក្រោមនេះ:<br>• ប្រជាពលរដ្ឋលែងមានទីលំនៅ រស់នៅនិងលែងមានដីធ្លី ។<br>• ការប្រកបមុខរបរចិញ្ចឹមជីវិតត្រូវអាក់ខាន ព្រោះពួកគាត់ត្រូវគេបណ្តេញឱ្យចេញពីដីរបស់គាត់ ។<br>• ប្រជាពលរដ្ឋត្រូវតែខ្ចីប្រាក់ក្នុងអត្រាការប្រាក់យ៉ាងខ្ពស់ ដើម្បីបន្តរស់នៅ និងក្រោយមក ពួកគាត់ត្រូវជាប់បំណុលរ៉ៃណ្ឌក រកប្រាក់សងគេវិញមិនបានឡើយ ។[២] |

[១] ធនាគារអភិវឌ្ឍន៍អាស៊ី របាយការណ៍និងអនុសាសន៍របស់ប្រធានធនាគារជូនក្រុមប្រឹក្សាភិបាល ស្តីពីសំណើប្រាក់កម្ចីជូន ព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម សម្រាប់គម្រោងអនុមហាទន្លេមេគង្គ: គម្រោងផ្លូវជាតិ ពីរាជធានីភ្នំពេញទៅទីក្រុងហូជីមិញ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ។

[២] គេហទំព័រឈ្មោះ Mekong Watch Japan, ចុះផ្សាយអត្ថបទមួយក្រោមចំណងជើងថា "ប្រទេសកម្ពុជា: ផ្លូវជាតិលេខ១" ។ សូមបើកមើលព័ត៌មាននេះតាមអាសយដ្ឋានគេហទំព័រដូចតទៅ: http://mekongwatch.org/english/country/cambodia/HighwayOne/index.html

នេះមានន័យថា ផលប៉ះពាល់ដែលបណ្ដាលមកពីគម្រោងសង់និងជួសជុលផ្លូវជាតិនេះ ធ្វើឱ្យប្រជាពលរដ្ឋកាន់តែក្រ និងគុណភាពនៃជីវភាពរស់នៅរបស់ពួកគាត់កាន់តែដុនដាប ដោយសារតែគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។ លទ្ធផលនៃគម្រោងនេះ គឺពិតជាផ្ទុយទៅនឹងបេសកកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ីយ៉ាងពិតប្រាកដ ណាស់ ។



*គម្រោងដែលផ្ដល់ប្រាក់ដោយធនាគារអភិវឌ្ឍន៍អាស៊ី មានផលវិជ្ជមាន និងផលប៉ះពាល់អវិជ្ជមាន ។ ផ្លូវជាតិថ្មីមួយអាចនឹងជួយវិស័យដឹកជញ្ជូនរបស់កម្ពុជាឱ្យល្អប្រសើរ ប៉ុន្តែវាក៏ធ្វើឱ្យមានប្រជាពលរដ្ឋបាត់បង់ ទីលំនៅដែរ ។*

ដើម្បីអនុវត្តតាមបេសកកម្មរបស់ខ្លួនឱ្យបានត្រឹមត្រូវ ធនាគារអភិវឌ្ឍន៍អាស៊ីមិនគួរផ្ដល់ប្រាក់កម្ចីទៅគម្រោងដែលបង្កើនភាពក្រីក្រ ឬធ្វើឱ្យប្រជាពលរដ្ឋមានការលំបាកវេទនានោះទេ ឬធ្វើឱ្យគុណភាពនៃជីវភាពរស់នៅកាន់តែអន់ជាងមុននោះទេ ។ ទោះបីជាមានប្រជាពលរដ្ឋតែប៉ុន្មានគ្រួសារដែលត្រូវខូចខាតដោយសារគម្រោងនោះក៏ដោយ ក៏ធនាគារអភិវឌ្ឍន៍អាស៊ីមិនគួរផ្ដល់ប្រាក់កម្ចីដែរ ប្រសិនបើគម្រោងនោះគ្មានផែនការល្អច្បាស់លាស់ដើម្បីបញ្ចៀសការខូចខាត នោះទេ ។

# ២. ការបង្កើតគោលនយោបាយការពារ

នៅអំឡុងទស្សវត្សរ៍ឆ្នាំ១៩៨០ និង១៩៩០ ក្រុមអង្គការសង្គមស៊ីវិលបានរិះគន់ធនាគារអភិវឌ្ឍន៍អាស៊ីជាសាធារណៈ អំពីផលប៉ះពាល់ដោយសារគម្រោង និងបញ្ហានានាដែលបណ្តាលមកពីរបៀបធ្វើការរបស់ធនាគារនេះ។ ក្រុមអង្គការសង្គមស៊ីវិលទាំងនេះបានលើកឡើងនូវហេតុផលមកពន្យល់ថា គម្រោងអភិវឌ្ឍន៍ទាំងនោះមិនគួរធ្វើឱ្យមានផលប៉ះពាល់ ឬបង្កការខូចខាត ឬប៉ះពាល់ដល់ប្រជាពលរដ្ឋ ឬបរិស្ថានទេ និងថាបណ្តាគម្រោងទាំងនោះគប្បីត្រូវមានផែនការច្បាស់លាស់ ដើម្បីឱ្យប្រជាពលរដ្ឋម្នាក់ៗទទួល បានផលប្រយោជន៍ទាំងអស់គ្នា មិនមែនមនុស្សតែមួយចំនួនតូច នោះទេ។




នៅឆ្នាំ១៩៩៥ ធនាគារអភិវឌ្ឍន៍អាស៊ី បានបង្កើតគោលនយោបាយការពារនានា។ គោលនយោបាយត្រូវបានកែសម្រួលឡើងវិញនៅឆ្នាំ២០០៩។ គោលនយោបាយនេះជាវិធានដែលធនាគារអភិវឌ្ឍន៍អាស៊ី និងរដ្ឋាភិបាលត្រូវតែគោរព នៅពេលមានកិច្ចព្រមព្រៀងធ្វើការលើគម្រោងណាមួយរួមគ្នា។ វិធានទាំងអស់នេះមានគោលបំណងការពារកុំឱ្យមានផលប៉ះពាល់លើប្រជាពលរដ្ឋ និងបរិស្ថាន ក្នុងការអនុវត្តគម្រោងដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី។ វិធានទាំងនេះ ក៏មានគោលបំណងធ្វើឱ្យប្រាកដដែរថា ប្រជាពលរដ្ឋដែលនឹងប្រឈមផលប៉ះពាល់ដោយសារគម្រោង ដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី នឹងអាចមានឱកាសទទួលបានព័ត៌មាន និងមានការពិគ្រោះយោបល់យ៉ាងត្រឹមត្រូវ។

**តើអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តតាមគោលនយោបាយនេះ?**

គោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី នឹងត្រូវអនុវត្តនៅពេលដែលធនាគារនេះផ្តល់មូលនិធិគាំទ្រគម្រោងណាមួយទៅបណ្តាប្រទេសនានា ដោយមានទាំងប្រទេសកម្ពុជាដែរ។ ទាំងរដ្ឋាភិបាល ទាំងធនាគារអភិវឌ្ឍន៍អាស៊ី ត្រូវតែគោរពគោលនយោបាយការពារទាំងនេះនៅពេលធ្វើផែនការ និងនៅពេលអនុវត្តគម្រោង។

នៅពេលដែលរដ្ឋាភិបាលចុះកិច្ចព្រមព្រៀងជាមួយធនាគារអភិវឌ្ឍន៍អាស៊ីដើម្បីខ្ចីប្រាក់ ឬទទួលប្រាក់ជំនួយឥតសំណងសម្រាប់គម្រោងណាមួយ រដ្ឋាភិបាលក៏ត្រូវតែយល់ព្រមអនុវត្តតាមគោលនយោបាយ នេះដែរ។

- វាជាការទទួលខុសត្រូវរបស់រដ្ឋាភិបាលក្នុងការបំពេញលក្ខខណ្ឌទាំងអស់នៅក្នុង គោលនយោបាយនេះ។
- វាជាការទទួលខុសត្រូវរបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងការគ្រប់គ្រង និងធ្វើឱ្យប្រាកដថា រដ្ឋាភិបាលអនុវត្តតាមគោលនយោបាយនេះយ៉ាងត្រឹមត្រូវ។

## ៣. ហេតុអ្វីបានជាយើងចាំបាច់ត្រូវដឹងអំពីគោលនយោបាយការពារនេះ?

គោលបំណងនៃគោលនយោបាយការពារគឺ ដើម្បីទប់ស្កាត់កុំឱ្យមានការខូចខាត ឬប៉ះពាល់ដល់ប្រជាជន និងបរិស្ថាន ដោយសារការអនុវត្តគម្រោងដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី។ ប៉ុន្តែ មានគំរូជាច្រើនទាក់ទងនឹងគម្រោងនានា ដែលរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ីមិនគោរពតាមគោលនយោបាយការពារនេះ។ ប្រជាជននៅតែត្រូវគេផ្លាស់ប្តូរទីលំនៅ និងមិនបានទទួលការដោះស្រាយ និងសងសំណងបានត្រឹមត្រូវទេ ចំណែកឯគុណភាពនៃជីវភាពរបស់ប្រជាជនកាន់តែដុនដាបជាងមុន។

ដោយសារហេតុដូច្នេះហើយ បានជាប្រជាជនចាំបាច់ត្រូវតែដឹងអំពី គោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងដឹងអំពីខ្លឹមសារនៃគោលនយោបាយនេះ។ ប្រសិនបើប្រជាជនដែលនឹងត្រូវប្រឈមផលប៉ះពាល់ដោយគម្រោងដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ដឹងអំពីខ្លឹមសារនៃគោលនយោបាយការពារទាំងនេះ ពេលនោះ ពួកគាត់អាចតាមឃ្លាំមើលការធ្វើផែនការ និងការអនុវត្តគម្រោង ដើម្បីឱ្យដឹងថា តើការធ្វើផែនការ និងការអនុវត្តនោះគោរព ឬមិនគោរពតាមវិធានការពារទាំងនេះ។ ប្រសិនរដ្ឋាភិបាលមិនគោរពតាមគោលនយោបាយនេះយ៉ាងត្រឹមត្រូវទេ នោះមានកិច្ចជាច្រើនដែលប្រជាពលរដ្ឋអាចធ្វើ ដើម្បីទាមទារឱ្យរដ្ឋាភិបាលគោរពសិទ្ធិរបស់គាត់ទៅតាមគោលនយោបាយនេះ។ កិច្ចការដែលពួកគាត់អាចធ្វើទាំងនោះនឹងត្រូវលើកមកពិភាក្សានៅក្នុងផ្នែកក្រោយៗ។



# លំហាត់ទី២: ផលប៉ះពាល់ពីគម្រោងគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី



**គោលបំណង: អ្នកចូលរួមនឹងយល់ថា គម្រោងដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី មាន ផលវិជ្ជមាន និង ផលអវិជ្ជមាន។ ពួកគាត់នឹងដឹងថា តើគោលនយោបាយនេះជាអ្វី និងតើវាមាន គោល បំណងអ្វី។ ពួកគាត់នឹងដឹងថា តើអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការអនុវត្ត គោលនយោបាយនេះ។**

**សម្ភារបង្រៀន:** ក្ដារខៀន ឬក្រដាសផ្ទាំងធំ ហ្វឺត ឯកសារសម្រាប់ចែកទី១, ២ និង៣។

**វិធីសាស្ត្រប្រើប្រាស់:** ការងារជាក្រុម បទបង្ហាញ ការបំផុសគំនិត ការពិភាក្សាក្រុមធំ និងការនិទានរឿងរ៉ាវនានា។

| **ដំណើរការ** | **រយៈពេល (គិតជានាទី)** |
|---|---|
| ១. ការពិភាក្សាក្រុមធំអំពីរឿង និងរូបភាព | ១០ |
| ២. ណែនាំព័ត៌មាននៅក្នុងផ្នែក១ | ១៥ |
| ៣. ពន្យល់លំហាត់ និងអានសេណារីយោ (ឈុតឆាក) | ៥ |
| ៤. ការងារជាក្រុម | ២០ |
| ៥. ការពិភាក្សាក្រុមធំ និងបទបង្ហាញតាមក្រុម | ២០ |
| ៦. ការណែនាំព័ត៌មាននៅក្នុងផ្នែកទី២ និងផ្នែក៣ | ២០ |
| ៧. ការសង្ខេបអំពីបទពិសោធន៍របស់អ្នកចូលរួម | ១៥ |
| **សរុប:** | **១០៥** |

## ការណែនាំសម្រាប់អ្នកសម្របសម្រួល

### ១. ការពិភាក្សាក្រុមធំអំពីរឿងនិងរូបភាព

- ចែកឯកសារទី១ ពីរ-បីច្បាប់ទៅអ្នកចូលរួម ដើម្បីឱ្យពួកគាត់អាចមើលរូបភាពផ្សេងៗ។
- ក្នុងចំណោមអ្នកចូលរួមទាំងអស់ ស្នើសុំឱ្យអ្នកចូលរួមម្នាក់អានរឿងនៅក្នុងឯកសារ សម្រាប់ចែកទី២អំពីរោងចក្រដែលកំពុងត្រូវបានសាងសង់នៅក្នុងភូមិមួយនៅជាយ ក្រុងភ្នំពេញ។
- សួរអ្នកចូលរួមថា តើការសាងសង់រោងចក្រនោះមានផលល្អអ្វីខ្លះ និងសួរថា តើអ្នកណាជាអ្នកទទួលផលប្រយោជន៍។
- សួរអ្នកចូលរួមថា តើការសាងសង់រោងចក្រនោះមានផលប៉ះពាល់អ្វីខ្លះ និងសួរថា តើអ្នកណាជាអ្នកទទួលការខូចខាត។
- ពន្យល់ថា គម្រោងនានា ដូចជាគម្រោងមួយនេះ អាចមើលទៅដូចជាមានគំនិតល្អ ព្រោះប្រជាពលរដ្ឋខ្លះនឹងបានទទួលផលប្រយោជន៍ ឬដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋខ្លះ។ ប៉ុន្តែ មានគម្រោងជាច្រើនក៏បង្កឱ្យមានផលប៉ះពាល់ ដែលធ្វើឱ្យអ្នកផ្សេង ឬក្រុមផ្សេងមានការ ខូចខាតដែរ។
- សួរអ្នកចូលរួមមើលថា តើពួកគាត់យល់ថា គម្រោងនេះយុត្តិធម៌ទេ។

### ២. ការបង្ហាញព័ត៌មាននៅក្នុងផ្នែកទី១

**ផ្នែកទី១:** វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមត្រូវយល់ដឹងថា:

- មុននឹងធនាគារយល់ព្រមផ្តល់ប្រាក់គាំទ្រគម្រោងណាមួយ ធនាគារ គប្បីត្រូវប្រាកដថា គម្រោងនោះនឹងពិតជាជួយលើកកម្ពស់គុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។
- គម្រោងជាច្រើនដែលធនាគារអភិវឌ្ឍន៍អាស៊ីគាំទ្រ មានផលល្អផងនិងផលប៉ះពាល់ផង។
- ធនាគារអភិវឌ្ឍន៍អាស៊ីមិនគួរផ្តល់មូលនិធិគាំទ្រគម្រោងណាដែលធ្វើឱ្យមានភាពក្រីក្រ និងការលំបាកកាន់តែខ្លាំងជាងមុន ឬដែលបង្កការខូចខាតយ៉ាងធ្ងន់ធ្ងរដល់បរិស្ថាននោះឡើយ។

### ៣. ពន្យល់លំហាត់និងអានសេណារីយោ (ឈុតឆាក)

- ពន្យល់អ្នកចូលរួមថា ពួកគាត់នឹងត្រូវចែកជាបីក្រុម ដែលក្រុមនីមួយៗនឹងមានឱកាសពិភាក្សាអំពីសេណារីយោមួយ។ សេណារីយោនេះទាក់ទងនឹងផែនការ សម្រាប់គម្រោងមួយជាតួយ៉ាង ដែលគាំទ្រដោយ

ធនាគារអភិវឌ្ឍន៍អាស៊ី។ គ្រប់ក្រុមត្រូវគិត និងពិភាក្សាអំពីផលល្អ និងផលប៉ះពាល់ដែលបណ្ដាលមកពីគម្រោងនេះ។

- ក្រុមនីមួយៗគប្បីត្រូវគិតរកលទ្ធផលនៃគម្រោងនេះ ឱ្យបានកាន់តែច្រើនតាមតែលទ្ធភាព ដែលក្រុមអាចគិតឃើញ និងពិភាក្សាគ្នាថា តើគម្រោងនេះគប្បីត្រូវបន្តអនុវត្ត ឬត្រូវបញ្ឈប់។
- ក្រុមនីមួយៗគប្បីសម្រេចចិត្តថា តើគម្រោងនេះអាចនឹងជួយសម្រេចបេសកកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ីដែរឬទេ។ យកល្អអ្នកគប្បីសរសេរបេសកកម្មរបស់ធនាគារនេះ នៅលើក្ដារខៀន ដើម្បីឱ្យក្រុមនីមួយៗមើលវានៅពេលដែលក្រុមកំពុងពិភាក្សាគ្នា។
- ចែកអ្នកចូលរួមជាបីក្រុម ហើយក្រុមនីមួយៗ ត្រូវមានឯកសារសំរាប់ចែកទី៣ពីរ-បីច្បាប់ និងក្រដាសផ្ទាំងធំ។
- ក្រុមនីមួយៗមានពេល២០នាទីសម្រាប់ជជែកគ្នាអំពីសំណួរពិភាក្សាទាំងនោះ ក្រោយមកទៀត ក្រុមនឹងត្រូវឡើងបង្ហាញលទ្ធផលដែលក្រុមបានពិភាក្សាគ្នាទៅ អ្នកចូលរួមផ្សេងៗ ទៀត។

## ៤. ការងារជាក្រុម

- ដើរត្រួតពិនិត្យគ្រប់ក្រុម ដើម្បីឱ្យប្រាកដថា អ្នកចូលរួមម្នាក់ៗយល់អំពីការងារដែលត្រូវធ្វើ។
- សូមប្រាកដថា នៅតាមក្រុមនីមួយៗត្រូវមានអ្នកណាម្នាក់ចេះអានអក្សរ ប្រសិនក្នុងក្រុមណាមួយគ្មានអ្នកចេះអានទេ សូមអ្នកអានសេណារីយោនោះឱ្យឮខ្លាំងៗ និងត្រូវប្រាកដថា ពួកគាត់ម្នាក់ៗយល់សេណារីយោនេះ។

## ៥. បទបង្ហាញរបស់ក្រុមនីមួយៗនិងការពិភាក្សាក្រុមធំ

- ផ្ដល់ពេល៥នាទីទៅក្រុមនីមួយៗដើម្បីឡើងបង្ហាញអំពីលទ្ធផលដែលក្រុមបានពិភាក្សា។
- ត្រូវប្រាកដថា ក្រុមនីមួយៗនឹងបង្ហាញលទ្ធផល ទាំងផលល្អ និងផលប៉ះពាល់របស់គម្រោង ក៏ដូចជាត្រូវបង្ហាញថា តើក្រុមសម្រេចចិត្តថាបន្តអនុវត្តគម្រោង ឬបញ្ឈប់ការអនុវត្តគម្រោង។ ក្រុមនីមួយៗក៏គប្បីត្រូវបង្ហាញដែរថា តើពួកគាត់គិតថាគម្រោងនោះជួយសម្រេចបេសកកម្មរបស់ធនាគារអភិវឌ្ឍន៍ដែរឬទេ។ តើហេតុអ្វីបានជាគម្រោងនេះជួយ ឬមិនជួយសម្រេចបេសកកម្មរបស់ធនាគារនេះ។
- ក្រោយពីក្រុមនីមួយៗបានឡើងបង្ហាញរួចហើយ អ្នកអាចសួរអ្នកចូលរួមថា តើត្រូវធ្វើអ្វីខ្លះ ដើម្បីបញ្ឈប់ផលប៉ះពាល់នៃគម្រោងនោះ។ អ្នកក៏អាចសួរដែរថា តើពួកគាត់គិតថា ចាំបាច់ ត្រូវការផ្លាស់ប្ដូរអ្វីខ្លះទាក់ទងនឹងគម្រោងនេះ ឬសួរថា តើត្រូវធ្វើអ្វីខ្លះទៀតដើម្បីធ្វើឱ្យគម្រោងអភិវឌ្ឍន៍នោះជាគម្រោងល្អ។ ពួកគាត់អាចនឹងគិតថា វាមិនអាចមានលទ្ធភាព ធ្វើអ្វីមួយដើម្បីកែប្រែគម្រោងនោះឱ្យល្អឡើងវិញទេ និងគិតថា ធនាគារអភិវឌ្ឍន៍អាស៊ីមិន គួរផ្ដល់ប្រាក់ជំនួយសម្រាប់គម្រោងនេះទេ។

## ៦. ការណែនាំព័ត៌មាននៅក្នុងផ្នែកទី២និងទី៣

**ផ្នែកទី២និងទី៣:** *វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមចាំបាច់ត្រូវយល់ដឹងថា:*

- គោលនយោបាយជាវិធានដែលធនាគារអភិវឌ្ឍន៍អាស៊ី និងរដ្ឋាភិបាលត្រូវតែគោរព នៅពេលដែលភាគីទាំងពីរឯកភាពធ្វើការរួមគ្នាលើគម្រោងណាមួយ ។
- គោលនយោបាយនេះក៏មានបំណងទប់ស្កាត់ផលប៉ះពាល់នានាទៅលើប្រជាពលរដ្ឋ និងបរិស្ថានដែលបណ្តាលមកពី គម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។
- គោលនយោបាយនេះក៏មានគោលបំណង ធ្វើឱ្យប្រាកដថា ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយសារគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី នឹងមានសិទ្ធិទទួលបានព័ត៌មាន និងការពិគ្រោះយោបល់យ៉ាងត្រឹមត្រូវ ។
- រដ្ឋាភិបាលជាអ្នកទទួលខុសត្រូវក្នុងការបំពេញលក្ខខណ្ឌនានានៅក្នុងគោលនយោបាយនេះ ចំណែកឯធនាគារអភិវឌ្ឍន៍អាស៊ីវិញ ក៏ត្រូវតែគ្រប់គ្រង និងត្រូវធ្វើឱ្យប្រាកដថា គោលនយោបាយរបស់ខ្លួនត្រូវបានគោរពយ៉ាងត្រឹមត្រូវ ។
- ហេតុអ្វីបានជាចាំបាច់ត្រូវដឹងអំពីគោលនយោបាយនេះ ។

## ៧. ការសង្ខេបអំពីបទពិសោធន៍ផ្ទាល់របស់អ្នកចូលរួម

- ស្នើសុំឱ្យអ្នកចូលរួមគិតអំពីគម្រោងដែលកំពុងធ្វើឱ្យប៉ះពាល់ដល់ពួកគាត់ ។ តើគម្រោងនេះ ធ្វើឱ្យមានផលប៉ះពាល់វិជ្ជមាន និងផលប៉ះពាល់អវិជ្ជមានអ្វីខ្លះ? តើមានអ្នកណាម្នាក់ ទទួលរងការខូចខាតដោយសារគម្រោងនេះទេ? សូមផ្តល់ឱកាសជូនអ្នកចូលរួមពីរ-បីនាក់ដើម្បីចែករំលែករឿងរ៉ាវរបស់គាត់ ។
- អ្នកអាចសួរអ្នកចូលរួមថា តើពួកគាត់គិតថា គម្រោងទាំងនោះគប្បីត្រូវបន្តឬទេ ប្រសិនបើវាបង្កឱ្យមានបញ្ហាច្រើន ។ តើចាំបាច់ត្រូវធ្វើអ្វីដើម្បីបញ្ឈប់គម្រោងនោះ កុំឱ្យជីវភាពរស់នៅ របស់ប្រជាពលរដ្ឋកាន់តែអន់ជាងមុន?
- សួរអ្នកចូលរួមមើលតើពួកគាត់ធ្លាប់ឮអំពីគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីទេពីមុន ។
- រំលឹកអ្នកចូលរួមថា រដ្ឋាភិបាលបានឯកភាពបំពេញលក្ខខណ្ឌដែលមានចែងនៅក្នុងគោលនយោបាយនោះ ពេលដែលចុះហត្ថលេខាលើកិច្ចព្រមព្រៀងដើម្បីទទួលប្រាក់កម្ចី ឬប្រាក់ជំនួយឥតសំណងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ។ ប្រសិនបើរដ្ឋាភិបាលមិនអនុវត្តតាមកិច្ចព្រមព្រៀងរបស់ខ្លួនទេ ដូច្នេះប្រជាពលរដ្ឋមានកិច្ចការជាច្រើនដែលពួកគាត់អាចធ្វើដើម្បីទាមទារឱ្យ រដ្ឋាភិបាលគោរពសិទ្ធិរបស់ពួកគាត់ ដែលនឹងត្រូវពិភាក្សាពេលក្រោយ ក្នុងអង្គសិក្ខាសាលានេះ ។

## ឯកសារសម្រាប់ចែកទី១៖ មេរៀនទី២






## ឯកសារសម្រាប់ចែកទី២៖ មេរៀនទី២

### រឿងនិទានអំពីការសាងសង់រោងចក្រមួយនៅជាយក្រុងភ្នំពេញ

មានភូមិមួយស្ថិតនៅកណ្ដាលរាជធានីភ្នំពេញត្រូវបំផ្លាញដោយអគ្គិសភ័យ។ រដ្ឋាភិបាលមិនបានជួយប្រជាពលរដ្ឋក្នុងការកសាងភូមិនេះឡើងវិញទេ ប៉ុន្តែបែរជាឱ្យអ្នកភូមិទាំងនោះទៅតាំងទីលំនៅថ្មី នៅឯជាយរាជធានីភ្នំពេញទៅវិញ។ អ្នកភូមិទាំងនោះនាំគ្នារអ៊ូរទាំថា ពួកគាត់គ្មានការងារធ្វើទេនៅភូមិថ្មីនោះ។ មានស្ទឹងមួយនៅជិតភូមិថ្មីនេះ ប៉ុន្តែមានតែប្រជាពលរដ្ឋតែពីរ-បីគ្រួសារតែប៉ុណ្ណោះដែលប្រកបរបរចិញ្ចឹមជីវិតដោយការនេសាទ និងលក់ត្រី។

ដើម្បីដោះស្រាយបញ្ហានេះ រដ្ឋាភិបាលបានរកក្រុមហ៊ុនមួយឱ្យមកសង់រោងចក្រយ៉ាងធំមួយនៅក្នុងភូមិនេះ។ ក្រុមហ៊ុនបានសង់រោងចក្ររួចជាស្ថាពរ និងបានជួលកម្មករជាច្រើនពីភូមិនេះឱ្យធ្វើការនៅក្នុងរោងចក្រ។ ប្រជាពលរដ្ឋជាច្រើនគ្រួសារនៅភូមិនេះសប្បាយចិត្តណាស់ ដោយសារពួកគាត់អាចមានការងារធ្វើ និងអាចរកប្រាក់ចំណូលបានដើម្បីចិញ្ចឹមជីវិត។

ទោះជាយ៉ាងនេះក្ដី ក៏ក្រុមហ៊ុននេះបានចាក់សំរាមពីរោងចក្រចូលទៅក្នុងទឹកស្ទឹងនោះ។ មិនយូរប៉ុន្មានទឹកស្ទឹងនោះក៏ត្រូវបំពុលដោយសារកាកសំណល់ពីរោងចក្រ ហើយត្រីនៅក្នុងស្ទឹងក៏ពុលងាប់អស់។ ពេលនោះគ្រួសារប្រជាពលរដ្ឋដែលជាអ្នកនេសាទ ក៏លែងអាចប្រកបរបរចិញ្ចឹមជីវិតដោយសារការនេសាទ និងលក់ត្រីបានទៀតហើយ ពួកគាត់មិនសប្បាយចិត្តទាល់តែសោះ។

## ឯកសារសម្រាប់ចែកទី៣: មេរៀនទី២



### ឈុតឆាក: តើធនាគារអភិវឌ្ឍន៍អាស៊ីគប្បីផ្តល់មូលនិធិគាំទ្រគម្រោងសាងសង់ផ្លូវថ្នល់ទេ?

រដ្ឋាភិបាលចង់សាងសង់ផ្លូវធំមួយពីរាជធានីភ្នំពេញ ទៅក្រុងបានលុង ខេត្តរតនគិរី និងបានស្នើសុំខ្ចីប្រាក់ពីធនាគារអភិវឌ្ឍន៍អាស៊ីសម្រាប់អនុវត្តគម្រោងនេះ។ មានក្រុមហ៊ុនឯកជនជាច្រើនចាប់អារម្មណ៍ចង់ចូលរួមបណ្តាក់ទុនក្នុងវិស័យកសិកម្ម និងរ៉ែនៅក្នុងខេត្តរតនគិរី ប៉ុន្តែរអ៊ូរទាំថា ត្រូវចំណាយពេលយូរក្នុងការធ្វើដំណើរទៅខេត្តនោះ។

រដ្ឋាភិបាល និងក្រុមហ៊ុនឯកជនដែលពាក់ព័ន្ធក្នុងគម្រោងនេះបានលើកហេតុផលមកពន្យល់ថា ពួកគាត់កំពុងជួយអភិវឌ្ឍខេត្តរតនគិរី និងបង្កើតការងារសម្រាប់ប្រជាពលរដ្ឋដែលរស់នៅទីនោះ។ ផ្លូវធំថ្មី អាចនឹងជួយនាំមកនូវប្រាក់កាន់តែច្រើនដល់តំបន់នេះ។ តម្លៃដីនៅខេត្តរតនគិរីនឹងឡើងខ្ពស់។ រីឯក្រុមទេសចរ ក៏អាចទៅលេងនៅខេត្តរតនគិរីនេះដែរ។ ផ្លូវចាស់នោះគ្មានសុវត្ថិភាពទេ ព្រមទាំងមិនអាចឱ្យរថយន្តបើកបរបានលឿនឡើយ ដូច្នេះចាំបាច់ត្រូវតែធ្វើផ្លូវនេះឱ្យធំនិងទំនើប។

ទោះជាយ៉ាងនេះក្តី ក៏មានការបារម្ភយ៉ាងខ្លាំងអំពីការសាងសង់ផ្លូវថ្មីនេះដែរ។ មានភូមិជាច្រើន នៅតាមចំណុចខ្លះ នៅតាមសងខាងផ្លូវដែលគ្រោងថានឹងសាងសង់នេះ នឹងត្រូវរុះរើចេញដើម្បីយកដីសម្រាប់សាងសង់ផ្លូវ។ ប្រជាពលរដ្ឋនៅក្នុងភូមិទាំងនោះនឹងមិនអាចបន្តរស់នៅក្នុងផ្ទះរបស់គាត់បានទេ រីឯប្រជាពលរដ្ឋជាច្រើនទៀត ក៏នឹងត្រូវបាត់បង់មុខរបររកស៊ី និងមុខរបរធ្វើស្រែចម្ការដែរ។

សហគមន៍ជនជាតិដើមភាគតិចនៅខេត្តរតនគិរី ក៏មានក្តីកង្វល់យ៉ាងខ្លាំងណាស់ដែរអំពីផលប៉ះពាល់នៃគម្រោងសាងសង់ផ្លូវនេះ។ សហគមន៍ទាំងនេះ បានប្រឈមមុខនឹងបញ្ហាជាច្រើន ដោយសារគម្រោងវិនិយោគលើវិស័យកសិកម្ម និងរ៉ែ នៅក្នុងខេត្តនេះ។ ឧទាហរណ៍ ក្រុមហ៊ុនដែលពាក់ព័ន្ធនឹងគម្រោងទាំងនេះបានរំលោភយកដីដែលប្រជាសហគមន៍ធ្លាប់រស់នៅ និងធ្វើស្រែចម្ការ បានបិទផ្លូវចេញចូលទៅក្នុងព្រៃ ដែលពួកគាត់ធ្លាប់រកជ័រ, និងបានបំផ្លាញព្រៃអារក្ស និងតំបន់ព្រៃកប់ខ្មោចខ្លះរបស់ពួកគាត់។ នៅពេលដែលជនជាតិដើមភាគតិចបាត់បង់ដី និងឱកាសទទួលបានធនធានព្រៃឈើដូច្នេះ ពួកគាត់កាន់តែ មានការលំបាកទៅៗក្នុងការរស់នៅ រីឯសហគមន៍របស់ពួកគាត់ និងជីវភាពរស់នៅ តាមបែបសមូហភាពរបស់ពួកគាត់ក៏ត្រូវបាត់បង់។

---

### សំណួរពិភាក្សាតាមក្រុម:

- តើផលវិជ្ជមាននិងផលប៉ះពាល់អវិជ្ជមានដោយសារគម្រោងនេះមានអ្វីខ្លះ?
- តើគម្រោងនេះជួយសម្រេចបេសកកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ីទេ?
- តើធនាគារអភិវឌ្ឍន៍អាស៊ីគប្បីយល់ព្រមផ្តល់ប្រាក់កម្ចីទៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងនេះទេ?

# គោលនយោបាយការពារការផ្លាស់ប្តូរទីលំនៅដោយបង្ខំ

**លទ្ធផលទទួលបាន**

ក្រោយពីបញ្ចប់ជំពូកនេះ អ្នកចូលរួមនឹងៈ

១. ដឹងថា ការផ្លាស់ប្តូរទីលំនៅដោយបង្ខំ គឺជាផលប៉ះពាល់អវិជ្ជមាន ជាទូទៅរបស់គម្រោងធនាគារអភិវឌ្ឍន៍អាស៊ី

២. ដឹងអំពីអត្ថន័យនៃពាក្យ "ការតាំងទីលំនៅថ្មីដោយបង្ខំ"

៣. ដឹងថា គោលនយោបាយស្តីពីការតាំងទីលំនៅថ្មីដោយបង្ខំជាអ្វី ។

៤. ដឹងអំពីប្រភេទផ្សេងៗនៃការផ្លាស់ប្តូរទីលំនៅដែលការពារដោយគោលនយោបាយនេះ ។

៥. ដឹងថា តើអ្នកណាត្រូវបានការពារដោយគោលនយោបាយនេះ ។

៦. ដឹងថា តាមគោលនយោបាយនេះ ការផ្លាស់ប្តូរទីលំនៅ គប្បីត្រូវបានបញ្ចៀស និងបន្ថយឱ្យនៅតិចបំផុត ។

## ១. គម្រោងគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី និងការផ្លាស់ប្តូរទីលំនៅ

ការផ្លាស់ប្តូរទីលំនៅ ជាផលប៉ះពាល់ដ៏អាក្រក់មួយក្នុងចំណោមផលប៉ះពាល់ជាទូទៅផ្សេងទៀត ដែលបណ្តាលមកពីគំរោងគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ។ មានករណីជាច្រើន ដែលប្រជាពលរដ្ឋត្រូវគេបណ្តេញចេញពីលំនៅដ្ឋាន និងដីធ្លីរបស់ពួកគាត់ ដើម្បីយកដីសម្រាប់ "**គម្រោងអភិវឌ្ឍន៍**" ។ ប្រជាជនជាច្រើននៅលើពិភពលោកបានធ្លាក់ខ្លួនកាន់តែក្រជាងមុនដោយសារតែការផ្លាស់ប្តូរទីលំនៅ ។ បន្ថែមលើនេះទៀត ពួកគាត់បាត់បង់សិទ្ធិមានដីធ្លី និងសិទ្ធិប្រើប្រាស់ធនធាននានា ដែលពួកគាត់ធ្លាប់ពឹងផ្អែកប្រើប្រាស់សម្រាប់ដាំដំណាំជាស្បៀងអាហារ និងសម្រាប់ការប្រកបរបរ ចិញ្ចឹមជីវិតរបស់ពួកគាត់ ។

នៅពេលដែលប្រជាពលរដ្ឋត្រូវគេបណ្តេញចេញពីតំបន់ប្រជុំជន និងត្រូវបង្ខំឱ្យផ្លាស់ទៅនៅកាន់តែឆ្ងាយពីតំបន់ប្រជុំជន ពេលនោះពួកគាត់បាត់បង់ឱកាសទទួលបានការងារធ្វើ ។ ចំណែកឯនៅតំបន់ជនបទវិញ ការផ្លាស់ប្តូរទីលំនៅអាចនាំឱ្យបាត់បង់ឱកាសទទួលផលពីធនធានធម្មជាតិ ដូចជា ព្រៃឈើ ស្ទឹង ទន្លេ និងដីស្រែចម្ការជាដើម ។ ពួកគាត់ក៏អាចនឹងបាត់បង់ឱកាសក្នុងការទទួលបាននូវ សេវាកម្មផ្សេងៗដែរ ដូចជាផ្ទះរួមរបស់សហគមន៍ សាលារៀន ឬមណ្ឌលសុខភាពជាដើម ។ ការផ្លាស់ប្តូរទីលំនៅ ជាទូទៅនាំឱ្យមានការបំបែកសហគមន៍ បណ្តាញសង្គម និងបណ្តាញគាំទ្រនានា ។



## ២.	គោលនយោបាយស្តីពីការតាំងទីលំនៅថ្មីដោយបង្ខំ

នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ ធនាគារអភិវឌ្ឍន៍អាស៊ីបានសម្រេចចិត្តថា ធនាគារចាំបាច់ត្រូវតែបង្កើតគោលនយោបាយមួយសម្រាប់គម្រោងទាំងអស់ដែលផ្តល់មូលនិធិគាំទ្រដោយធនគារអភិវឌ្ឍន៍អាស៊ី ដើម្បីបញ្ចៀស និងកាត់បន្ថយការខូចខាតដោយសារការផ្លាស់ប្តូរទីលំនៅ។ គោលនយោបាយនេះ ត្រូវអនុម័តនៅឆ្នាំ១៩៩៥ និងត្រូវបានពិនិត្យកែសម្រួលជាថ្មីនៅឆ្នាំ២០០៩។ ធនាគារនេះហៅគោលនយោបាយនេះថា **គោលនយោបាយការពារស្តីពីការតាំងទីលំនៅថ្មីដោយបង្ខំ។**

| តើ “ការតាំងទីលំនៅថ្មីដោយបង្ខំ”ជាអ្វី? |
| --- |
| **“ការតាំងទីលំនៅថ្មីដោយបង្ខំ”** គឺជាស្ថានភាពណាមួយដែលរដ្ឋាភិបាលដកហូតយកដី ឬហាមឃាត់មិនឱ្យចូលប្រើប្រាស់ដីដែលប្រជាពលរដ្ឋរស់នៅ ឬធ្វើស្រែចម្ការលើដីនោះ ឬប្រើវាសម្រាប់ប្រកបរបរចិញ្ចឹមជីវិត រីឯប្រជាពលរដ្ឋដែលនឹងត្រូវរដ្ឋឱ្យផ្លាស់ប្តូរទីលំនៅគ្មានសិទ្ធិបដិសេធឡើយ។ |

## ៣. ការផ្លាស់ប្តូរទីលំនៅថ្មីប្រភេទណាខ្លះ ដែលត្រូវការពារដោយគោលនយោបាយនេះ?

គោលនយោបាយនេះ មានគោលបំណងការពារប្រជាពលរដ្ឋដែលនឹងត្រូវផ្លាស់ប្តូរទីលំនៅដោយគម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ីកុំឱ្យបាត់បង់:

- លំនៅដ្ឋាន
- ដីធ្លី
- ការងារ និង
- ធនធានផ្សេងៗទៀតដែលជាទីពឹងពាក់សម្រាប់ការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគាត់។

ការផ្លាស់ប្តូរទីលំនៅអាចនឹងកើតឡើងដោយសារៈ

- រដ្ឋដកហូតយកដីសម្រាប់អនុវត្តគម្រោង
- ឬដោយសាររដ្ឋហាមប្រាមប្រជាពលរដ្ឋមិនឱ្យប្រើ ឬចូលទៅនៅលើដីនោះ ព្រោះដីជាដីសម្រាប់គម្រោង។

គោលនយោបាយនេះការពារប្រជាពលរដ្ឋ នៅពេលដែលពួកគាត់បាត់បង់ដី ឬបាត់បង់ឱកាសប្រើប្រាស់ដីៈ

- ជារៀងរហូត ឬ
- មួយរយៈពេលជាកំណត់ ដូចជា មានរយៈពេលកំណត់៦ខែ ឬមួយឆ្នាំ។



*ប្រជាពលរដ្ឋត្រូវផ្លាស់ប្តូរទីលំនៅពីផ្ទះ ដី មុខរបរ និងធនធានធម្មជាតិដែលពួកគាត់ ប្រើប្រាស់សម្រាប់ជីវភាពរស់នៅរបស់គាត់ ដោយសារគម្រោងដែលផ្តល់មូលនិធិគាំទ្រ ដោយធនាគារអភិវឌ្ឍន៍អាស៊ី ត្រូវបានការពារដោយគោលនយោបាយនេះ ។*

## តើគោលនយោបាយផ្លាស់ប្តូរទីលំនៅដោយបង្ខំនេះការពារអ្នកណា?

គោលនយោបាយនេះ ការពារប្រជាពលរដ្ឋដែលត្រូវតែរុះរើចេញពីទីលំនៅ និងដីធ្លីដែលពួកគាត់រស់នៅ ដោយសារគម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី។ ឧទាហរណ៍ វាការពារគ្រួសារមួយដែលត្រូវរុះរើចេញពីទីលំនៅរបស់ គាត់ដោយសារផែនការរបស់រដ្ឋាភិបាល ដែលត្រូវសង់ស្ពានដោយប្រើមូលនិធិពីធនាគារអភិវឌ្ឍន៍អាស៊ី នៅទីតាំងនៃផ្ទះរបស់គាត់ ។

គោលនយោបាយនេះការពារប្រជាពលរដ្ឋដែលនឹងបាត់បង់សិទ្ធិប្រើប្រាស់ដីធ្លី បាត់បង់ឱកាសរកស៊ី ឬបាត់បង់អ្វីៗផ្សេងទៀត ដែលគាត់ប្រើប្រាស់សម្រាប់ប្រកបរបរចិញ្ចឹមជីវិត។ ឧទាហរណ៍ គោលនយោបាយនេះការពារកសិករដែលបាត់បង់សិទ្ធិប្រើប្រាស់ដីស្រែរបស់គាត់ដោយសារដីរបស់គាត់ត្រូវរដ្ឋយកទៅធ្វើផ្លូវរថភ្លើងមួយខ្សែ។ វាក៏ការពារគ្រួសារប្រជាពលរដ្ឋដែលនឹងបាត់បង់សិទ្ធិប្រើប្រាស់ព្រៃ ដែលពួកគាត់ធ្លាប់ប្រើប្រាស់ដើម្បីរកអនុផលព្រៃឈើ និងអ្វីៗផ្សេងទៀតដើម្បីលក់ ។

គោលនយោបាយនេះក៏ការពារប្រជាពលរដ្ឋណា ដែលនឹងបាត់បង់ឱកាសប្រកបមុខរបររបស់គាត់ដោយសារគម្រោងណាមួយ ។ ឧទាហរណ៍ វាការពារអ្នកលក់ផ្លែឈើ ដែលលែងអាចមានលទ្ធភាពលក់ផ្លែឈើនៅតាមតូបរបស់

គាត់តទៅទៀត ដោយសារដីនោះត្រូវប្រើប្រាស់សម្រាប់អគារថ្មីមួយរបស់រដ្ឋាភិបាល។

ប្រជាពលរដ្ឋប្រភេទនេះ ត្រូវបានការពារដោយគោលនយោបាយនេះ ប្រសិនបើពួកគាត់ត្រូវរុះរើចេញពីដីធ្លីរបស់គាត់ ឬប្រសិនបើឱកាសឬសិទ្ធិប្រើប្រាស់ដីត្រូវបានហាមប្រាមដោយគម្រោង។

## ៤. ការបញ្ជៀសការផ្លាស់ប្តូរទីលំនៅ

គោលបំណងទី១ របស់គោលនយោបាយការពារការផ្លាស់ប្តូរទីលំនៅដោយបង្ខំ គឺត្រូវបញ្ជៀសការផ្លាស់ប្តូរទីលំនៅ។ គោលនយោបាយនេះចែងថា ចំពោះគម្រោងណាមួយដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ីៈ

- ការផ្លាស់ប្តូរទីលំនៅគប្បីត្រូវចៀសវាង ប្រសិនបើអាចធ្វើបាន។
- ត្រូវកាត់បន្ថយការផ្លាស់ប្តូរទីលំនៅឱ្យនៅកម្រិតតិចបំផុត។

នេះមានន័យថា នៅពេលដែលរដ្ឋាភិបាលធ្វើផែនការអនុវត្តគម្រោង រដ្ឋាភិបាលមានកាតព្វកិច្ចគិតគូររកវិធីកាត់បន្ថយការផ្លាស់ប្តូរទីលំនៅឱ្យនៅតិចបំផុតទៅតាមលទ្ធភាពដែលអាចធ្វើបាន។ ប្រសិនបើចាំបាច់ត្រូវមានការផ្លាស់ប្តូរទីលំនៅខ្លះ រដ្ឋាភិបាលគប្បីត្រូវប្រាកដថា មានប្រជាពលរដ្ឋតិចតួចបំផុត ដែលនឹងត្រូវផ្លាស់ប្តូរទីលំនៅ និងប្រាកដថា ការផ្លាស់ប្តូរទីលំនៅនោះ មានផលប៉ះពាល់តិចបំផុតតាមតែអាចធ្វើបាន។

រដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ី គប្បីត្រូវសួរអំពីគំនិតរបស់ប្រជាពលរដ្ឋថា តើត្រូវធ្វើបែបណា ដើម្បីបញ្ជៀសការផ្លាស់ប្តូរទីលំនៅ។ ទាំងរដ្ឋាភិបាល និងធនាគារ គប្បីត្រូវពិចារណាគំនិត ដូចជា ការប្រើប្រាស់ដីតិចសម្រាប់គម្រោងនោះ ឬរកទីតាំងនៅកន្លែងផ្សេង ឬរកកន្លែងសម្រាប់ធ្វើផ្លូវ ដែលគ្មានផ្ទះរបស់ប្រជាពលរដ្ឋ គ្មានស្រែចម្ការ ឬគ្មានធនធានធម្មជាតិសំខាន់ៗផ្សេងទៀត។




*រដ្ឋាភិបាលនិងធនាគារអភិវឌ្ឍន៍អាស៊ី គប្បីប្រើប្លង់ទី២ ព្រោះវាបញ្ចៀសឬកាត់បន្ថយការផ្លាស់ប្តូរទីលំនៅឱ្យនៅតិចបំផុត ។*

ប្រសិនបើគម្រោងមួយនឹងបណ្តាលឱ្យមានការផ្លាស់ប្តូរទីលំនៅ ព្រមទាំងបណ្តាលឱ្យមានបញ្ហាច្រើនដល់ប្រជាពលរដ្ឋ ដូច្នេះទាំងរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ីគប្បីពិចារណាបញ្ឈប់គម្រោងនោះ ។

សំខាន់បំផុតប្រជាពលរដ្ឋត្រូវផ្តល់យោបល់អំពីវិធីដើម្បីបញ្ចៀស និងកាត់បន្ថយការផ្លាស់ប្តូរទីលំនៅឱ្យបានឆាប់ នៅពេលដែលគម្រោងកំពុងត្រូវបានពិចារណា ។ នៅពេលដែលគម្រោងត្រូវបានអនុម័ត ដោយធនាគារអភិវឌ្ឍន៍អាស៊ី និងរដ្ឋាភិបាលរួចហើយ វាមានការលំបាកក្នុងការបញ្ឈប់គម្រោងនោះណាស់ ។ ម្យ៉ាងទៀតប្រជាពលរដ្ឋគប្បីត្រូវព្យាយាមបញ្ចុះបញ្ចូលនៅក្នុងដំណាក់កាលនៃការរៀបចំបង្កើតគម្រោង ដើម្បីអាចបញ្ចៀសផលប៉ះពាល់នានាដែលបណ្តាលមកពីការផ្លាស់ប្តូរទីលនៅ ។

# លំហាត់ទី៣៖ ការបញ្ចៀសការផ្លាស់ប្តូរទីលំនៅ



**គោលបំណង៖ អ្នកចូលរួមនឹងដឹងថា គោលនយោបាយការពារស្តីពីការតាំងទីលំនៅថ្មីដោយបង្ខំជាអ្វី និងដឹងថា តើវាការពារអ្នកណា។ អ្នកចូលរួមនឹងដឹងថា គោលនយោបាយនេះ បានចែងថា បណ្តាគម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍអាស៊ី គប្បីត្រូវបញ្ចៀសការផ្លាស់ប្តូរទីលំនៅ ឱ្យបានកាន់តែច្រើនកាន់តែល្អ។**

*សម្ភារ៖* ក្តារខៀន ឬក្រដាសផ្ទាំងធំ ហ្វឺត ឯកសារចែកជូនទី១

*វិធីសាស្ត្រប្រើប្រាស់៖* គំនូរ បំផុសគំនិត និង ការពិភាក្សាក្រុមតូច

| **ដំណើរការ** | | **រយៈពេល (គិតជានាទី)** |
|---|---|---|
| ១. | គំនូរបំផុសគំនិត អំពីការផ្លាស់ប្តូរទីលំនៅ | ១០ |
| ២. | ណែនាំព័ត៌មាននៅក្នុងផ្នែកទី១ | ១០ |
| ៣. | ណែនាំព័ត៌មាននៅក្នុងផ្នែកទី២ និងទី៣ | ១៥ |
| ៤. | តើអ្នកណាត្រូវគោលនយោបាយនេះការពារ | ៥ |
| ៥. | ណែនាំព័ត៌មាននៅក្នុងផ្នែកទី៤ | ២០ |
| ៦. | សង្ខេប | ២០ |
| **សរុប៖** | | **៨០** |

## ការណែនាំសម្រាប់អ្នកសម្របសម្រួល

### ១. គំនូរបំផុសគំនិតអំពីការផ្លាស់ប្តូរទីលំនៅ

- សូមសរសេរពាក្យ "ការផ្លាស់ប្តូរទីលំនៅ" នៅលើក្រដាសផ្ទាំងធំ ឬនៅលើក្តាខៀន។ សួរអ្នកចូលរួមក្រែងលោមានអ្នកណាម្នាក់អាចពន្យល់ពាក្យនេះបាន។ ផ្តល់ឱកាសឱ្យ អ្នកចូលរួមពីរ-បីនាក់ឆ្លើយសំណួរ។
- សុំឱ្យអ្នកចូលរួមគិតអំពីបញ្ហានានាដែលប្រជាពលរដ្ឋប្រឈម នៅពេលដែលពួកគាត់ត្រូវគេឱ្យផ្លាស់ប្តូរទីលំនៅ។ ត្រូវប្រាកដថា អ្នកចូលរួមមានប៊ិច និងក្រដាស រួចត្រូវទុករយៈពេលពីរ-បីនាទី ដើម្បីឱ្យពួកគាត់គូររូបផ្សេងៗទាក់ទងនឹងប្រជាពលរដ្ឋបាត់បង់សិទ្ធិ នៅពេលដែលពួកគាត់ត្រូវគេឱ្យផ្លាស់ប្តូរទីលំនៅ។
- សុំឱ្យអ្នកចូលរួមពីរ-បីនាក់ពន្យល់អំពីរូបគំនូររបស់គាត់ទៅអ្នកចូលរួមផ្សេងៗទៀត។

### ២. ណែនាំព័ត៌មាននៅក្នុងផ្នែកទី១

**ផ្នែកទី១:** *វាមានសារសំខាន់ណាស់ដែលអ្នកចូលរួមយល់:*

- ថា ការផ្លាស់ប្តូរទីលំនៅ ជាផលប៉ះពាល់មួយនៃផលប៉ះពាល់នានា និងជាផលប៉ះពាល់ខ្លាំងបំផុត របស់គម្រោងធនាគារអភិវឌ្ឍន៍អាស៊ី។
- នៅពេលដែលប្រជាពលរដ្ឋ ត្រូវគេផ្លាស់ប្តូរទីលំនៅ បន្ថែមលើការបាត់បង់ផ្ទះសម្បែង និងដីធ្លីពួកគាត់តែងតែបាត់បង់សិទ្ធិប្រើប្រាស់ ធនធាន និងសេវាកម្មនានា នៅក្នុងមូលដ្ឋាន។
- មានប្រជាជនជាច្រើននៅក្នុងពិភពលោក បានក្លាយខ្លួនកាន់តែក្រទៅ ដោយសារការផ្លាស់ប្តូរទីលំនៅ។

### ៣. ណែនាំព័ត៌មានក្នុងផ្នែកទី២និងទី៣

**ផ្នែកទី២ និងទី៣:** *វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់:*

- ថា ធនាគារអភិវឌ្ឍន៍អាស៊ីបានបង្កើតគោលនយោបាយស្តីពីការតាំងទីលំនៅដោយបង្ខំនេះឡើង ដើម្បីការពារប្រជាពលរដ្ឋ កុំឱ្យមានគ្រោះថ្នាក់ពីការផ្លាស់ប្តូរទីលំនៅដោយសារគម្រោង ធនាគារអភិវឌ្ឍន៍អាស៊ី។
- អំពីអត្ថន័យនៃពាក្យ "ការតាំងទីលំនៅថ្មីដោយបង្ខំ"។
- អំពីប្រភេទផ្សេងៗគ្នានៃការផ្លាស់ប្តូរទីលំនៅ និងដឹងថា តើអ្នកណាខ្លះដែលត្រូវការការពារដោយគោលនយោបាយនេះ។

## ៤. តើអ្នកណាត្រូវគោលនយោបាយនេះការពារ?

- សុំឱ្យអ្នកចូលរួមក្រោកឈរ ប្រសិនបើពួកគាត់នឹងត្រូវគេបង្ខំឱ្យផ្លាស់ប្តូរទីលំនៅ ដោយសារគម្រោង ដែលជាមូលនិធិធនាគារអភិវឌ្ឍន៍អាស៊ីដែលប៉ះពាល់ដល់ពួកគាត់។ (ពួកគាត់ត្រូវនៅឈរ)។

- សួរអ្នកចូលរួមនោះមើលតើ មានផ្នែកណាមួយនៃផ្ទះរបស់គាត់ ឬសំណង់ផ្សេងៗរបស់គាត់ នឹងត្រូវបំផ្លាញ ឬរងផលប៉ះពាល់ដោយសារគម្រោងនោះ។

- បន្ទាប់មកទៀត សុំឱ្យអ្នកចូលរួមក្រោកឈរ ប្រសិនបើពួកគាត់នឹងត្រូវគេបង្ខំឱ្យផ្លាស់ចេញពីដីរបស់គាត់ ឬដែលត្រូវបាត់បង់សិទ្ធិប្រើប្រាស់ដីមួយផ្នែករបស់គាត់ ដូចជា ដីស្រែចម្ការ ដោយសារគម្រោងនេះ។ សួរពួកគាត់មើលថា តើមានផលដំណាំ ឬដើមឈើផ្សេងៗ របស់អ្នកណាម្នាក់នឹងត្រូវទទួលរងការខូចខាតទេ។ (នេះអាចជាមនុស្សដដែល ដែលកំពុងឈរស្រាប់)។

- សួរអ្នកចូលរួមមើលថា តើប្រាក់ចំណូល ឬការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគាត់នឹងត្រូវទទួលរងផលប៉ះពាល់ ដោយសារតែពួកគាត់ត្រូវគេបង្ខំឱ្យផ្លាស់ប្តូរទីលំនៅដោយសារគម្រោងនេះ ឬដោយសារសិទ្ធិរបស់គាត់ក្នុងការប្រើប្រាស់ដីត្រូវគេរារាំង ឬហាត់ឃាត់។

- ពន្យល់ថា អ្នកចូលរួមគ្រប់រូបដែលកំពុងតែឈរ ដោយសារពួកគាត់នឹងត្រូវគេបង្ខំឱ្យផ្លាស់ប្តូរទីលំនៅនោះ គប្បីត្រូវការពារដោយគោលនយោបាយស្តីពីការតាំងទីលំនៅដោយបង្ខំនេះ។ នេះមានន័យថា រដ្ឋាភិបាលមានការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ ដើម្បីបញ្ជៀស និងកាត់បន្ថយការផ្លាស់ប្តូរទីលំនៅឱ្យនៅកម្រិតតិចបំផុត។

## ៥. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៤

**ផ្នែកទី៤:** *វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ថា:*

- *គោលនយោបាយនេះចែងថា សម្រាប់គម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ការតាំងទីលំនៅដោយបង្ខំគប្បីត្រូវបញ្ជៀស បើអាចធ្វើបាន និងគប្បីត្រូវកាត់បន្ថយ។*
- *រដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ីគប្បីត្រូវសុំគំនិតពីប្រជាពលរដ្ឋ ទាក់ទងនឹងរបៀប ដែលថាតើត្រូវធ្វើយ៉ាងណាដើម្បីបញ្ជៀស និងកាត់បន្ថយការផ្លាស់ប្តូរទីលំនៅ។*

- បង្ហាញរូបភាពនៅក្នុងឯកសារសម្រាប់ចែកទី១ឱ្យអ្នកចូលរួមមើល រួចពន្យល់ពួកគាត់ថា ក្នុងរូបភាពនេះបង្ហាញជម្រើសពីរសម្រាប់គម្រោងធ្វើផ្លូវ។

- សួរអ្នកចូលរួមនូវសំណួរខាងក្រោមនេះ:

- តើអ្នកអាចរៀបរាប់អំពីគម្រោងទាំងពីរនៅក្នុងរូបភាពនោះបានទេ និងអាចរៀបរាប់បានទេថា តើវាធ្វើឱ្យប៉ះពាល់ដល់ប្រជាពលរដ្ឋនៅក្នុងភូមិ នៅក្នុងកម្រិតណា? (ចម្លើយៈ គម្រោងផ្លូវទី១ នឹងត្រូវធ្វើផ្លូវកាត់ភូមិ ដូច្នេះ អ្នកភូមិជាច្រើនគ្រួសារនឹងត្រូវរុះរើលំនៅដ្ឋាន។ គម្រោងទី២ នឹងធ្វើឱ្យមានផលប៉ះពាល់ផ្ទះតិចតួច ដូច្នេះមានប្រជាពលរដ្ឋតិចគ្រួសារទេ ដែលត្រូវផ្លាស់ប្តូរទីលំនៅ)។

- តើអ្នកគិតថា រដ្ឋាភិបាលគប្បីត្រូវជ្រើសរើសយកគម្រោងណា? ហេតុអ្វី?

## ៦. សង្ខេប

- សុំឱ្យអ្នកចូលរួមធ្វើការជាក្រុមដែលមានគ្នាបីនាក់ ដើម្បីពិភាក្សាអំពីគម្រោងដែលកំពុងតែធ្វើឱ្យមានផលប៉ះពាល់ដល់ពួកគាត់។ ពួកគាត់គប្បីត្រូវពិភាក្សាលើសំណួរដូចខាងក្រោមនេះ:

    - តើប្រភេទនៃការផ្លាស់ប្តូរទីលំនៅដែលបណ្តាលមកពីគម្រោងមានអ្វីខ្លះ? (ឧទាហរណ៍ ការផ្លាស់ប្តូរពីទីលំនៅពីដីធ្លី និងពីការងារ)។

    - តើពួកគាត់គិតថា រដ្ឋាភិបាលគប្បីត្រូវធ្វើអ្វីខ្លះដើម្បីបញ្ចៀស ការផ្លាស់ប្តូរទីលំនៅ ឬដើម្បីកាត់បន្ថយផលប៉ះពាល់ដោយសារការផ្លាស់ប្តូរទីលំនៅ?

- ៥នាទីក្រោយមក សុំឱ្យអ្នកចូលរួមពីរ-បីនាក់ឡើងចែករំលែកចម្លើយ និងគំនិតរបស់គាត់ ទៅអ្នកចូលរួមផ្សេងៗទៀត។

- រំលឹកសិក្ខាកាមទាំងអស់ថា ការផ្លាស់ប្តូរទីលំនៅបណ្តាលឱ្យមានបញ្ហាច្រើនណាស់ សម្រាប់ប្រជាពលរដ្ឋ និងជាទូទៅការផ្លាស់ប្តូរទីលំនៅច្រើនតែធ្វើឱ្យប្រជាពលរដ្ឋកាន់តែក្រទៅៗ។ ហេតុដូច្នេះហើយបានជាវាសំខាន់ណាស់ដែលពួកគាត់ត្រូវព្យាយមផ្តល់គំនិតរបស់ពួកគាត់ទៅរដ្ឋាភិបាល អំពីវិធីដែលត្រូវបញ្ចៀស និងបន្ថយការផ្លាស់ប្តូរទីលំនៅ តាំងពីដំបូង។

## ឯកសារសម្រាប់ចែកទី១៖ មេរៀនទី៣

ផែនការទី ១



ផែនការទី ២



# ការតាំងទីលំនៅថ្មីដោយបង្ខំ និង សិទ្ធិទទួលសំណង

**លទ្ធផលទទួលបាន**

បន្ទាប់ពីបញ្ចប់ជំពូកនេះ អ្នកចូលរួមនឹងៈ

១. យល់ដឹងអំពីគោលបំណងនៃគោលនយោបាយការពារការតាំងទីលំនៅថ្មីដោយបង្ខំ។

២. ដឹងថា មានសិទ្ធិទទួលសំណងខុសៗគ្នាសម្រាប់ម្ចាស់កម្មសិទ្ធិ អ្នកកាន់កាប់ស្របច្បាប់ និងអ្នកកាន់កាប់ខុសច្បាប់។

៣. ដឹងអំពីរបៀបទូទាត់ប្រាក់សំណងដែលពួកគាត់មានសិទ្ធិទទួលបាន។

៤. ដឹងថា តើប្រជាពលរដ្ឋនឹងត្រូវទទួលបានអ្វី ប្រសិនបើ ពួកគាត់ត្រូវគេផ្លាស់ប្តូរទីលំនៅថ្មី។

៥. ដឹងថា តើប្រជាពលរដ្ឋនឹងត្រូវទទួលបានអ្វី ប្រសិនបើ ពួកគាត់បាត់បង់ឱកាសប្រើប្រាស់ប្រភពសម្រាប់ការប្រកបរបរចិញ្ចឹមជីវិត។

## ១. មិនត្រូវធ្វើឱ្យប្រជាពលរដ្ឋធ្លាក់កាន់តែក្រជាងមុនឡើយ

ទោះបីជារដ្ឋាភិបាលមានកាតព្វកិច្ចត្រូវព្យាយាមបញ្ចៀសការផ្លាស់ប្តូរទីលំនៅយ៉ាងណាក៏ដោយ ក៏រាល់គម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ីនៅតែបណ្តាលឱ្យមានការផ្លាស់ប្តូរទីលំនៅដដែល។ គោលបំណងរបស់គោលនយោបាយការពារការតាំងទីលំនៅថ្មីដោយបង្ខំគឺ ការពារប្រជាពលរដ្ឋដែលនឹងត្រូវផ្លាស់ប្តូរទីលំនៅដោយសារគម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី មិនឱ្យកាន់តែក្រជាងមុនទេ។ ជាការពិត គោលបំណងនៃគោលនយោបាយនេះ គឺដើម្បីលើកកម្ពស់ និងស្តារឡើងវិញនូវជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ចំពោះប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋដែលងាយរងគ្រោះដែលត្រូវផ្លាស់ប្តូរទីលំនៅវិញ គោលបំណងនៃគោលនយោបាយនេះគឺដើម្បីធ្វើឱ្យកម្រិតជីវភាពរស់នៅរបស់ពួកគាត់កាន់តែមានលក្ខណៈ**ប្រសើរជាង** មុនពេលដែលពួកគាត់ ត្រូវផ្លាស់ប្តូរទីលំនៅ។

| អ្នកមិនត្រូវធ្វើឱ្យកាន់តែក្រជាងមុនដោយសារគម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ីទេ |
|---|
| គោលនយោបាយការពារស្តីពីការតាំងទីលំនៅថ្មីដោយបង្ខំចែងថា ប្រជាពលរដ្ឋមិនត្រូវធ្វើឱ្យធ្លាក់ខ្លួនកាន់តែក្រដោយសារគម្រោងដែលផ្តល់មូលនិធិដោយធនាគារអភិវឌ្ឍន៍អាស៊ីទេ។ នេះមានន័យថា ជីវភាពមិនត្រូវកាន់តែលំបាកនោះទេ ចំណែកឯក្រុមគ្រួសារប្រជាពលរដ្ឋក៏មិនត្រូវធ្វើឱ្យកាន់តែក្រជាងមុន ដោយសារតែអ្នកទទួលរងផលប៉ះពាល់ដោយគម្រោងឡើយ។ ជាការពិត ប្រសិនបើគ្រួសាររបស់អ្នកជាគ្រួសារក្រីក្រ រដ្ឋាភិបាលគប្បីត្រូវជួយអ្នកដើម្បីឱ្យមានកម្រិតជីវភាពរស់នៅកាន់តែល្អប្រសើរ។ សិទ្ធិទទួលសំណងរបស់អ្នកតាមគោលនយោបាយនេះ គឺមានគោលបំណងសម្រេចគោលបំណងបែបនេះ។ |

គោលនយោបាយនេះ ចែងថា ប្រជាពលរដ្ឋដែលត្រូវផ្លាស់ប្តូរលំនៅដ្ឋានឬដីធ្លី ឬប្រជាពលរដ្ឋដែលបាត់បង់ឱកាសការងារ បាត់បង់មុខរបររកស៊ីចិញ្ចឹមជីវិតនិងធនធាននានា ត្រូវទទួលបានសំណងអ្វី ដើម្បីកុំឱ្យពួកគាត់ធ្លាក់ខ្លួនក្រជាងមុន។

## ២. សិទ្ធិទទួលសំណងខុសៗគ្នា សម្រាប់ម្ចាស់កម្មសិទ្ធិ អ្នកកាន់កាប់ស្របច្បាប់ និងអ្នកកាន់កាប់ខុសច្បាប់

ប្រជាពលរដ្ឋដែលមាន**ប័ណ្ណកម្មសិទ្ធិ**ដីធ្លី ឬដែលអាចដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដោយសារគាត់មានសិទ្ធិភោគៈ (សិទ្ធិកាន់កាប់) មានសិទ្ធិទទួលសំណងខុសពីប្រជពលរដ្ឋដែលកាន់កាប់ដីដោយគ្មានប័ណ្ណកម្មសិទ្ធិ ឬដែលគ្មានសិទ្ធិកាន់កាប់។

| **ម្ចាស់កម្មសិទ្ធិ អ្នកកាន់កាប់ស្របច្បាប់ និងអ្នកកាន់កាប់ខុសច្បាប់** |
|---|
| តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា មានភាពខុសគ្នារវាងម្ចាស់កម្មសិទ្ធិភោគី (អ្នកកាន់កាប់ស្របច្បាប់) និងអ្នកកាន់កាប់ខុសច្បាប់។<br>• **ម្ចាស់កម្មសិទ្ធិ** ជាជនទាំងឡាយដែលបានចុះបញ្ជីដីរបស់ពួកគាត់ជាផ្លូវការនៅក្នុង **សៀវភៅគោលបញ្ជីដី** ព្រមទាំងមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ចំពោះដីនោះ។ កម្មសិទ្ធិជាសិទ្ធិរឹងមាំបំផុត ដែលប្រជាពលរដ្ឋមានលើដីធ្លី។ វាអនុញ្ញាតឱ្យកម្មសិទ្ធិករ ប្រើប្រាស់ដីរបស់គាត់ធ្វើអ្វីៗតាមចិត្តរបស់គាត់ ដរាបណាគាត់មិនធ្វើអ្វីដែលខុសច្បាប់។<br>• **ភោគី (អ្នកកាន់កាប់ស្របច្បាប់)** ជាជនទាំងឡាយដែលរស់នៅលើដីនោះមុនថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ (នៅពេលច្បាប់ភូមិបាលត្រូវបានអនុម័ត) ឬបានទិញ ឬទទួលមរតកពីអ្នកណា ម្នាក់ដែលបានរស់នៅលើដីនោះមុនកាលបរិច្ឆេទនោះ។ ដីនេះមិនមែនជាដីរបស់សាធារណៈរបស់រដ្ឋ មិនមែនជាកម្មសិទ្ធិរបស់អ្នកណាផ្សេងឡើយ។ ការកាន់កាប់របស់គាត់ក៏ត្រូវតែបំពេញលក្ខខណ្ឌមួយ ចំនួនដូចជា: ការកាន់កាប់របស់ពួកគាត់ត្រូវតែជាការកាន់កាប់ដោយគ្មានហិង្សា និងស្មោះត្រង់ ពួកគាត់ត្រូវតែកាន់កាប់ដីនោះគ្មានអាក់ខាន និងត្រូវតែច្បាស់ថា គាត់ជាអ្នកកាន់កាប់ដីនោះ ការកាន់កាប់របស់គាត់ត្រូវតែមានការដឹងឮជាសាធារណៈ។[៣] អ្នកកាន់កាប់ស្របច្បាប់មានសិទ្ធិកាន់កាប់ ដែលស្រដៀងគ្នាទៅនឹងសិទ្ធិកម្មសិទ្ធិដែរ។ តាមច្បាប់ភូមិបាល ពួកគាត់មានសិទ្ធិ ស្របច្បាប់ក្នុងការសុំប័ណ្ណកម្មសិទ្ធិ។[៤] |

[៣] ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា៣០និង៣៨។

[៤] ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា៣០។

- ប្រជាពលរដ្ឋដែលមកតាំងទីលំនៅលើដីនោះក្រោយខែសីហាឆ្នាំ២០០១ ឬ បានរស់នៅលើដីសាធារណៈ របស់រដ្ឋ ឬដីដែលជាកម្មសិទ្ធិរបស់អ្នកផ្សេង មិនមែនជាអ្នកកាន់កាប់ស្របច្បាប់ទេ និងគ្មានសិទ្ធិស្របច្បាប់ ក្នុងការសុំប័ណ្ណកម្មសិទ្ធិទេ។ តាមច្បាប់ភូមិបាល ពួកគាត់ ជាអ្នកកាន់កាប់ដោយខុសច្បាប់។ ប្រជាពលរដ្ឋប្រភេទនេះ តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងគោលនយោបាយករបស់ធនាគារអភិវឌ្ឍន៍អាស៊ី មានសិទ្ធិទទួលសំណងផ្សេង។ សិទ្ធិនេះ នឹងមានពន្យល់ខាងក្រោម។

ម្ចាស់កម្មសិទ្ធិដី និងអ្នកកាន់កាប់ដីស្របច្បាប់ មានសិទ្ធិទទួលបានដីជាសំណង ឬសំណងជាសាច់ប្រាក់សម្រាប់ដីដែលត្រូវរដ្ឋដកហូត។ ប្រជាពលរដ្ឋដែលគ្មានប័ណ្ណកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់គ្មានសិទ្ធិស្របច្បាប់ទទួលបានសំណងបែបនេះទេ។

ប៉ុន្តែទោះជាយ៉ាងនេះក្តី ពួកគាត់ម្នាក់ៗមានសិទ្ធិស្របច្បាប់ក្នុងការទទួល បានសំណងសម្រាប់លំនៅដ្ឋាន និងសំណង់ផ្សេងៗដែលពួកគាត់បាត់បង់។ ពួកគាត់ក៏មានសិទ្ធិស្របច្បាប់ ទទួលបានសំណងសម្រាប់ការប្រើប្រាស់ដីនោះ ដូចជាផលដំណាំដែលពួកគាត់បានដាំ ឬប្រព័ន្ធប្រឡាយ ទឹកដែលពួកគាត់បានធ្វើនៅលើដីនោះជាដើម។

ប្រជាពលរដ្ឋគប្បីត្រូវមានលទ្ធភាព ជ្រើសរើសថា តើពួកគាត់ចង់បានសំណងជាសាច់ប្រាក់ ឬសំណងជារបស់ជំនួសនូវអ្វីៗដែលបាត់បង់នោះ។



*ទោះបីជា គ្រួសារនេះមិនមែនជាកម្មសិទ្ធិករ ឬមិនមែនជាអ្នកកាន់កាប់ស្របច្បាប់ក៏ដោយ ក៏ពួកគាត់នៅតែមានសិទ្ធិស្របច្បាប់ទទួលបានសំណងសម្រាប់ការបាត់ផ្ទះសម្បែង និងសំណង់ផ្សេងៗ និងដំណាំ និង ប្រព័ន្ធប្រឡាយទឹកដែរ។*

ប្រជាពលរដ្ឋគប្បីត្រូវតែទទួលបានសំណងជារបស់ជំនួស ឬសំណងជាសាច់ប្រាក់ *មុននឹង* ឱ្យពួកគាត់ផ្លាស់ប្តូរទីលំនៅ។

ប្រសិនបើពួកគាត់គ្មានសិទ្ធិទទួលបានសំណងសម្រាប់ដីរបស់គាត់ទេ ឧទាហរណ៍ ដោយសារពួកគាត់ជាអ្នកកាន់កាប់ដីរដ្ឋដោយខុសច្បាប់ ដូច្នេះ រដ្ឋាភិបាលក៏ត្រូវតែដោះស្រាយដីលំនៅដ្ឋានថ្មី ជូនប្រជាពលរដ្ឋ មុនពេលផ្លាស់ប្តូរទីលំនៅរបស់គាត់ ដោយសារគម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ីដែរ ដើម្បីកុំឱ្យពួកគាត់គ្មានទីជម្រករស់នៅ។ ការតាំងទីលំនៅថ្មី នឹងត្រូវលើកមកពិភាក្សាគ្នាក្នុងផ្នែកខាងក្រោម នេះ។

## ៣. សំណងជារបស់ជំនួស ឬសំណងជាសាច់ប្រាក់?

ប្រជាពលរដ្ឋដែលមានប័ណ្ណកម្មសិទ្ធិ ឬមានសិទ្ធិកាន់កាប់លើដីធ្លីរបស់ពួកគាត់ មានសិទ្ធិស្រប ច្បាប់ទទួលបាន:

- សំណងជារបស់ជំនួស "គ្រប់គ្រាន់និងសមរម្យ" សម្រាប់ ដី ផ្ទះ និងសំណង់ផ្សេងៗដែលពួកគាត់មាននៅលើដីនោះផង ឬ
- ចំនួនទឹកប្រាក់ដែលពួកគាត់ត្រូវការទិញដីមួយឡូត៍ ទិញផ្ទះ និងសំណង់ផ្សេងៗទៀតដែលមានតម្លៃប្រហាក់ប្រហែលនឹងអ្វីៗដែលគាត់បាត់បង់។

គោលនយោបាយការពារស្តីពីការតាំងទីលំនៅថ្មីដោយបង្ខំចែងថា ប្រជាពលរដ្ឋដែលប្រើប្រាស់ដីសម្រាប់ប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគាត់ ដូចជាប្រជាកសិករ គប្បីត្រូវទទួលបានដីជំនួស ឬលំនៅដ្ឋានជំនួសសមរម្យ ជាជាងការសងសំណងជាសាច់ប្រាក់។ ដីនោះគប្បី យ៉ាងហោចណាស់ ត្រូវមានគុណភាព និងតម្លៃដូចគ្នានឹងដីដែលរដ្ឋដកហូតយកនោះដែរ។ រដ្ឋាភិបាលអាចប្រើដីរបស់រដ្ឋ សម្រាប់ដោះស្រាយបញ្ហានេះ ឬទិញដីឯកជនមកប្រើប្រាស់សម្រាប់គោលបំណងនេះ។

ទោះជាយ៉ាងនេះក្តី ប្រសិនបើប្រជាពលរដ្ឋចង់ទទួលយកសំណងជាប្រាក់ជាង ឬថាពិតជាគ្មានដីសម្រាប់ដោះស្រាយជូនប្រជាពលរដ្ឋទាំងនេះទេ ដូច្នេះរដ្ឋាភិបាលគប្បីផ្តល់សំណងជាសាច់ប្រាក់ជំនួសវិញ។ ប្រសិនបើសំណងជាសាច់ប្រាក់នឹងត្រូវផ្តល់ជូនប្រជាពលរដ្ឋដែលរងផលប៉ះពាល់សម្រាប់ដី និងទ្រព្យសម្បត្តិដែលបាត់បង់ផ្សេងៗទៀត ដូច្នេះរដ្ឋាភិបាលត្រូវតែផ្តល់ការគាំទ្រដើម្បីស្តារមុខរបរចិញ្ចឹមជីវិតរបស់គាត់ឡើងវិញ ក្រោយពីពួកគាត់បានផ្លាស់ប្តូរទីលំនៅ។



*រដ្ឋាភិបាលត្រូវការដីដែលជាកម្មសិទ្ធិរបស់គ្រួសារនេះ សម្រាប់គម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ។*
*ពួកគាត់មានសិទ្ធិស្របច្បាប់ទទួលសំណងជាប្រាក់ផង និងសំណងជារបស់ជំនួស ដី និងផ្ទះរបស់គាត់ផង ។*

| ដី ឬ ប្រាក់? |
| --- |
| ប្រសិនបើប្រជាពលរដ្ឋដែលត្រូវរុះរើផ្ទះចេញពីដីរបស់គាត់នោះត្រូវបានរដ្ឋប្រគល់ដីដែលមានគុណភាពល្អ និងនៅក្នុងតំបន់ ឬទីតាំងដែលល្អ វាជាការល្អដែលប្រជាពលរដ្ឋត្រូវយកដីដែលជាសំណងជំនួស ជាជាងជ្រើសរើសយកសំណងជាសាច់ប្រាក់ ព្រោះប្រជាពលរដ្ឋដែលជ្រើសរើសយកប្រាក់នឹងប្រើប្រាស់ប្រាក់នោះ អស់លឿនណាស់ ដូចជាប្រើលើការជួលផ្ទះ និងដី និងចំណាយលើអ្វីៗផ្សេងៗទៀត ដែលក្រោយមកពួក គាត់នឹងចាយប្រាក់នោះអស់ ដោយគ្មានដី និងគ្មានសល់ប្រាក់ឡើយ ។<br><br>មានដីដែលមានគុណភាពល្អ នៅក្នុងទីតាំងដែលល្អជាការប្រសើរខ្លាំងណាស់សម្រាប់ប្រជាពលរដ្ឋ ដើម្បីឱ្យប្រាកដថា ពួកគាត់អាចបន្តរស់នៅរកស៊ីចិញ្ចឹមជីវិតនិងគ្រួសាររបស់គាត់នាពេលអនាគត ។ |

## លំហាត់ទី៤: សិទ្ធិទទួលសំណង: ដី ឬ ប្រាក់?



**គោលបំណង:** អ្នកចូលរួមនឹងដឹងថា គោលនយោបាយស្តីពីការតាំងទីលំនៅថ្មីដោយបង្ខំ មានគោលបំណងធានាថា ប្រជាពលរដ្ឋដែលនឹងត្រូវផ្លាស់ប្តូរទីលំនៅដោយគម្រោងដែលផ្តល់មូលនិធិ គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី មិនកាន់តែ ក្រជាងមុនទេ។ អ្នកចូលរួមនឹងយល់អំពីភាពខុសគ្នារវាងម្ចាស់កម្មសិទ្ធិ ភោគី (អ្នកកាន់កាប់ស្របច្បាប់) និងអ្នកកាន់កាប់ខុសច្បាប់ និងយល់ថាប្រជាពលរដ្ឋទាំងនោះ មានសិទ្ធិទទួលបានសំណងខុសៗគ្នា ទៅតាមគោលនយោបាយស្តីពីការតាំងទីលំនៅថ្មីដោយបង្ខំ។ អ្នកចូលរួម ក៏នឹងបានគិតអំពីគុណតម្លៃនៃការទទួលសំណងជាដី ជាជាងទទួលសំណងជាសាច់ប្រាក់ដែរ។

**សម្ភារ:** ក្តារខៀន ឬក្រដាសផ្ទាំងធំ និងហ្វឺត

**វិធីសាស្រ្តប្រើប្រាស់:** ការពិភាក្សាក្រុមធំ ល្បែង និងការប្រកាន់គោលជំហរ

| ដំណើរការ | រយៈពេល (គិតជានាទី) |
|---|---|
| ១. ណែនាំព័ត៌មាននៅក្នុងផ្នែក១ និងផ្នែក២ | ៣០ |
| ២. ល្បែង | ២៥ |
| ៣. ការបង្ហាញព័ត៌មាននៅក្នុងផ្នែក៣ | ១៥ |
| ៤. ការប្រកាន់គោលជំហរ | ២០ |
| ៥. សង្ខេបមេរៀន | ២០ |
| **សរុប:** | **១១០** |

# ការណែនាំសម្រាប់អ្នកសម្របសម្រួល

## ១. ណែនាំព័ត៌មាននៅក្នុងផ្នែក១ និងផ្នែក២

**ផ្នែក១ និងផ្នែក២:** *វាមានសារសំខាន់ណាស់ដែលអ្នកចូលរួមត្រូវយល់ថា:*

- គោលបំណងនៃគោលនយោបាយការពារស្តីពីការតាំងទីលំនៅថ្មីដោយបង្ខំគឺដើម្បីលើកកម្ពស់ ឬយ៉ាងហោចណាស់គឺដើម្បីស្តារជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឡើងវិញ ក្រោយពីពួកគាត់ត្រូវផ្លាស់ប្តូរទីលំ នៅ។
- ម្ចាស់កម្មសិទ្ធិមានប័ណ្ណកម្មសិទ្ធិដីជាផ្លូវការ។
- អ្នកកាន់កាប់ស្របច្បាប់ បានមករស់នៅលើដីរបស់គាត់មុនខែសីហា ឆ្នាំ២០០១ និងលើដីដែលមិនមែនជាដីរបស់រដ្ឋ ឬមិនមែនជាដីរបស់អ្នកដទៃ។
- អ្នកកាន់កាប់ខុសច្បាប់ បានមករស់នៅលើដីនោះក្រោយខែសីហា ឆ្នាំ២០១០ ឬរស់នៅលើដីរបស់រដ្ឋ ឬលើដីរបស់អ្នកដទៃ។
- ម្ចាស់កម្មសិទ្ធិ និងអ្នកកាន់កាប់ស្របច្បាប់ មានសិទ្ធិទទួលសំណងជាដី ឬសំណង់ជាប្រាក់ យ៉ាង ពេញលេញ។
- ប្រជាពលរដ្ឋគ្រប់រូប រួមទាំងអ្នកកាន់កាប់ខុសច្បាប់ផង មានសិទ្ធិទទួលសំណងជារបស់ជំនួស ឬសំណងជាប្រាក់យ៉ាងពេញលេញ សម្រាប់ផ្ទះ និងសំណង់ផ្សេងៗ និងសម្រាប់ការអភិវឌ្ឍន៍ផ្សេងៗលើដីនោះ។
- ប្រជាពលរដ្ឋគប្បីទទួលសំណងជារបស់និងសំណងជាសាច់ប្រាក់ជានិច្ច *មុននឹង* ពួកគាត់ត្រូវផ្លាស់ប្តូរ ទីលំនៅ។
- រដ្ឋាភិបាលក៏ត្រូវតែដោះស្រាយទីលំនៅដល់ប្រជាពលរដ្ឋ ដែលនឹងមិនត្រូវទទួលបានសំណង សម្រាប់ដីរបស់គាត់ ហើយដែលត្រូវរុះរើចេញពីលំនៅដ្ឋាន។

## ២. ល្បែង

- ពន្យល់អ្នកចូលរួមថា ពួកគាត់នឹងលេងល្បែងមួយដើម្បីឱ្យដឹងថា តើពួកគាត់យល់ ឬមិនយល់មេរៀន។ ចែកអ្នកចូលរួមជាបី ឬបួនក្រុម ព្រមទាំងត្រូវប្រាកដថា ក្រុមនីមួយៗអង្គុយជុំគ្នា។
- ស្នើឱ្យក្រុមនីមួយៗជ្រើសយកសំឡេងណាមួយជាសញ្ញា ប្រសិនបើក្រុមដឹងអំពីចម្លើយនៃសំណួរដែលអ្នកនឹងសួរ។ ឧទាហរណ៍ សំឡេងរបស់ក្រុមទី១គឺ អាចជាសំឡេងកង្កែប រីឯក្រុមទី២ អាចជាសំឡេងទះដៃ ឬហួច។ល។ ដូច្នេះក្រុមនីមួយៗត្រូវតែមានសំឡេងរបស់ខ្លួន។
- ពន្យល់ថា អ្នកនឹងអានរឿងខ្លីមួយឮខ្លាំងៗ ហើយក្រុមដែលដឹងចម្លើយចំពោះសំណួរខាងក្រោមដែលទាក់ទងនឹងរឿងនេះ ក្រុមគប្បីបន្លឺសំឡេងរបស់ខ្លួន។ ក្រុមដែលបានបន្លឺសំឡេងមុន នឹងមានឱកាសឆ្លើយមុន។

ប្រសិនបើក្រុមឆ្លើយត្រូវ ក្រុមនឹងទទួលបាន២ពិន្ទុ។ ប្រសិនបើក្រុមឆ្លើយមិនត្រូវទេ ក្រុមផ្សេងមានឱកាសឆ្លើយ។ ប្រសិនបើគ្មានអ្នកណាម្នាក់ ឬក្រុមណាមួយដឹងចម្លើយត្រឹមត្រូវទេ អ្នកគប្បីត្រូវប្រាប់ចម្លើយនោះ។ សំណួរដែលក្រុម ត្រូវការឆ្លើយចំពោះរឿងនីមួយៗគឺ:

- តើអ្នកនោះជាម្ចាស់កម្មសិទ្ធិ អ្នកកាន់កាប់ស្របច្បាប់ ឬជាអ្នកកាន់កាប់ខុស ច្បាប់?
- តាមគោលនយោបាយស្តីពីការតាំងទីលំនៅថ្មីដោយបង្ខំរបស់ធនាគារ តើពួកគាត់មានសិទ្ធិទទួលបានអ្វីខ្លះ?

  (ប្រសិនបើសរសេរសំណួរទាំងនេះ នៅលើក្តារខៀនឬក្រដាសផ្ទាំងធំ វានឹងជួយដល់អ្នកចូលរួមនៅពេលលេងល្បែងនេះ)

- ត្រូវប្រាកដថា អ្នកចូលរួមម្នាក់ៗយល់អំពីរបៀបលេងល្បែងនេះ។ ពន្យល់ថា ពួកគាត់គប្បីរក្សាភាពស្ងៀមស្ងាត់ និងស្តាប់ដោយប្រុងប្រយ័ត្ន នៅពេលដែលអ្នកកំពុងអានរឿងនីមួយៗ។ នៅពេលដែលក្រុមនីមួយៗបានត្រៀមខ្លួនរួចហើយ អ្នកអាចចាប់ផ្តើមលេងល្បែងនេះបាន ដោយអានរឿងដូចខាងក្រោមនេះ។

**រឿងទី១:** សុធាមានប័ណ្ណកម្មសិទ្ធិដីស្រែចម្ការរបស់នាងនៅឯខេត្តបាត់ដំបង។ ឥឡូវនេះ រដ្ឋាភិបាលចង់យកដីរបស់នាងដើម្បីសង់ទំនប់មួយ ដោយខ្ចីប្រាក់ពីធនាគារ អភិវឌ្ឍន៍អាស៊ី។

**ចម្លើយ:**

- សុធាជាកម្មសិទ្ធិករ ព្រោះនាងមានប័ណ្ណកម្មសិទ្ធិ ដូច្នេះដីរបស់នាងត្រូវតែមាន ចុះបញ្ជី។
- នាងមានសិទ្ធិស្របច្បាប់ទទួលបានសំណងជាដី ឬជាសាច់ប្រាក់សម្រាប់ដីរបស់នាង។ នាងក៏មានសិទ្ធិស្របច្បាប់ទទួលបានសំណងសម្រាប់ផ្ទះ និងសំណង់ផ្សេងៗទៀត ដែលនាងបានធ្វើនៅលើដី ចម្ការនោះ និងការរៀបចំ និងប្រើប្រាស់ដីនេះ ដូចជា ដំណាំផ្សេងៗ។

**រឿងទី២:** វុទ្ធីបានផ្លាស់ទីលំនៅមកភ្នំពេញ នៅឆ្នាំ២០០៣ និងបានឃើញដីទំនេរមួយឡូត៍នៅក្បែរទន្លេ។ គាត់បានសង់ផ្ទះតូចមួយនៅលើដីនោះ។ ឥឡូវនេះ រដ្ឋាភិបាលចង់យកដីដែលគាត់សង់ផ្ទះនៅនេះ ធ្វើស្ពានមួយដោយខ្ចីប្រាក់ពីធនាគារអភិវឌ្ឍន៍អាស៊ី។

**ចម្លើយ:**

- វុទ្ធី ជាអ្នកកាន់កាប់ដីនេះ ព្រោះគាត់បានចាប់ផ្តើមរស់នៅលើដីនេះ ក្រោយខែសីហា ឆ្នាំ២០០១។

- គាត់គ្មានសិទ្ធិទទួលបានសំណងសម្រាប់ដីនោះទេ ប៉ុន្តែគាត់មានសិទ្ធិទទួលបានសំណងសម្រាប់ផ្ទះរបស់គាត់ និងសម្រាប់អ្វីៗដែលគាត់បានធ្វើនៅលើដីនេះ។ គាត់ក៏ត្រូវទទួលបាននូវការដោះស្រាយ ទីលំនៅដែរ ដើម្បីកុំឱ្យគាត់គ្មានលំនៅដ្ឋាន។

**រឿងទី៣:** សុឃីមបានរស់នៅលើដីរបស់គាត់នៅខេត្តកំពត ដោយសុខសាន្ត និងគ្មានអាក់ខានតាំងពីឆ្នាំ១៩៨០។ នៅភូមិរបស់គាត់ គ្មានអ្នកណាម្នាក់មានប័ណ្ណកម្មសិទ្ធិទេ។ ឥឡូវនេះរដ្ឋាភិបាលចង់យកដីរបស់គាត់ ពាក់កណ្តាលដើម្បីធ្វើផ្លូវ ដោយខ្ចីប្រាក់ពីធនាគារអភិវឌ្ឍន៍អាស៊ី។

**ចម្លើយ:**

- សុឃីម ប្រហែលអាចជាអ្នកកាន់កាប់ស្របច្បាប់ ព្រោះគាត់បានរស់នៅលើដីនោះតាំងពីមុនខែសីហា ឆ្នាំ២០០១ ព្រមទាំងបានបំពេញលក្ខខណ្ឌផ្សេងទៀត។ គាត់មិនមែនជាកម្មសិទ្ធិករ ពេញលេញនោះទេ ព្រោះគាត់គ្មានប័ណ្ណកម្មសិទ្ធិ និងមិនបានចុះបញ្ជីដីរបស់គាត់ទេ។
- គាត់មានសិទ្ធិទទួលបានសំណងជាដី ឬសំណងជាសាច់ប្រាក់សម្រាប់ដីរបស់គាត់មួយផ្នែកដែលរដ្ឋាភិបាលកំពុងយកនេះ។ គាត់ក៏មានសិទ្ធិទទួលបានសំណងសម្រាប់សំណង់ផ្សេងៗដែលគាត់បានសង់ នៅលើផ្នែកនៃដីរបស់គាត់ និងសម្រាប់ អ្វីៗផ្សេងទៀត ដែលគាត់បានធ្វើនៅលើដីនោះ។

**រឿងទី៤:** ផាន់ណា និងគ្រួសាររបស់នាង វុធថារ៉ាបានរស់នៅលើដីរបស់គាត់នៅតាមមាត់ទន្លេនៅខេត្តក្រចេះ តាំងពីអំឡុងឆ្នាំ១៩៨០។ ពួកគាត់បានសង់ផ្ទះមួយខ្នង សម្រាប់គ្រួសាររបស់គាត់ និងផ្ទះមួយខ្នងទៀត សម្រាប់គ្រួសាររបស់ប្អូនស្រីរបស់ផាន់ណា។ ឥឡូវនេះរដ្ឋាភិបាលចង់យកដីរបស់គាត់ សម្រាប់គម្រោងអភិវឌ្ឍន៍ ដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី។ មន្ត្រីរដ្ឋាភិបាលបានប្រាប់ ផាន់ណា និងវុធថារ៉ាថា ពួកគាត់កំពុងរស់នៅលើដីសាធារណៈរបស់រដ្ឋ ព្រោះពួកគាត់រស់នៅជាប់នឹងច្រាំងទន្លេ។

**ចម្លើយ:**

- ទោះបីជា ផាន់ណា និងវុធថារ៉ា បានរស់នៅលើដីនោះតាំងពីអំឡុងឆ្នាំ១៩៨០ ក៏ដោយក៏ពួកគាត់រស់នៅលើដីសាធារណៈរបស់រដ្ឋដែរ។ ដូច្នេះពួកគាត់ជា អ្នកកាន់កាប់ដីនោះ។
- ផាន់ណានិងវុធថារ៉ា គ្មានសិទ្ធិទទួលសំណងសម្រាប់ដីនោះទេ ប៉ុន្តែពួកគាត់មានសិទ្ធិទទួលបានសំណងសម្រាប់ផ្ទះពីរខ្នងដែលពួកគាត់បានសង់។ ផាន់ណា និងវុធថារ៉ា និងក្រុមគ្រួសាររបស់គាត់ រួមទាំងគ្រួសាររបស់ប្អូនស្រីរបស់ផាន់ណាផង គប្បីទទួលបាននូវការដោះស្រាយដើម្បីកុំឱ្យពួកគាត់គ្មានលំនៅដ្ឋានរស់នៅ។

- បូកសរុបពិន្ទុ តើក្រុមណាឈ្នះ។

## ៣. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៣

**ផ្នែកទី៣:** វាមានសារសំខាន់ដែលអ្នកចូលរួមត្រូវយល់:

- ថាតើប្រជាពលរដ្ឋដែលមានប័ណ្ណកម្មសិទ្ធិ ឬសិទ្ធិភោគៈ (សិទ្ធិកាន់កាប់) លើដីរបស់គាត់ មានសិទ្ធិទទួលបានអ្វីខ្លះ?
- សំណងជាដីជំនួស យ៉ាងហោចណាស់ក៏គប្បីត្រូវមានគុណភាព និងតម្លៃដូចដីដែលត្រូវរដ្ឋ ដកហូតនោះដែរ ។
- ថា ប្រសិនបើរដ្ឋផ្តល់សំណងជាសាច់ប្រាក់ រដ្ឋក៏ត្រូវផ្តល់ការគាំទ្រដើម្បីស្តារជីវភាពរស់នៅឡើងវិញ ដែរ ។

- សូមកុំអាលពន្យល់ព័ត៌មាននៅក្នុងប្រអប់ "ដី ឬប្រាក់" ចាំដល់ពេល "សង្ខេប" នៅចុងបញ្ចប់នៃមេរៀននេះសិន ។

## ៤. ការប្រកាន់គោលជំហរ

- សូមសរសេរនៅលើក្រដាសផ្ទាំងធំថា "ដី" និងបិទវានៅខាងចុងម្ខាងនៃបន្ទប់ ។ សរសេរ នៅលើក្រដាសផ្ទាំងធំមួយទៀតថា "ប្រាក់" និងបិទវានៅខាងចុងម្ខាងទៀតនៃបន្ទប់ ។ នៅក្រដាសទី៣ សរសេរសញ្ញា "?" និងដាក់វានៅកណ្តាលបន្ទប់ ។ (អ្នកក៏អាចប្រើរូបភាពបាន ដែរ) ។
- ត្រូវប្រាកដថា មានទីធ្លាធំគ្រប់គ្រាន់ សម្រាប់អ្នកចូលរួមឈរនៅក្បែរសញ្ញាទាំងអស់នោះ ។
- បង្ហាញអ្នកចូលរួមនូវអ្វីដែលអ្នកបានសរសេរ នៅក្រដាសផ្ទាំងធំនីមួយៗ ។ ពន្យល់ពួកគាត់ថាអ្នកនឹងសួរពួកគាត់មួយសំណួរ រួចគប្បីឱ្យពួកគាត់ឈរនៅឯសញ្ញា "ដី" ឬ "ប្រាក់" ទៅតាមគំនិតរបស់គាត់ ។ ប្រសិនបើពួកគាត់មិនប្រាកដថាត្រូវឈរនៅកន្លែងណា សូមឈរនៅត្រង់សញ្ញា "?" ។
- បន្ទាប់មកទៀត សួរអ្នកចូលរួមនូវសំណួរខាងក្រោមនេះ:

---

*"ប្រសិនបើ រដ្ឋាភិបាលចង់យកដីរបស់ពួកគាត់សម្រាប់គម្រោងធនាគារអភិវឌ្ឍន៍អាស៊ី តើពួកគាត់ចង់យកសំណងជាដី ឬសំណងជាប្រាក់?"*

---

- លើកទឹកចិត្តអ្នកចូលរួមឱ្យគិតអំពីចម្លើយ និងឱ្យពួកគាត់ឈរនៅក្បែរសញ្ញាណាមួយ "ដី" ឬ "ប្រាក់" ។ ប្រាប់ពួកគាត់កុំឱ្យបារម្ភអំពី អ្វីដែលអ្នកចូលរួមផ្សេងទៀតកំពុងគិត ។ វាគ្មានចម្លើយត្រូវ ឬខុសនោះទេ ។
- ក្រោយពីអ្នកចូលរួមទាំងអស់បានឈរនៅត្រង់សញ្ញាណាមួយហើយ សូមសួរអ្នកចូលរួម ដែលឈរនៅត្រង់សញ្ញា "ដី" ថាហេតុអ្វីបានជាពួកគាត់ជ្រើសរើសយកដី ហេតុអ្វីមិនជ្រើសរើសយកប្រាក់ ។

- ក្រោយពីអ្នកចូលរួមពីរ-បីនាក់បានពន្យល់អំពីហេតុផលរបស់ពួកគាត់ហើយ សូមសួរសិក្ខាកាមដែលឈរនៅត្រង់សញ្ញា "ប្រាក់" ថាហេតុអ្វីបានជាពួកគាត់ជ្រើសរើសយក "ប្រាក់" ហេតុអ្វីបានជាមិនជ្រើសយកដី។
- បន្ទាប់មកទៀត អ្នកអាចសួរអ្នកដែលឈរនៅក្បែរសញ្ញា "?" មើលថា តើពួកគាត់មានអ្វីត្រូវពន្យល់ទេ ឬក៏បញ្ជាក់គាត់មើលក្រែងលោពួកគាត់ចង់ប្តូរទៅ "ដី" ឬ "ប្រាក់" វិញ ក្រោយពីបានស្តាប់ក្រុមទាំងពីរពន្យល់អំពីហេតុផលរួចមក។
- រំលឹកអ្នកចូលរួមថា គ្មានចម្លើយត្រូវ ឬខុសនោះទេ វាគ្រាន់តែជាការពិភាក្សា ដើម្បីឱ្យពួកគាត់មានពេលគិតថា តើពួកគាត់គប្បីត្រូវជ្រើសរើសយកអ្វី នៅពេលរដ្ឋផ្តល់ជម្រើសឱ្យពួកគាត់ជ្រើសរើស។

## ៥. សង្ខេប

- សុំឱ្យអ្នកចូលរួមរំលឹកឡើងវិញនូវអ្វីដែលពួកគាត់បានរៀន។ អ្នកអាចសួរថាតើម្ចាស់កម្មសិទ្ធិភោគៈ (អ្នកកាន់កាប់ស្របច្បាប់) និងអ្នកកាន់កាប់ខុសច្បាប់ខុសគ្នាដូចម្តេច? អ្នកក៏អាចសួរ ដែរថាតើម្ចាស់កម្មសិទ្ធិអ្នកកាន់កាប់ស្របច្បាប់ មានសិទ្ធិទទួលបានសំណងអ្វីខ្លះ និងតើអ្នកកាន់កាប់ខុសច្បាប់មានសិទ្ធិទទួលបានសំណងអ្វី?
- ចុងបញ្ចប់ ពន្យល់ព័ត៌មាននៅក្នុងប្រអប់: "ដី ឬ ប្រាក់?" អ្នកក៏អាចសង្ខេបឡើងវិញអំពីចំណុចសំខាន់ៗដែលអ្នកចូលរួមឈរនៅត្រង់សញ្ញា "ដី" និង "ប្រាក់" បានលើកឡើងដែរ។

## ៤. តើប្រជាពលរដ្ឋគប្បីទទួលសំណងចំនួនប៉ុន្មាន?

នៅពេលដែលប្រជាពលរដ្ឋទទួលសំណងជាប្រាក់សម្រាប់ដីលំនៅដ្ឋាន ឬអ្វីៗដែលជាកម្មសិទ្ធិរបស់គាត់ រដ្ឋាភិបាលត្រូវតែប្រាកដថា ប្រជាពលរដ្ឋទទួលបាននូវចំនួនប្រាក់ដែលពួកគាត់ត្រូវការ ដើម្បីទិញដី ឬអ្វីៗដែលពួកគាត់នឹងបាត់បង់ ឬត្រូវខូចខាតទាំងស្រុងមកវិញ។

ឧទាហរណ៍ ប្រសិនបើអ្នកណាម្នាក់នឹងបាត់បង់ដី និងលំនៅដ្ឋានរបស់គាត់ ហើយគាត់ត្រូវចំណាយ ២០.០០០ (ពីរម៉ឺន) ដុល្លារ ដើម្បីទិញដីមួយឡូត៍ និងផ្ទះមួយនៅក្បែរនោះ ដែលមានទំហំនិងគុណភាពដូចគ្នា ដូច្នេះគាត់ត្រូវតែទទួលបានសំណងជាប្រាក់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារ។ ប្រសិនបើគាត់ត្រូវចំណាយ ២.០០០ (ពីរពាន់) ដុល្លារ សម្រាប់ការរុះរើចេញ និងបង់ថ្លៃសុំប័ណ្ណកម្មសិទ្ធិ ឬចំណាយផ្សេងៗទៀត គាត់ក៏ត្រូវទទួលបានប្រាក់សម្រាប់ចំណាយបែបនេះដែរ។ រដ្ឋាភិបាលចាំបាច់ត្រូវប្រាកដថា គាត់ទទួលបានប្រាក់ចំនួន ២២.០០០ (ពីរម៉ឺនពីរពាន់) ដុល្លារ ដើម្បីពួកគាត់អាចទិញបានដី និងផ្ទះ ដែលគាត់បាត់បង់នោះទាំងស្រុង ដោយមិនត្រូវចំណាយដោយខ្លួនគាត់ឡើយ។

ប្រសិនបើផ្ទះមួយផ្នែករបស់គ្រួសារណាមួយ ត្រូវកំទេចចោលដើម្បីយកដីសម្រាប់គម្រោងអភិវឌ្ឍន៍ ប៉ុន្តែគ្រួសារនោះមិនអាចបន្តរស់នៅទីនោះតទៅទៀតបានទេ រដ្ឋាភិបាលត្រូវតែសងថ្លៃសំណង់ ទាំងអស់ដែលគ្រួសារនេះបាត់បង់។



*ប្រជាពលរដ្ឋត្រូវទទួលសំណង**មុនពេល**ឱ្យពួកគាត់ផ្លាស់ទីលំនៅ។*

## ៥. តើប្រជាពលរដ្ឋត្រូវទទួលបានអ្វីខ្លះ ប្រសិនបើពួកគាត់ត្រូវតាំងទីលំនៅថ្មី?

ប្រសិនបើប្រជាពលរដ្ឋគ្មានសិទ្ធិទទួលសំណងសម្រាប់ដីរបស់ពួកគាត់ទេ ឧទាហរណ៍ ដោយសារពួកគាត់ជាអ្នកកាន់កាប់ដីរបស់រដ្ឋ ដូច្នេះ រដ្ឋត្រូវតែផ្តល់ជូនពួកគាត់នូវដីសម្រាប់តាំងទីលំនៅថ្មី មុននឹងឱ្យពួកគាត់ផ្លាស់ប្តូរទីលំនៅ។ ពួកគាត់ក៏ត្រូវទទួលបានប្រាក់ ឬការគាំទ្រផ្សេងៗទៀតដើម្បីពួកគាត់អាច រុះរើទៅកន្លែងតាំងទីលំនៅថ្មីនោះបាន។

ទន្ទឹមនឹងនេះ រដ្ឋាភិបាលត្រូវតែប្រាកដថា ប្រជាពលរដ្ឋដែលត្រូវផ្លាស់ប្តូរទៅរស់នៅទីតាំងថ្មីមាន **សុវត្ថិភាពនៃការកាន់កាប់** នៅឯ**តំបន់តាំងទីលំនៅថ្មី**។ នេះមានន័យថា រដ្ឋាភិបាលត្រូវតែធានាតាមផ្លូវច្បាប់ថា ពួកគាត់មិនត្រូវគេបណ្តេញចេញពីលំនៅដ្ឋានថ្មីរបស់គាត់ដោយបង្ខំនោះទេ។

រដ្ឋាភិបាលត្រូវតែធានាថា ប្រជាពលរដ្ឋមានលំនៅដ្ឋានល្អប្រសើរនៅឯតំបន់តាំងទីលំនៅថ្មី ជាងលំនៅដ្ឋានចាស់របស់គាត់។

តំបន់តាំងទីលំនៅថ្មីគប្បីមិនត្រូវនៅឆ្ងាយពេកទេ ដើម្បីកុំឱ្យប្រជាពលរដ្ឋដែលផ្លាស់ទៅនៅទីនោះពិបាករកប្រាក់ចិញ្ចឹមជីវិត ឬមិនអាចមានលទ្ធភាពប្រើប្រាស់សេវាកម្មផ្សេងៗ ដែលពួកគាត់ត្រូវការ ដូចជាសាលារៀន និងមន្ទីរពេទ្យជាដើម។ រដ្ឋាភិបាលក៏ត្រូវតែប្រាកដដែរថា ប្រជាពលរដ្ឋដែល ទៅរស់នៅឯតំបន់ថ្មីនោះ មាន**ឱកាសប្រកបរបរចិញ្ចឹមជីវិត** មានហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មសំខាន់ៗដូចជា ទឹក អនាម័យ អគ្គិសនី និងកន្លែងចាក់សំរាម។

តំបន់តាំងទីលំនៅថ្មី ត្រូវតែមានលំនៅដ្ឋាននិងសេវាកម្មសមរម្យ និងមានអ្វីៗដែលប្រជាពលរដ្ឋ ត្រូវការសម្រាប់រស់នៅ *មុននឹង* ប្រជាពលរដ្ឋផ្លាស់ទៅរស់នៅទីនោះ។



## ៦. ការចរចាជាមួយរដ្ឋាភិបាល

គោលនយោបាយការពារស្តីពីការតាំងទីលំនៅថ្មីដោយបង្ខំ ចែងថា រដ្ឋាភិបាលគប្បីត្រូវតែព្យាយាមចរចាជាមួយប្រជាពលរដ្ឋថា តើប្រជាពលរដ្ឋត្រូវទទួលអ្វីសម្រាប់ដី លំនៅដ្ឋាន ឬអ្វីៗ ផ្សេងទៀតដែលពួកគាត់ ត្រូវបាត់បង់ដោយគម្រោងអភិវឌ្ឍន៍។ ការចរចាត្រូវតែប្រព្រឹត្តទៅដោយយុត្តិធម៌ និងគ្មានអ្នកណា ម្នាក់ត្រូវគេបង្ខំឱ្យទទួលយកអ្វីដែលពួកគាត់មិនចង់បាននោះទេ។

គ្មានប្រជាពលរដ្ឋណាម្នាក់ត្រូវយល់ព្រមចំពោះអ្វីមួយនៅក្នុងពេលចរចា ដែលពួកគាត់មិនពេញចិត្តនឹងទទួលនោះឡើយ។ ប្រជាពលរដ្ឋត្រូវតែដឹងថា តាមគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី តើពួកគាត់មានសិទ្ធិអ្វីខ្លះចំពោះសំណង និងការតាំងទីលំនៅថ្មី។ ពួកគាត់គប្បីយល់ព្រមតែចំពោះអ្វីៗ តាមរយៈការចរចា ប្រសិនបើពួកគាត់គិតថា *ល្អប្រសើរជាងសិទ្ធិរបស់ពួកគាត់នៅក្នុងគោលនយោបាយនេះ។*

# លំហាត់ទី៥: សំណង និងការតាំងទីលំនៅថ្មី

**គោលបំណង:** **អ្នកចូលរួមនឹងដឹងរបៀបគិតអំពីចំនួនប្រាក់សំណង ដែលប្រជាពលរដ្ឋត្រូវទទួល នៅពេលដែលពួកគាត់ទទួលរងផលប៉ះពាល់ដោយសារគម្រោងដែល ផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ។ អ្នកចូលរួមនឹងយល់ដឹងអំពីអ្វីរដ្ឋាភិបាល ត្រូវតែផ្តល់ជូនប្រជាពលរដ្ឋដែលត្រូវតាំងទីលំនៅថ្មី ។**



**សម្ភារ:** ក្តារខៀន ឬក្រដាសផ្ទាំងធំ ហ្វឺត និងឯកសារសម្រាប់ចែកទី១

**វិធីសាស្ត្រប្រើប្រាស់:** ការគូររូប ការពិភាក្សារួមក្នុងថ្នាក់ ការងារជាក្រុម និងបទបង្ហាញ

| ដំណើរការ | រយៈពេល (គិតជានាទី) |
|---|---|
| ១. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៤ | ១០ |
| ២. ការគូររូបអំពីតំបន់តាំងទីលំនៅថ្មី | ១០ |
| ៣. ណែនាំព័ត៌មានក្នុងផ្នែកទី៥ និងទី៦ | ១៥ |
| ៤. ពន្យល់លំហាត់ | ៥ |
| ៥. ការងារជាក្រុម | ១៥ |
| ៦. បទបង្ហាញ | ២០ |
| ៧. សង្ខេប | ១៥ |
| **សរុប:** | **៩០** |

## ការណែនាំសម្រាប់អ្នកសម្របសម្រួល

### ១. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៤

**ផ្នែកទី៤: វាមានសារសំខាន់ណាស់ដែលអ្នកចូលរួមត្រូវយល់ថា:**

- នៅពេលដែលប្រជាពលរដ្ឋត្រូវផ្តល់សំណងជាប្រាក់ សម្រាប់ដី ផ្ទះ ឬរបស់ផ្សេងៗដែលជាកម្មសិទ្ធិរបស់ពួកគាត់ ពេលនោះរដ្ឋាភិបាលត្រូវតែធានាថា ប្រជាពលរដ្ឋបានទទួលចំនួនទឹកប្រាក់ ដែលពួកគាត់ត្រូវការដើម្បីទិញបានដីដូចដើម ឬអ្វីៗដែលពួកគាត់នឹងបាត់បង់នោះ។
- ប្រជាពលរដ្ឋទាំងនោះត្រូវទទួលបានសំណង *មុនពេល* ពួកគាត់ត្រូវរុះរើ ផ្លាស់ទីលំនៅ។

### ២. ការគូររូបតំបន់តាំងទីលំនៅថ្មី

- ចង្អុលក្រដាសផ្ទាំងធំ និងប្រាប់អ្នកចូលរួមឱ្យនឹកស្រមៃថា នេះជាផែនទីនៃតំបន់តាំងទីលំនៅថ្មី ដែលពួកគាត់ត្រូវផ្លាស់ទៅរស់នៅទីនោះ ប្រសិនបើដីរបស់ពួកគាត់ត្រូវរដ្ឋាភិបាលដកហូតយកសម្រាប់អនុវត្តគម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី។ ពន្យល់ថា ក្នុងខណៈនេះ ផែនទីនេះជាក្រដាសទទេ ដូច្នេះវាជាភារកិច្ចរបស់អ្នកចូលរួមត្រូវបំពេញ ផែនទីនេះ។
- ស្នើសុំអ្នកចូលរួមឱ្យមកគូររូបអ្វីដែលពួកគាត់ចង់ឱ្យមាននៅតំបន់តាំងទីលំនៅថ្មី។ អ្នកអាចចាប់ផ្តើមបន្ថែមឧទាហរណ៍របស់អ្នកផ្ទាល់នៅក្នុងផែនទីនោះ ដូចជា សាលារៀន ឬការប្រើប្រាស់ទឹកស្អាតជាដើម។ អញ្ជើញអ្នកចូលរួមឱ្យបានកាន់តែច្រើនកាន់តែល្អ ដើម្បីមកគូររូបនៅក្នុងផែនទីនេះ។
- ក្រោយពីបានធ្វើលំហាត់ខ្លីនេះចប់ សុំឱ្យអ្នកចូលរួមលើកដៃ ប្រសិនបើពួកគាត់ពេញចិត្តទៅរស់នៅតំបន់នោះ នៅពេលដែលរដ្ឋតម្រូវឱ្យពួកគាត់ទៅនៅទីនោះ ដោយសារតែពួកគាត់ទទួលរងផលប៉ះពាល់ដោយគម្រោងអភិវឌ្ឍន៍។

### ៣. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៥ និងទី៦

**ផ្នែកទី៥និងទី៦:** វាមានសារៈសំខាន់ណាស់ ដែលអ្នកចូលរួមយល់ថា:

- នៅពេលប្រជាពលរដ្ឋគ្មានសិទ្ធិទទួលសំណងសម្រាប់ដី និងត្រូវផ្លាស់ប្តូរទីលំនៅដោយសារគម្រោង ដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី រដ្ឋាភិបាលត្រូវតែផ្តល់ដីសម្រាប់សង់លំនៅថ្មី ព្រមទាំងផ្តល់ប្រាក់ និងការគាំទ្រផ្សេងទៀតដើម្បីជួយពួកគាត់រុះរើទៅកន្លែងថ្មី។

- រដ្ឋាភិបាលក៏ត្រូវតែប្រាកដដែរថា ប្រជាពលរដ្ឋមានសុវត្ថិភាពនៃការកាន់កាប់ នៅឯតំបន់តាំងទីលំ នៅថ្មី។
- តំបន់តាំងទីលំនៅថ្មីគប្បីមានលំនៅដ្ឋាន និងសេវាកម្មសមរម្យ និងមានអ្វីៗដែលប្រជាពលរដ្ឋ ត្រូវការសម្រាប់ការរស់នៅ *មុននឹង* ឱ្យប្រជាពលរដ្ឋរើទៅរស់នៅទីនោះ។
- ប្រជាពលរដ្ឋត្រូវតែដឹងថា តាមគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី តើពួកគាត់មានសិទ្ធិអ្វីខ្លះចំពោះសំណង និងការតាំងទីលំនៅថ្មី និងថា ពួកគាត់គប្បីយល់ព្រមតែចំពោះអ្វីៗ តាមរយៈការចរចា ដែល *ល្អប្រសើរជាងអ្វីដែលពួកគាត់មានសិទ្ធិទទួលបាន។*

## ៤. ពន្យល់លំហាត់

- ពន្យល់ថា អ្នកចូលរួមនឹងត្រូវចែកជាបួនក្រុម។ ក្រុមទាំងនោះនឹងទទួលបានករណីសិក្សាខ្លីចំនួនបួន ហើយក្រុមត្រូវព្យាយាមគិតថា តើប្រជាពលរដ្ឋនៅករណីសិក្សានេះ មានសិទ្ធិទទួលបានប្រាក់ចំនួនប៉ុន្មាន និងគិតថា តើពួកគាត់មានសិទ្ធិតាំងទីលំនៅថ្មីដែរឬទេ។ ក្រុមគប្បីត្រូវពិភាក្សាគ្នាលើគ្រប់ករណីសិក្សា និងគប្បីត្រូវព្យាយាមស្វែងរកចម្លើយសម្រាប់ករណីសិក្សា នីមួយៗ។
- ក្រុមនីមួយៗមានរយៈពេល២០នាទីដើម្បីធ្វើលំហាត់នេះ។

## ៥. ការងារជាក្រុម

- ក្រុមនីមួយៗទទួលបានឯកសារសម្រាប់ចែកជូនទី១មួយច្បាប់។
- ដើរចល័តតាមក្រុមនីមួយៗ ដើម្បីឱ្យ ប្រាកដថា សមាជិកក្រុមម្នាក់ៗយល់ដឹងអំពីភារកិច្ច របស់ខ្លួន។

## ៦. បទបង្ហាញ

- ទោះបីជាគ្រប់ក្រុមពិភាក្សាលើករណីសិក្សាទាំងបួនក៏ដោយ ក៏សូមឱ្យក្រុមនីមួយៗ ឡើងបង្ហាញចម្លើយរបស់ខ្លួន តែមួយករណីសិក្សាតែប៉ុណ្ណោះ។ ឧទាហរណ៍ ក្រុម១ឡើងបង្ហាញចម្លើយលើករណីសិក្សាទី១ រីឯក្រុម២ឡើងបង្ហាញ ចម្លើយករណីសិក្សាទី២។ ក្រោយពីក្រុមនីមួយៗ បានបញ្ចប់បទបង្ហាញរបស់ក្រុម សួរក្រុមផ្សេងមើលតើ ពួកគាត់ឯកភាព នឹងចម្លើយនោះដែរឬទេ។

**ចម្លើយដែលអាចទទួលយកបាន:**

**ករណីសិក្សាទី១:** ស៊ីម៉ាគប្បីទទួលបានយ៉ាងតិចណាស់ក៏៨.៥០០ដុល្លារដែរ។

**ករណីសិក្សាទី២:** ផលគប្បីត្រូវទទួលបានប្រាក់ចំនួន១០.០០០ ដុល្លារ ដើម្បីសង់ផ្ទះ បូកនឹងប្រាក់សម្រាប់ចំណាយលើការរុះរើ និងដឹកជញ្ជូន។ គាត់ក៏មានសិទ្ធិទទួលបានដីឡូត៍ និងសេវាកម្មផ្សេងៗ នៅតំបន់តាំងទីលំនៅថ្មី។ គាត់ក៏គប្បីមានសិទ្ធិទទួលបានសេវាកម្ម ដូចជា ទឹក អនាម័យ អគ្គិសនី និងមានកន្លែងចោលសំរាមជាដើម។ សេវាកម្មផ្សេងៗទៀត ដូចជា សាលារៀន និងមន្ទីរ ពេទ្យមិនគួរនៅឆ្ងាយទេ។ គប្បីមានឱកាសការងារនៅជិតៗនោះ។ គាត់គប្បីទទួលបាននូវឯកសារ ដែលធានាសុវត្ថិភាពកាន់កាប់ដីថ្មីរបស់គាត់។

**ករណីសិក្សាទី៣:** វិភូគប្បីត្រូវទទួលបានយ៉ាងតិចណាស់ក៏ ៤.០០០ដុល្លារ សម្រាប់ដីពាក់កណ្តាលរបស់គាត់ បូកនឹង២.០០០ដុល្លារទៀត សម្រាប់ការរុះរើ និងសង់ផ្ទះថ្មី។ ដូច្នេះ គាត់ គប្បីទទួលបានប្រាក់សរុបទាំងអស់ចំនួន ៦.០០០ដុល្លារ។

**ករណីសិក្សាទី៤:** ភារម្យ និងគ្រួសាររបស់គាត់ មានសិទ្ធិទទួលសំណងសម្រាប់ផ្ទះរបស់គាត់ ប៉ុន្តែគ្មានសិទ្ធិទទួលសំណងសម្រាប់ដីទេ ព្រោះពួកគាត់ជាអ្នកកាន់កាប់ដីដោយខុសច្បាប់។ គ្រួសារនេះមានសិទ្ធិក្នុងការទៅតាំងទីលំនៅថ្មី ដែលស្ថិតនៅមិនឆ្ងាយ។ ពួកគាត់គប្បីមាន ផ្ទះដែលល្អប្រសើរជាងផ្ទះចាស់របស់គាត់ ដែលអាចការពារទឹកភ្លៀងបាន។ ពួកគាត់គប្បីមានសិទ្ធិទទួលបានសេវាកម្ម ដូចជា ទឹក អនាម័យ អគ្គិសនី និងកន្លែងចោលសំរាម។ សេវាកម្មផ្សេងៗទៀត ដូចជា សាលារៀន និងមន្ទីរពេទ្យមិនត្រូវនៅឆ្ងាយទេ។ ត្រូវមានឱកាសការងារនៅជិតៗនោះ។ ពួកគាត់គប្បីត្រូវទទួលបានឯកសារដែលធានា សុវត្ថិភាព កាន់កាប់ដីថ្មីរបស់ពួកគាត់។

## ៧. សង្ខេប

- សួរអ្នកចូលរួម តើពួកគាត់គិតថា ពួកគាត់បានទទួលប្រាក់សំណងត្រឹមត្រូវទៅតាម គោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីដែរឬទេ។
- សួរអ្នកចូលរួម តើតំបន់តាំងទីលំនៅថ្មី ដែលពួកគាត់បានផ្លាស់ទៅ ឬនឹងផ្លាស់ទៅនោះ មានអ្វីគ្រប់យ៉ាងដែលត្រូវមាន តាមគោលនយោបាយរបស់ធនាគារដែរឬទេ។
- អ្នកអាចសម្របសម្រួលការពិភាក្សាដោយសួរសំណួរដូចខាងក្រោម:
  - តើនៅតំបន់តាំងទីលំនៅថ្មី មានផ្ទះ ទឹកស្អាត អនាម័យ អគ្គិសនី និងកន្លែង ចោលសំរ៉ាមទេ?
  - តើមានឱកាសដែលប្រជាពលរដ្ឋអាចរកការងារធ្វើ ឬឱកាសសម្រាប់ប្រកបរបរចិញ្ចឹមជីវិតទេនៅជិតៗនោះទេ?
  - តើមានសាលារៀន និងមន្ទីរពេទ្យនៅជិតៗនោះទេ?
  - តើរដ្ឋាភិបាលបានផ្តល់ឯកសារផ្លូវច្បាប់ដែលធានាថា ពួកគាត់អាចរស់នៅទីនោះទេ? ប្រសិនបើបាន តើឯកសារនោះនិយាយអំពីអ្វី?

- ប្រសិនបើ មានបញ្ហាជាមួយនឹងសំណង ឬតំបន់តាំងទីលំនៅថ្មី អ្នកអាចស្នើថា ពួកគាត់អាចលើកឡើងបញ្ហាទាំងនេះទៀត ក្រោយការបណ្តុះបណ្តាលនេះ ដើម្បីពួកគាត់អាចពិភាក្សាគ្នាថា តើពួកគាត់ត្រូវធ្វើអ្វីចំពោះបញ្ហាទាំងនោះ ។

## ឯកសារសម្រាប់ចែកទី១៖ លំហាត់ទី៥

### ករណីសិក្សាទី១៖

ស៊ីម៉ាមានដីនៅខេត្តកំពង់ស្ពឺ។ នាងបានរស់នៅ និងធ្វើស្រែចម្ការលើដីនោះ។ រដ្ឋាភិបាលត្រូវការដីរបស់គាត់ដើម្បីធ្វើទំនប់ទឹកមួយ ដែលជាគម្រោងដែលផ្ដល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី។ ស៊ីម៉ាដឹងថាគាត់អាចទិញដីដូច ដីរបស់គាត់នៅក្បែរនោះដែលមានទំហំ និងគុណភាពដូចគ្នានឹងដីរបស់គាត់ដែរក្នុងតម្លៃ ៥.០០០ ដុល្លារ។ គាត់ត្រូវចំណាយ ៣.០០០ដុល្លារដើម្បីរុះរើ និងសង់ផ្ទះថ្មី។ គាត់ក៏ត្រូវចំណាយ៥០០ដុល្លារទៀតដើម្បីចុះបញ្ជីដីជាកម្មសិទ្ធិរបស់គាត់។

តើស៊ីម៉ាត្រូវទទួលបានប្រាក់សំណងចំនួនប៉ុន្មាន?

### ករណីសិក្សាទី២៖

លោក ផល រស់នៅលើដីរដ្ឋ នៅជាប់ផ្លូវរថភ្លើងនៅរាជធានីភ្នំពេញ។ រដ្ឋាភិបាលត្រូវការដីនេះដើម្បីជួសជុលផ្លូវរថភ្លើងនេះ ដែលផ្ដល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី។ គាត់មានផ្ទះថ្មមួយខ្នងយ៉ាងល្អដែលគាត់បានចំណាយលើការសាងសង់អស់ ១០.០០០ ដុល្លារ។

តើលោក ផល ត្រូវទទួលបានសំណងប៉ុន្មាន? តើគាត់មានសិទ្ធិតាំងទីលំនៅថ្មីទេ? ប្រសិនបើមាន តើគាត់នឹងទទួលបានអ្វីខ្លះនៅឯតំបន់តាំងទីលំនៅថ្មី?

### ករណីសិក្សាទី៣៖

អ្នកស្រី វិជ្ជូ មានដីនិងផ្ទះតូចមួយនៅខេត្តបន្ទាយមានជ័យ។ គាត់គ្មានប័ណ្ណកម្មសិទ្ធិទេ ប៉ុន្តែជាអ្នកកាន់កាប់ដោយស្របច្បាប់។ រដ្ឋាភិបាលត្រូវការដីរបស់គាត់ពាក់កណ្ដាលដើម្បីសង់ផ្លូវមួយខ្សែរ ដែលជាគម្រោងដែលផ្ដល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី។ ផ្ទះរបស់គាត់ស្ថិតនៅលើដីពាក់កណ្ដាលរដ្ឋត្រូវការនោះ។ អ្នកស្រី វិជ្ជូ ចង់បន្តរស់នៅលើដីនៅសល់ និងចង់ទទួលសំណងសម្រាប់ដីពាក់កណ្ដាល ដែលរដ្ឋាភិបាលដកហូតយកនោះ។ គាត់ចង់សង់ផ្ទះថ្មីមួយខ្នងនៅ លើដីនៅសល់នោះ។ គាត់ដឹងថា គាត់អាចលក់ដីទាំងអស់បាន៨.០០០ដុល្លារ និងអាចសង់ផ្ទះថ្មីក្នុងតម្លៃ២.០០០ ដុល្លារ។

តើអ្នកស្រី វិជ្ជូ ត្រូវទទួលបានប្រាក់សំណងប៉ុន្មាន?

**ករណីសិក្សាទី៤:**

ភារម្យ និងគ្រួសាររបស់គាត់រស់នៅលើដីមួយឡូត៍នៅរាជធានីភ្នំពេញ។ គាត់បានមករស់នៅលើដីនេះតាំងពីឆ្នាំ២០០៤ ក្រោយពីគាត់បានលក់ដីរបស់គាត់នៅខេត្តបាត់ដំបងដើម្បីសងបំណុលគេ។ នៅពេលគាត់មកដល់ទីនេះដីនេះជា ដីទំនេរគ្មានលំនៅដ្ឋានទេ។ គាត់បានសង់ផ្ទះយ៉ាងតូចមួយសម្រាប់គ្រួសាររបស់គាត់រស់នៅ តែផ្ទះនេះមិនអាចការពារទឹកភ្លៀង និងអ្វីៗផ្សេងទៀតបានស្រួលបួលទេ។ រដ្ឋាភិបាលត្រូវការដីនោះ ដើម្បីសង់ស្ថានីយ៍រថភ្លើងថ្មីមួយ ដែលជាគម្រោងដោយមានការផ្តល់មូលនិធិគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី។

តើភារម្យ និងគ្រួសាររបស់គាត់ មានសិទ្ធិទទួលបានសំណងសម្រាប់ដី ឬផ្ទះរបស់គាត់ទេ? តើគាត់មានសិទ្ធិតាំងទីលំនៅថ្មីទេ? ប្រសិនបើមាន តើគាត់ត្រូវទទួលបានអ្វីខ្លះនៅឯតំបន់តាំងទីលំនៅថ្មី?

# ៧. តើប្រជាពលរដ្ឋត្រូវទទួលបានអ្វី ប្រសិនបើពួកគាត់បាត់បង់ឱកាសប្រកបអាជីវកម្ម បាត់បង់ការងារ ឬការប្រកបរបរចិញ្ចឹមជីវិតផ្សេងៗទៀត?

នៅពេលដែលរដ្ឋឱ្យប្រជាពលរដ្ឋផ្លាស់ប្តូរទីលំនៅពីកន្លែងប្រកបអាជីវកម្ម កន្លែងធ្វើការ ឬបាត់បង់ឱកាសការងារ ឱកាសប្រកបអាជីវកម្ម ឬលែងមានឱកាសប្រើប្រាស់ធនធានដែលពួកគាត់ធ្លាប់ប្រើប្រាស់ ដើម្បីប្រកបរបរចិញ្ចឹមជីវិត ពេលនោះពួកគាត់ក៏បាត់បង់ប្រាក់ចំណូលដែលពួកគាត់ធ្លាប់រកបាននោះដែរ។ ពួកគាត់ក៏អាចនឹងបាត់បង់ឱកាសប្រើប្រាស់អ្វីៗដែលពួកគាត់ត្រូវការដើម្បីទ្រទ្រង់ជីវិត ដូចជា ប្រភពស្បៀងអាហារជាដើម។ គោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី តម្រូវឱ្យរដ្ឋាភិបាលផ្តល់សំណង និងការគាំទ្រដល់ប្រជាពលរដ្ឋដែលបាត់បង់ប្រាក់ចំណូល ឬដែលបាត់បង់ប្រភពនៃការប្រកបរបរចិញ្ចឹមជីវិត ដើម្បីឱ្យពួកគាត់អាចចាប់ផ្តើមប្រកបអាជីវកម្មឡើងវិញ ឬរកវិធីថ្មីដើម្បីប្រកបរបរចិញ្ចឹមជីវិត។ ទំរាំតែប្រជាពលរដ្ឋមានលទ្ធភាពស្តារប្រាក់ចំណូល និងរបរចិញ្ចឹមជីវិតឡើងវិញបាន រដ្ឋាភិបាលត្រូវតែផ្តល់សំណងជូនពួកគាត់សម្រាប់ការខាតបង់ប្រាក់ចំណូល និងការបាត់បង់របរចិញ្ចឹមជីវិតនោះ។

## ៧.១ អ្នកប្រកបអាជីវកម្ម

ប្រសិនបើអ្នកប្រកបអាជីវកម្មណាម្នាក់មិនអាចបន្តមុខរបររបស់គាត់តទៅទៀតបាន ដោយសារគេដកហូតដីរបស់គាត់ ឬគេឱ្យពួកគាត់ផ្លាស់ប្តូរទីលំនៅដោយសារគម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ដូច្នេះរដ្ឋាភិបាលត្រូវសងសំណងសម្រាប់ការបាត់បង់ប្រាក់ចំណូលនោះ។ ក្នុងស្ថានភាពនេះ រដ្ឋត្រូវតែទូទាត់សងគាត់នូវចំនួននៃប្រាក់ចំណូលដែលពួកគាត់ធ្លាប់រកបានសម្រាប់រយៈពេល ដែលពួកគាត់មិនអាចបន្តមុខរបររបស់គាត់នោះ ឬនៅពេលដែលគាត់មិនទាន់អាចរកប្រាក់ចំណូលបាន។

ប្រសិនបើហាង ឬតូបលក់ដូរ ឬសម្ភារះរបស់អ្នកណាម្នាក់ដែលគាត់ធ្លាប់ប្រើសម្រាប់ការប្រកបអាជីវកម្មនឹងត្រូវគេបំផ្លាញ ឬត្រូវបាត់បង់ដោយសារតែគម្រោងនេះ ពួកគាត់ក៏ត្រូវទទួលបានចំនួនប្រាក់ ដែលគាត់ត្រូវការដើម្បីផ្លាស់ទៅនៅកន្លែងថ្មី និងចាប់ផ្តើមប្រកបអាជីវកម្មឡើងវិញនៅកន្លែងថ្មីនោះ ដែរ។



នៅពេលដែលអ្នកប្រកបអាជីវិកម្ម មានប័ណ្ណកម្មសិទ្ធិ ឬមានសិទ្ធិកាន់កាប់ស្របច្បាប់លើដីដែលគាត់កំពុងតែប្រកបអាជីវកម្មនោះ គាត់ក៏ត្រូវទទួលបានសំណងជាដី ឬសំណងជាប្រាក់ដែរ។ សំណងជាដីត្រូវតែមានតម្លៃស្មើ ឬច្រើនជាងដីដែលរដ្ឋដកហូតនោះ។ ប្រាក់ដែលជាសំណងត្រូវតែមាន ចំនួនគ្រប់គ្រាន់ដើម្បីទិញដី មួយកន្លែងផ្សេងទៀតដែលមានតម្លៃដូចគ្នា។

ប្រសិនបើប្រជាពលរដ្ឋប្រកបអាជីវកម្ម នៅលើដីដែលពួកគាត់គ្មានប័ណ្ណកម្ម ឬសិទ្ធិកាន់កាប់ទេ ពួកគាត់នឹងមិនមានសិទ្ធិទទួលសំណងសម្រាប់ដីទេ។ ទោះជាយ៉ាងនេះក្តី ប្រសិនបើពួកគាត់បានសង់អ្វីៗនៅលើដីនោះ ដូចជាមានដាំដំណាំ ឬប្រើប្រាស់ដីនោះដើម្បីធ្វើអ្វីផ្សេងៗ ដូចជាធ្វើប្រព័ន្ធប្រឡាយទឹក ជាដើម ដូច្នេះពួកគាត់ត្រូវទទួលបានសំណងសម្រាប់របស់ទាំងនោះ។ ពួកគាត់ត្រូវទទួលបានចំនួនប្រាក់ ដែលជាសំណងសម្រាប់អ្វីៗដែលគាត់បានសង់ ឬដាំនៅលើដីនោះ។



## ៧.២ ការងារ និងការប្រកបរបរចិញ្ចឹមជីវិតផ្សេងៗទៀត

ប្រសិនបើប្រជាពលរដ្ឋមិនអាចបន្តការងាររបស់គាត់តទៅទៀតទេ ឬប្រសិនបើពួកគាត់ត្រូវគេកាត់ផ្តាច់ពីការប្រកបរបរចិញ្ចឹមជីវិតផ្សេងៗទៀត ដូច្នេះរដ្ឋាភិបាលត្រូវតែផ្តល់សំណងជូនពួកគាត់។ សំណងនេះគឺជាចំនួនប្រាក់ ដែលស្មើនឹងអ្វីដែលពួកគាត់បាត់បង់។ ឧទាហរណ៍ ប្រសិនបើមានប្រជាពលរដ្ឋ ដែលបាត់បង់ការងាររបស់គាត់ ព្រមទាំងមិនអាចរកប្រាក់ចំណូលបានរយៈពេលប្រាំមួយខែ ដូច្នេះរដ្ឋាភិបាលត្រូវតែផ្តល់ចំនួនប្រាក់ ដែលពួកគាត់ធ្លាប់រកបានសម្រាប់រយៈពេលប្រាំមួយខែនោះ។




ប្រសិនបើអ្នកណាម្នាក់បាត់បង់ឱកាសប្រើប្រាស់ព្រៃដែលគាត់ធ្លាប់រកស្បៀងអាហារ ឬប្រសិនបើបាត់បង់ឱកាសប្រើទន្លេដែលពួកគាត់ធ្លាប់នេសាទត្រីសម្រាប់ជាអាហារ ឬដើម្បីលក់យកប្រាក់ដោះស្រាយតម្រូវការ ដូច្នេះរដ្ឋត្រូវផ្តល់សំណងជូនគាត់ដើម្បីគាត់អាចបន្តផ្គត់ផ្គង់ និងចិញ្ចឹមគ្រួសាររហូតដល់ពួកគាត់រកបានវិធីថ្មីដើម្បីទ្រទ្រង់គ្រួសាររបស់គាត់ ។



## លំហាត់ទី៦: សំណងសម្រាប់ការបាត់បង់មុខរបរចិញ្ចឹមជីវិត

**គោលបំណង: អ្នកចូលរួមនឹងដឹងថា តើប្រជាពលរដ្ឋត្រូវទទួលបានអ្វី ប្រសិនបើពួកគាត់បាត់បង់ឱកាសប្រកបអាជីវកម្ម ការងារ ឬការប្រកបរបរចិញ្ចឹមជីវិតផ្សេងៗទៀត។ ពួកគាត់នឹងបានយល់ដឹងអំពីរបៀបគិតរកចំនួនសំណងដែលប្រជាពលរដ្ឋត្រូវទទួលបាន។**

**សម្ភារ:** ក្ដារខៀន ឬក្រដាសផ្ទាំងធំ ហ្វឺត ឯកសារចែកជូនទី១ ទី២ និងទី៣

**វិធីសាស្ត្រប្រើប្រាស់:** ការពិភាក្សារួមក្នុងថ្នាក់ ការងារជាក្រុម និងការសម្ដែងតួ

| ដំណើរការ | រយៈពេល (គិតជានាទី) |
|---|---|
| ១. ណែនាំព័ត៌មាននៅក្នុងផ្នែក៧ (រួមទាំងចំណុច៧.១ និង៧.២ផង) | ២៥ |
| ២. ពន្យល់លំហាត់ | ៥ |
| ៣. ក្រុមរៀបចំការសម្ដែងតួ | ២០ |
| ៤. ការសម្ដែងតួ និងការពិភាក្សា | ២០ |
| ៥. សង្ខេប | ១០ |
| **សរុប:** | **៨០** |

# ការណែនាំសម្រាប់អ្នកសម្របសម្រួល

## ១.　ណែនាំព័ត៌មាននៅក្នុងផ្នែក៧

**ផ្នែក៧:** វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ថា

- អ្នកប្រកបអាជីវកម្មដែលមិនអាចបន្តប្រកបអាជីវកម្មតទៅទៀតបាន ដោយសាររដ្ឋដកហូតយកដី ឬរដ្ឋឱ្យពួកគាត់ផ្លាស់ប្តូរទីលំនៅ ដោយសារគម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ត្រូវទទួលសំណង សម្រាប់ប្រាក់ចំណូលដែលពួកគាត់ខាតបង់។
- អ្នកប្រកបអាជីវកម្មដែលតូប ឬកន្លែងលក់ដូរ ឬសម្ភារៈរបស់គាត់ត្រូវបាត់បង់ ឬត្រូវបំផ្លាញដោយសារគម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ត្រូវទទួលបាននូវសំណងជាទឹកប្រាក់ដែលពួកត្រូវការសម្រាប់ការរុះរើ និងរៀបចំកន្លែងរកស៊ីរបស់គាត់ឡើងវិញ។
- អ្នកប្រកបអាជីវកម្មដែលមានប័ណ្ណកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ដីដែលពួកគាត់កំពុងប្រកបអាជីវកម្មនោះត្រូវទទួលបានសំណងជាដី ឬជាប្រាក់ ប្រសិនបើដីរបស់គត់ត្រូវដកហូតដើម្បីអនុវត្ត គម្រោង។
- អ្នកប្រកបអាជីវកម្មទាំងអស់ដែលទទួលរងផលប៉ះពាល់ ត្រូវទទួលបាននូវសំណងសម្រាប់សំណង់ផ្សេងៗ ដើមឈើ ផលដំណាំ ឬការរៀបចំកែលម្អផ្សេងៗនៅលើដីនោះ។
- ប្រជាពលរដ្ឋដែលមិនអាចបន្តការងាររបស់គាត់ ឬអ្នកដែលត្រូវគេផ្តាច់ពីការប្រកបមុខរបរចិញ្ចឹមជីវិត ត្រូវទទួលបានសំណងយ៉ាងពេញលេញសម្រាប់ការខាតបង់ប្រាក់ចំណូល និងប្រភពប្រាក់ចំណូលផ្សេងៗទៀត។

## ២.　ពន្យល់លំហាត់

- ពន្យល់ថា អ្នកចូលរួមនឹងត្រូវចែកជាបីក្រុម។ ក្រុមនីមួយៗនឹងទទួលបានរឿងមួយ។ ក្រុមត្រូវពិភាក្សាគ្នាអំពីរឿងនោះ និងពិភាក្សាថា តើប្រជាពលរដ្ឋនៅក្នុងរឿងនោះនឹងត្រូវទទួលបានសំណងអ្វីសម្រាប់ការបាត់បង់អាជីវកម្ម ឬប្រាក់ចំណូលរបស់គាត់។ ក្រុមនីមួយៗត្រូវរៀបចំការសម្តែងតួអំពីរឿងនេះដោយបង្ហាញថា តើពួកគាត់នឹងត្រូវបាត់បង់អ្វី និងតើត្រូវទទួលបានសំណងអ្វី។
- ការសម្តែងតួនេះ គួរប្រើរយៈពេលតែពីរ-បីនាទីបានហើយ។
- ក្រុមមានរយៈពេល២០នាទីដើម្បីរៀបចំការសម្តែងតួ។

## ៣. ក្រុមរៀបចំការសម្តែងតួ

- ចែករឿងនៅក្នុងឯកសារសម្រាប់ចែកទី១ ទី២ និងទី៣ ទៅក្រុមនីមួយៗ។
- ដើរមើលតាមក្រុមនីមួយៗ ដើម្បីឱ្យប្រាកដថា សមាជិកក្រុមម្នាក់ៗយល់អំពីកិច្ចការដែល ត្រូវធ្វើ។

## ៤. ការសម្តែងតួ និងការពិភាក្សា

- អញ្ជើញក្រុមនីមួយៗឱ្យឡើងសម្តែងតួ។
- សួរអ្នកចូលរួមដទៃទៀតមើលតើ ពួកគាត់អាចពន្យល់បានទេថា តើមានអ្វីកើតឡើងនៅក្នុងការសម្តែងតួនេះ។ តើប្រជាពលរដ្ឋនៅក្នុងរឿងនេះ ត្រូវទទួលបានសំណងអ្វី និង ហេតុអ្វី?
- ប្រសិនបើ អ្នកចូលរួមយល់មិនសូវច្បាស់អំពីអ្វីដែលបានកើតឡើង សូមស្នើសមាជិកនៅក្នុងក្រុម ដែលឡើងសម្តែងតួនេះឱ្យពន្យល់អំពីអ្វីដែលបានកើតឡើង ឬឱ្យអានរឿងនោះ។ ក្រុមក៏ត្រូវពន្យល់ដែរអំពីរបៀបដែលពួកគាត់គិតរកចំនួនសំណងដែលប្រជាពលរដ្ឋនៅក្នុងរឿងត្រូវទទួល។ ប្រសិនបើក្រុមមិនមានចម្លើយត្រឹមត្រូវទេ អ្នកត្រូវជួយក្រុមដោយប្រើចម្លើយដែលអាចទទួលយកបានដូចខាងក្រោម នេះ។

**ចម្លើយដែលអាចទទួលយកបាន៖**

**រឿងរបស់វីរៈ**

- វីរៈមានដី និងហាងលក់ដូរ ដូច្នេះគាត់ត្រូវទទួលបានប្រាក់ចំនួន ១០.០០០ ដុល្លារ ជាសំណងសម្រាប់ដីនិងហាងលក់ដូរនោះ។
- គាត់ក៏ត្រូវទទួលបានប្រាក់ចំនួន២.០០០ដុល្លារ ដែលគាត់ត្រូវការចំណាយលើការរុះរើសម្ភារៈទាំងអស់របស់គាត់ និងធ្វើហាងលក់ដូរមួយថ្មីឱ្យរួចស្រេច។
- ដោយសារគាត់មិនអាចរកប្រាក់ចំណូលដែលជាធម្មតាគាត់អាចរកបាន៥០០ដុល្លារក្នុងមួយ ខែ រហូតដល់បីខែ ដែលគាត់ត្រូវរុះរើហាងលក់ដូររបស់គាត់ ដូច្នេះគាត់ត្រូវទទួលបានសំណងចំនួន១.៥០០ ដុល្លារ សម្រាប់ការខាតបង់ប្រាក់ចំណូលរបស់គាត់។
- ដូច្នេះវីរៈនឹងទទួលបានប្រាក់សំណងសរុប១៣.៥០០ដុល្លារ។

**រឿងរបស់សំអាត និងសុខា:**

- សំអាត និងសុខា គ្មានកម្មសិទ្ធិដីទេ ព្រោះពួកគាត់បានមករស់នៅទីនោះ នៅឆ្នាំ២០០២ ក្រោយពេលដែលច្បាប់ភូមិបាលត្រូវបានអនុម័ត។ ពួកគាត់គ្មានសិទ្ធិទទួលសំណងសម្រាប់ដីដែលពួកគាត់បានរស់នៅនោះទេ។

- ពួកគាត់មានសិទ្ធិទទួលបានសំណងសម្រាប់តម្លៃដើមឈើរបស់គាត់ ដែលគាត់បានប៉ាន់ស្មានថាមានតម្លៃ ៣.០០០ ដុល្លារ។

- ពួកគាត់ក៏មានសិទ្ធិទទួលបានសំណងសម្រាប់តម្លៃប្រព័ន្ធស្រោចស្រប់ ដែលពួកគាត់បានសង់នៅលើដីនោះ ដែលមានតម្លៃប្រហែល៣០០ដុល្លារដែរ។

- សំអាត និងសុខា រកបានប្រាក់ពីការធ្វើស្រែចម្ការ ចំនួន១.៥០០ដុល្លារក្នុងមួយឆ្នាំកន្លងទៅ ឬប្រហែល១២៥ដុល្លារ ក្នុងមួយខែ។ រហូតដល់ពួកគាត់អាចចាប់ផ្តើមធ្វើស្រែចម្ការជាថ្មី ឬរកវិធីថ្មីដើម្បីរកប្រាក់ពួកគាត់មិនអាចមានប្រាក់ចំណូលទេ។ ដូច្នេះ ពួកគាត់ត្រូវតែទទួលបានសំណងសម្រាប់ ការខាតបង់ប្រាក់ចំណូលរយៈពេល ដែលពួកគាត់មិនទាន់រកប្រាក់ចំណូលបាននេះ។

- សំអាត និងសុខាត្រូវទទួលបានប្រាក់សំណងសរុបប្រហែល៣.៣០០ដុល្លារ ព្រមទាំងត្រូវទទួលបានប្រាក់សំណង១២៥ដុល្លារមួយខែ រហូតពួកគាត់អាចចាប់ផ្តើមរកបានប្រាក់ចំណូល ជាថ្មី។

- រដ្ឋាភិបាលអាចផ្តល់សំណងជាដីជូន សំអាតនិងសុខាដើម្បីពួកគាត់អាចដាំដំណាំថ្មី និងចាប់ផ្តើមរកបានប្រាក់ចំណូលឡើងវិញក្នុងពេលឆាប់ៗខាងមុខ។

**រឿងរបស់ឡេង:**

- ជាចម្មតាឡេងធ្វើការនៅផ្ទះសំណាក់នោះដោយ ទទួលបានប្រាក់ខែ១០០ដុល្លារក្នុងមួយខែ។ ប្រសិនបើ គាត់មិនអាចបន្តធ្វើការនេះតទៅទៀតដោយសារតែគាត់ត្រូវផ្លាស់ប្តូរទីលំនៅទៅ ឆ្ងាយ ដូច្នេះគាត់ត្រូវទទួលបានសំណងសម្រាប់ការបាត់បង់ប្រាក់ខែ សម្រាប់រយៈពេល ដែលគាត់មិនទាន់រកការងារថ្មីបានធ្វើ ឬមិនទាន់រកប្រាក់ចំណូលបាន។

- ប្រសិនបើរដ្ឋាភិបាលរកបានតំបន់តាំងទីលំនៅថ្មីនៅកាន់តែជិត ដូច្នេះឡេងអាចបន្តធ្វើការនៅផ្ទះសំណាក់នោះ រីឯរដ្ឋាភិបាលមិនចាំត្រូវសងសំណងដល់គាត់សម្រាប់ការខាតបង់ប្រាក់ខែនោះទេ។ ប្រសិនបើតំបន់តាំងទីលំនៅថ្មីនោះនៅឆ្ងាយ រដ្ឋាភិបាលអាចផ្តល់មធ្យោបាយធ្វើដំណើរ ដោយមិនគិតប្រាក់ ឬយកថ្លៃថោកល្មមដែលលោក ឡេង និងអ្នកផ្សេងអាចមានលទ្ធភាពធ្វើដំណើរទៅធ្វើការនៅភ្នំពេញ និងត្រឡប់មកផ្ទះវិញជារៀងរាល់ថ្ងៃ។

## ៥. សង្ខេប

- សួរអ្នកចូលរួមមើលថាតើ ពួកគាត់គិតថា គោលនយោបាយស្តីពីការផ្តល់សំណងជូនប្រជាពលរដ្ឋ ដែលបាត់បង់ឱកាសប្រកបអាជីវកម្ម ឬបាត់បង់ការងារ យុត្តិធម៌ឬអត់? ប្រសិនបើរដ្ឋាភិបាលផ្តល់សំណងត្រឹមត្រូវតើពួកគាត់គិតថា ប្រសិនបើពួកគាត់បាត់បង់ឱកាសការងារ ឬឱកាសប្រកបអាជីវកម្ម តើការធ្វើបែបនេះអាច បញ្ឈប់ពួកគាត់មិនឱ្យធ្លាក់ខ្លួនកាន់តែក្រទៅៗទេ?
- តើរដ្ឋាភិបាលត្រូវបន្តសងសំណងសម្រាប់ការខាតបង់ប្រាក់ចំណូលយូរប៉ុណ្ណា?
- តើប្រជាពលរដ្ឋត្រូវការ ការគាំទ្រប្រភេទផ្សេងទៀតទេដើម្បីឱ្យប្រាកដថា ពួកគាត់អាចបន្តមុខរបររបស់ពួកគាត់ ឬចាប់ផ្តើមការប្រកបអាជីវកម្មថ្មី និងដើម្បីធ្វើឱ្យប្រាកដថា កម្រិតជីវភាពរស់នៅរបស់ពួកគាត់មិនកាន់តែអន់ជាងមុន?
- អ្នកអាចពន្យល់ថា ពួកគាត់នឹងពិភាក្សាបញ្ហាទាំងនេះបន្ថែមទៀតនៅក្នុងលំហាត់ក្រោយ ។

## ឯកសារសម្រាប់ផ្នែកទី១ៈ  លំហាត់ទី៦

### រឿងរបស់វីរៈ

វីរៈមានកន្លែងជួសជុលយានយន្តមួយ នៅតាមផ្លូវមួយដែលមានមនុស្សធ្វើដំណើរទៅមកជាច្រើន នៅចំកណ្តាលខេត្តព្រះសីហនុ។ គាត់មានសម្ភារៈសម្រាប់ប្រើប្រាស់ដើម្បីជួសជុលរថយន្ត។ គាត់បានសង់កន្លែងជួលជុលរថយន្តនេះនៅលើដីដែលជារបស់គាត់។ គាត់ប្រកបមុខរបរជួសជុលយានយន្តនេះបានកាក់កបណាស់។ ជាធម្មតាគាត់អាចរកបានប្រាក់ចំណូល ពីការជួសជុលរថយន្ត និងម៉ូតូប្រហែល ៥០០ដុល្លារក្នុងមួយខែ។




ឥឡូវនេះមានមន្ត្រីរាជការមកប្រាប់គាត់ថា រដ្ឋត្រូវពង្រីកផ្លូវនេះ និងត្រូវការដកហូតយកដីនៅក្បែរផ្លូវរួមទាំងដីរបស់គាត់ដែរ។ មន្ត្រីនោះបានប្រាប់គាត់ថា គម្រោងពង្រីកផ្លូវនេះជាគម្រោង ដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី។

វីរៈមិនសប្បាយចិត្តទេ ព្រោះការប្រកបអាជីវកម្មរបស់គាត់កាក់កបណាស់ ព្រមទាំងមិនចង់បាត់បង់ប្រាក់ចំណូលទេ។ គត់ត្រូវការរកកន្លែងផ្សេងនៅក្បែរៗនេះ ដើម្បីគាត់អាចបន្តមុខរបររបស់គាត់ និងអាចរក្សាអតិថិជនរបស់គាត់។ គាត់បានដើររកមើលដីនៅក្បែរៗនោះ និងឃើញថាគាត់អាចទិញដីមួយឡូត៍ដូចគ្នានេះដោយមានយានដ្ឋាននៅក្បែរនេះក្នុងតម្លៃ**១០.០០០ដុល្លារ**។ គាត់ត្រូវចំណាយប្រហែល**២.០០០ដុល្លារ**សម្រាប់រុះរើសម្ភារៈរបស់គាត់ទៅយានដ្ឋានថ្មីនោះ។ ការរុះរើនោះនឹងត្រូវប្រើរយៈពេលប្រហែល**បីខែ** ទើបរួច

រាល់អាចបើកបម្រើអតិថិជនបាន។ គាត់បារម្ភថា គាត់នឹងមិនអាចរកបានប្រាក់ចំណូល**៥០០ដុល្លារមួយខែ**ទេ ចាប់ពីពេលរុះរើ និងចាប់ផ្តើមបើកជួសជួលឡើងវិញនោះ។

- តើវីរៈត្រូវទទួលបានប្រាក់សំណងប៉ុន្មាន?
- សូមរៀបចំការសម្តែងតួមួយអំពីរឿងរបស់វីរៈ និងការសន្ទនារបស់គាត់អំពីសំណងជាមួយតំណាងរបស់រដ្ឋាភិបាល។

## ឯកសារសម្រាប់ផ្នែកទី២៖ លំហាត់ទី៦

### រឿងរបស់សំអាតនិងសុខា៖

នៅឆ្នាំ២០០២ សំអាត និងសុខាបានឃើញដីទំនេរមួយកន្លែងនៅខេត្តឧត្តរមានជ័យ។ ពួកគាត់បានចាប់ផ្ដើមធ្វើស្រែចម្ការនៅលើដីនោះ ព្រមទាំងបានធ្វើប្រព័ន្ធប្រឡាយទឹក ដើម្បីបូមទឹកពីទន្លេក្បែរនោះមកចម្ការរបស់ពួកគាត់។ ពួកគាត់បានចាប់ផ្ដើមធ្វើចម្ការតូចមួយ ដើម្បីដាំដើមឈើ ដូចជាដើមស្វាយ ខ្នុរ និងដើមចេក។



ឥឡូវនេះមានតំណាងរបស់រដ្ឋាភិបាលបានមកប្រាប់ពួកគាត់ថា រដ្ឋកំពុងធ្វើទំនប់ទឹកមួយយ៉ាងធំ នៅក្នុងតំបន់នេះ ព្រមទាំងបានប្រាប់ថា រដ្ឋត្រូវការដកហូតដីរបស់សំអាត និងសុខាដើម្បីអនុវត្តគម្រោង ដែលផ្ដល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី។

មន្ត្រីរដ្ឋាភិបាលប្រាប់សំអាតនិងសុខាថា ពួកគាត់គ្មានកម្មសិទ្ធិលើដីនោះទេ ព្រោះពួកគាត់ផ្លាស់មកនៅលើដីនេះនៅឆ្នាំ២០០២ ហើយដីនេះជាដីរបស់រដ្ឋ។

សំអាតនិងសុខាគណនាឃើញថា ដើមឈើរបស់គាត់មានតម្លៃ**៣.០០០ដុល្លារ**។ សម្ភារៈសម្រាប់ប្រព័ន្ធប្រឡាយទឹកមានតម្លៃប្រហែល**៣០០ដុល្លារ**។

ពួកគាត់លក់ផ្លែខ្នុរ ផ្លែស្វាយ និងផ្លែចេក បានប្រាក់ប្រហែល**១.៥០០ដុល្លារ** ក្នុងឆ្នាំកន្លងទៅ។ នៅពេលដែលពួកគាត់ត្រូវចាកចេញពីចម្ការនេះ ពួកគាត់ពិតជាមិនអាចរកប្រាក់ចំណូលបានទេ នៅពេលដែលពួកគាត់

មិនអាចទិញដីចម្ការថ្មី និងដាំដំណាំថ្មីឡើងវិញ ឬនៅពេលដែលពួកគាត់មិនទាន់រកមធ្យោបាយថ្មីដើម្បីរកប្រាក់ចំណូល ។

- តើសំអាតនិងសុខាត្រូវទទួលសំណងប៉ុន្មានសម្រាប់ចម្ការដំណាំរបស់គាត់ និងសម្រាប់ការបាត់បង់ប្រាក់ចំណូលរបស់គាត់? ( សូមចាំថា ពួកគាត់គ្មានកម្មសិទ្ធិលើដីនោះទេ) ។
- តើការគាំទ្រប្រភេទអ្វីទៀត ដែលជួយសំអាតនិងសុខា ដើម្បីចាប់ផ្តើមមុខរបររបស់គាត់ឡើងវិញ?
- សូមរៀបចំការសម្តែងតួមួយអំពីរឿងរបស់សំអាតនិងសុខា និងការសន្ទនារបស់គាត់អំពីសំណងជាមួយតំណាងរបស់រដ្ឋាភិបាល ។

# ឯកសារសម្រាប់ផ្នែកទី៣ៈ លំហាត់ទី៦

## រឿងរបស់ឡេង

ឡេងរស់នៅ និងធ្វើការនៅទីក្រុងភ្នំពេញ។ គាត់ធ្វើការនៅផ្ទះសំណាក់មួយ។ គាត់សប្បាយចិត្តនឹងធ្វើការជាមួយទេសចរដែលជាធម្មតាជាភ្ញៀវមកពីបរទេស។ គាត់ទទួលបានប្រាក់ខែ ១០០ ដុល្លារ ក្នុងមួយខែសម្រាប់ធ្វើការនៅផ្ទះសំណាក់នេះ។




ឡេងរស់នៅតាមដងទន្លេមេគង្គ។ យប់មួយគាត់ទៅផ្ទះ ហើយប្រពន្ធគាត់ប្រាប់គាត់ថា មានអាជ្ញាធរមូលដ្ឋានបានមកប្រាប់ថា ពួកគាត់ត្រូវតែរុះរើផ្ទះចេញ ព្រោះរដ្ឋត្រូវការដីដែលពួកគាត់កំពុងរស់នៅនេះ ដើម្បីធ្វើស្ពានមួយតភ្ជាប់ផ្លូវធំ៧ពីរ។ ធនាគារអភិវឌ្ឍន៍អាស៊ីជាអ្នកផ្តល់មូលនិធិគាំទ្រគម្រោងនេះ។ ដោយសារដីនៅតាមដងទន្លេទាំងអស់ជាដីរបស់រដ្ឋ ដូច្នេះពួកគាត់គ្មានសិទ្ធិទទួលសំណងសម្រាប់ដីទេ។ ទោះជាយ៉ាងនេះក្តី ក៏រដ្ឋនឹងផ្តល់ដីនិងផ្ទះមួយខ្នងជូនពួកគាត់ នៅឯតំបន់តាំងទីលំនៅថ្មី ប៉ុន្តែតំបន់នោះនៅឆ្ងាយណាស់។

ឡេងមានក្តីបារម្ភខ្លាំងណាស់ ព្រោះគាត់នឹងមិនអាចមកធ្វើការនៅផ្ទះសំណាក់នោះជារៀងរាល់ថ្ងៃបានទេ។ គាត់ត្រូវចំណាយច្រើនណាស់សម្រាប់ការធ្វើដំណើរទៅមកពីតំបន់តាំងទីលំនៅថ្មី និងរាជធានីភ្នំពេញ។

ឡេង និងប្រពន្ធរបស់គាត់បានទៅជួបអាជ្ញាធរមូលដ្ឋាន។ ចៅសង្កាត់បាននិយាយថា រដ្ឋនឹងជួយរកការងារថ្មីនៅជិតតំបន់តាំងទីលំនៅថ្មីនោះឱ្យពួកគាត់ធ្វើ និងប្រាប់ថារដ្ឋនឹងផ្តល់សំណងខ្លះជូនគាត់រហូតដល់

ពេលគាត់រកការងារថ្មីបានធ្វើ។ ពេលនោះឡេងបានធូរចិត្តបន្តិច ប៉ុន្តែនៅតែមិនសប្បាយចិត្តទេ ព្រោះពួកគាត់ត្រូវផ្លាស់ទៅរស់នៅកន្លែងឆ្ងាយ និងមិនអាចបន្តការងាររបស់គាត់ដែលគាត់ពេញចិត្ត នោះទេ។

- តើឡេង និងប្រពន្ធរបស់គាត់ត្រូវទទួលសំណងប៉ុន្មាន សម្រាប់ការបាត់បង់ប្រាក់ចំណូលរបស់គាត់ ប្រសិនបើពួកគាត់ត្រូវផ្លាស់ប្តូរទៅនៅតំបន់ឆ្ងាយ និងមិនអាចបន្តការងាររបស់គាត់បាន?
- តើអ្នកអាចគិតថា មានវិធីផ្សេងដែលរដ្ឋអាចជួយឡេង ឱ្យរក្សាការងាររបស់គាត់បានទេ?
- រៀបចំការសម្តែងតួមួយអំពីរឿងរបស់ឡេង។

## ៨. ការគាំទ្រការប្រកបរបរចិញ្ចឹមជីវិត

នៅពេលដែលរដ្ឋឱ្យប្រជាពលរដ្ឋផ្លាស់ប្តូរទីលំនៅ ឬនៅពេលដែលពួកគាត់បាត់បង់ឱកាសប្រកបអាជីវកម្ម ធ្វើការងារ ឬបាត់បង់ឱកាសប្រើប្រាស់ប្រភពសម្រាប់ប្រកបរបរចិញ្ចឹមជីវិត ដោយសារគម្រោង ដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី រដ្ឋាភិបាលត្រូវតែផ្តល់ការគាំទ្រដើម្បីឱ្យប្រជាពលរដ្ឋស្តារឡើងវិញនូវកម្រិតប្រាក់ចំណូល និងកម្រិតជីវភាពរស់នៅរបស់ពួកគាត់។ នេះមានន័យថា ប្រជាពលរដ្ឋត្រូវតែមានការគាំទ្រដោយរដ្ឋាភិបាល ដើម្បីធ្វើឱ្យកម្រិតប្រាក់ចំណូល និងកម្រិតជីវភាព រស់នៅរបស់គាត់មានលក្ខណៈដូចមុន ឬប្រសើរជាងមុនពេល ដែលរដ្ឋឱ្យពួកគាត់ផ្លាស់ប្តូរទីលំនៅដោយសារការអនុវត្តគម្រោង។

**ការគាំទ្រការប្រកបរបរចិញ្ចឹមជីវិត** មានន័យថា ជួយប្រជាពលរដ្ឋដើម្បីឱ្យពួកគាត់អាចរកវិធីរកប្រាក់ និងផ្គត់ផ្គង់ខ្លួនឯង និងក្រុមគ្រួសារនូវអ្វីៗដែលពួកគាត់ត្រូវការដើម្បីរស់នៅ ដូចជា ស្បៀង អាហារ ទឹក លំនៅដ្ឋាន ការថែទាំសុខភាព និងការអប់រំជាដើម។ ដើម្បីធ្វើបែបនេះបាន ប្រជាពលរដ្ឋ ត្រូវតែមានឱកាសមានការងារធ្វើ មានដីស្រែចម្ការ ទីផ្សារ ឬមានឱកាសប្រើប្រាស់ធនធានផ្សេងៗទៀត ដែលពួកគាត់ត្រូវការដើម្បីចាប់ផ្តើមអាជីវកម្មខ្នាតតូច។ ពួកគាត់ក៏ត្រូវតែមានឱកាសអភិវឌ្ឍជំនាញ ដែលពួកគាត់ត្រូវការដើម្បីភាពជោគជ័យក្នុងការងារ និងការប្រកបអាជីវកម្ម។

ចំពោះប្រជាពលរដ្ឋដែលងាយរងគ្រោះវិញ ដូចជាប្រជាពលរដ្ឋក្រីក្រជាដើម រដ្ឋាភិបាលត្រូវតែផ្តល់ការគាំទ្រជាពិសេស ដើម្បីឱ្យពួកគាត់អាចរកប្រាក់ចំណូល និងប្រកបរបរចិញ្ចឹមជីវិតបានកាន់តែល្អប្រសើរ។



ការគាំទ្រមុខរបរចិញ្ចឹមជីវិត អាចមានន័យថា ជួយប្រជាពលរដ្ឋឱ្យចាប់ផ្តើម ឬប្រកបអាជីវកម្មរបស់គាត់បានកាន់តែល្អប្រសើរ ដោយជួយបណ្តុះបណ្តាលជំនាញដែលគាត់ត្រូវការ ឬដោយជួយគាត់ឱ្យមានឱកាសប្រើប្រាស់ធនធាននានា។ ឧទាហរណ៍ វាអាចមានន័យថា បើកវគ្គបណ្តុះបណ្តាល បំប៉នជំនាញ បច្ចេកទេសធ្វើស្រែ-ចម្ការ ឬជួយពួកគាត់ឱ្យទិញពូជ ដី ឬគ្រឿងយន្តល្អៗ ជាដើម។ គោលនយោបាយ របស់ធនាគារអភិវឌ្ឍន៍អាស៊ីចែងថា ការគាំទ្រអាចមានដូចជាផ្តល់ **ឱកាសទទួលបានប្រាក់ឥណទាន** ទទួលការបណ្តុះបណ្តាល ឬឱកាសមានការងារធ្វើ។



*ទីនេះ ពួកគាត់កំពុងរៀនដើម្បីក្លាយជាជាងកាត់ដេរ។*

មានឱកាសទទួលបានប្រាក់ឥណទាន មានន័យថា ពួកគាត់អាចខ្ចីប្រាក់បាន។ ប្រជាពលរដ្ឋតែងតែត្រូវការឱកាសទទួលបានប្រាក់ឥណទាន ដើម្បីពួកគាត់អាចជួសជុលកែលម្អផ្ទះរបស់ពួកគាត់ឱ្យកាន់តែល្អ អាចទិញគ្រាប់ពូជសម្រាប់ដាំដំណាំ ឬដើម្បីចាប់ផ្តើមប្រកបអាជីវកម្មខ្នាតតូចជាដើម។ ការធ្វើឱ្យប្រាកដថា ប្រជាពលរដ្ឋមានឱកាសទទួលបានឥណទាន មានន័យថា ពួកគាត់អាចខ្ចីប្រាក់ ដែលពួកគាត់អាចមានលទ្ធភាពលៃលកសងវិញបាននាពេលអនាគត រួមទាំងការប្រាក់ផង។ អត្រាការប្រាក់ត្រូវតែមានកម្រិតទាបល្មម ដើម្បីកុំឱ្យក្រុមគ្រួសារធ្លាក់ខ្លួនកាន់តែក្រទៅៗ ដោយសារការសងប្រាក់វិញនោះ។

ចំពោះប្រជាពលរដ្ឋដែលប្រកបរបរចិញ្ចឹមជីវិតដោយផ្អែកលើការប្រើប្រាស់ដី ដើម្បីធ្វើស្រែចម្ការ ដូចជា កសិករជាដើម វិធីដែលសំខាន់បំផុតសម្រាប់រដ្ឋាភិបាលដើម្បីស្តារការប្រកបមុខរបរចិញ្ចឹមជីវិតរបស់ពួកគាត់ឡើងវិញ គឺត្រូវជួយពួកគាត់ឱ្យមានឱកាសទទួលបានដីបម្រុង (សម្រាប់ធ្វើស្រែចម្ការ)។ ដីបម្រុងដែលប្រគល់ឱ្យពួកគាត់នោះ ត្រូវតែជាដីដែលមានគុណភាពល្អ និងស្ថិតនៅក្នុងទីតាំងសមស្រប។ ឧទាហរណ៍ ប្រសិនបើក្រុមគ្រួសារដែលរងផលប៉ះពាល់ប្រកប

របរចិញ្ចឹមជីវិតដោយធ្វើស្រែ ដូច្នេះរដ្ឋាភិបាលអាចផ្តល់ដីបម្រុងដែលសមស្របសម្រាប់ធ្វើស្រែ ដែលស្ថិតនៅជិតកន្លែងដែលពួកគាត់រស់នៅ ។

## ៩. ការទទួលផលប្រយោជន៍រួមពីគម្រោង

គោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ក៏លើកចិត្តរដ្ឋាភិបាលឱ្យរកវិធីដើម្បីឱ្យប្រជាពលរដ្ឋ ដែលត្រូវផ្លាស់ប្តូរទីលំនៅដោយសារគម្រោងគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ទទួលបានផលប្រយោជន៍ពីគម្រោងនោះដែរ ។

ឧទាហរណ៍ ប្រជាពលរដ្ឋដែលត្រូវផ្លាស់ប្តូរទីលំនៅ អាចមានឱកាសទទួលបានការងារ ដែលបង្កើតឡើងដោយគម្រោងនេះ ។ ប្រសិនបើគម្រោងនេះមានគោលបំណងសង់ ឬជួសជុលកែលម្អប្រព័ន្ធប្រឡាយទឹកស្រោចស្រប់ ដូច្នេះប្រជាពលរដ្ឋដែលត្រូវផ្លាស់ប្តូរទីលំនៅ ត្រូវរើទៅនៅលើដីផ្សេងនៅក្បែរនោះ និងទទួលបានផលប្រយោជន៍ពីប្រព័ន្ធប្រឡាយទឹកថ្មីនោះដែរ ។ ប្រសិនបើមានសង់ទំនប់វារីអគ្គិសនី ប្រជាពលរដ្ឋដែលត្រូវផ្លាស់ប្តូរទីលំនៅដោយសារទំនប់នេះ អាចមានឱកាសប្រើប្រាស់អគ្គិសនីក្នុងតម្លៃទាប នៅឯលំនៅដ្ឋានថ្មីរបស់គាត់ ។



# លំហាត់ទី៧: ការគាំទ្រការប្រកបរបរចិញ្ចឹមជីវិត

**គោលបំណង:** អ្នកចូលរួមនឹងដឹងថា រដ្ឋាភិបាលត្រូវតែផ្តល់ការគាំទ្រដល់ការប្រកបរបរចិញ្ចឹមជីវិត នៅពេលដែលការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋត្រូវទទួលរងផលប៉ះពាល់ដោយគម្រោង ដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី។ ពួកគាត់នឹងយល់ដឹងថា ការគាំទ្រការប្រកបរបរចិញ្ចឹមជីវិតជាអ្វី ព្រមទាំងមានឱកាសគិតថា តើការគាំទ្រប្រភេទណាដែលពួកគាត់យល់ថា មានប្រយោជន៍។ ពួកគាត់ក៏មានឱកាសគិតថា តើមានវិធីណាខ្លះដែលប្រជាពលរដ្ឋផ្លាស់ប្តូរទីលំនៅ ដោយសារគម្រោងអាចទទួលផល ប្រយោជន៍រួមពីគម្រោង។

**សម្ភារ:** ក្តារខៀន ឬក្រដាសផ្ទាំងធំ និងហ្វឺត

**វិធីសាស្ត្រប្រើប្រាស់:** ការពិភាក្សារួមក្នុងថ្នាក់ ការបំផុសគំនិត

| ដំណើរការ | | រយៈពេល (គិតជានាទី) |
|---|---|---|
| ១. | ណែនាំព័ត៌មាននៅក្នុងផ្នែកទី៨និងផ្នែកទី៩ | ២៥ |
| ២. | ការធ្វើផែនការសម្រាប់គាំទ្រការប្រកបរបរចិញ្ចឹមជីវិត | ៣០ |
| ៣. | ការពិភាក្សាអំពីផែនការសម្រាប់គាំទ្រការប្រកបរបរចិញ្ចឹមជីវិត | ១៥ |
| ៤. | ពិភាក្សាអំពីឥណទាន | ១០ |
| ៥. | សង្ខេបអំពីសិទ្ធិទទួលសំណង | ១៥ |
| **សរុប:** | | **៩៥** |

## ការណែនាំសម្រាប់អ្នកសម្របសម្រួល

### ១. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៨ និងទី៩

- សូមចាប់ផ្តើមលំហាត់ដោយសួរអ្នកចូលរួមពីរ-បីនាក់ថា តើពួកគាត់ធ្វើការអ្វី ឬប្រកបមុខរបរអ្វី? តើពួកគាត់ធ្វើអ្វីដើម្បីរកប្រាក់ចិញ្ចឹមគ្រួសារ? រួចសួរថា តើពួកគាត់នឹងអាចបន្តការងារ ឬមុខរបររបស់គាត់ទេ នៅពេលដែលពួកគាត់ត្រូវផ្លាស់មករស់នៅកន្លែងថ្មី។ តើវាមានការលំបាកក្នុងការរកប្រាក់ ដើម្បីទ្រទ្រង់ជីវភាពរស់នៅទេ?

- ក្រោយពីមានអ្នកចូលរួមពីរ-បីនាក់បានចូលរួមឆ្លើយសំណួរខាងលើរួចហើយ សូមចាប់ផ្តើមណែនាំព័ត៌មាននៅក្នុងផ្នែកទី៨ និងទី៩។

**ផ្នែកទី៨ និងទី៩:** វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ថា:

- រដ្ឋាភិបាលត្រូវតែផ្តល់ការគាំទ្រ ដើម្បីឱ្យប្រជាពលរដ្ឋអាចរកប្រាក់ចំណូលសារថ្មី និងការប្រកបរបរចិញ្ចឹមជីវិតកាន់តែល្អប្រសើរ ដែលយ៉ាងហោចណាស់ក៏មិនត្រូវធ្វើឱ្យជីវភាពរបស់ពួកគាត់កាន់តែអន់ជាងមុនឡើយ។
- អ្វីជាការគាំទ្រការប្រកបរបរចិញ្ចឹមជីវិត និងយល់អំពីឧទាហរណ៍ខ្លះៗនៃការគាំទ្រការប្រកបរបរចិញ្ចឹមជីវិត។
- តើឱកាសទទួលបានឥណទានមានន័យដូចម្តេច?
- វិធីយ៉ាងល្អដើម្បីឱ្យប្រជាពលរដ្ឋដែលប្រកបរបរចិញ្ចឹមជីវិតដោយផ្អែកលើការធ្វើស្រែ-ចម្ការ អាចរកប្រាក់ចំណូលសារថ្មីគឺ ត្រូវផ្តល់ជូនពួកគាត់នូវឱកាសប្រើប្រាស់ដីបម្រុងសមស្រប។
- គោលនយោបាយស្តីពីការពារការផ្លាស់ប្តូរទីលំនៅដោយបង្ខំ ក៏បានលើកទឹកចិត្តឱ្យរដ្ឋាភិបាលរកវិធីផ្សេងៗដើម្បីឱ្យប្រជាពលរដ្ឋដែលត្រូវផ្លាស់ប្តូរទីលំនៅដោយសារគម្រោង ដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ីទទួលបានផលប្រយោជន៍ពីគម្រោងនោះដែរ។

### ២. ការធ្វើផែនការសម្រាប់គាំទ្រការប្រកបរបរចិញ្ចឹមជីវិត

- ពន្យល់ថា ឥឡូវនេះអ្នកចូលរួមនឹងមានឱកាសគិតថា តើការគាំទ្រការប្រកបរបរចិញ្ចឹមជីវិតប្រភេទណាដែលពួកគាត់ចង់បាន ដើម្បីឱ្យពួកគាត់អាចបង្កើនប្រាក់ចំណូល និងលើកកម្ពស់ កម្រិតជីវភាពរស់នៅរបស់ពួកគាត់។

- អ្នកចូលរួមគប្បីត្រូវពិភាក្សាគ្នាជាក្រុមដែលមានសមាជិកបីនាក់ ដោយសមាជិកម្នាក់ៗនៅក្នុងក្រុមត្រូវចូលរួមចែករំលែកគំនិតគ្នាអំពីការគាំទ្រការប្រកបរបរចិញ្ចឹមជីវិត។ ប្រសិនបើពួកគាត់មិនអាចនឹកឃើញគំនិតណាមួយអំពីការគាំទ្រនេះទេ ពួកគាត់អាចពន្យល់អំពីអ្វី ដែលពួកគាត់កំពុងធ្វើដើម្បីរកប្រាក់ទ្រទ្រង់

ជីវភាព រីឯសមាជិកផ្សេងទៀតអាចជួយគាត់ នឹករកគំនិតសម្រាប់ការគាំទ្រនោះ។ ក្រុមអាចនឹងរៀបចំគំនិតទាំងអស់នោះទៅជាគំនិតតែមួយ និងធ្វើផែនការសម្រាប់ក្រុមទាំងមូល ឬសមាជិកម្នាក់ៗអាចធ្វើផែនការមួយផ្ទាល់ខ្លួន។ សមាជិកក្នុងក្រុមត្រូវតែមកពីសហគមន៍ដូចគ្នាប្រសិនបើមាន។

- ក្រុមអាចនឹកគិតអំពីផែនការមួយ ដើម្បីធ្វើឱ្យកាន់តែប្រសើរនូវអ្វីដែលពួកគាត់កំពុងប្រកបរបរចិញ្ចឹមជីវិត ឬអាចនឹកគិតអំពីផែនការមួយសម្រាប់ធ្វើអាជីវកម្មថ្មី (ការប្រកបមុខរបរ ថ្មី)។

- ឧទាហរណ៍ ក្រុមមួយអាចសម្រេចចិត្តថា ពួកគាត់ចង់បានការគាំទ្រមួយសម្រាប់ចាប់ផ្តើមមុខរបរជាជាងកាត់ដេរខោអាវ។ ដូច្នេះក្រុមនេះអាចធ្វើផែនការមួយដែលបង្ហាញថា ពួកគាត់ត្រូវការរៀនជំនាញកាត់ដេរ និងត្រូវការប្រាក់កម្ចី (ត្រូវការខ្ចីប្រាក់) មួយចំនួន ដើម្បីទិញម៉ាស៊ីនដេរ និងសម្ភារៈផ្សេងទៀត។ ចំណែកឯក្រុមមួយទៀត អាចនឹកឃើញអំពីគម្រោងចិញ្ចឹមមាន់ ព្រមទាំងគិតអំពីការគាំទ្រគ្រប់បែបយ៉ាងដែលពួកគាត់ត្រូវការដើម្បីចិញ្ចឹមមាន់។

- លើកទឹកចិត្តពួកគាត់ឱ្យគូរ ឬសរសេរអ្វីដែលជាក់លាក់។ ឧទាហរណ៍ ជាជាងគ្រាន់តែនិយាយថា ពួកគាត់ចង់ទទួលបានការបណ្តុះបណ្តាល អ្នកត្រូវស្នើពួកគាត់ឱ្យគិតថា តើជំនាញ ឬព័ត៌មានអ្វីដែលពួកគាត់ចង់រៀន ឬចង់បានដើម្បីជួយដល់ពួកគាត់។ ជាជាងគ្រាន់តែថា ពួកគាត់ចង់មានឱកាសទទួលបានឥណទាន (ខ្ចីប្រាក់) អ្នកត្រូវស្នើពួកគាត់ឱ្យគិតថា តើគាត់យកប្រាក់ដែលខ្ចីនោះទៅធ្វើអ្វី និងគិតថា តើធ្វើយ៉ាងម៉េចដើម្បីឱ្យប្រាកដថាពួកគាត់អាចសងប្រាក់នោះវិញ។

- ផ្តល់រយៈពេល២០នាទីសម្រាប់ក្រុមនីមួយៗដើម្បីធ្វើលំហាត់នេះ។

## ៣. ការពិភាក្សាអំពីផែនការសម្រាប់គាំទ្រការប្រកបរបរចិញ្ចឹមជីវិត

- នៅពេលដែលក្រុមទាំងអស់បានចំណាយពេលល្មមក្នុងការធ្វើផែនការហើយ សូមអញ្ជើញ អ្នកចូលរួមពីរ-បីនាក់ ដើម្បីឡើងមកពន្យល់អ្នកចូលរួមផ្សេងទៀតអំពីគំនិតរបស់ពួកគាត់។ ពួកគាត់គប្បីពន្យល់អំពីប្រភេទនៃការគាំទ្រអ្វីដែលពួកគាត់ចង់បាន និងតើការគាំទ្រនោះជួយពួកគាត់ឱ្យធ្វើអ្វី។

- សួរអ្នកចូលរួមផ្សេងទៀត តើពួកគាត់មានយោបល់ ឬមានគំនិតអ្វីដើម្បីចូលរួមចែករំលែកដល់ក្រុមនោះដើម្បីជួយដល់ពួកគាត់ក្នុងការរៀបចំផែនការឱ្យកាន់តែល្អជាងនេះ។

- សូមប្រាប់អ្នកចូលរួមថា ប្រសិនបើពួកគាត់រៀបចំផែនការមួយបានល្អច្បាស់លាស់ អំពីការគាំទ្រការប្រកបរបរចិញ្ចឹមជីវិតដែលពួកគាត់ចង់បាន ដូច្នេះពួកគាត់អាចដាក់ផែនការទាំងនោះជូនរដ្ឋាភិបាល និងអង្គការទទួលបន្ទុកផ្នែកផ្តល់ការគាំទ្រការប្រកបរបរចិញ្ចឹមជីវិត។

## ៤. ការពិភាក្សាអំពីឥណទាន

- សួរអ្នកចូលរួមមើលថា តើក្នុងចំណោមពួកគាត់មានអ្នកណាធ្លាប់ខ្ចីប្រាក់ទេពីមុន និងត្រូវសងប្រាក់គេវិញក្នុងអត្រាការប្រាក់ខ្ពស់ទេ?
- តើពួកគាត់មានបញ្ហាក្នុងការសងប្រាក់គេវិញទេ? តើវានឹងមានបញ្ហាអ្វីកើតឡើង ប្រសិនបើពួកគាត់មិនអាចមានលទ្ធភាពសងប្រាក់គេវិញ? តើពួកគាត់ធ្លាប់ឮអំពីរឿង ដែលប្រជាពលរដ្ឋខ្ចីប្រាក់គេ ហើយមិនអាចមានលទ្ធភាពសងគេវិញទេ?
- បង្ហាញពួកគាត់ថា ថ្វីបើការមានឱកាសទទួលបានឥណទានអាចមានប្រយោជន៍ ក្នុងការចាប់ផ្តើមប្រកបអាជីវកម្ម ឬធ្វើឱ្យអាជីវកម្មកាន់តែល្អប្រសើរក៏ដោយ ក៏វារឿងសំខាន់ដែលពួកគាត់ត្រូវតែមានការប្រយ័ត្នប្រយែងក្នុងការខ្ចីប្រាក់ដែរ។ វាជាការសំខាន់ ដែលត្រូវប្រាកដថា អ្នកមិនខ្ចីប្រាក់ច្រើនពេកទេ ព្រមទាំងត្រូវប្រាកដថា អ្នកអាចមានលទ្ធភាពសងប្រាក់នោះវិញ រួមទាំងការប្រាក់ផង។ វាក៏ជារឿងសំខាន់ដែរ ដែលពួកគាត់ត្រូវដឹងថា ប្រសិនបើពួកគាត់មិនអាចមានលទ្ធភាពសងប្រាក់កម្ចីនោះវិញទេ តើនឹងមានអ្វីកើតឡើងចំពោះពួកគាត់។
- ពួកគាត់ក៏ត្រូវតែគិតរកគំនិតផ្សេងៗដែរ ដូចជា ក្រុមសន្សំប្រាក់នៅសហគមន៍ជាជាងការខ្ចីប្រាក់ពីអ្នកនៅក្រៅសហគមន៍។

## ៥. សង្ខេបអំពីសិទ្ធិទទួលសំណង

- អ្នកអាចប្រើឱកាសនេះដើម្បីសង្ខេបព័ត៌មានទាំងអស់អំពីសិទ្ធិទទួលសំណង ទៅតាមគោលនយោបាយការពារស្តីពីការតាំងទីលំនៅដោយបង្ខំរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។
- តើអ្នកចូលរួមគិតដូចម្តេច អំពីសិទ្ធិទទួលសំណងទៅតាមគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី? តើពួកគាត់គិតថា គោលនយោបាយនេះយុត្តិធម៌ទេ?
- តើពួកគាត់គិតថា រដ្ឋាភិបាលគោរពគោលនយោបាយនោះទេ?
- តើពួកគាត់អាចព្យាយាមធ្វើដូចម្តេច ដើម្បីធ្វើឱ្យប្រាកដថា រដ្ឋាភិបាលគោរពគោលនយោបាយនេះ ព្រមទាំងផ្តល់ជូនពួកគាត់នូវសំណង ការតាំងទីលំនៅថ្មី និងការគាំទ្រ ដែលពួកគាត់មានសិទ្ធិទទួលបាន?

- ពន្យល់ថា រហូតមកដល់ពេលនេះ ពួកគាត់បានដឹងថា គោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីមានចែងអ្វីខ្លះអំពីសិទ្ធិទទួលសំណងរបស់ប្រជាពលរដ្ឋ ដូច្នេះពួកគាត់អាចឃ្លាំមើលអ្វីដែលរដ្ឋាភិបាលកំពុងធ្វើ ព្រមទាំងផ្ទៀងផ្ទាត់ថា តើការអនុវត្តនោះត្រឹមត្រូវទេ។
- ពន្យល់ថា នៅក្នុងពីរ-បីមេរៀនបន្តបន្ទាប់ទៀតនេះ ពួកគាត់នឹងពិភាក្សាថា តើរដ្ឋាភិបាលត្រូវផ្តល់ព័ត៌មានអ្វីខ្លះជូនប្រជាពលរដ្ឋ អំពីគម្រោងផលប៉ះពាល់ សំណង និងការតាំងទីលំនៅថ្មី។ ពួកគាត់ក៏នឹងពិភាក្សាគ្នាដែរអំពីរបៀប ដែលពួកគាត់ត្រូវចូលរួមផ្តល់យោបល់ និងសម្តែងមតិអំពីក្តីកង្វល់របស់ពួកគាត់ទាក់ទងនឹងបញ្ហាទាំងអស់នេះ។

# ព័ត៌មាន និង ការពិគ្រោះយោបល់

**លទ្ធផលទទួលបាន:**

ក្រោយពីបញ្ចប់ជំពូកនេះ អ្នកចូលរួមនឹង:

១. ដឹងថា រដ្ឋាភិបាលត្រូវតែផ្តល់ព័តិមាន និងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ។

២. ដឹងថា តើព័តិមានអ្វីខ្លះដែលត្រូវប្រកាសផ្សាយ ឬដាក់ឱ្យមើលជាសាធារណៈដោយរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ី ។

៣. យល់ដឹងថា ប្រជាពលរដ្ឋដែលប្រឈមនឹងផលប៉ះពាល់ត្រូវតែមានឱកាស ឬមានសិទ្ធិទទួល ព័តិមាន ។

៤. ដឹងថា តើព័តិមានទាក់ទងនឹងផែនការតាំងទីលំនៅថ្មីអ្វីខ្លះ ដែលពួកគាត់ត្រូវពិនិត្យ ។

៥. យល់ដឹងថា តើពួកគាត់ត្រូវចូលរួមពិគ្រោះយោបល់សំខាន់ៗអ្វីខ្លះ ។

៦. ដឹងថា តើត្រូវពិគ្រោះយោបល់ជាមួយអ្នកណាខ្លះ ។

៧. ដឹងថា តើរដ្ឋាភិបាលត្រូវពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅពេលណា?

## ១. ភារកិច្ចរបស់រដ្ឋាភិបាលក្នុងការផ្តល់ព័ត៌មាន និងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ

ប្រជាពលរដ្ឋដែលត្រូវរដ្ឋាភិបាលផ្លាស់ប្តូរទីលំនៅ ដោយសារគម្រោងដែលផ្តល់មូលនិធិគាំទ្រ ដោយធនាគារអភិវឌ្ឍន៍អាស៊ី មានសិទ្ធិទទួលព័តិមានអំពីគម្រោងនោះ ។ តើពួកគាត់ត្រូវប្រឈមផលប៉ះពាល់កម្រិតណា មានសិទ្ធិទទួលសំណង និងជម្រើសអ្វីខ្លះ ។ គោលនយោបាយការពារ ស្តីពីការតាំងទីលំនៅថ្មីដោយបង្ខំចែងថា រដ្ឋត្រូវតែជូនដំណឹងប្រជាពលរដ្ឋអំពីបញ្ហាទាំងអស់នេះ ព្រមទាំងត្រូវតែប្រាកដថា មានព័តិមាន និងឯកសារសំខាន់ៗទាំងនេះជូនប្រជាពលរដ្ឋ ។

គោលនយោបាយនេះក៏បានចែងដែរថា រដ្ឋាភិបាលត្រូវតែផ្តល់ *ជម្រើសជូន* ប្រជាពលរដ្ឋដែលត្រូវផ្លាស់ប្តូរទីលំនៅ ព្រមទាំងត្រូវ*ពិគ្រោះយោបល់ជាមួយ*ពួកគាត់ អំពីការជ្រើសរើសសម្រាប់ការតាំងទីលំនៅថ្មី និងសំណង ។

នេះមានន័យថា ប្រជាពលរដ្ឋមានសិទ្ធិធ្វើការជ្រើសរើសយ៉ាងគ្រប់គ្រាន់អំពីការគាំទ្រ និងជំនួយ ដែលនឹងជួយពួកគាត់ក្នុងការបន្ត ឬបង្កើនរបរចិញ្ចឹមជីវិត និងកម្រិតជីវភាពរស់នៅរបស់ពួកគាត់ ។

## ការទទួលព័ត៌មាន និងការចូលរួមយ៉ាងសកម្មក្នុងការពិគ្រោះយោបល់

អ្នកមានសិទ្ធិទទួលព័ត៌មាន និងមានសិទ្ធិពិគ្រោះយោបល់ អំពីកម្រិតដែលអ្នកនឹងត្រូវប្រឈមផលប៉ះពាល់ដោយសារគម្រោងណាមួយ អំពីសិទ្ធិទទួលសំណង និងជម្រើសផ្សេងៗ។ រដ្ឋាភិបាលត្រូវតែជូនដំណឹង និងពិគ្រោះយោបល់ជាមួយអ្នក។

វាមានសារៈសំខាន់ណាស់ដែលអ្នកត្រូវទាមទារសិទ្ធិទទួលព័ត៌មាន ដើម្បីលោកអ្នកនឹងបានយល់ដឹងអំពីសិទ្ធិទទួលសំណង និងជម្រើសផ្សេងៗ។ វាក៏មានសារៈសំខាន់ណាស់ដែរ ដែលអ្នកត្រូវចូលរួមយ៉ាងសកម្មក្នុងការពិគ្រោះយោបល់ អំពីជម្រើសសម្រាប់ការតាំងទីលំនៅថ្មី និងសំណង។

ការធ្វើបែបនេះនឹងជួយអ្នកឱ្យទទួលបាននូវការគាំទ្រ និងជំនួយដែលអ្នកត្រូវការដើម្បីបង្កើន ឬយ៉ាងណាស់ក៏អាចបន្ត របរចិញ្ចឹមជីវិត និងកម្រិតជីវភាពរស់នៅ ដើម្បីកុំឱ្យអ្នកប្រឈមគ្រោះថ្នាក់ ឬការខាតបង់ដោយសារការផ្លាស់ប្តូរទីលំនៅ។



វាជាការរំលោភគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ប្រសិនបើរដ្ឋាភិបាលមិនបានរៀបចំ ព័ត៌មានជាក់លាក់អំពីបញ្ហានេះសម្រាប់ប្រជាពលរដ្ឋទេ ឬប្រសិនបើរដ្ឋាភិបាលមិនបានពិគ្រោះយោបល់ត្រឹមត្រូវជាមួយពួកគាត់ទេ។ អ្វីដែលអ្នកអាចធ្វើបានដើម្បីឱ្យរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ីមានការទទួលខុសត្រូវនៅពេលមិនគោរពគោលនយោបាយនេះ នឹងត្រូវលើកមកពិភាក្សានៅក្នុងផ្នែកក្រោយ។

## ២. តើព័ត៌មានអ្វីខ្លះដែលចាំបាច់ត្រូវតែមានសម្រាប់ប្រជាពលរដ្ឋ?

រដ្ឋាភិបាលត្រូវតែប្រាកដថា ប្រជាពលរដ្ឋដែលរដ្ឋាភិបាលឱ្យផ្លាស់ប្តូរទីលំនៅដោយសារគម្រោង ដឹងថាពួកគាត់នឹងប្រឈមផលប៉ះពាល់។ ពួកគាត់ត្រូវតែទទួលបានព័ត៌មានគ្រប់គ្រាន់អំពីសំណង និងការតាំងទីលំនៅថ្មី ព្រមទាំងយល់ដឹងថា តើពួកគាត់មានសិទ្ធិ និងមានជម្រើសអ្វីខ្លះក្នុងការទទួលសំណង និងការតាំងទីលំនៅថ្មី។

រដ្ឋាភិបាលត្រូវតែរៀបចំ **ផែនការតាំងទីលំនៅថ្មី** សម្រាប់គម្រោងណាមួយដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី និងដែលបណ្តាលឱ្យមានការផ្លាស់ប្តូរទីលំនៅ។ **គណៈកម្មាធិការអន្តរ ក្រសួងទទួលបន្ទុកការតាំងទីលំនៅថ្មី** មានការទទួលខុសត្រូវក្នុងការរៀបចំ និងអនុវត្តផែនការតាំងទីលំនៅថ្មី សម្រាប់បណ្តាគម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ីនៅកម្ពុជា។ គោលបំណងរបស់ផែនការតាំងទីលំនៅថ្មីគឺ ដើម្បីពន្យល់លម្អិត ថាតើរដ្ឋាភិបាលត្រូវធ្វើយ៉ាងណា ដើម្បីឱ្យប្រាកដថា ប្រជាពលរដ្ឋដែលត្រូវផ្លាស់ប្តូរទីលំនៅដោយសារការអនុវត្តគម្រោង នឹងទទួលបាននូវអ្វី ដែលពួកគាត់មានសិទ្ធិទៅតាមគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។




គណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុកការតាំងទីលំនៅថ្មី ត្រូវតែមានផែនការតាំងទីលំនៅថ្មីសម្រាប់សាធារណជន ជាពិសេសសម្រាប់ប្រជាពលរដ្ឋដែលប្រឈមផលប៉ះពាល់ដោយសារគម្រោង គឺត្រូវតែមានផែនការតាំងទីលំនៅថ្មីទាំងផែនការព្រាង និងផែនការស្ថាពរដើម្បីឱ្យពួកគាត់ស្វែងយល់។ ភាពខុសគ្នារវាងផែនការព្រាង និងស្ថាពរនៃការតាំងទីលំនៅថ្មីត្រូវលើកមកពិភាក្សានៅក្នុងផ្នែក៦។

ផែនការតាំងទីលំនៅថ្មីមានព័ត៌មានសំខាន់ណាស់ ហេតុដូច្នេះវាមានសារៈសំខាន់ ដែលសហគមន៍ទាំងឡាយដែលត្រូវប្រឈមផលប៉ះពាល់ដោយសារគម្រោងត្រូវយល់ថា តើផែនការនោះនិយាយអំពីអ្វី។ គណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុកការតាំងទីលំនៅថ្មី មានកាតព្វកិច្ចត្រូវធ្វើឱ្យប្រាកដថា ប្រជាពលរដ្ឋដែលប្រឈមផលប៉ះពាល់ដោយសារគម្រោងនឹងទទួលបានព័ត៌មានគ្រប់គ្រាន់ ថាតើផែនការតាំងទីលំនៅថ្មីមានចែងអំពីអ្វីខ្លះ។ ប្រសិនបើគណៈកម្មាធិការនេះ

មិនបានផ្ដល់ផែនការតាំងទីលំនៅថ្មីជូនអ្នកទេ និង មិនបានពន្យល់អំពីខ្លឹមសារនៃផែនការនេះទេ នោះអ្នកមានសិទ្ធិទាមទារឱ្យគណៈកម្មាធិការនេះផ្ដល់ជូនអ្នក និងពន្យល់អំពីផែនការនោះ ។

| តើនៅក្នុងផែនការតាំងទីលំនៅថ្មីមានព័ត៌មានអ្វីខ្លះ? |
|---|
| ផែនការតាំងទីលំនៅថ្មីមានព័តិមានសំខាន់ៗអំពីៈ<br>• គម្រោង,<br>• ដីដែលរដ្ឋត្រូវការសម្រាប់គម្រោង រួមទាំងផែនទីផង,<br>• ផលប៉ះពាល់ដែលបណ្ដាលមកពីការផ្លាស់ប្ដូរទីលំនៅ,<br>• អ្នកណានឹងត្រូវផ្លាស់ប្ដូរទីលំនៅដោយសារគម្រោងនេះ និងតើមានប៉ះពាល់អ្វីដល់ជីវភាពរបស់គាត់,<br>• របៀបដែលរដ្ឋាភិបាលត្រូវធ្វើឱ្យប្រាកដថា ប្រជាពលរដ្ឋទទួលបានព័តិមានគ្រប់គ្រាន់ និងមានការពិគ្រោះយោបល់,<br>• តើប្រជាពលរដ្ឋដែលប្រឈមការផ្លាស់ប្ដូរទីលំនៅមានសិទ្ធិទទួលបានអ្វីខ្លះ,<br>• ជម្រើសផ្សេងៗសម្រាប់ការផ្លាស់ទៅទីតាំងថ្មី និងតំបន់តាំងទីលំនៅថ្មី<br>• កម្មវិធីគាំទ្រ និងផ្ដល់ជំនួយដល់របរចិញ្ចឹមជីវិត ។<br><br>ត្រូវមានព័តិមានទាំងអស់នេះសម្រាប់សាធារណជន ជាពិសេសប្រជាពលរដ្ឋដែលប្រឈម ផលប៉ះពាល់ដោយសារគម្រោង ។ |

គណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុកការតាំងទីលំនៅថ្មី ក៏ត្រូវមានកាតព្វកិច្ចរាយការណ៍ជូនធនាគារអភិវឌ្ឍន៍អាស៊ី អំពីការអនុវត្តផែនការតាំងទីលំនៅថ្មី ព្រមទាំងត្រូវតែមានរបាយការណ៍នេះ ទុកជូនសាធារណជនមើល ។

## ៣. ព័ត៌មានត្រូវតែមានលក្ខណៈងាយយល់

ផែនការតាំងទីលំនៅថ្មីអាចជាឯកសារមួយស្មុគស្មាញ និងពិតជាលំបាកអាននិងយល់ ។ ប្រជាពលរដ្ឋជាច្រើនដែលប្រឈមផលប៉ះពាល់ ដោយសារគម្រោងដែលផ្ដល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី មិនអាចយល់ថាតើផែនការតាំងទីលំនៅថ្មីនិយាយពីអ្វីទេ និងមិនអាចយល់ថា តើវាប៉ះពាល់ដល់ពួកគាត់ក្នុងកម្រិតណានោះទេ ។

គណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុកការតាំងទីលំនៅថ្មី មានកាតព្វកិច្ចត្រូវរៀបចំព័តិមាននៅក្នុងផែនការតាំងទីលំនៅថ្មី ឱ្យមានលក្ខណៈងាយយល់សម្រាប់ប្រជាពលរដ្ឋ ដែលត្រូវប្រឈមផលប៉ះពាល់ដោយសារគម្រោង ។ នេះមានន័យថា ត្រូវពន្យល់ខ្លឹមសារព័តិមាននេះទៅតាមវិធីដែលប្រជាពលរដ្ឋអាចយល់ និងដោយប្រើភាសា ឬពាក្យពេចន៍ដែលពួកគាត់និយាយ ឬប្រើប្រាស់ប្រចាំថ្ងៃ ។

ជាធម្មតាគ្រាន់តែចែកផែនការតាំងទីលំនៅថ្មីជូនប្រជាពលរដ្ឋមិនគ្រប់គ្រាន់ទេ ជាពិសេសសម្រាប់ប្រជាពលរដ្ឋដែលមិនចេះអានអក្សរ។ គណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុកការតាំងទីលំនៅថ្មី ត្រូវតែប្រាកដថាប្រជាពលរដ្ឋយល់ខ្លឹមសារនៃផែនការនេះ ដោយរៀបចំព្រឹត្តិការណ៍ផ្សេងៗ ដូចជា ប្រជុំប្រជាពលរដ្ឋដើម្បីពន្យល់ និងពិភាក្សាអំពីផែនការនេះ ដោយប្រើរូបគំនូរ រូបថត វីឌីអូជាដើម ឬរៀបចំដំណើរទស្សនកិច្ចទៅមើលតំបន់តាំងទីលំនៅថ្មីសំខាន់ៗ។

ប្រសិនបើមានប្រជាពលរដ្ឋ ឬក្រុមដែលនិយាយភាសាផ្សេងគ្នា ដូចជា ក្រុមជនជាតិដើមភាគតិច ជាដើម ដូច្នេះរដ្ឋាភិបាលត្រូវតែប្រាកដថា ភាសានិងទម្រង់ដែលប្រើដើម្បីពន្យល់អំពីព័ត៌មានត្រូវតែសមស្របសម្រាប់ពួកគាត់ ឬ ត្រូវតែមានលក្ខណៈដែលពួកគាត់អាចយល់។



## ៤. ការពិនិត្យព័ត៌មាននៅក្នុងផែនការតាំងទីលំនៅថ្មី

វាមានសារៈសំខាន់ណាស់ដែលត្រូវពិនិត្យថា អ្នកសប្បាយចិត្តនឹងព័ត៌មាននៅក្នុងផែនការតាំងទីលំនៅថ្មី។ វាក៏មានសារៈសំខាន់ណាស់ដែរ ដែលត្រូវពិនិត្យថា ផែនការតាំងទីលំនៅថ្មីនេះគោរពតាមគោលនយោបាយស្តីពីការតាំងទីលំនៅថ្មីដោយបង្ខំ។

នេះមានន័យថា អ្នកគប្បីត្រូវរកឱ្យឃើញថា តើអ្នកត្រូវបានរដ្ឋកំណត់ជាអ្នកដែលត្រូវផ្លាស់ប្តូរទីលំនៅដោយសារគម្រោង និងត្រូវបានបញ្ចូលទៅក្នុងផែនការតាំងទីលំនៅថ្មីសម្រាប់គម្រោងនោះដែរឬទេ។

អ្នកក៏ត្រូវតែពិនិត្យថា សិទ្ធិទទួលសំណងដែលអ្នកនឹងត្រូវទទួលនៅក្នុងផែនការតាំងទីលំនៅថ្មីបំពេញតាមបទដ្ឋាននៃគោលនយោបាយនេះ។

| តើអ្នកគប្បីត្រូវពិនិត្យព័ត៌មានអ្វីខ្លះនៅក្នុងផែនការតាំងទីលំនៅថ្មី? |
| --- |
| វាមានសារៈសំខាន់ណាស់ដែលត្រូវពិនិត្យព័ត៌មាននៅក្នុងផែនការតាំងទីលំនៅថ្មី ដូចខាងក្រោម នេះ<br>• ពិនិត្យថាអ្នកនឹងទទួលបានសំណងគ្រប់គ្រាន់ដើម្បីអ្នកអាចជំនួសមកវិញទាំងស្រុងនូវអ្វីៗដែលអ្នកនឹងបាត់បង់ ។<br>• ពិនិត្យថា ប្រសិនបើអ្នកត្រូវផ្លាស់ទៅតាំងទីលំនៅថ្មី អ្នកពេញចិត្តនឹងទីតាំងនៃតំបន់តាំងទីលំនៅថ្មី ដែលមានបង្ហាញនៅក្នុងផែនការតាំងទីលំនៅថ្មីនោះ ។<br>• ពិនិត្យថា ប្រសិនបើអ្នកត្រូវផ្លាស់ទៅតាំងទីលំនៅថ្មី អ្នកនឹងមានសុវត្ថិភាពនៃការកាប់ដីធ្លីនៅតំបន់តាំងទីលំនៅថ្មីនោះ ។<br>• ពិនិត្យថា លំនៅដ្ឋាន និងសេវាកម្មមូលដ្ឋាននានាដែលត្រូវផ្តល់ជូន និងផ្គត់ផ្គង់នៅតំបន់តាំងទីលំនៅថ្មីមានលក្ខណៈសមរម្យ ។<br>• ពិនិត្យថា អ្នកសប្បាយចិត្តនឹងការគាំទ្របរចិញ្ចឹមជីវិតដែលរដ្ឋគាំទ្រនោះ ព្រមទាំងពិនិត្យថា អ្នកពេញចិត្តព្រោះការផ្លាស់ប្តូរទីលំនៅនេះមិនធ្វើឱ្យអ្នកធ្លាក់ខ្លួនក្រជាងមុនទេ ។ |

ប្រសិនបើ អ្នកមានកង្វល់អំពីព័ត៌មានណាមួយនៅក្នុងផែនការតាំងទីលំនៅថ្មីនេះ អ្នកគប្បីត្រូវលើកឡើងនូវក្តីកង្វល់នោះទៅគណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុកការតាំងទីលំនៅថ្មីឱ្យបានកាន់តែឆាប់កាន់តែល្អ ។ កិច្ចការផ្សេងៗទៀត ដែលអ្នកអាចធ្វើបានទាក់ទងនឹងក្តីកង្វល់អំពីផែនការតាំងទី លំនៅថ្មីនឹងត្រូវលើកមកពិភាក្សានៅក្នុងផ្នែកក្រោយ ។



# លំហាត់ទី៨: ការរៀបចំព័ត៌មានដែលប្រជាពលរដ្ឋងាយយល់

**គោលបំណង: អ្នកចូលរួមនឹងដឹងថា គោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីមានលក្ខខណ្ឌតម្រូវឱ្យរដ្ឋាភិបាលផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ និងពិគ្រោះយោបល់ជាមួយពួកគាត់ អំពីសិទ្ធិរបស់ពួកគាត់ក្នុងការទទួលសំណង និងការតាំងទីលំនៅ ដោយវិធីដែលពួកគាត់អាចយល់។ អ្នកចូលរួមនឹងដឹងថា តើផែនការតាំងទីលំនៅថ្មីជាអ្វី ព្រមទាំងដឹងថា តើពួកគាត់ត្រូវពិនិត្យមើលព័ត៌មានអ្វីខ្លះនៅក្នុងផែនការតាំងទីលំនៅនោះ។**

**សម្ភារ:** ក្ដារខៀន ឬក្រដាសផ្ទាំងធំ ហ្វឺត និង (ប្រសិនបើមាន) ផែនការតាំងទីលំនៅថ្មី សម្រាប់គម្រោង ដែលអ្នកចូលរួមប្រឈមផលប៉ះពាល់។

**វិធីសាស្ត្រប្រើប្រាស់:** ការពិភាក្សាក្រុមធំ ការបំផុសគំនិត

| ដំណើរការ | | រយៈពេល (គិតជានាទី) |
|---|---|---|
| ១. | ការពិភាក្សាខ្លីអំពីព័ត៌មាន និងការពិគ្រោះយោបល់ | ១០ |
| ២. | ណែនាំព័ត៌មាននៅក្នុងផ្នែក១ | ១៥ |
| ៣. | ការបំផុសគំនិតអំពីព័ត៌មានគម្រោង | ១០ |
| ៤. | ណែនាំព័ត៌មានផ្នែក២ | ១៥ |
| ៥. | ផ្សព្វផ្សាយផែនការតាំងទីលំនៅ (ប្រសិនបើអាច) | ៥ |
| ៦. | ណែនាំព័ត៌មាននៅក្នុងផ្នែក៣ | ១០ |
| ៧. | ការបំផុសគំនិត និងការពិភាក្សាអំពីព័ត៌មានដែលមានលក្ខណៈងាយយល់ | ២០ |
| ៨. | ណែនាំព័ត៌មាននៅក្នុងផ្នែក៤ | ១៥ |
| ៩. | សង្ខេប | ១០ |
| **សរុប:** | | **១១០** |

## ការណែនាំសម្រាប់អ្នកសម្របសម្រួល

### ១. ការពិភាក្សាខ្លីអំពីព័ត៌មាន និងការពិគ្រោះយោបល់

- ចាប់ផ្ដើមលំហាត់ដោយសួរអ្នកចូលរួមមើល ថាតើពួកគាត់បានទទួលព័ត៌មានអំពីគម្រោង ដែលធ្វើឱ្យប៉ះពាល់ពួកគាត់ អំពីសិទ្ធិទទួលសំណង និងផែនការតាំងទីលំនៅថ្មីទេ? ប្រសិនបើពួកគាត់ធ្លាប់ទទួលបាន សួរគាត់ថា តើព័ត៌មានអំពីអ្វីដែលពួកបានទទួល និងអ្នកណាជាអ្នកផ្ដល់ព័ត៌មានជូនពួកគាត់។

- បន្ទាប់មកទៀត សួរអ្នកចូលរួមមើលតើ ពួកគាត់ធ្លាប់មានតំណាងរដ្ឋាភិបាលចុះទៅសួរ ព័ត៌មានអំពីស្ថានភាពរបស់ពួកគាត់ទេ។ តើពួកគាត់ធ្លាប់មានតំណាងរដ្ឋាភិបាលចុះទៅសួរនាំអំពី យោបល់ ឬគំនិតរបស់ពួកគាត់ទាក់ទងនឹងគម្រោង ឬធ្លាប់សួរថា តើគម្រោងនោះប៉ះពាល់ពួកគាត់យ៉ាងម៉េចទេ? តើតំណាងរដ្ឋាភិបាលធ្លាប់ផ្ដល់ឱកាសឱ្យពួកគាត់ជ្រើស រើសសំណង ឬការតាំងទីលំនៅថ្មីទេ និងធ្លាប់សួរអំពីការជ្រើសរើស ឬទស្សនៈរបស់ពួកគាត់ទេ?

- ពីរ-បីនាទីក្រោយពីបានការពិភាក្សា សូមណែនាំព័ត៌មានក្នុងផ្នែក១។

### ២. ណែនាំព័ត៌មាននៅក្នុងផ្នែក១

**ផ្នែក១:** វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ដឹងថា:

- គោលនយោបាយការពារស្ដីពីការតាំងទីលំនៅដោយបង្ខំចែងថា រដ្ឋាភិបាលត្រូវតែផ្ដល់ព័ត៌មានជូនប្រជាពលរដ្ឋ និងពិគ្រោះយោបល់ជាមួយពួកគាត់អំពីគម្រោង អំពីកម្រិតនៃផលប៉ះពាល់ និងអំពីសិទ្ធិទទួលសំណង ព្រមទាំងអំពីជម្រើសនានា។
- ប្រជាពលរដ្ឋមានសិទ្ធិធ្វើការជ្រើសរើសយ៉ាងច្បាស់លាស់អំពីការគាំទ្រ និងជំនួយដែលនឹងជួយពួកគាត់ឱ្យបន្ត ឬបង្កើនរបរចិញ្ចឹមជីវិត និងជីវភាពរស់ឱ្យកាន់តែប្រសើរ។

### ៣. ការបំផុសគំនិតអំពីព័ត៌មានគម្រោង

- សួរអ្នកចូលរួមថា តើព័ត៌មានអ្វីខ្លះដែលពួកគាត់ចង់ដឹងអំពីគម្រោងនោះ និងអំពីផលប៉ះពាល់លើពួកគាត់។ តើពួកគាត់មានសំណួរអ្វីខ្លះចង់សួររដ្ឋាភិបាល ឬធនាគារអភិវឌ្ឍន៍អាស៊ី អំពីកម្រិតនៃផលប៉ះពាល់លើពួកគាត់ ឬអំពីសិទ្ធិទទួលសំណង?

- សរសេរសំណួររបស់អ្នកចូលរួម និងព័ត៌មានដែលពួកគាត់ចង់ដឹង នៅលើក្ដារខៀនឬក្រដាសផ្ទាំងធំ។

## ៤. ណែនាំព័ត៌មាននៅក្នុងផ្នែក២

**ផ្នែក២:** វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ដឹង:

- ថា រដ្ឋាភិបាលត្រូវតែរៀបចំផែនការតាំងទីលំនៅថ្មី សម្រាប់គម្រោងដែលផ្តល់មូលនិធិគាំទ្រដោយ ធនាគារអភិវឌ្ឍន៍អាស៊ី ដែលបណ្តាលឱ្យមានការផ្លាស់ប្តូរទីលំនៅ។
- ថា តើផែនការតាំងទីលំនៅថ្មីជាអ្វី។
- ថា ផែនការតាំងទីលំនៅថ្មី ត្រូវតែប្រកាសផ្សព្វផ្សាយជូនសាធារណជន ជាពិសេសចំពោះប្រជាពលរដ្ឋដែលប្រឈមផលប៉ះពាល់ដោយសារគម្រោង។
- តើ នៅក្នុងផែនការតាំងទីលំនៅថ្មីមានព័ត៌មានអ្វីខ្លះ។

## ៥. ផ្សព្វផ្សាយផែនការតាំងទីលំនៅថ្មី

- ប្រសិនបើ អ្នកអាចរកបានផែនការតាំងទីលំនៅថ្មីសម្រាប់គម្រោងដែលប៉ះពាល់ដល់អ្នកចូលរួម សូមលើកវាឡើង និងចែកជូនអ្នកចូលរួមទាំងអស់ដើម្បីឱ្យពួកគាត់មើល។ (ប្រសិនបើអ្នក មិនអាចមានវាទេ សូមរំលងផ្នែកនេះ ដោយគ្រាន់តែពន្យល់ចំណុចចុងក្រោយបានហើយ)។

- សួរអ្នកចូលរួមមើល តើពួកគាត់គិតដូចម្តេចចំពោះផែនការតាំងទីលំនៅថ្មីនេះ។ តើពួកគាត់គិតថា ផែនការនេ មានភាពងាយស្រួលយល់សម្រាប់ពួកគាត់ទេ? ប្រសិនបើ អ្នកមានផែនការតាំងទីលំនៅថ្មីជាភាសាអង់គ្លេស អ្នកចូលរួមភាគច្រើនមិនចេះអានទេ។ ប្រសិនបើ អ្នកមានផែនការនេះជាភាសាខ្មែរ ក៏វាប្រហែលជានៅតែពិបាកយល់ដដែល។

- ពន្យល់ថា ផែនការតាំងទីលំនៅថ្មីជាឯកសារស្មុគស្មាញ ព្រមទាំងពិបាកអាននិងយល់ណាស់។ ប្រជាពលរដ្ឋជាច្រើនដែលប្រឈមផលប៉ះពាល់ដោយសារគម្រោងដែលផ្តល់
មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី មិនអាចយល់ថា ផែនការតាំងទីលំនៅថ្មីនិយាយអំពីអ្វី និងមានផលប៉ះពាល់ដល់ពួកគាត់កម្រិតណានោះទេ។

## ៦. ណែនាំព័ត៌មាននៅក្នុងផ្នែក៣

**ផ្នែក៣:** វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ដឹង:

- ថា រដ្ឋាភិបាលមានកាតព្វកិច្ចធ្វើផែនការតាំងទីលំនៅថ្មីដែល មានភាពងាយយល់ដល់ប្រជាពលរដ្ឋ ដែលប្រឈមផលប៉ះពាល់ដោយគម្រោង ។
- ថា ការធ្វើព័ត៌មានឱ្យងាយយល់ មានន័យថា ពន្យល់ក្នុងរបៀបដែលប្រជាពលរដ្ឋអាចយល់ និងប្រើប្រាស់ភាសាដែលពួកគាត់និយាយ ។
- អំពីកិច្ចការ ដែលរដ្ឋាភិបាលអាចធ្វើបានដើម្បីប្រាកដថា ប្រជាពលរដ្ឋយល់ព័ត៌មាននោះ ។
- ថា ប្រសិនបើប្រជាពលរដ្ឋណា ឬក្រុមណាដែលនិយាយភាសាខុសគ្នា ដូចជាក្រុមជនជាតិដើម ភាគតិចជាដើម រដ្ឋាភិបាលត្រូវតែធ្វើឱ្យប្រាកដថា ព័ត៌មានដែលត្រូវពន្យល់ពួកគាត់ត្រូវតែជាភាសា ដែលសមស្របសម្រាប់ពួកគាត់ ។

## ៧. ការបំផុសគំនិត និងការពិភាក្សាអំពីព័ត៌មានដែលមានលក្ខណៈងាយយល់

- ស្នើសុំឱ្យអ្នកចូលរួម គិតអំពីវិធីខុសៗគ្នាដែលអាចធ្វើឱ្យព័ត៌មានស្មុគស្មាញ ដូចជា ផែនការតាំងទីលំនៅថ្មី ងាយស្រួលយល់ដល់ប្រជាពលរដ្ឋ។ លើកទឹកចិត្តអ្នកចូលរួមឱ្យគិតអំពីវិធីច្នៃប្រឌិត ដែលពួកគាត់ចង់បង្ហាញព័ត៌មាន ។

- អ្នកអាចសួរថា:តើរដ្ឋាភិបាលគប្បីត្រូវធ្វើអ្វីខ្លះដើម្បីធ្វើឱ្យប្រាកដថាអ្នកយល់ដឹងអំពីកម្រិតនៃផលប៉ះពាល់ ដែលពួកគាត់ប្រឈម និងយល់ព័ត៌មាននៅក្នុងផែនការតាំងទីលំនៅថ្មី?

- សូមលើកទឹកចិត្តអ្នកចូលរួមឱ្យ ចែករំលែកគំនិតរបស់គាត់ ។ សរសេរគំនិតរបស់ពួកគាត់ នៅលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ ។

## ៨. ណែនាំព័ត៌មាននៅក្នុងផ្នែក៤

**ផ្នែក៤:** វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់:

- ថា វាមានសារៈសំខាន់ណាស់ដែលត្រូវពិនិត្យថា ផែនការតាំងទីលំនៅថ្មីគោរពគោលនយោបាយការពារស្តីពីការតាំងទំលំនៅដោយបង្ខំ ។
- តើ ព័ត៌មានអ្វីខ្លះដែលពួកគាត់ត្រូវពិនិត្យនៅក្នុងផែនការតាំងទីលំនៅថ្មី ។

## ៩. សង្ខេប

- សួរអ្នកចូលរួមមើល តើពួកគាត់មានអារម្មណ៍ថា ពួកគាត់មានសិទ្ធិទទួលបានព័ត៌មាន សំខាន់ៗអំពីគម្រោងទេ ដូចជាផែនការតាំងទីលំនៅថ្មី។ តើគណៈកម្មាធិករអន្តរក្រសួងទទួលបន្ទុកការតាំងទីលំនៅថ្មី បំពេញការងាររបស់ខ្លួនបានល្អទេក្នុងការធ្វើឱ្យព័ត៌មាន មាន លក្ខណៈងាយយល់?

- ប្រសិនបើមិនបំពេញការងារបានល្អទេ តើពួកគាត់ចង់ធ្វើអ្វីដើម្បីទទួលបានព័ត៌មាន? តើពួកគាត់មានគំនិតអ្វីដើម្បីព្យាយាមទទួលព័ត៌មានដែលពួកគាត់ចង់បាន?

- អ្នកអាចស្នើឡើងថា ពួកគាត់អាចផ្ញើលិខិតទៅគណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុកការតាំងទីលំនៅថ្មី និងធនាគារអភិវឌ្ឍន៍អាស៊ី ដោយមានសំណួរមួយចំនួន ព្រមទាំងព័ត៌មានដែលពួកគាត់ចង់បានទាក់ទងនឹងគម្រោង។ លិខិតនោះ ក៏អាចមានបញ្ចូលនូវសំណើមួយចំនួនដែរ អំពីរបៀបដែលពួកគាត់ចង់ឱ្យបង្ហាញព័ត៌មានជូនពួកគាត់។

## ៥. តើការពិគ្រោះយោបល់ត្រឹមត្រូវមានន័យដូចម្ដេច?

រដ្ឋាភិបាលត្រូវតែប្រាកដថា ប្រជាពលរដ្ឋ និងក្រុមផ្សេងៗទៀតដែលទទួលរងផលប៉ះពាល់ ត្រូវទទួលបាននូវការពិគ្រោះយោបល់ត្រឹមត្រូវអំពីគម្រោង និងផលប៉ះពាល់នៃគម្រោងនោះ។ រដ្ឋាភិបាល ក៏ត្រូវតែពិគ្រោះយោបល់ត្រឹមត្រូវដែរ ជាមួយប្រជាពលរដ្ឋអំពីជម្រើសទាក់ទងនឹងសំណងការតាំង ទីលំនៅថ្មី និងជម្រើសផ្សេងទៀតទាក់ទងនឹងប្រភេទនៃការផ្ដល់ជំនួយ និងការគាំទ្រផ្សេងៗដើម្បីឱ្យ ប្រាកដថា ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ មិនធ្លាក់ខ្លួនកាន់តែក្រជាងមុនដោយសារគម្រោងនោះ ឡើយ។

- **ការពិគ្រោះយោបល់ត្រឹមត្រូវ**មានន័យថា ប្រជាពលរដ្ឋទទួលបានព័ត៌មានយ៉ាងពេញលេញ ព្រមទាំងមានន័យថា ពួកគាត់មានឱកាសក្នុងការបញ្ចេញទស្សនៈរបស់ពួកគាត់ និងថា សំណួររបស់គាត់ ត្រូវបានឆ្លើយយ៉ាងច្បាស់លាស់។ នេះមានន័យថា ក្ដីបារម្ភរបស់ប្រជាពលរដ្ឋ ត្រូវបានដោះស្រាយ រីឯគំនិតរបស់ពួកគាត់ ក៏ត្រូវបានលើកមកគិតពិចារណានៅក្នុងដំណើរការនៃការធ្វើសេចក្ដីសម្រេចចិត្តដែរ។

- **ការពិគ្រោះយោបល់ត្រឹមត្រូវ**មានន័យថា ប្រជាពលរដ្ឋដែលនឹងត្រូវទទួលរងផលប៉ះពាល់ នឹងមានឱកាសចូលរួមផ្ដល់យោបល់ប្រកបដោយឥទ្ធិពលលើផែនការតាំងទីលំនៅថ្មីតាំងពីដើមដំបូង រហូតដល់ពេលអនុវត្តផែនការនោះ។

- **ការពិគ្រោះយោបល់ត្រឹមត្រូវ**មានន័យថា ប្រជាពលរដ្ឋមិនមានអារម្មណ៍ភ័យខ្លាច ឬទទួលរងការគាបសង្កត់ពីសំណាក់តំណាងរដ្ឋាភិបាល ឬអ្នកណាផ្សេងទៀតទេ និងម្យ៉ាងទៀត ពួកគាត់អាចបញ្ចេញទស្សនៈ និងសួរសំណួររបស់ពួកគាត់ដោយសេរី និងគ្មានការភ័យខ្លាច។

- **ការពិគ្រោះយោបល់ត្រឹមត្រូវ**មានន័យថា សំឡេងរបស់ស្ត្រីត្រូវគេយកចិត្តទុកដាក់ស្ដាប់ និងពួកគាត់ជាអ្នកចូលរួមយ៉ាងសកម្មក្នុងការពិគ្រោះយោបល់។

- **ការពិគ្រោះយោបល់ត្រឹមត្រូវ**មានន័យថា ក្រុមប្រជាពលរដ្ឋដែលងាយរងគ្រោះនិងទន់ខ្សោយ ដូចជាជនជាតិដើមភាគតិច[៥] មនុស្សចាស់ កុមារ ប្រជាពលរដ្ឋដែលគ្មានដីធ្លី និងប្រជាពលរដ្ឋដែលគ្មានប័ណ្ណកម្មសិទ្ធិ មានឱកាសពិសេស ដើម្បីលើកឡើងអំពីកង្វល់របស់គាត់ ហើយកង្វល់ទាំងនេះត្រូវគេយកចិត្តទុកដាក់ស្ដាប់ និងដោះស្រាយ។

---

[៥] មានគោលនយោបាយការពារពិសេស សម្រាប់ជនជាតិដើមភាគតិច ដែលនឹងត្រូវទទួលផលប៉ះពាល់ដោយសារគម្រោងដែលផ្ដល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី។ ជនជាតិដើមភាគតិចដែលនឹងត្រូវផ្លាស់ប្ដូរទីលំនៅដោយសារគម្រោងដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី គប្បីត្រូវស្វែងរកព័ត៌មានអំពីគោលនយោបាយទាំងនោះ។



## ៦. តើត្រូវពិគ្រោះយោបល់ជាមួយអ្នកណា?

គោលនយោបាយការពារស្តីពីការតាំងទីលំនៅដោយបង្ខំចែងថា រដ្ឋាភិបាលត្រូវតែពិគ្រោះយោបល់ជាមួយ

- *ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង។* នេះមានន័យថា ត្រូវពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដែលត្រូវផ្លាស់ចេញពី ឬបាត់បង់ លំនៅដ្ឋាន ដីធ្លីកន្លែងប្រកបអាជីវកម្ម កន្លែងធ្វើការ ឬធនធាននានាដែលពួកគាត់ប្រើប្រាស់ដើម្បីប្រកបរបរចិញ្ចឹមជីវិត។ ត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះស្ត្រី និងចំពោះក្រុមប្រជាពលរដ្ឋដែលងាយរងគ្រោះ និងទន់ខ្សោយ ដូចជា ជនជាតិដើមភាគតិច មនុស្សចាស់ កុមារ ប្រជាពលរដ្ឋដែលគ្មានដីធ្លី និងប្រជាពលរដ្ឋដែលគ្មានប័ណ្ណកម្មសិទ្ធិ ដើម្បីឱ្យប្រាកដថា ពួកគាត់មានឱកាសបញ្ចេញទស្សនៈ និងក្តីកង្វល់របស់ពួកគាត់ និង ម្យ៉ាងទៀត ទស្សនៈ និងកង្វល់របស់ពួកគាត់ត្រូវបានលើកយកទៅពិចារណា។

- *ប្រជាពលរដ្ឋនៅតាមភូមិដែលប្រជាពលរដ្ឋនឹងទៅតាំងទីលំនៅថ្មី។* ត្រូវពិគ្រោះយោបល់ជាមួយ អ្នកភូមិមូលដ្ឋានទាំងនេះ ដើម្បីស្តាប់អំពីទស្សនៈនិងក្តីកង្វល់របស់ពួកគាត់ថា តើពួកគាត់នឹងទទួល ផលប៉ះពាល់អ្វីខ្លះ នៅពេលដែលមានប្រជាពលរដ្ឋផ្លាស់មកតាំងទីលំនៅថ្មី នៅសហគមន៍របស់គាត់។ ពួកគាត់ក៏គប្បីត្រូវមានការពិគ្រោះយោបល់ដែរថា តើពួកគាត់អាចនឹងទទួលបានផលប្រយោជន៍អ្វីខ្លះ ពីកម្មវិធីនិងសេវាកម្មថ្មីៗនៅក្នុងសហគមន៍របស់ពួកគាត់ ដូចជា ការផ្តល់ជំនួយប្រកបរបរចិញ្ចឹមជីវិតជាដើម។ ការផ្តល់ឱកាសដល់អ្នកភូមិចូលរួមក្នុងការពិគ្រោះយោបល់ និងការរកវិធីដើម្បីឱ្យ ពួកគាត់ចែករំលែកផលប្រយោជន៍នឹងជួយធ្វើឱ្យប្រាកដថា ពួកគាត់នឹងរស់នៅជាមួយក្រុមគ្រួសារ ដែលផ្លាស់មកតាំងទីលំនៅថ្មីនៅក្នុងភូមិរបស់គាត់ដោយសុខសាន្ត។

- *សហគមន៍ បណ្ដាញ ឬអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗទៀត* ដែលចាប់អារម្មណ៍ និងចង់ចូលរួមចំណែកក្នុងការពិភាក្សា។

## ៧. តើរដ្ឋាភិបាលត្រូវតែពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ នៅពេលណា?

ការពិគ្រោះយោបល់ត្រឹមត្រូវ ជាដំណើរការបន្តពីអ្វីៗដែលបានចាប់ផ្ដើមចាប់តាំងពីពេលដែល រដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ី បានសម្រេចអនុវត្តគម្រោងជាមួយគ្នា។

មុនដំបូងគឺ ត្រូវពិគ្រោះយោបល់ជាមួយ ប្រជាពលរដ្ឋសហគមន៍ បណ្ដាញ និងអង្គការមិនមែន រដ្ឋាភិបាលនានាអំពីគម្រោងនេះ ដោយរួមមានការពិគ្រោះយោបល់អំពីហេតុផលនៃការសម្រេចចិត្ត និង របៀបនៃការអនុវត្តគម្រោង។ ប្រសិនបើ ប្រជាពលរដ្ឋមានក្ដីបារម្ភយ៉ាងខ្លាំងអំពីផលប៉ះពាល់របស់គម្រោង ដូចជា គម្រោងធ្វើឱ្យមានគ្រោះថ្នាក់ ឬខូចខាតដល់មនុស្ស ឬបរិស្ថានជាដើម ដូច្នេះរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ី គប្បីត្រូវពិចារណាលើក្ដីបារម្ភទាំងនេះក្នុងការសម្រេចចិត្តថា តើត្រូវឬមិនត្រូវ បន្តគម្រោង។ រដ្ឋក៏ត្រូវពិចារណា រកគំនិតដែរថា តើមានវិធីអ្វីដែលអាចអនុវត្តគម្រោងទៅបានដោយ បញ្ចៀស និងបន្ថយការផ្លាស់ប្ដូរទីលំនៅឱ្យថយចុះនៅកម្រិតតិចបំផុត។




ប្រសិនបើ គេសម្រេចចិត្តថា គម្រោងត្រូវបន្តដំណើរការទៅមុខ និងប្រសិនបើ ការសម្រេចចិត្តនោះ បណ្ដាលឱ្យមានការផ្លាស់ប្ដូរទីលំនៅ តាមគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីចែងថា រដ្ឋាភិបាលត្រូវតែពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ រកវិធីធ្វើយ៉ាងណាដើម្បីឱ្យប្រាកដថា ជីវភាពប្រជាពលរដ្ឋមិនធ្លាក់ខ្លួនកាន់តែក្រជាងមុនឡើយ។ រដ្ឋាភិបាលត្រូវតែយកគំនិតមតិ និងក្ដីបារម្ភ របស់ប្រជាពលរដ្ឋទៅពិចារណាឱ្យបានល្អិតល្អន់ នៅពេលដែលរដ្ឋាភិបាលធ្វើ *សេចក្ដីព្រាងផែនការដំបូងស្ដីពី ការតាំងទីលំនៅថ្មី*។

ក្រោយពីរដ្ឋាភិបាលបានរៀបចំ សេចក្ដីព្រាងផែនការដំបូងស្ដីពីការតាំងទីលំនៅថ្មីនេះរួចហើយ រដ្ឋាភិបាលត្រូវតែដាក់ឱ្យប្រជាពលរដ្ឋមើល ឬប្រកាសផ្សព្វផ្សាយជាសាធារណៈ និងត្រូវតែប្រាកដថា ប្រជាពលរដ្ឋដែលរងផលប៉ះពាល់យល់ថា មានផលប៉ះពាល់ដល់ពួកគាត់ក្នុងកម្រិតណា។ ក្រោយមកទៀត រដ្ឋាភិបាលត្រូវតែស្វែងយល់អំពីគំនិតរបស់ប្រជាពលរដ្ឋ ទាក់ទងនឹងសេចក្ដីព្រាងនៃផែនការនោះ ព្រមទាំងត្រូវតែពិចារណាយ៉ាងល្អិតល្អន់អំពីគំនិតទាំងនោះក្នុងការធ្វើ *ផែនការស្ដារស្ដីពីការតាំងទីលំនៅ ថ្មី*។

រដ្ឋាភិបាលត្រូវតែផ្ដល់ជម្រើសសម្រាប់ការតាំងទីលំនៅថ្មីជូនប្រជាពលរដ្ឋសម្រេច ព្រមទាំងត្រូវតែ ពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋអំពីជម្រើសរបស់ពួកគាត់ថា តើពួកគាត់ជ្រើស*រើសយក ការតាំង ទីលំនៅថ្មី និងសំណង បែបណា*។ រដ្ឋាភិបាលក៏ត្រូវតែពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដែរ ដើម្បីដឹងអំពីទស្សនៈរបស់ពួកគាត់ ថាតើត្រូវអនុវត្តផែនការតាំងទីលំនៅថ្មីដោយរបៀបណា។

## លំហាត់ទី៩: តើការពិគ្រោះយោបល់ត្រឹមត្រូវមានន័យដូចម្តេច?



**គោលបំណង:** អ្នកចូលរួមនឹងយល់ដឹងថា ការពិគ្រោះយោបល់ត្រឹមត្រូវមានន័យដូចម្តេច។ ពួកគាត់នឹងដឹងថា រដ្ឋាភិបាលត្រូវតែពិគ្រោះយោបល់ជាមួយអ្នកណា និងត្រូវពិគ្រោះយោបល់ជាមួយពួកគាត់នៅពេលណា។

**សម្ភារ:** ក្តារខៀន ឬក្រដាសផ្ទាំងធំ និងហ្វឺន និងឯកសារចែកសម្រាប់ចែកទី១ - ៤

**វិធីសាស្ត្រប្រើប្រាស់:** ការពិភាក្សារួមក្នុងថ្នាក់ កិច្ចការជាក្រុម ការឡើងសម្តែងតួ

| ដំណើរការ | | រយៈពេល (គិតជានាទី) |
|---|---|---|
| ១. | ណែនាំព័ត៌មាននៅក្នុងផ្នែក៤ | ១៥ |
| ២. | ការពិភាក្សាខ្លីអំពីការពិគ្រោះយោបល់ | ១០ |
| ៣. | ណែនាំព័ត៌មាននៅក្នុងផ្នែក៥ និង៦ | ១៥ |
| ៤. | ពន្យល់លំហាត់ | ៥ |
| ៥. | ការរៀបចំក្រុម | ២០ |
| ៦. | កិច្ចប្រជុំពិគ្រោះយោបល់ | ២០ |
| ៧. | សង្ខេប | ១៥ |
| **សរុប:** | | **១០០** |

# ការណែនាំសម្រាប់អ្នកសម្របសម្រួល

## ១. ណែនាំព័ត៌មាននៅក្នុងផ្នែក៤

- មុនដំបូង សូមសួរអំពីទស្សនៈរបស់អ្នកចូលរួមថា តើការពិគ្រោះយោបល់ត្រឹមត្រូវមានន័យ ដូចម្តេច។ លើកទឹកចិត្តអ្នកចូលរួមពីរ-បីនាក់ឱ្យចូលរួមចែករំលែកទស្សនៈរបស់ពួកគាត់។

**ផ្នែក៤:** វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមត្រូវយល់ដឹងថា:

- រដ្ឋាភិបាលត្រូវតែប្រាកដថា មានការពិគ្រោះយោបល់ត្រឹមត្រូវជាមួយប្រជាពលរដ្ឋ ដែលទទួលផលប៉ះពាល់ និងក្រុមប្រជាពលរដ្ឋផ្សេងៗទៀត អំពីគម្រោងនិងផលប៉ះពាល់នៃគម្រោងនោះ។
- រដ្ឋាភិបាលក៏ត្រូវតែពិគ្រោះយោបល់ត្រឹមត្រូវដែរ ជាមួយប្រជាពលរដ្ឋទាំងនោះ អំពីសំណងជម្រើស នៃការតាំងទីលំនៅថ្មី និងប្រភេទនៃការផ្តល់ជំនួយ និងការគាំទ្រផ្សេងៗទៀត។
- និយមន័យនៃការពិគ្រោះយោបល់ត្រឹមត្រូវ។

- វាជាគំនិតមួយយ៉ាងល្អដែលត្រូវសរសេរអត្ថន័យនៃការពិគ្រោះយោបល់ត្រឹមត្រូវ នៅលើក្រដាសផ្ទាំងធំ រួចបិទវានៅលើជញ្ជាំង ដើម្បីឱ្យអ្នកចូលរួមទាំងអស់អាចមើលវា នៅពេលអនុវត្តលំហាត់នេះ។

## ២. ការពិភាក្សាខ្លីអំពីការពិគ្រោះយោបល់

- សួរអ្នកចូលរួមមើល តើពួកគាត់ធ្លាប់ចូលរួមក្នុងការពិគ្រោះយោបល់ត្រឹមត្រូវណាមួយ ដែលពួកគាត់មានអារម្មណ៍ថា គេបានយកចិត្តទុកដាក់ស្តាប់ទស្សនៈនិងគំនិតរបស់ពួកគាត់ ព្រមទាំងបានយកទស្សនៈនិងគំនិតរបស់ពួកគាត់ទៅពិចារណាយ៉ាងល្អិតល្អន់ទេ។ បើសិនបើធ្លាប់ សូមស្នើសុំឱ្យគាត់ពន្យល់ថា តើមានអ្វីកើតឡើងនៅពេលពិគ្រោះយោបល់នោះ។

- សួរអ្នកចូលរួមថា តើពួកគាត់មានអារម្មណ៍ថា ពួកគាត់ត្រូវបានពិគ្រោះយោបល់ត្រឹមត្រូវ អំពីគម្រោងដែលធ្វើឱ្យប៉ះពាល់ដល់ពួកគាត់ទេ។ ប្រសិនបើដូច្នេះ តើហេតុអ្វី? ប្រសិនបើ មិនដូច្នោះទេ តើហេតុអ្វី? សូមលើកទឹកចិត្តឱ្យអ្នកចូលរួមចូលរួមចំណែកចែករំលែកអំពី បទពិសោធន៍របស់ពួកគាត់។

- តើមានអ្នកចូលរួមណាខ្លះដែលធ្លាប់ទទួលការគាបសង្កត់ ឬបង្ខំឱ្យរុះរើទីលំនៅ និងទទួលសំណង ឬការតាំងទីលំនៅថ្មីមិនសមរម្យទេ? សូមពន្យល់ថា ប្រសិនបើ ប្រជាពលរដ្ឋមានអារម្មណ៍ថា ពួកគាត់មានការគាបសង្កត់ ឬការគំរាមកំហែង នេះជាបញ្ហានៃការរំលោភគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ។

## ៣. ណែនាំព័ត៌មាននៅក្នុងផ្នែក៥និង៦

**ផ្នែក៥និង៦:** *វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមត្រូវយល់ដឹងថាៈ*

- តើរដ្ឋាភិបាលត្រូវតែពិគ្រោះយោបល់ជាមួយអ្នកណា។
- តើរដ្ឋាភិបាលត្រូវតែពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅពេលណា។

## ៤. ពន្យល់លំហាត់

- ពន្យល់ថា ឥឡូវនេះអ្នកចូលរួមទាំងអស់នឹងមានឱកាសរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ មួយអំពីគម្រោង ដែលធ្វើឱ្យប៉ះពាល់ដល់ពួកគាត់ បន្ទាប់មកពួកគាត់ហាត់អនុវត្តកិច្ចប្រជុំនេះ។

- អ្នកចូលរួមនឹងត្រូវចែកចេញជាក្រុមតូចៗ។ គ្រប់ក្រុមទាំងអស់ លើកលែងតែមួយក្រុម នឹងឡើងសម្តែង តួជាសមាជិកសហគមន៍ ដែលទទួលរងផលប៉ះពាល់ដោយគម្រោង។ ក្រុមទាំងនេះ ត្រូវរៀបចំការ ពិគ្រោះយោបល់មួយ ដោយពិភាក្សាគ្នាថា តើត្រូវត្រៀម សំណួរអ្វីខ្លះដើម្បីសួរមន្ត្រីរដ្ឋាភិបាល នៅពេល ប្រជុំពិគ្រោះយោបល់ និងតើព័ត៌មានអ្វីខ្លះ ដែលពួកគាត់ចង់បាន។ ក្រុមក៏អាចធ្វើបញ្ជីមួយអំពីក្តីបារម្ភ ទាំងឡាយដែលពួកគាត់ចង់យកទៅពិគ្រោះជាមួយរដ្ឋាភិបាល។

- មានមួយក្រុមត្រូវសម្តែងតួជាមន្ត្រីរដ្ឋាភិបាល មកពីគណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុក ការតាំងទី លំនៅថ្មី។ ក្រុមនេះនឹងត្រូវពន្យល់អំពី ផលប៉ះពាល់នៃគម្រោង សិទ្ធិទទួលសំណងរបស់ប្រជាពលរដ្ឋ និងឆ្លើយសំណួររបស់សហគមន៍។ ពន្យល់ថា អ្នកសម្របសម្រួល នឹងធ្វើការជាមួយក្រុមនេះ ដើម្បីជួយ ក្រុមក្នុងការរៀបចំ។

- ក្រុមនីមួយៗមានពេល២០នាទី ក្នុងការរៀបចំកិច្ចពិគ្រោះយោបល់នេះ បន្ទាប់មកក្រុមត្រូវត្រឡប់មក ជួបជុំគ្នាវិញ ដើម្បីអនុវត្តកិច្ចប្រជុំពិគ្រោះយោបល់នេះ។

- ក្រុមត្រូវគិតអំពីនិយមន័យនៃការពិគ្រោះយោបល់ត្រឹមត្រូវ នៅពេលពិភាក្សាតាមក្រុម និងនៅពេល ប្រជុំពិគ្រោះយោបល់។

## ៥. ការរៀបចំក្រុម

- ចែកអ្នកចូលរួមជាបួនក្រុម។ ក្នុងចំណោមក្រុមទាំងបួននេះ មានមួយក្រុមមានសមាជិកសុទ្ធតែស្ត្រី។

- ក្រុមនីមួយៗនឹងទទួលបានសេចក្តីណែនាំមួយ នៅក្នុងឯកសារចែកជូន ទី១ ទី២ ទី៣ និង៤។ (ត្រូវ ប្រាកដថា ក្រុមស្ត្រីត្រូវមានសេចក្តីណែនាំសម្រាប់ស្ត្រី)

- ដើរពិនិត្យក្រុមនីមួយៗ ដើម្បីឱ្យប្រាកដថា អ្នកចូលរួមម្នាក់ៗយល់អំពីកិច្ចការរបស់ខ្លួនថា ត្រូវធ្វើអ្វី និងថាតើ ក្រុមមានក្រដាសគ្រប់គ្រាន់សម្រាប់សរសេរផែនការរបស់ក្រុម។
- ពិនិត្យមើលថា ក្រុមនីមួយៗត្រូវមានអ្នកចេះអាន។ ប្រសិនបើគ្មានទេ ត្រូវអានសេចក្តីណែនាំនោះ ឱ្យពួកគាត់ស្តាប់។
- អ្នកសម្រួលសម្រួលគប្បីត្រូវធ្វើការជាមួយក្រុមដែលនឹងសម្តែងតួជាមន្ត្រីរដ្ឋាភិបាល និង ជួយក្រុមនេះក្នុងការរៀបចំផែនការរបស់ក្រុម សម្រាប់ផ្តល់ព័ត៌មាន និងឆ្លើយសំណួររបស់ប្រជាពលរដ្ឋ។

## ៦. កិច្ចប្រជុំពិគ្រោះយោបល់

- ហៅក្រុមទាំងអស់ឱ្យចូលមកជុំគ្នាវិញ ដើម្បីចាប់ផ្តើមកិច្ចប្រជុំពិគ្រោះយោបល់។
- អ្នកគប្បីត្រូវដើរតួជាអ្នកសម្របសម្រួលកិច្ចពិភាក្សានេះ និងត្រូវធ្វើយ៉ាងណាឱ្យក្រុមទាំងអស់មានឱកាសបានឡើងបញ្ចេញមតិ។ ក្រុមដែលសម្តែងតួជាមន្ត្រីរដ្ឋាភិបាលគប្បីត្រូវ ពន្យល់ព័ត៌មាន និងឆ្លើយសំណួររបស់ប្រជាពលរដ្ឋ។ ត្រូវប្រាកដថា ក្រុមសហគមន៍នីមួយៗ មានឱកាសសួរសំណួរ ចែករំលែកទស្សនៈរបស់ពួកគាត់ និងលើកឡើងអំពីក្តីកង្វល់ផ្សេងៗ។
- ទុកឱ្យកិច្ចប្រជុំនេះប្រព្រឹត្តទៅរយៈពេល២០នាទី ក្រោយមកត្រូវស្នើឱ្យអ្នកចូលរួមទាំងអស់ ទៅកាន់កន្លែងរៀងៗខ្លួនវិញ។

## ៧. សង្ខេប

- សួរអ្នកចូលរួម តើពួកគាត់យល់ដូចម្តេចចំពោះកិច្ចប្រជុំពិគ្រោះយោបល់នេះ។ តើជាការពិគ្រោះយោបល់ត្រឹមត្រូវទេ? តើខាងក្រុមសហគមន៍ទាំងអស់ ជាពិសេស ក្រុមស្ត្រី និងក្រុមដែលងាយរងគ្រោះយល់ថាពួកគាត់មានឱកាសសួរសំណួរ ចូលរួមបញ្ចេញទស្សនៈ និងលើកឡើងនូវក្តីកង្វល់នានាទេ?
- តើក្រុមដែលសម្តែងតួជាមន្ត្រីរដ្ឋាភិបាលយល់យ៉ាងណាដែរចំពោះកិច្ចប្រជុំពិគ្រោះយោបល់នេះ?
- តើកិច្ចប្រជុំដែលជាការសម្តែងនេះ ដូច ឬខុសពីកិច្ចប្រជុំពិគ្រោះយោបល់ជាក់ស្តែងដែលគេ ធ្លាប់ធ្វើទាក់ទងនឹងគម្រោងដែលប៉ះពាល់ដល់ពួកគាត់ទេ? តើវាខុសគ្នាកន្លែងណាខ្លះ?
- ប្រសិនបើ វាសមស្របសម្រាប់រឿងរបស់ពួកគាត់ អ្នកអាចផ្តល់សំណើថា ពួកគាត់អាចផ្ញើ លិខិតទៅគណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុកការតាំងទីលំនៅថ្មី និងធនាគារអភិវឌ្ឍន៍ អាស៊ី ដោយពន្យល់ថាពួកគាត់មានសំណូមពរចង់ឱ្យមានសិក្ខាសាលាពិគ្រោះយោបល់មួយ ដើម្បីឱ្យប្រាកដថា ពួកគាត់មានព័ត៌មានគ្រប់គ្រាន់ និងបានពិគ្រោះយោបល់ត្រឹមត្រូវ ទាក់ទងនឹងគម្រោង សិទ្ធិរបស់ពួកគាត់ក្នុងការទទួលសំណង និងជម្រើសនានាសម្រាប់ ការតាំងទីលំនៅថ្មី។ ពួកគាត់ក៏អាចបញ្ចូលគំនិតរបស់ពួកគាត់អំពីរបៀបរៀបចំ កិច្ចប្រជុំ ពិគ្រោះយោបល់ត្រឹមត្រូវទៅក្នុងលិខិតនេះដែរ។

# ឯកសារសម្រាប់ផ្នែកទី១:  លំហាត់ទី៩

**ការណែនាំសម្រាប់ក្រុម១:**

ក្រុមរបស់អ្នកនឹងត្រូវសម្តែងតួជាមន្ត្រីរដ្ឋាភិបាលមកពី គណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុក ការតាំងទីលំនៅថ្មី។ តួនាទីរបស់ក្រុមគឺត្រូវពន្យល់អំពីផលល្អ និងផលប៉ះពាល់របស់គម្រោង អំពីសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលសំណង និងត្រូវព្យាយាមឆ្លើយសំណួររបស់សហគមន៍។

ក្នុងការរៀបចំក្រុមរបស់អ្នកគប្បីត្រូវពិភាក្សាគ្នាអំពីរបៀបពន្យល់:

- អំពីផលល្អ និងផលប៉ះពាល់របស់គម្រោងទៅលើសហគមន៍។
- ថាតើ ប្រជាពលរដ្ឋមានសិទ្ធិទទួលបានអ្វីខ្លះ ដូចជា សំណងសម្រាប់ដីធ្លី ផ្ទះសម្បែង និងអាជីវកម្មរបស់គាត់។
- អំពីព័ត៌មានទាក់ទងនឹងតំបន់តាំងទីលំនៅថ្មី។ តើវានៅទីណា និងមានអ្វីខ្លះនៅទីនោះ។
- តើប្រជាពលរដ្ឋមានជម្រើសអ្វីខ្លះ។ (ឧទាហរណ៍ តើមានតំបន់តាំងទីលំនៅថ្មីផ្សេងៗដែល ពួកគាត់អាចជ្រើសរើសតាមការពេញចិត្តរបស់គាត់ទេ?)។
- ថា ពួកគាត់នឹងទទួលបាននូវការគាំទ្រការប្រកបរបរចិញ្ចឹមជីវិត និងអាចមានអ្វីពាក់ព័ន្ធខ្លះ។

ត្រូវនឹកគិតអំពីអត្ថន័យនៃពាក្យ ពិគ្រោះយោបល់ត្រឹមត្រូវ។

អ្នកនឹងមានពេល២០នាទីក្នុងការរៀបចំ រួចនឹងត្រូវជួបជាមួយក្រុមសហគមន៍ដើម្បីពិគ្រោះ យោបល់។

## ឯកសារសម្រាប់ចែកទី២: លំហាត់ទី៩

### ការណែនាំសម្រាប់ក្រុមទី២:

ក្រុមរបស់អ្នកនឹងត្រូវសម្តែងតួជាសមាជិកសហគមន៍ ដែលទទួលរងផលប៉ះពាល់ដោយសារគម្រោងមួយ។

ក្នុងការរៀបចំនេះ ក្រុមរបស់អ្នកគប្បីត្រូវពិភាក្សាគ្នាដើម្បីរកសំណួរណាខ្លះដែលអ្នកចង់សួរ និងគំនិតអ្វីខ្លះដែលអ្នកចង់ចូលរួមចែករំលែក។ ឧទាហរណ៍ អ្នកអាចមានសំណួរ និងគំនិតដូចខាងក្រោមនេះ:

- ផលល្អ និងផលប៉ះពាល់របស់គម្រោងទៅលើសហគមន៍មានអ្វីខ្លះ។
- អ្នកមានសិទ្ធិទទួលបានអ្វីខ្លះ ដូចជា សំណងសម្រាប់ដីធ្លី ផ្ទះសម្បែង និងអាជីវកម្មរបស់អ្នក។
- អំពីព័តិមានទាក់ទងនឹងតំបន់តាំងទីលំនៅថ្មី។ វានៅទីណា និងមានអ្វីខ្លះនៅទីនោះ។
- តើអ្នកមានជម្រើសអ្វីខ្លះ។ (ឧទាហរណ៍ តើមានតំបន់តាំងទីលំនៅថ្មីផ្សេងៗ ដែលអ្នកអាចជ្រើសរើសតាមការពេញចិត្តរបស់អ្នកទេ?)។
- អ្នកនឹងទទួលបានការគាំទ្រអ្វីខ្លះ ដើម្បីកុំឱ្យអ្នកកាន់តែក្រទៅៗ និងមានជីវភាពកាន់តែអន់ជាងមុន។

អ្នកក៏ត្រូវរៀបចំបញ្ជីមួយអំពីក្តីកង្វល់មួយចំនួន ដែលអ្នកត្រូវលើកឡើងនៅពេលប្រជុំពិគ្រោះយោបល់។

ត្រូវនឹក គិតអំពីអត្ថន័យនៃពាក្យពិគ្រោះយោបល់ត្រឹមត្រូវ។

អ្នកនឹងមានពេល២០នាទីក្នុងការរៀបចំ រួចនឹងត្រូវជួបជាមួយមន្ត្រីរដ្ឋាភិបាល និងក្រុមសហគមន៍ផ្សេងៗទៀត ដើម្បីពិគ្រោះយោបល់។

## ឯកសារសម្រាប់ចែកទី៣: លំហាត់ទី៩

### ការណែនាំសម្រាប់ក្រុមទី៣:

ក្រុមរបស់អ្នកនឹងត្រូវសម្ដែងតួជា ស្ត្រីនៅក្នុងសហគមន៍ដែលទទួលរងផលប៉ះពាល់ដោយសារ គម្រោងមួយ។

ក្នុងការរៀបចំនេះ ក្រុមរបស់អ្នកគប្បីត្រូវពិភាក្សាគ្នាដើម្បីរកសំណួរណាខ្លះដែលអ្នកចង់សួរ និងតើមានគំនិតអ្វីខ្លះ ដែលអ្នកចង់ចូលរួមចែករំលែក។ អ្នកគប្បីត្រូវគិតអំពីបញ្ហាជាក់លាក់មួយចំនួន ដែលកើតមានចំពោះស្ត្រី។ ឧទាហរណ៍ អ្នកអាចមានសំណួរ និងគំនិតដូចខាងក្រោមនេះ:

- ផលល្អ និងផលប៉ះពាល់របស់គម្រោងទៅលើស្ត្រីក្នុងសហគមន៍។
- អ្នកមានសិទ្ធិទទួលបានអ្វីខ្លះ ដូចជា សំណងសម្រាប់ដីធ្លី ផ្ទះសម្បែង និងអាជីវកម្ម របស់អ្នក។
- ព័ត៌មានទាក់ទងនឹងតំបន់តាំងទីលំនៅថ្មី។ វានៅទីណា និងមានអ្វីខ្លះនៅទីនោះ ដើម្បីឱ្យប្រាកដថាស្ត្រីនិង កុមារមានអ្វីៗដែលគេត្រូវការ។
- តើអ្នកមានជម្រើសអ្វីខ្លះ។ (ឧទាហរណ៍ តើមានតំបន់តាំងទីលំនៅថ្មីផ្សេងៗដែលអ្នកអាចជ្រើសរើស តាមការពេញចិត្តរបស់អ្នកទេ?)។
- ថា មានការគាំទ្រអ្វីខ្លះ ដែលស្ត្រីនឹងទទួលបាន ដើម្បីកុំឱ្យពួកគាត់កាន់តែក្រទៅៗ និងមានជីវភាព កាន់តែអន់ជាងមុន។

អ្នកក៏ត្រូវរៀបចំបញ្ជីមួយអំពីក្ដីកង្វល់មួយចំនួន ដែលអ្នកត្រូវលើកឡើងនៅពេលប្រជុំពិគ្រោះយោបល់។

ត្រូវនឹកគិតអំពីអត្ថន័យនៃពាក្យពិគ្រោះយោបល់ត្រឹមត្រូវ។

អ្នកនឹងមានពេល២០នាទីក្នុងការរៀបចំ រួចនឹងត្រូវជួបជាមួយមន្ត្រីរដ្ឋាភិបាល និងក្រុមសហគមន៍ផ្សេងៗទៀត ដើម្បីពិគ្រោះយោបល់។

## ឯកសារសម្រាប់ចែកទី៤: លំហាត់ទី៩

### ការណែនាំសម្រាប់ក្រុមទី៤:

ក្រុមរបស់អ្នកនឹងត្រូវសម្តែងតួជាប្រជាពលរដ្ឋដែលងាយរងគ្រោះ នៅក្នុងសហគមន៍ ដែលទទួលរងផលប៉ះពាល់ដោយសារគម្រោងមួយ ។ ឧទាហរណ៍ ក្រុមរបស់អ្នកអាចជាប្រជាពលរដ្ឋដែលពិការ ជាមនុស្សចាស់ជរា ជាប្រជាពលរដ្ឋ ដែលក្រីក្រជាងគេ។ ក្នុងក្រុមរបស់អ្នក ម្នាក់ៗអាចតើតួជាជនងាយរងគ្រោះ ក្នុងហេតុផលណាមួយនៃហេតុផល ដូចខាងក្រោម ។

ក្នុងការរៀបចំនេះ ក្រុមរបស់អ្នកគប្បីត្រូវពិភាក្សាគ្នាដើម្បីរកសំណួរណាខ្លះអ្នកចង់សួរ និងតើមានគំនិតអ្វីខ្លះ ដែលអ្នកចង់ចូលរួមចែករំលែក។ អ្នកគប្បីគិតអំពីបញ្ហាជាក់លាក់មួយចំនួន ដែលកើតមានចំពោះប្រជាពលរដ្ឋដែលងាយរងគ្រោះ។ ឧទាហរណ៍ អ្នកអាចមានសំណួរ និងគំនិតដូចខាងក្រោមនេះ:

- ផលល្អ និងផលប៉ះពាល់របស់គម្រោងទៅលើសហគមន៍ ។
- អ្នកមានសិទ្ធិទទួលបានអ្វីខ្លះ ដូចជា សំណងសម្រាប់ដីធ្លី ផ្ទះសម្បែង និងអាជីវកម្មរបស់អ្នក ។
- អំពីព័ត៌មានទាក់ទងនឹងតំបន់តាំងទីលំនៅថ្មី។ វានៅទីណា និងមានអ្វីខ្លះនៅទីនោះ ដើម្បីឱ្យប្រាកដថា ប្រជាពលរដ្ឋដែលងាយរងគ្រោះមានអ្វីៗដែលពួកគាត់ត្រូវការ ។
- តើអ្នកមានជម្រើសអ្វីខ្លះ ។ (ឧទាហរណ៍ តើមានតំបន់តាំងទីលំនៅថ្មីផ្សេងៗ ដែលអ្នកអាចជ្រើសរើសតាមការពេញចិត្តរបស់អ្នកទេ?) ។
- អ្នកនឹងមានការគាំទ្រពិសេសអ្វី ដើម្បីឱ្យជីវភាពរបស់អ្នកកាន់តែល្អប្រសើរ ។

អ្នកក៏ត្រូវរៀបចំបញ្ជីមួយអំពីក្តីកង្វល់មួយចំនួន ដែលអ្នកត្រូវលើកឡើងនៅពេលប្រជុំពិគ្រោះយោបល់ ។

ត្រូវនឹកគិតអំពីអត្ថន័យនៃពាក្យ ពិគ្រោះយោបល់ត្រឹមត្រូវ ។

អ្នកនឹងមានពេល២០នាទីក្នុងការរៀបចំ បន្ទាប់មកត្រូវជួបជាមួយមន្ត្រីរដ្ឋាភិបាល និងក្រុមសហគមន៍ផ្សេងៗទៀត ដើម្បីពិគ្រោះយោបល់ ។

# ការទទួលខុសត្រូវរបស់រដ្ឋាភិបាល និង ធនាគារ អភិវឌ្ឍន៍អាស៊ី

**លទ្ធផលទទួលបាន:**

ក្រោយពីបញ្ចប់ជំពូកនេះ អ្នកចូលរួមនឹង:

១. យល់ដឹងថា គោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីមិនត្រូវបានគេគោរពជានិច្ចនោះទេ។

២. យល់ដឹងថា មានកិច្ចការដែលពួកគាត់អាចធ្វើបានដើម្បីធ្វើឱ្យរដ្ឋាភិបាលនិងធនាគារអភិវឌ្ឍន៍មានការទទួលខុសត្រូវ។

៣. ដឹងអំពីរបៀបតាមដានការអនុវត្តគម្រោង។

៤. ដឹងថា អ្វីដែលពួកគាត់ត្រូវធ្វើនៅក្នុងប្រទេស ឬនៅមូលដ្ឋានរបស់គាត់ដើម្បីព្យាយាមស្វែងរកដំណោះស្រាយ។

៥. ដឹងថា ពួកគាត់អាចប្រើយន្តការទទួលខុសត្រូវរបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងការស្វែងរក ដំណោះស្រាយ។

៦. យល់ដឹងថា តើដំណើរការនៃការទទួលខុសត្រូវរបស់ធនាគារអភិវឌ្ឍន៍អាស៊ីមានអ្វីខ្លះ។

៧. យល់ដឹងអំពី កម្រិតនៃដំណើរការទទួលខុសត្រូវទាំងឡាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

៨. ដឹងថា ពួកគាត់អាចប្រើវិធីតស៊ូមតិផ្សេងៗក្នុងការព្យាយាមស្វែងរកដំណោះស្រាយ និងធ្វើឱ្យរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ីមានការទទួលខុសត្រូវ។

## ១. គោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីមិនត្រូវបានគេគោរពជានិច្ចនោះទេ

ទោះបីជា ធនាគារអភិវឌ្ឍន៍អាស៊ីមានគោលនយោបាយ ដែលនឹងការពារប្រជាពលរដ្ឋមិនឱ្យមានការខូចខាតដោយសារគម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារនេះក្តី ក៏ជាអកុសល មានពេលខ្លះ គោលនយោបាយទាំងនេះមិនត្រូវបានគេគោរពត្រឹមត្រូវទេ ដូច្នេះប្រជាពលរដ្ឋត្រូវផ្លាស់ប្តូរទីលំនៅ និង មានជីវភាពកាន់តែដុនដាបជាមុន។

មានករណីខ្លះទៀត ប្រជាពលរដ្ឋមិនទទួលបានសំណង ឬការតាំងទីលំនៅថ្មីសមរម្យទេ ទោះបីជា ពួកគាត់មានសិទ្ធិស្របច្បាប់ក្នុងការទទួលសំណង ឬចំពោះការតាំងទីលំនៅថ្មីនោះក៏ដោយ។ មានករណីខ្លះទៀត ពួកគាត់គ្មានការគាំទ្រសមរម្យទេ ដូចជាផ្តល់កម្មវិធីល្អៗ និងជំនួយផ្សេងៗទៀត ដើម្បីធានាថា ការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគាត់បានល្អប្រសើរ ឬយ៉ាងហោចអាចស្តារស្ថានភាពដូចដើមវិញ។

មានករណីជាច្រើនដែលប្រជាពលរដ្ឋមិនបានដឹង ឬមិនត្រូវបានពិគ្រោះយោបល់ត្រឹមត្រូវអំពីគម្រោងផលប៉ះពាល់របស់គម្រោង និងសិទ្ធិទទួលសំណង និងជម្រើសនានាទេ បើទោះបីជា ពួកគាត់មាន សិទ្ធិទទួលព័ត៌មាន និងពិគ្រោះយោបល់ទៅតាមគោលនយោបាយនោះក៏ដោយ។ នៅពេលដែលប្រជាពលរដ្ឋ ដែលត្រូវរដ្ឋឱ្យផ្លាស់ប្តូរទីលំនៅមិនទទួលបានព័ត៌មាន និងការពិគ្រោះយោបល់ត្រឹមត្រូវបែបនេះ ពួកគាត់តែងតែមិនសប្បាយចិត្តនឹងសំណង ការតាំងទីលំនៅថ្មី និងជំនួញប្រកបរបរចិញ្ចឹមជីវិតទេ ព្រោះរដ្ឋមិនបានពិចារណាអំពីគំនិត និងទស្សនៈដែលថា ត្រូវគាំទ្រពួកគាត់បែបណាទើបល្អបំផុតនោះទេ។



## ២. ការធ្វើឱ្យរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ីមានការទទួលខុសត្រូវ

មានកិច្ចការជាច្រើនដែលអ្នកអាចធ្វើបាន នៅពេលដែលគ្មានការគោរពគោលនយោបាយនោះ ដើម្បីធ្វើឱ្យរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ី **មានការទទួលខុសត្រូវ**។ "មានការទទួលខុសត្រូវ" មានន័យថា ប្រសិនបើរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ីខកខានមិនបានគោរពគោលនយោបាយនោះទេ ពេលនោះរដ្ឋាភិបាល និងធនាគារត្រូវទទួលខុសត្រូវ និងរកវិធីបញ្ឈប់កុំឱ្យមានការខូចខាតដល់ប្រជាពលរដ្ឋ ឬសងប្រជាពលរដ្ឋនូវការខូចខាតដែលបណ្តាលមកពីគម្រោងនោះ។ ប្រសិនបើ គម្រោងនោះនឹងបង្កឱ្យមានការខូចខាតធ្ងន់ធ្ងរ "មានការទទួលខុសត្រូវ" ក៏មានន័យដែរថា រដ្ឋនិងធនាគារត្រូវតែបញ្ឈប់ការអនុវត្តគម្រោង ប្រសិនបើរដ្ឋនិងធនាគារមិនអាចធានាបានថា គោលនយោបាយនោះត្រូវបានគោរពទេ។

វាអាស្រ័យទៅលើអ្នក និងប្រជាពលរដ្ឋផ្សេងៗទៀតដែលទទួលផលប៉ះពាល់ដោយសារគម្រោងនោះ ក្នុងការធ្វើការរួមគ្នាដើម្បីធ្វើឱ្យរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ីមានការទទួលខុសត្រូវ ដោយតាមដានយ៉ាងយកចិត្តទុកដាក់ ទទួលព័ត៌មានជាប្រចាំ ចូលរួមក្នុងការពិគ្រោះយោបល់ និងដោយដាក់ពាក្យបណ្តឹង ប្រសិនបើអ្នកមានបញ្ហា ឬកង្វល់ផ្សេងៗ។




## ៣. ការតាមដានគម្រោង

ដើម្បីធ្វើឱ្យរដ្ឋាភិបាលនិងធនាគារអភិវឌ្ឍន៍អាស៊ីមានការទទួលខុសត្រូវ វាមានសារៈសំខាន់ណាស់ ដែលប្រជាពលរដ្ឋត្រូវតែមានព័ត៌មាន និង**តាមដាន**គម្រោងជាប្រចាំ ដើម្បីឱ្យដឹងថា តើគោលនយោបាយនោះ ត្រូវបានគោរពតាមត្រឹមត្រូវទេ។

**របៀបតាមដានគម្រោង**

ការតាមដានគម្រោងត្រូវមានជំហានដូចខាងក្រោមនេះ:

- ប្រមូលព័ត៌មាន ជួបជជែកជាមួយប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ ចូលរួមក្នុងការពិគ្រោះយោបល់ និងសួរសំណួរអំពីគម្រោង។
- ឃ្លាំមើលដោយប្រុងប្រយ័ត្នចំពោះអ្វីៗដែលកើតឡើងនៅក្នុងសហគមន៍ដោយសារគម្រោង។
- គិតថា តើព័ត៌មានអ្វីដែលសំខាន់ ព្រោះវាប៉ះពាល់អ្នក ឬប្រជាពលរដ្ឋផ្សេងៗទៀត។
- កត់ត្រាព័ត៌មានសំខាន់ៗ: ឧទាហរណ៍ សរសេរ ឬថតរូប។
- រាយការណ៍អំពីព័ត៌មាននោះនៅពេលប្រជុំសហគមន៍ ឬរាយការណ៍ទៅអង្គការមិនមែនរដ្ឋាភិបាល ដែលផ្តល់

ការគាំទ្រ ធ្វើដូច្នេះអ្នកទាំងអស់គ្នាអាចសម្រេចចិត្តថាត្រូវចាត់វិធានការអ្វី។

វាជាគំនិតមួយល្អក្នុងការជ្រើសរើស អ្នកតាមដានគម្រោងពីរ-បីនាក់ពីសហគមន៍ដែលទទួលរង ផលប៉ះពាល់។ អ្នកតាមដានគម្រោង ជាមនុស្សដែលទទួលខុសត្រូវក្នុងការអនុវត្តជំហាន ដូចបាន រៀបរាប់ ខាងលើ ដើម្បីតាមដាន និងរាយការណ៍អំពីហេតុការណ៍ដែលកើតឡើងដោយសារគម្រោងនោះ។



មានចំណុចសំខាន់ៗបួន ដែលអ្នកអាចតាមដានដើម្បីឱ្យដឹងថា តើរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ី គោរព ឬមិន គោលនយោបាយនោះ។ ចំណុចទាំងបួននោះគឺៈ

១. អ្នកអាចតាមដានដើម្បីពិនិត្យផ្ទៀងផ្ទាត់ថា តើគណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុកការតាំង ទីលំនៅថ្មី ផ្តល់ *ព័ត៌មាន* សំខាន់ៗ ដែលអ្នកអាចយល់ដែរឬទេ។

២. អ្នកអាចតាមដានដើម្បីដឹងថា តើគណៈកម្មាធិការនេះកំពុងរៀបចំការប្រជុំ *ពិគ្រោះយោបល់* ត្រឹមត្រូវ ឬទេ។

៣. អ្នកអាចពិនិត្យផ្ទៀងផ្ទាត់ជាមួយនឹងផែនការតាំងទីលំនៅថ្មី ដើម្បីឱ្យប្រាកដថា សំណង និងជម្រើសនៃ ការតាំងទីលំនៅថ្មី គោរពទៅតាមគោលនយោបាយរបស់ធនាគារ និងដើម្បីឱ្យប្រាកដថា មានផែនការ ល្អៗសម្រាប់ *គាំទ្រដល់ការប្រកបរបរចិញ្ចឹមជីវិត* ព្រមទាំងទទួលបានផលចំណេញពីគម្រោងទាំងអស់គ្នា។

៤. អ្នកក៏អាចតាមដានលើ *របៀបនៃការអនុវត្តការតាំងទីលំនៅថ្មី* ដែរ ដើម្បីផ្ទៀងផ្ទាត់ថា គណៈកម្មាធិការអន្តរក្រសួងនោះអនុវត្តត្រឹមត្រូវទៅតាមផែនការ ។

ការប្រើព័ត៌មានដែលអ្នកកត់ត្រាទុកពីការតាមដានគម្រោងនោះ នាំឱ្យអ្នកនិងប្រជាពលរដ្ឋផ្សេងៗទៀត ដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង អាចទាមទារឱ្យរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ីមានការទទួលខុសត្រូវចំពោះការមិនគោរពគោលនយោបាយនោះ ។ កិច្ចការមួយចំនួនដែលអ្នកអាចអនុវត្ត នឹងត្រូវលើកមកពិភាក្សានៅពេលបន្ទាប់ ។



# លំហាត់ទី១០: ការតាមដានគម្រោង

**គោលបំណង: អ្នកចូលរួមនឹងដឹងថា មានកិច្ចការជាច្រើនដែលពួកគាត់អាចធ្វើបាន ប្រសិនបើគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីត្រូវរំលោភបំពាន ដើម្បីធ្វើឱ្យរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ីមានការទទួលខុសត្រូវ។ ពួកគាត់នឹងយល់ដឹងថាតើ "មានការទទួលខុសត្រូវ" មានន័យដូចម្តេច? អ្នកចូលរួមនឹងដឹងអំពី របៀបតាមដានគម្រោងណាមួយ និងចំណុចសំខាន់ៗអ្វីខ្លះដែលត្រូវតាមដាន។**



**សម្ភារៈ:** ក្ដារខៀន ឬក្រដាសផ្ទាំងធំ ហ្វឺត និងឯកសារសម្រាប់ចែកទី១

**វិធីសាស្ត្រប្រើប្រាស់:** ការពិភាក្សារួមគ្នា កិច្ចការជាក្រុម និងបទបង្ហាញ

| ដំណើរការ | រយៈពេល (គិតជានាទី) |
|---|---|
| ១. ណែនាំព័ត៌មាននៅក្នុងផ្នែក១ និងផ្នែក២ | ១៥ |
| ២. ការពិភាក្សាអំពីការទទួលខុសត្រូវ | ១៥ |
| ៣. ណែនាំព័ត៌មាននៅក្នុងផ្នែក៣ | ១៥ |
| ៤. ការរៀបចំផែនការតាមដាន | ២៥ |
| ៥. សង្ខេបដោយមានបទបង្ហាញ | ២០ |
| **សរុប:** | **៩០** |

# ការណែនាំសម្រាប់អ្នកសម្របសម្រួល

## ១. ណែនាំព័ត៌មាននៅក្នុងផ្នែក១និងផ្នែក២

**ផ្នែក១និងផ្នែក២:** វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមត្រូវយល់ដឹង:

- ថា ពេលខ្លះគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីមិនត្រូវបានគោរពទេ និងបណ្តាលឱ្យមានការខូចខាតដល់ប្រជាពលរដ្ឋ ដោយសារការអនុវត្តគម្រោង ដែលផ្តល់មូលនិធិគាំទ្រដោយធនាគារនេះ ។
- ថា មានកិច្ចការជាច្រើនដែលពួកគាត់អាចធ្វើបាន ដើម្បីធ្វើឱ្យរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ី មានការទទួលខុសត្រូវ ។
- អំពីអត្ថន័យនៃពាក្យ "មានការទទួលខុសត្រូវ" ។

## ២. ការពិភាក្សាអំពីការទទួលខុសត្រូវ

- សួរអ្នកចូលរួមមើលតើ ពួកគាត់ធ្លាប់មានការខូចខាតដោយសារការអនុវត្តគម្រោង ដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ីទេ ឬសួរពួកគាត់មើលថា តើពួកគាត់មាន ក្តីកង្វល់ថានឹងមានបញ្ហាកើតឡើងនៅក្នុងពេលអនាគតទេ។ សូមស្នើឱ្យអ្នកចូលរួម ម្នាក់ ឬ ពីរនាក់និយាយអំពីបញ្ហា ឬក្តីកង្វល់របស់គាត់ ។
- សួរពួកគាត់មើលថា តើគោលនយោបាយនោះត្រូវគេរំលោភបំពានទេ ប្រសិនបើត្រូវគេរំលោភបំពាន តើហេតុអ្វី?
- បន្ទាប់មកទៀត សួរពួកគាត់មើលថា តើពួកគាត់គិតថា អ្នកណាជាអ្នកដែលធ្វើឱ្យមានការខូចខាត ឬមានបញ្ហា និងសួរថា តើអ្នកណាគប្បីទទួលខុសត្រូវចំពោះបញ្ហានោះ ។
- ទីបំផុត សួរថា តើពួកគាត់គិតថា ពួកគាត់គប្បីត្រូវធ្វើអ្វីដើម្បីដោះស្រាយការខូចខាត ឬ បញ្ហានោះ និងសួរថា តើអ្នកណាជាអ្នកទទួលខុសត្រូវទង្វើនេះ ។

## ៣. ណែនាំព័ត៌មានក្នុងផ្នែក៣

**ផ្នែក៣:** វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមត្រូវយល់ដឹង:

- ថាហេតុអ្វីបានជាការតាមដានគម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ីមានសារៈសំខាន់ ។
- អំពីរបៀបតាមដានគម្រោង ។
- អំពីចំណុចសំខាន់ៗទាំងបួនដែលត្រូវតាមដាន ។

## ៤. ការរៀបចំផែនការតាមដាន

- ពន្យល់ថា អ្នកចូលរួមនឹងត្រូវចែកជាក្រុម។ ប្រសិនបើអាចធ្វើបាន ពួកគាត់គប្បីត្រូវធ្វើការជាមួយសមាជិកដែលមកពីសហគមន៍ដូចគ្នា។ ក្រុមទាំងនេះនឹងធ្វើផែនការមួយសម្រាប់ការតាមដានគម្រោងដែលធ្វើឱ្យប៉ះពាល់ដល់សហគមន៍របស់គាត់។ ពួកគាត់គប្បីត្រូវគិតអំពីបណ្ដាជំហានដែលពួកគាត់ត្រូវអនុវត្ត នៅពេលពួកគាត់ត្រឡប់ទៅសហគមន៍វិញ ដើម្បីតាមដានគម្រោង និងផលប៉ះពាល់របស់គម្រោងនោះមកលើប្រជាពលរដ្ឋ។
- ឧទាហរណ៍ ជាអ្នកតាមដានគម្រោង ពួកគាត់អាចនឹងសម្រេចចិត្តជួបប្រជាពលរដ្ឋ នៅក្នុងសហគមន៍ដើម្បីសម្ភាស។ ពួកគត់អាចនឹងសម្រេចចិត្តចុះទៅតំបន់តាំងទីលំនៅថ្មី ដើម្បីពិនិត្យស្ថានភាព និងដើម្បីជួបជជែកជាមួយប្រជាពលរដ្ឋដែលកំពុងរស់នៅទីនោះ។ ពួកគាត់អាចទៅជួបគណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុកការតាំងទីលំនៅថ្មី ដើម្បីសួរសំណួរមួយចំនួន ឬដើម្បីសុំថតចម្លងប្លង់តាំងទីលំនៅថ្មី។ ពួកគាត់អាចរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ ឬប្រជុំសហគមន៍។ ផែនការនេះត្រូវតែធ្វើឱ្យបានច្បាស់លាស់បំផុតតាមដែលអាចធ្វើបាន។
- ក្រុមទាំងនោះក៏គប្បីត្រូវគិតដែរអំពីរបៀបកត់ត្រាព័ត៌មាន។ ឧទាហរណ៍ តើពួកគាត់ត្រូវសរសេរ ថតសម្លេងពេលសម្ភាស ឬថតរូបថត ។ល។?
- តើពួកគាត់ត្រូវរាយការណ៍ព័ត៌មានយ៉ាងសំខាន់នេះទៅអ្នកណា? តើពួកគាត់ត្រូវធ្វើយ៉ាងណាដើម្បីឱ្យមានប្រជាពលរដ្ឋទាំងអស់នៅក្នុងសហគមន៍ ចូលរួមសម្រេចចិត្តថា តើត្រូវយកព័ត៌មាននេះទៅធ្វើអ្វី?
- ទុកពេល២០នាទី ឱ្យក្រុមនីមួយៗដើម្បីរៀបចំផែនការរបស់ក្រុម។

## ៥. សង្ខេបដោយមានបទបង្ហាញ

- អញ្ជើញក្រុមនីមួយៗឡើងបង្ហាញផែនការតាមដានរបស់ក្រុម។ ប្រសិនបើ ផែនការទាំងនោះមិនច្បាស់លាស់ទេ សូមសួរសំណួរដូចជា: តើពួកគាត់នឹងចុះទៅតំបន់តាំងទីលំនៅថ្មីនៅពេលណា? ឬតើពួកគាត់នឹងអញ្ជើញអ្នកណាឱ្យចូលរួមប្រជុំ?
- ក្រោយពីក្រុមនីមួយៗបញ្ចប់បទបង្ហាញរបស់ខ្លួន សូមសួរអ្នកចូលរួមក្រុមផ្សេងៗ ថាតើពួកគាត់មានយោបល់ ឬគំនិតអ្វីបន្ថែមដើម្បីឱ្យក្រុមអាចធ្វើផែនការរបស់ខ្លួនឱ្យកាន់តែល្អទេ?
- ដល់ចុងបញ្ចប់នៃលំហាត់នេះ សូមសួរសំណួរទាក់ទងនឹងការតាមដានគម្រោង ដែលផ្ដល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ដូចខាងក្រោមនេះ:

- តើហេតុអ្វីបានជាការតាមដានគម្រោងមានសារៈសំខាន់?
- តើមានជំហានអ្វីខ្លះក្នុងការតាមដានគម្រោង?
- តើចំណុចសំខាន់ទាំងបួនដែលត្រូវតាមដានមានអ្វីខ្លះ?

- សូមរំលឹកអ្នកចូលរួមទាំងអស់ថា ការតាមដានគម្រោងដើម្បីពិនិត្យមើលថា តើគោលនយោបាយនេះត្រូវបានគោរពយ៉ាងត្រឹមត្រូវ គឺជាជំហានទីមួយក្នុងការធ្វើឱ្យរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ីមានការទទួលខុសត្រូវ។ មេរៀនបន្ទាប់នេះនឹងពន្យល់ថា តើពួកគាត់អាចធ្វើអ្វីខ្លះ នៅពេលដែលពួកគាត់មានព័ត៌មានយ៉ាងសំខាន់ដែលទទួលបានពីការតាមដានគម្រោង។

# ៤. ការដោះស្រាយបញ្ហានានានៅមូលដ្ឋាន

## ៤.១ យន្តការបណ្តឹងសារទុក្ខនៅមូលដ្ឋាន

គោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីចែងថា រដ្ឋាភិបាលត្រូវតែរៀបចំឱ្យ**មានយន្តការបណ្តឹងសារទុក្ខនៅមូលដ្ឋាន** សម្រាប់គម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី។ នេះមានន័យថា ត្រូវរៀបចំឱ្យមានដំណើរការពិសេស ដោយគណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុកការតាំងទីលំនៅថ្មី ដើម្បីឱ្យអ្នកអាចដាក់ពាក្យបណ្តឹងអំពីក្តីកង្វល់ ឬបញ្ហានានា ដែលអ្នកមានដោយសារគម្រោងនោះ។ ក្តីកង្វល់របស់អ្នកនឹងត្រូវយកទៅពិចារណាយ៉ាងយកចិត្តទុកដាក់ រដ្ឋាភិបាលត្រូវតែស្វែងរកដំណោះស្រាយយ៉ាងល្អ ឱ្យបានកាន់តែរហ័សតាមដែលអាចធ្វើទៅបាន។

ដំណើរការបណ្តឹងនៅថ្នាក់មូលដ្ឋានត្រូវតែមានលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការអនុវត្ត និងមានលក្ខណៈដែលប្រជាពលរដ្ឋងាយយល់។ ដំណើរការនេះត្រូវតែមានលក្ខណៈងាយស្រួលដល់ស្ត្រី។ វាក៏ត្រូវតែមានលក្ខណៈងាយស្រួលដែរ សម្រាប់ក្រុមប្រជាពលរដ្ឋដែលងាយទទួលរងគ្រោះ និងទន់ខ្សោយដែលនិយាយភាសាផ្សេង។




ផែនការតាំងទីលំនៅថ្មីត្រូវតែមាន ព័ត៌មានអំពីដំណើរការបណ្តឹងនៅមូលដ្ឋាន។ គណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុកការតាំងទីលំនៅថ្មីត្រូវប្រាកដថា ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ ដោយសារគម្រោងទទួលបានព័ត៌មានគ្រប់គ្រាន់អំពីដំណើរការនេះ និងដឹងអំពីរបៀបអនុវត្តដំណើរការនេះ។

**ឧទាហរណ៍នៃយន្តការបណ្តឹងៈ គម្រោងផ្លូវរថភ្លើងនៅព្រះរាជាណាចក្រកម្ពុជា**

នៅក្នុងឆ្នាំ២០០៦ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ចេញផែនការតាំងទីលំនៅថ្មីមួយ ដែលជាគម្រោងផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីជួសជុលផ្លូវរថភ្លើងមួយខ្សែនៅកម្ពុជា។

ផែនការតាំងទីលំនៅថ្មីនេះ មានព័ត៌មានទាក់ទងនឹងយន្តការបណ្តឹង ដែលត្រូវបានរៀបចំឡើងសម្រាប់គម្រោងនេះ។ ផែនការតាំងទីលំនៅថ្មីនេះពន្យល់អំពីជំហាននានាដែលប្រជាពលរដ្ឋអាចអនុវត្ត ប្រសិនបើពួកគាត់មានបញ្ហា ឬកង្វល់នានាដោយសារគម្រោងនេះ។ ឧទាហរណ៍ ប្រសិនបើវុទ្ធីមានកង្វល់មួយអំពីតំបន់តាំងទីលំនៅថ្មី ដូច្នេះគាត់អាចធ្វើដូចខាងក្រោមនេះៈ

**ជំហានទី១ៈ** គាត់អាចដាក់បណ្តឹងរបស់គាត់ទៅអនុគណៈកម្មាធិការភូមិឬឃុំដែលទទួលបន្ទុក ការតាំងទីលំនៅថ្មី ឬដាក់បណ្តឹងរបស់គាត់ ទៅក្រុមការងាររបស់គណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុកខាងការតាំងទីលំនៅថ្មី។ អនុគណៈកម្មាធិការនោះត្រូវបញ្ជាក់ជាលាយលក្ខណ៍អក្សរប្រាប់វុទ្ធីថា បានទទួលពាក្យបណ្តឹងពីវុទ្ធី។

**ជំហានទី២ៈ** ប្រសិនបើរយៈពេល១៥ថ្ងៃក្រោយមក អនុគណៈកម្មាធិការនេះមិនឆ្លើយតបបណ្តឹងរបស់វុទ្ធីទេ ឬប្រសិនបើវុទ្ធីមិនសប្បាយចិត្តនឹងការឆ្លើយតបនោះទេ ពេលនោះគាត់អាចឡើងទៅសាលាស្រុក។

**ជំហានទី៣ៈ** ប្រសិនបើរយៈពេល១៥ថ្ងៃក្រោយមក នៅតែគ្មានដំណោះស្រាយទេ សាលាស្រុកត្រូវតែបញ្ជូនបណ្តឹងនោះទៅគណៈកម្មាធិការទទួលនិងដោះស្រាយបណ្តឹងថ្នាក់ខេត្ត។ គណៈកម្មាធិការនេះត្រូវតែជួបវុទ្ធី ដើម្បីរកដំណោះ។ គណៈកម្មាធិការនេះមានរយៈពេល៣០ថ្ងៃ ចាប់ពីថ្ងៃទទួលពាក្យបណ្តឹង ក្នុងការធ្វើសេចក្តីសម្រេចចិត្តជាលាយលក្ខណ៍អក្សរ។ គណៈកម្មាធិការនេះត្រូវតែប្រគល់ជូនវុទ្ធី និងរដ្ឋាភិបាលនូវសេចក្តីសម្រេចចិត្តជាលាយលក្ខណ៍អក្សរនេះមួយច្បាប់។

វាមានសារៈសំខាន់ណាស់ដែលត្រូវសរសេរបញ្ហា ឬកង្វល់នៅក្នុងលិខិត និងរក្សាវាទុកមួយច្បាប់។ វាក៏ជាគំនិតល្អម្យ៉ាងដែរ ដែលត្រូវផ្ញើលិខិតនេះមួយច្បាប់ទៅអង្គការមិនមែនរដ្ឋាភិបាលដែលជួយគាំទ្រ។ ប្រសិនបើបណ្តឹងរបស់អ្នកត្រូវបានសរសេរជា លាយលក្ខណ៍អក្សរ ដូច្នេះនៅពេលដែលអ្នកមិនអាចរកដំណោះស្រាយបាន ពេលនោះអ្នកអាចប្រើវាជាភស្តុតាងបញ្ជាក់ថា អ្នកបានព្យាយាមប្រើយន្តការដោះស្រាយបណ្តឹងនៅថ្នាក់មូលដ្ឋាន។ លុះក្រោយមកទៀត អ្នកអាចប្រើលិខិតបណ្តឹងនេះ ទៅអាជ្ញាធរថ្នាក់ខ្ពស់ជាងនេះ ឬទៅធនាគារអភិវឌ្ឍន៍អាស៊ី។

ប្រសិនបើអ្នកមិនចេះអាន ឬសរសេរទេ ដូច្នេះអ្នកអាចសុំឱ្យអ្នកណាម្នាក់នៅក្នុងសហគមន៍ជួយអ្នកបាន។ អ្នកក៏អាចទៅជួបជាមួយអង្គការមិនមែនរដ្ឋាភិបាលដើម្បីសុំជំនួយ។ អ្នកតាមដាននៅក្នុង គប្បីត្រូវមានវត្តមានជួយសមាជិកផ្សេងៗ នៅក្នុងសហគមន៍ក្នុងការរៀបចំ និងដាក់ពាក្យបណ្តឹង ឬក្នុងការជួបទាក់ទងអង្គការមិនមែនរដ្ឋាភិបាលដើម្បីសុំជំនួយ។

| គំរូនៃពាក្យបណ្ដឹង |
|---|
| **គោរពជូន: លោកប្រធានគណៈកម្មាធិការតាំងទីលំនៅថ្មីថ្នាក់ឃុំ**<br>**ចម្លងជូន:** ធនាគារអភិវឌ្ឍន៍អាស៊ី ប្រចាំរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា<br>នាងខ្ញុំឈ្មោះ អៀង សុធារី ជាប្រជាពលរដ្ឋម្នាក់ដែលទទួលរងផលប៉ះពាល់ដោយសារគម្រោងជួសជុលផ្លូវរថភ្លើង។ នាងខ្ញុំមានអាយុ៤២ឆ្នាំ មានមុខងារជាចុងភៅនៅភោជនីយដ្ឋានមួយនៅក្បែរផ្ទះរបស់ខ្ញុំ ដែលស្ថិតនៅក្នុងខណ្ឌដូនពេញ។ នាងខ្ញុំជាស្ត្រីមេម៉ាយ មានកូនបីនាក់ កូនស្រីពីរនាក់ និងកូនប្រុសម្នាក់។ កូនស្រីច្បង មានអាយុ១៧ឆ្នាំ និងកូនស្រីទី២មានអាយុ១៦ឆ្នាំ ចំណែកឯកូនប្រុសពៅមានអាយុ១០ឆ្នាំ។<br><br>គេបានប្រាប់ខ្ញុំថា ក្រុមគ្រួសាររបស់ខ្ញុំនឹងត្រូវផ្លាស់ទៅទីតាំងថ្មី ដោយទទួលបានដីមួយឡូតិ៍ មានទំហំ ៤ គុណ និង១៦ម៉ែត្រ នៅក្នុងខណ្ឌដង្កោ។ ខ្ញុំបារម្ភថា ទីតាំងថ្មីនេះស្ថិតនៅឆ្ងាយពេកពីកន្លែងធ្វើការរបស់ខ្ញុំនៅក្នុងទីក្រុង។ ខ្ញុំមិនអាចមានប្រាក់គ្រប់គ្រាន់សម្រាប់ចំណាយលើការធ្វើដំណើរបានទេ។ ខ្ញុំក៏បារម្ភដែរថា កូនស្រីទាំងពីររបស់ខ្ញុំនឹងមិនអាចបន្តការសិក្សារបស់នាងបានទេ ពីព្រោះគ្មានសាលាវិទ្យាល័យនៅជិតទីតាំងថ្មីនោះទេ។<br><br>ខ្ញុំគិតថា ការតាំងទីលំនៅថ្មីនេះ នឹងធ្វើឱ្យគ្រួសាររបស់ខ្ញុំកាន់តែក្រទៅ។<br><br>អាស្រ័យហេតុនេះ សូមគណៈកម្មាធិការតាំងទីលំនៅថ្មីមេត្តារកជម្រើសផ្សេង សម្រាប់គ្រួសាររបស់ខ្ញុំ ដើម្បីឱ្យយើងខ្ញុំអាចបន្តរស់នៅជិតកន្លែងធ្វើការ និងមានសេវាកម្មសំខាន់ៗនៅក្នុងទីក្រុង។<br><br>សូមលោកប្រធានទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។<br><br>ធ្វើនៅភ្នំពេញ, ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១០<br><br>(ស្នាមផ្តិតមេដៃ)<br><br>អៀង សុធារី |

## ៤.២. ការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា

ជាការល្អ នៅពេលអ្នកផ្ញើចេញ ឬទទួលលិខិតនៅក្នុងដំណើរការនៃបណ្តឹងតវ៉ា អ្នកគប្បីត្រូវផ្ញើលិខិតនោះមួយច្បាប់ទៅការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំនៅកម្ពុជា។ ប្រសិនបើអ្នករស់នៅក្នុងរាជធានីភ្នំពេញ អ្នកអាចយកសំបុត្រនោះ ទៅជូនធនាគារដោយផ្ទាល់ដៃ។ ប្រសិនបើអ្នកមានការលំបាក ក្នុងការផ្ញើលិខិតនោះទៅការិយាល័យធនាគារ

អភិវឌ្ឍន៍អាស៊ី អ្នកអាចស្នើសុំអង្គការមិនមែនរដ្ឋាភិបាលដែលគាំទ្រ អ្នកឱ្យជួយអ្នកក្នុងការផ្ញើលិខិតនោះទៅការិយាល័យធនាគារនោះបាន។

ប្រសិនបើអ្នកបានព្យាយាមប្រើប្រាស់យន្តការបណ្តឹងនៅមូលដ្ឋានដែរ ប៉ុន្តែបញ្ហារបស់អ្នក មិនត្រូវបានដោះស្រាយទេ វាមានសារៈសំខាន់ណាស់ ដែលអ្នកត្រូវទាក់ទងជួបជាមួយការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំនៅកម្ពុជា ដើម្បីពន្យល់អំពីបញ្ហា និងក្តីកង្វល់នានារបស់អ្នក។ អ្នកអាចស្នើសុំអង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់ការគាំទ្រ ដើម្បីជួយអ្នកក្នុងការផ្ញើលិខិត ឬជួយរៀបចំការជួបប្រជុំជាមួយបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលធ្វើការងារលើគម្រោង នោះ។

អ្នកអាចស្វែងរកព័ត៌មានលម្អិត អំពីការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំនៅកម្ពុជា និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ដែលអ្នកអាចទាក់ទងឱ្យជួយអ្នកក្នុងរឿងនេះ មាននៅផ្នែកខាងក្រោយនៃសៀវភៅនេះ។

## ៤.៣. តុលាការកម្ពុជា

ប្រសិនបើច្បាប់ណាមួយត្រូវបានរំលោភបំពានដោយគម្រោងនេះ ដែលធ្វើឱ្យមានការខូចខាតដល់អ្នក ដូច្នេះអ្នកមានសិទ្ធិទៅតុលាការដើម្បីស្វែងរកដំណោះស្រាយ និងធ្វើឱ្យរដ្ឋាភិបាលមានការទទួលខុសត្រូវ។

ច្បាប់មួយចំនួនត្រូវគេរំលោភបំពាន ដែលនាំឱ្យអ្នកត្រូវផ្លាស់ប្តូរទីលំនៅ ព្រមទាំងមិនទទួលបានសងសំណងសមរម្យទេ។ ច្បាប់ទាំងនេះមានដូចជា:

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ភូមិបាល ឆ្នាំ២០០១ និង
- ច្បាប់អស្សាមិករណ៍ ឆ្នាំ២០១០

ប្រសិនបើអ្នកចង់រកព័ត៌មានបន្ថែម ដើម្បីដឹងថា តើច្បាប់ត្រូវ ឬមិនត្រូវគេរំលោភបំពាន និង ចង់ដឹងថាតើអ្នកអាច ឬមិនអាចដាក់បណ្តឹងទៅតុលាការនោះ អ្នកអាចទាក់ទងជួបមេធាវី ឬអង្គការជំនួយផ្នែកច្បាប់ ដែលមានរាយឈ្មោះនៅក្នុងផ្នែកខាងក្រោយនៃសៀវភៅនេះ។



**បញ្ហាក្នុងការប្រើប្រាស់តុលាការនៅព្រះរាជាណាចក្រកម្ពុជា**

វាមានសារៈសំខាន់ណាស់ដែលអ្នកត្រូវកត់សម្គាល់ថា មានប្រជាពលរដ្ឋជាច្រើនបានដាក់បណ្តឹង ទៅតុលាការ ប៉ុន្តែតុលាការគ្មានចៅក្រមគ្រប់គ្រាន់ក្នុងការដោះស្រាយរឿងក្តីទាំងអស់បានរហ័សទេ។ នេះមានន័យថា វាអាចប្រើពេលយូរណាស់ មុននឹងតុលាការបើកសវនាការ និងចេញសាលក្រមអំពីរឿងក្តីរបស់អ្នក។ មានពេលខ្លះ ចៅក្រមទាំងនោះក៏ទទួលរងឥទ្ធិពលដោយកត្តាជាច្រើនទៀត និងមិនបានធ្វើសេចក្តីសម្រេចចិត្តទៅតាមច្បាប់ ឬទៅតាមអ្វីដែលអ្នកគិតថា ជាការសម្រេចចិត្តដោយយុត្តិធម៌នោះទេ។

ដោយហេតុដូច្នេះហើយ វាជាគំនិតល្អណាស់ដែលអ្នកត្រូវធ្វើអ្វីៗផ្សេងទៀតដើម្បីស្វែងរកដំណោះស្រាយ ដូចជាការប្រើប្រាស់យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ីជាដើម។ វាក៏ជាគំនិតល្អណាស់ដែរ ដែលអ្នកត្រូវប្រើទម្រង់នៃការតស៊ូមតិផ្សេងៗ ដូចជា ការនិយាយទៅកាន់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជាដើម។ យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងទម្រង់នៃការតស៊ូមតិផ្សេងៗ នឹងត្រូវបានលើកមកពិភាក្សានៅក្នុងផ្នែកបន្ទាប់។

## លំហាត់ទី១១: ការធ្វើឱ្យរដ្ឋាភិបាលនិងធនាគារអភិវឌ្ឍន៍អាស៊ីទទួលខុសត្រូវ: យន្តការនៅមូលដ្ឋាន

**គោលបំណង:** អ្នកចូលរួមនឹងដឹងថា រដ្ឋាភិបាលត្រូវតែរៀបចំឱ្យមានយន្តការដោះស្រាយបណ្តឹងនៅមូលដ្ឋាន ដែលប្រជាពលរដ្ឋអាចប្រើបាន ព្រមទាំងស្វែងរកដំណោះស្រាយជូនពួកគាត់។ អ្នកចូលរួមក៏ដឹងដែរថា នៅពេលណាដែលពួកគាត់អាចដាក់បណ្តឹងទៅតុលាការ និងដឹងអំពីបញ្ហាមួយចំនួនក្នុងការប្រើប្រាស់តុលាការនៅកម្ពុជា។

**សម្ភារ:** ក្តារខៀន ឬក្រដាសផ្ទាំងធំ ហ្វឺត ឯកសារសម្រាប់ចែកទី១

**វិធីសាស្ត្រប្រើប្រាស់:** ការពិភាក្សារួមគ្នា

| **ដំណើការ** | **រយៈពេល (គិតជានាទី)** |
|---|---|
| ១. ណែនាំព័ត៌មាននៅក្នុងផ្នែក៤.១ និង៤.២ | ២០ |
| ២. ការពិភាក្សារួមគ្នា អំពីដំណើរការបណ្តឹងនៅមូលដ្ឋាន | ១៥ |
| ៣. ណែនាំព័ត៌មាននៅក្នុងផ្នែក៤.៣ | ១០ |
| ៤. សង្ខេបអំពីដំណើរការបណ្តឹងនៅមូលដ្ឋាន | ១៥ |
| **សរុប:** | **៦០** |

# ការណែនាំសម្រាប់អ្នកសម្របសម្រួល

## ១. ណែនាំព័ត៌មាននៅក្នុងផ្នែក៤.១ និង៤.២

**ផ្នែក៤.១ និង ៤.២:** វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមទាំងអស់ត្រូវយល់ដឹងថាៈ

- គោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីចែងថា រដ្ឋាភិបាលត្រូវតែរៀបចំឱ្យមានយន្តការ បណ្ដឹងនៅមូលដ្ឋាន សម្រាប់គម្រោងដែលផ្ដល់មូលនិធិគាំទ្រ ដោយធនាគារអភិវឌ្ឍន៍អាស៊ី។
- យន្តការបណ្ដឹងនេះត្រូវតែស្វែងរកដំណោះស្រាយចំពោះបញ្ហារបស់ប្រជាពលរដ្ឋ។
- យន្តការនេះត្រូវតែមានលក្ខណៈងាយស្រួលក្នុងការអនុវត្ត។
- គណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុកការតាំងទីលំនៅថ្មី ត្រូវតែធ្វើឱ្យប្រាកដថា ប្រជាពលរដ្ឋ ដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង ទទួលបានព័ត៌មានគ្រប់គ្រាន់និងច្បាស់លាស់អំពី យន្តការបណ្ដឹងតវ៉ានេះ ព្រមទាំងយល់ដឹងថា តើពួកគាត់អាចប្រើប្រាស់វាដោយរបៀបណា។

*(សូមកុំអាលអានឧទាហរណ៍អំពី យន្តការបណ្ដឹង សម្រាប់គម្រោងផ្លូវរថភ្លើង)*

- វាជាគំនិតមួយល្អដែលអ្នកធ្វើបណ្ដឹងជាលាយលក្ខណ៍អក្សរ និងផ្ញើវាមួយច្បាប់ ទៅការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ីនៅរាជធានីភ្នំពេញ។
- ប្រសិនបើគ្មានដំណោះស្រាយណាមួយទេ វាមានសារៈសំខាន់ណាស់ដែលអ្នកត្រូវទាក់ទងទៅ ការិយាល័យធនាគារ អភិវឌ្ឍន៍អាស៊ីប្រចាំនៅប្រទេសកម្ពុជា ដើម្បីស្វែងរកដំណោះស្រាយបញ្ហា។

## ២. ការពិភាក្សារួមគ្នាអំពីយន្តការបណ្ដឹងនៅមូលដ្ឋាន

- សួរអ្នកចូលរួមមើល តើពួកគាត់ធ្លាប់បានឮអំពីយន្តការបណ្ដឹងនៅមូលដ្ឋានសម្រាប់គម្រោង ដែលប៉ះពាល់ដល់ពួកគាត់ទេ។

- ប្រសិនបើពួកគាត់ធ្លាប់បានឮ សូមសួរថា តើពួកគាត់បានឮអ្វីខ្លះអំពីដំណើរការនៃយន្តការនោះ និងសួរថា តើមានអ្នកណាម្នាក់ធ្លាប់បានប្រើយន្តការនោះដែរឬទេ។ តើពួកគាត់ធ្លាប់មានបទពិសោធន៍អ្វីខ្លះ? តើពួកគាត់គិតថាយន្តការនេះល្អងាយស្រួលក្នុងការអនុវត្តទេ?

- សូមអាន ឬពន្យល់អំពីយន្តការបណ្ដឹង សម្រាប់គម្រោងផ្លូវរថភ្លើង រួចសួរអ្នកចូលរួមមើល តើពួកគាត់គិតថា ជាយន្តការនេះល្អទេ?

- ប្រសិនបើពួកគាត់មិនធ្លាប់បានឮអំពីយន្តការបណ្ដឹងនៅមូលដ្ឋានទេ អ្នកអាចពន្យល់ថា រដ្ឋាភិបាលមានកាតព្វកិច្ច ត្រូវបង្កើតយន្តការនេះមួយ និងត្រូវជូនដំណឹងអំពីយន្តការនេះឱ្យប្រជាពលរដ្ឋដឹង។

- ប្រសិនបើអ្នកចូលរួមមានចំណាប់អារម្មណ៍ ក្នុងការដាក់បណ្ដឹងទៅយន្តការបណ្ដឹងនេះ អ្នកអាចរៀបចំពេលមួយនៅក្នុងពេលធ្វើសិក្ខាសាលានេះ ឬក្រោយពីចប់សិក្ខាសាលានេះ ដើម្បីជួយពួកគាត់ក្នុងការសរសេរបណ្ដឹង ពន្យល់អំពីបញ្ហា និងក្ដីបារម្ភរបស់ពួកគាត់។

- សូមប្រគល់ឯកសារសម្រាប់ចែកទី១ អំពីពាក្យបណ្ដឹងដែលជាឧទាហរណ៍ ទៅអ្នកចូលរួម និង ពន្យល់ថាពួកគាត់អាចប្រើឯកសារនេះជាឧទាហរណ៍ ដើម្បីជួយពួកគាត់ក្នុងការសរសេរពាក្យបណ្ដឹង។

## ៣. ណែនាំព័ត៌មាននៅក្នុងផ្នែក៤.៣

**ផ្នែក៤.៣:** *វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមត្រូវយល់ដឹងៈ*

- ថា ប្រសិនបើច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ត្រូវគេរំលោភបំពានដោយសារគម្រោង និងធ្វើឱ្យប្រជាពលរដ្ឋមានការខូចខាត ដូច្នេះពួកគាត់មានសិទ្ធិប្ដឹងទៅតុលាការដើម្បីឱ្យរដ្ឋាភិបាល មានការទទួលខុសត្រូវ។
- អំពីបញ្ហាមួយចំនួនក្នុងការប្រើប្រាស់តុលាការនៅកម្ពុជា។

## ៤. សង្ខេបអំពីការប្រើប្រាស់យន្តការបណ្ដឹងនៅមូលដ្ឋាន

- សួរអ្នកចូលរួមមើលតើពួកគាត់មានដែលធ្លាប់ពាក់ព័ន្ធក្នុងរឿងក្ដីនៅតុលាការទេ។ ប្រសិនបើធ្លាប់ សូមឱ្យគាត់ជួយចែករំលែកអំពីបទពិសោធន៍របស់គាត់។

- សួរអ្នកចូលរួមមើលថា តើពួកគាត់គិតថា ការប្រើប្រាស់តុលាការជាមធ្យោបាយមួយល្អ ក្នុងការស្វែងរកដំណោះស្រាយបញ្ហារបស់ពួកគាត់ និងក្នុងការធ្វើឱ្យរដ្ឋាភិបាលទទួលខុសត្រូវ នៅពេលដែលមានការរំលោភ ច្បាប់ដែរឬទេ?

- តើពួកគាត់គិតថា តើការប្រើប្រាស់យន្តការនៅថ្នាក់មូលដ្ឋានអាចជាមធ្យោបាយ ដែលអាចទទួលបានជោគជ័យក្នុងការស្វែងរកដំណោះស្រាយបញ្ហានានា ដែលបណ្ដាលមកពីគម្រោង ដែលផ្ដល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ីទេ? ហេតុអ្វីអាច ឬហេតុអ្វីមិនអាច? សូមលើកទឹកចិត្តអ្នកចូលរួមឱ្យចូលរួមចែករំលែក និងពិភាក្សាគ្នាអំពីយោបល់គំនិត និងរឿងរ៉ាវនានារបស់ពួកគាត់ អំពីការប្រើប្រាស់យន្តការនៅមូលដ្ឋាន ដើម្បីធ្វើឱ្យរដ្ឋាភិបាល ឬអ្នកដទៃមានការទទួលខុសត្រូវ។

- ពន្យល់ថា នៅក្នុងលំហាត់ក្រោយ អ្នកនឹងពិភាក្សាថា តើពួកគាត់អាចធ្វើអ្វី ប្រសិនបើពួកគាត់មិនអាចរកដំណោះស្រាយដោយប្រើយន្តការបណ្ដឹងថ្នាក់មូលដ្ឋានទេ។

## ឯកសារសម្រាប់ផ្នែកទី១៖ លំហាត់ទី១១

### ឧទាហរណ៍នៃពាក្យបណ្តឹង

**គោរពជូន:** លោកប្រធានគណៈកម្មាធិការតាំងទីលំនៅថ្មីថ្នាក់ឃុំ

**ចម្លងជូន:** ធនាគារអភិវឌ្ឍន៍អាស៊ី ប្រចាំរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា

នាងខ្ញុំឈ្មោះ អៀង សុធារី ជាប្រជាពលរដ្ឋម្នាក់ដែលទទួលរងផលប៉ះពាល់ដោយសារគម្រោងជួសជុលផ្លូវរថភ្លើង។ នាងខ្ញុំមានអាយុ៤២ឆ្នាំ មានមុខងារជាចុងភៅនៅភោជនីយដ្ឋានមួយនៅក្បែរផ្ទះរបស់ខ្ញុំ ដែលស្ថិតនៅក្នុង ខណ្ឌដូនពេញ។ នាងខ្ញុំជាស្ត្រីមេម៉ាយ មានកូនបីនាក់ កូនស្រីពីរនាក់ និងកូនប្រុសម្នាក់។ កូនស្រីច្បងមានអាយុ១៧ឆ្នាំ និង កូនស្រីទី២មានអាយុ១៦ឆ្នាំ ចំណែកឯកូនប្រុសពៅមានអាយុ១០ឆ្នាំ។

គេបានប្រាប់ខ្ញុំថា ក្រុមគ្រួសាររបស់ខ្ញុំនឹងត្រូវផ្លាស់ទៅទីតាំងថ្មី ដោយទទួលបានដីមួយឡូតិ៍ មានទំហំ ៤ គុណនិង១៦ម៉ែត្រ នៅក្នុងខណ្ឌដង្កោ។ ខ្ញុំបារម្ភថា ទីតាំងថ្មីនេះស្ថិតនៅឆ្ងាយពេកពីកន្លែងធ្វើការរបស់ខ្ញុំនៅក្នុងទីក្រុង។ ខ្ញុំមិនអាចមានប្រាក់គ្រប់គ្រាន់សម្រាប់ចំណាយលើការធ្វើដំណើរបានទេ។ ខ្ញុំក៏បារម្ភដែរថា កូនស្រីទាំងពីររបស់ខ្ញុំនឹងមិនអាចបន្តការ សិក្សារបស់នាងបានទេ ពីព្រោះគ្មានសាលាវិទ្យាល័យនៅជិតទីតាំងថ្មីនោះទេ។

ខ្ញុំគិតថា ការតាំងទីលំនៅថ្មីនេះ នឹងធ្វើឱ្យគ្រួសាររបស់ខ្ញុំកាន់តែក្រទៅ។

អាស្រ័យហេតុនេះ សូមគណៈកម្មាធិការតាំងទីលំនៅថ្មី មេត្តារកជម្រើសផ្សេងសម្រាប់គ្រួសាររបស់ខ្ញុំ ដើម្បីឱ្យយើងខ្ញុំ អាចបន្តរស់នៅជិតកន្លែងធ្វើការ និងមានសេវាកម្មសំខាន់ៗនៅក្នុងទីក្រុងផង។

សូមលោកប្រធានទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១០

(ស្នាមផ្តិតមេដៃ)

អៀង សុធារី

# ៥. ការប្រើប្រាស់យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី

ធនាគារអភិវឌ្ឍន៍អាស៊ីមានយន្តការរបស់ខ្លួនផ្ទាល់ សម្រាប់ដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋ ដែលទទួលរងការខូចខាត ឬដែលគិតថា ពួកគាត់នឹងត្រូវទទួលរងការខូចខាតដោយសារគម្រោង ដែលផ្តល់មូលនិធិគាំទ្រដោយធនាគារ អភិវឌ្ឍន៍អាស៊ី។ យន្តការនេះមានឈ្មោះថា **យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី**។ យន្តការនេះមានពីរដំណាក់កាល ដែលនឹងត្រូវពន្យល់នៅខាងក្រោមនេះ។ ការិយាល័យនៃយន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី មានទីតាំងស្ថិតនៅឯការិយាល័យធំនៅក្រុងម៉ានីលប្រទេសហ្វីលីពីន។

វាមានសារៈសំខាន់ណាស់ដែលអ្នកត្រូវលើកឡើងនូវក្តីកង្វល់ និងបញ្ហានានារបស់អ្នកទៅ គណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុកការតាំងទីលំនៅថ្មី និងទៅបុគ្គលិករបស់ធនាគាអភិវឌ្ឍន៍អាស៊ីនៅក្នុងប្រទេសចិនព្រមទាំងត្រូវព្យាយាមប្រើយន្តការដោះស្រាយបណ្តឹងនៅមូលដ្ឋាន សម្រាប់គម្រោងនោះ មុននឹងដាក់បណ្តឹងទៅយន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ប្រសិនបើអ្នកមិនទាន់បានដាក់ពាក្យបណ្តឹង ដើម្បីរកដំណោះស្រាយនៅឯការិយាល័យរបស់ធនាគារអភិវឌ្ឍន៍អាស៊ីនៅក្នុងប្រទេសកម្ពុជាជាមុនសិនទេ នោះយន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ីនឹងមិនទទួលបណ្តឹងរបស់អ្នកទេ។

ប៉ុន្តែប្រសិនបើអ្នកមិនអាចរកដំណោះស្រាយបានល្អពីរដ្ឋាភិបាល និងពីបុគ្គលិកធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំនៅក្នុងប្រទេសទេ ដូច្នេះអ្នកអាចប្រើយន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីស្វែងរកដំណោះស្រាយបញ្ហារបស់អ្នកបាន។

ប្រសិនបើអ្នកចង់ផ្ញើបណ្តឹងចេញ អ្នកប្រហែលជាត្រូវស្វែងរកព័ត៌មានបន្ថែមទៀត និងស្វែងរកការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល។ ព័ត៌មានលម្អិតរបស់ការិយាល័យអង្គការមិនមែនរដ្ឋាភិបាល ដែលអ្នកអាចទាក់ទងសុំឱ្យជួយអ្នកក្នុងការ ផ្ញើបណ្តឹងរបស់អ្នក និងការប្រើប្រាស់យន្តការគណនេយ្យភាពរបស់ធនាគារអភិឌ្ឍន៍អាស៊ី មាននៅផ្នែកខាងក្រោយនៃសៀវភៅនេះ។

## ៥.១ ដំណាក់កាលនៃការពិគ្រោះយោបល់: ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស

ប្រសិនបើ អ្នកសម្រេចចិត្តថា ត្រូវប្រើប្រាស់យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី កិច្ចការដំបូងដែលអ្នកអាចធ្វើបានគឺត្រូវធ្វើលិខិតទៅ **ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស**។ ការិយាល័យនេះត្រូវបានបង្កើត ឡើងជាពិសេសដោយធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីដោះស្រាយក្តីបារម្ភរបស់ប្រជាពលរដ្ឋ អំពីគម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី។ នៅពេលដែលការិយាល័យនេះបានយល់ព្រមទទួលបណ្តឹងណាមួយហើយក្រុមអ្នកសម្របសម្រួលគម្រោងពិសេសនេះ នឹងព្យាយាមរកដំណោះស្រាយបញ្ហាទាំងនោះ ដោយចុះទៅស្វែងយល់អំពីស្ថានភាពជាក់ស្តែង និងបន្ទាប់មក លើកសំណើថា តើបញ្ហាទាំងនោះអាចដោះស្រាយដោយរបៀបណា។



*មន្ត្រីអ្នកសំរបសំរួលការិយាល័យគំរោងពិសេស ចុះស៊ើបអង្កេតស្ថានភាពបន្ទាប់ពីទទួលពាក្យបណ្តឹង*

ប្រជាពលរដ្ឋដែលជាអ្នកដាក់ពាក្យបណ្តឹង ធនាគារអភិវឌ្ឍន៍អាស៊ី គណៈកម្មាធិករអន្តរក្រសួងទទួលបន្ទុកការតាំងទីលំនៅថ្មី និងអ្នកផ្សេងៗទៀតដែលពាក់ព័ន្ធចាំបាច់ត្រូវតែឯកភាពគ្នាលើដំណោះស្រាយ។ អ្នកនឹងមានឱកាសពន្យល់អំពីគំនិត និងទស្សនៈរបស់អ្នកអំពីសំណើរបស់ក្រុមអ្នកសម្របសម្រួលគម្រោងពិសេសនេះ។ ហេតុដូច្នេះ គេហៅវាថាជា "ដំណាក់កាលពិគ្រោះយោបល់"។

ប្រសិនបើគ្រប់គ្នាឯកភាពលើដំណោះស្រាយនោះ ពួកគាត់នឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយ។ វាមានសារៈសំខាន់ណាស់ ដែលអ្នកត្រូវតាមដានការអនុវត្តកិច្ចព្រមព្រៀងនោះ ដើម្បីធ្វើឱ្យប្រាកដថា បញ្ហារបស់អ្នកត្រូវបានដោះស្រាយត្រឹមត្រូវ។ ការតាមដាននេះ ក៏ជាការទទួលខុសត្រូវរបស់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេសដែរ។

នៅផ្នែកខាងក្រោយនៃសៀវភៅនេះ មានព័ត៌មានលម្អិតរបស់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេសនេះសម្រាប់ទាក់ទង។

## ករណីសិក្សា៖ ផ្លូវជាតិនៅប្រទេសប៉ាគីស្ថាន

នៅឆ្នាំ២០០៦ ធនាគារអភិវឌ្ឍន៍អាស៊ី បានយល់ព្រមផ្តល់ប្រាក់កម្ចីទៅរដ្ឋាភិបាលប្រទេសប៉ាគីស្ថា ដើម្បីជួសជុលកែលម្អផ្លូវជាតិមួយខ្សែ។ ប្រជាជនដែលត្រូវទទួលរងផលប៉ះពាល់ដោយសារគម្រោងនេះ មានក្តីបារម្ភថា ពួកគាត់នឹងត្រូវរដ្ឋាភិបាលឱ្យផ្លាស់ប្តូរទីលំនៅ និងមានក្តីបារម្ភថា រដ្ឋមិនផ្តល់សំណងជូនពួកគាត់ត្រឹមត្រូវទេ។ ពួកគាត់បានផ្ញើលិខិតមួយច្បាប់ទៅការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស ដោយបង្ហាញអំពីក្តីបារម្ភរបស់ពួកគាត់។

ក្រុមអ្នកសម្របសម្រួលនៃការិយាល័យនេះបានស្តាប់ប្រជាជន អំពីក្តីបារម្ភរបស់គាត់។ ប្រជាជនបារម្ភខ្លាចបាត់បង់មុខរបរចិញ្ចឹមជីវិត ប្រសិនបើរដ្ឋឱ្យពួកគាត់ផ្លាស់ប្តូរទីលំនៅដោយសារគម្រោងនេះ។ ពួកគាត់ខ្លាចរដ្ឋមិនផ្តល់សំណងដល់ពួកគត់ ឬផ្តល់សំណងឱ្យពួកគាត់មិនទាន់ពេល។ គេមិនបានជូនដំណឹងពួកគាត់ថា តើគេនឹងផ្តល់សំណងឱ្យពួកគាត់ចំនួនប៉ុន្មាននោះទេ។ ស្ត្រីៗមានក្តីបារម្ភថា ប្រសិនបើរដ្ឋឱ្យពួកគាត់ផ្លាស់ប្តូរទីលំនៅ នោះពួកគាត់នឹងគ្មានកន្លែងរស់នៅទេ។ ពួកគាត់នឹកគិតថា នៅពេលដែលភូមិរបស់គាត់ត្រូវព័ទ្ធជុំវិញដោយផ្លូវជាតិ ដែលមានបួនជួរនោះ តើកូនៗរបស់គាត់ធ្វើម៉េចនឹងអាចទៅ ដល់សាលារៀនដោយសុវត្ថិភាព ឬថា តើគោក្របីរបស់ពួកគាត់ធ្វើម៉េច អាចដើរឆ្លងផ្លូវដែលមានរថយន្ត រត់ទៅមក យ៉ាងច្រើននោះបានទៅ។[៦]

សហគមន៍ រដ្ឋាភិបាល និងបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ីដែលធ្វើការលើគម្រោងនោះ សុទ្ធតែឯកភាពគ្នាថានឹងផ្តល់ព័ត៌មានកាន់តែងាយយល់ទាក់ទងនឹងគម្រោងជូនសហគមន៍។ ពួកគេទាំងអស់ក៏បានឯកភាពគ្នាដែរថា គេនឹងត្រូវពិគ្រោះយោបល់ជាមួយសហគមន៍អំពីផែនការតាំងទីលំនៅថ្មីមុននឹងចេញផែនការស្ថាពរ។

ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេសនេះ បានបើកកិច្ចប្រជុំពិគ្រោះយោបល់ពេញមួយ ថ្ងៃរួមមួយដែលមានសហគមន៍និងមន្ត្រីរដ្ឋាភិបាលពាក់ព័ន្ធចូលរួម។ អង្គប្រជុំពិគ្រោះយោបល់នោះបានឯកភាពគ្នា ពេលប្រជុំនោះថា រដ្ឋាភិបាលត្រូវអនុវត្តដូចខាងក្រោមនេះ៖

- ផ្ញើជូនសហគមន៍នូវបញ្ជីគ្រួសារប្រជាជនទាំងអស់ដែលនឹងត្រូវទទួលរងផលប៉ះពាល់
- ពន្យល់អំពីរបៀបគណនាអត្រាប្រាក់សំណង
- ពិចារណាលើសំណើរបស់ប្រជាជនដែលសុំទទួលអត្រាសំណងច្រើនជាង
- ផ្តល់ជូនសហគមន៍នូវផែនការតាំងទីលំនៅថ្មីដែលកែសម្រួលរួចហើយ និង
- បើកកិច្ចប្រជុំពិគ្រោះយោបល់ជាមួយសហគមន៍អំពីផែនការតាំងទីលំនៅថ្មីដែលកែសម្រួលនេះ។

[៦] ដកស្រង់ពីរបាយការណ៍ចុងក្រោយរបស់ក្រុមអ្នកសម្របសម្រួលគម្រោងពិសេស ស្តីពីកម្មវិធីវិនិយោគលើវិស័យអភិវឌ្ឍន៍ផ្លូវជាតិ នៅប្រទេសប៉ាគីស្ថាន៖ ខែមីនា ឆ្នាំ២០១០។

ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេសនេះ បានរក្សាទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយ សហគមន៍ រដ្ឋាភិបាល និងបុគ្គលិកធនាគារអភិវឌ្ឍន៍អាស៊ីដែលធ្វើការលើគម្រោងនេះ ដើម្បីតាមដានការអនុវត្តកិច្ចព្រមព្រៀងនោះ។ បុគ្គលិកធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់យោបល់ និងណែនាំរដ្ឋាភិបាល ក្នុងការរៀបចំ និងអនុវត្តផែនការតាំងទីលំនៅថ្មី។ រដ្ឋាភិបាលបានបង្កើនប្រាក់សំណងជូនគ្រួសារ ដែលជាអ្នកទទួលរងផលប៉ះពាល់។

## ៥.២. ការពិនិត្យការប្រតិបត្តិ

ប្រសិនបើអ្នកមិនអាចរកបានដំណោះស្រាយល្អនៅក្នុងដំណាក់កាលនៃការពិគ្រោះយោបល់នេះទេ ឬប្រសិនបើអ្នកមិនសប្បាយចិត្តនឹងរបៀបនៃការអនុវត្តផែនការនោះទេ ដូច្នេះអ្នកអាចដាក់ពាក្យបណ្តឹងទៅ **ក្រុមពិនិត្យការប្រតិបត្តិ**។ អ្នកមិនត្រូវរង់ចាំរហូតទាល់តែការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស បញ្ចប់ដំណាក់កាលនៃការពិគ្រោះយោបល់ ដើម្បីធ្វើពាក្យបណ្តឹងទៅក្រុមពិនិត្យការប្រតិបត្តិនោះទេ។ ឧទាហរណ៍ ប្រសិនបើអ្នកមិនសប្បាយចិត្តនឹងសំណើនានារបស់ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេសទេ ដូច្នេះ អ្នកអាចសម្រេចចិត្តបញ្ឈប់ដំណាក់កាលនៃការពិគ្រោះយោបល់ នោះរួចផ្ញើលិខិត ទៅក្រុមពិនិត្យការប្រតិបត្តិវិញ។

ក្រុមពិនិត្យការប្រតិបត្តិខុសពីក្រុមអ្នកសម្របសម្រួលគម្រោងពិសេស ព្រោះថាក្រុមនេះ ចុះស៊ើបសួរឱ្យដឹងថាតើការទទួលរងការខូចខាត ឬទំនងជានឹងទទួលរងការខូចខាតនោះពិតជាបណ្តាល មកពីការរំលោភគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីមែនឬអត់។

ប្រសិនបើ ក្រុមពិនិត្យការប្រតិបត្តិសម្រេចចិត្តថា មានការរំលោភលើគោលនយោបាយមែននោះ ក្រុមនេះនឹងចុះស៊ើបសួរអំពីស្ថានភាពនោះ និងសរសេររបាយការណ៍អមដោយអនុសាសន៍នានា ដើម្បីធ្វើឱ្យប្រាកដថា គោលនយោបាយនោះ ត្រូវគោរពប្រតិបត្តិ។ អនុសាសន៍ទាំងនេះអាចជា:

- ធ្វើឱ្យមានការផ្លាស់ប្តូរគម្រោង។
- ធ្វើឱ្យមានការផ្លាស់ប្តូរផែនការតាំងទីលំនៅថ្មី។
- ធ្វើឱ្យមានការផ្លាស់ប្តូរចំពោះរបៀបដែលត្រូវអនុវត្តផែនការតាំងទីលំនៅថ្មី។
- ការផ្តល់ជូនប្រជាពលរដ្ឋនូវសំណង ឬការផ្តល់ជម្រើសក្នុងការជ្រើសទីលំនៅថ្មីកាន់តែល្អ។
- ការផ្តល់ជូនប្រជាពលរដ្ឋនូវការគាំទ្រកាន់តែល្អ ដើម្បីឱ្យការប្រកបរបរចិញ្ចឹមជីវិត និងជីវភាពរស់នៅរបស់ពួកគាត់ មិនក្លាយទៅជាកាន់តែអន់ជាងមុនដោយសារគម្រោងនោះទេ។

ប្រសិនបើមានផលប៉ះពាល់ធ្ងន់ធ្ងរលើប្រជាពលរដ្ឋ ដែលមិនអាចចៀសផុតទេ ក្រុមពិនិត្យការប្រតិបត្តិនោះ ក៏អាចចេញអនុសាសន៍ឱ្យបញ្ឈប់គម្រោងនោះដែរ ។

អ្នកនឹងមានឱកាសពន្យល់គំនិត និងទស្សនៈរបស់អ្នក អំពីសំណើរបស់ក្រុមពិនិត្យការប្រតិបត្តិនោះ។ នៅពេលដែល ក្រុមពិនិត្យការប្រតិបត្តិនេះបានសរសេររបាយការណ៍របស់ខ្លួនជាស្ថាពរ ហើយក្រុមត្រូវផ្ញើវាទៅ **ក្រុមប្រឹក្សានាយកធនាគារអភិវឌ្ឍន៍អាស៊ី** ដើម្បីសុំសេចក្តីអនុម័ត។ ក្រុមប្រឹក្សានេះ មានការទទួលខុសត្រូវលើការធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗរបស់ ធនាគារអភិវឌ្ឍន៍អាស៊ី រួមមាន ការអនុម័តលើអនុសាសន៍របស់ក្រុមពិនិត្យការប្រតិបត្តិ។ ប្រសិនបើផែនការនេះត្រូវបានអនុម័ត រីឯរដ្ឋាភិបាលក៏ឯកភាព ពេលនោះអនុសាសន៍នោះនឹងត្រូវអនុវត្ត ព្រមទាំងត្រូវពិនិត្យតាមដាន ដោយប្រុងប្រយ័ត្ន ដោយធនាគារអភិវឌ្ឍន៍អាស៊ីសម្រាប់រយៈពេលប្រាំឆ្នាំក្រោយ ។

នៅផ្នែកខាងក្រោយនៃសៀវភៅនេះ មានព័ត៌មានលម្អិត សម្រាប់ទាក់ទងទៅក្រុមពិនិត្យការប្រតិបត្តិ ។



*ធនាគារអភិវឌ្ឍន៍អាស៊ី និងរដ្ឋាភិបាលបានឯកភាពគ្នាលើដំណោះស្រាយ និងបានសាងសង់លំនៅដ្ឋានល្អប្រសើរសំរាប់ប្រជាពលរដ្ឋនៅតាមបណ្តោយផ្លូវសាងសង់ថ្មី*

## ៥.៣. គុណវិបត្តិនៃយន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី

ការប្រើប្រាស់យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ជារបៀបមួយយ៉ាងសំខាន់ក្នុង ការស្វែងរកការដោះស្រាយបញ្ហារបស់អ្នក និងក្នុងការធ្វើឱ្យធនាគារនេះមានការទទួលខុសត្រូវ នៅពេលដែល គោលនយោបាយរបស់ធនាគារ នេះត្រូវគេរំលោភបំពាន។ ប៉ុន្តែ យន្តការគណនេយ្យភាពរបស់ធនាគារនេះ ក៏មានគុណវិបត្តិមួយចំនួនដែរ ព្រោះថា ប្រជាជន ដែលបានដាក់ពាក្យបណ្តឹងក៏មិនមែនចេះតែទទួលបានដំណោះស្រាយល្អៗ ចំពោះបញ្ហារបស់ពួកគាត់ជានិច្ចនោះឡើយ។

ហេតុផលយ៉ាងសំខាន់ដែលថាមានគុណវិបត្តិនោះគឺថា យន្តការគណនេយ្យភាពរបស់ធនាគារ អភិវឌ្ឍន៍អាស៊ីមិនអាចបង្ខំរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ីឱ្យធ្វើអ្វីមួយ ដើម្បីដោះស្រាយបញ្ហា ឬការខូចខាតរបស់អ្នកដែលបានកើតឡើងនោះទេ សូម្បីតែនៅពេលដែលក្រុមពិនិត្យការប្រតិបត្តិសម្រេចចិត្តថា គោលនយោបាយរបស់ធនាគារត្រូវបានគេរំលោភបំពាន ព្រមទាំងចេញអនុសាសន៍ និងផែនការយ៉ាងល្អ ដើម្បីដោះស្រាយបញ្ហានោះក៏ដោយ ក៏ក្រុមប្រឹក្សារបស់ធនាគារអភិវឌ្ឍន៍អាស៊ីអាចមិនយល់ព្រម ឬមិនអនុម័តលើផែនការនោះ ឬអ្វីៗដែលមាននៅក្នុងផែនការនោះឡើយ។

ប្រសិនបើ រដ្ឋាភិបាលមិនឯកភាពនឹងផែនការនោះទេ ដូច្នេះ វាមានការលំបាកសម្រាប់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងការដោះស្រាយបញ្ហាដែលបណ្តាលមកពីគម្រោងនោះ និងពិបាករកដំណោះស្រាយចំពោះការខូចខាត ដែលប្រជាពលរដ្ឋ ទទួលរងផលប៉ះពាល់នោះណាស់។ ជាទូទៅ វាជាតួនាទីរបស់រដ្ឋាភិបាល ក្នុងការអនុវត្តផែនការនៅក្នុងរបាយការណ៍របស់ក្រុមពិនិត្យការប្រតិបត្តិនោះ ហេតុដូច្នេះហើយ ប្រសិនបើរដ្ឋាភិបាលមិនព្រមអនុវត្តទេ អ្វីៗដែលធនាគារអភិវឌ្ឍន៍អាស៊ី អាចធ្វើដើម្បីដោះស្រាយបញ្ហាមានលទ្ធភាពតិចណាស់។

ធនាគារអភិវឌ្ឍន៍អាស៊ីបញ្ជាក់ថា ធនាគារនឹងមិនផ្តល់មូលនិធិ ទៅគម្រោងណាដែលមិនគោរពគោលនយោបាយរបស់ខ្លួន ឬច្បាប់ប្រទេសរបស់ខ្លួនទេ។ ប្រសិនបើរដ្ឋាភិបាលមិនគោរពគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងបដិសេធមិនដោះស្រាយបញ្ហាឬការខូចខាតធ្ងន់ធ្ងរដែលបណ្តាលមកពីគម្រោងនោះទេ ដូច្នេះ ធនាគារអភិវឌ្ឍន៍អាស៊ីត្រូវពិចារណាដកមូលនិធិរបស់ខ្លួនពីគម្រោងនោះវិញ។



ដោយសារតែគុណវិបត្តិនៃយន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដូច្នេះ វាមានសារៈសំខាន់ណាស់ ដែលប្រជាពលរដ្ឋត្រូវប្រើទម្រង់នៃការតស៊ូមតិ ឬការស្វែងរកការគាំទ្រផ្សេងៗទៀត ដើម្បីដាក់សម្ពាធលើរដ្ឋាភិបាល និង ធនាគារអភិវឌ្ឍន៍អាស៊ី ឱ្យគោរពគោលនយោបាយនោះ និងដើម្បីដោះស្រាយបញ្ហាទាំងឡាយណា ដែលបណ្តាលមកពី គម្រោង។ ទម្រង់នៃការតស៊ូមតិ ឬការស្វែងរកការគាំទ្រផ្សេងៗនឹងត្រូវលើកមកពិភាក្សានៅក្នុងផ្នែកបន្ទាប់។

# លំហាត់ទី១២៖ យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី



**គោលបំណង៖** អ្នកចូលរួមទាំងអស់នឹងដឹងថា យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ីជាដំណើរការ សម្រាប់ការដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋ ដែលទទួលរងការខូចខាត ឬដែលគិតថាពួកគាត់នឹងទទួលរង ការខូចខាត ដោយសារគម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី។ ពួកគាត់នឹងដឹងថា ការអនុវត្តយន្តការ គណនេយ្យភាពនេះមានពីរដំណាក់កាល។ អ្នកចូលរួមក៏នឹងយល់ដឹងដែរថា យន្តការគណនេយ្យភាពរបស់ធនាគារ អភិវឌ្ឍន៍អាស៊ីមានគុណវិបត្តិមួយចំនួន។

**សម្ភារ៖** ក្តារខៀន ឬក្រដាសផ្ទាំងធំ និងហ្វឺត

**វិធីសាស្ត្រប្រើប្រាស់៖** ការពិភាក្សារួមគ្នា និងសំណួរល្បងចំណេះដឹង

| ដំណើរការ | រយៈពេល (គិតជានាទី) |
|---|---|
| ១. ណែនាំព័ត៌មាននៅក្នុងផ្នែក៥ (សេចក្តីផ្តើម) និងផ្នែក៥.១ | ១៥ |
| ២. អាននិងពិភាក្សាលើករណីសិក្សា | ១៥ |
| ៣. ណែនាំព័ត៌មាននៅក្នុងផ្នែក៥.២ និង៥.៣ | ២០ |
| ៤. ការពិភាក្សារួមគ្នា | ១៥ |
| ៥. សង្ខេបដោយមានសំណួរល្បងចំណេះដឹង | ១៥ |
| **សរុប៖** | **៨០** |

# ការណែនាំសម្រាប់អ្នកសម្របសម្រួល

## ១. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៥ និង៥.១

**ផ្នែកទី៥ (សេចក្តីផ្តើម) និងផ្នែកទី៥.១:** វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមទាំងអស់ យល់ដឹងថា:

- ធនាគារអភិវឌ្ឍន៍អាស៊ីមានយន្តការរបស់ខ្លួនផ្ទាល់សម្រាប់ដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋ ដែលទទួលរងការខូចខាត ឬគិតថា ពួកគាត់នឹងទទួលរងការខូចខាតដោយសារគម្រោង។
- យន្តការនេះហៅថា យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលមានពីរដំណាក់កាល។
- ពួកគាត់ត្រូវព្យាយាមស្វែងរកដំណោះស្រាយបញ្ហារបស់ពួកគាត់នៅក្នុងប្រទេសសិនគឺ ជាមួយគណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុកការតាំងទីលំនៅថ្មី និងការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំនៅកម្ពុជា។
- ប្រសិនបើ ពួកគាត់មិនពេញចិត្ត នឹងដំណោះស្រាយដោយគណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុកការតាំងទីលំនៅថ្មី និងបុគ្គលិកធនាគារអភិវឌ្ឍន៍អាស៊ីនៅកម្ពុជាទេ ដូច្នេះ ពួកគាត់អាចដាក់បណ្តឹងទៅការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេសបាន។
- មានអ្វីកើតឡើង ឬត្រូវធ្វើអ្វីនៅក្នុងដំណាក់កាលនៃការពិគ្រោះយោបល់។

## ២. អាន និងពិភាក្សាករណីសិក្សា

- សូមអាន ឬសង្ខេបករណីសិក្សាអំពីគម្រោងផ្លូវជាតិនៅប្រទេសប៉ាគីស្ថាន។
- សួរអ្នកចូលរួមមើលថា តើពួកគាត់យល់យ៉ាងណាចំពោះករណីសិក្សានោះ។ តើពួកគាត់មាន ក្តីកង្វល់ដូចគ្នានឹងក្តីកង្វល់របស់ប្រជាជននៅប្រទេសប៉ាគីស្ថានដែលទទួលរងផលប៉ះពាល់ ដោយសារគម្រោងដែលផ្តល់មូលនិធិ គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ីនោះដែរឬទេ។
- បន្ទាប់មកទៀត ស្នើអ្នកចូលរួមឱ្យពន្យល់អំពីដំណើរការដែលការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស អនុវត្តនៅក្នុងករណីសិក្សានេះ ដើម្បីដោះស្រាយបញ្ហានោះ។
- ក្រោយពីមានអ្នកចូលរួមម្នាក់ ឬពីរនាក់បានឆ្លើយ អ្នកអាចបង្ហាញថា ការិយាល័យអ្នកសម្របសម្រួលគម្រោង ពិសេសបានស្តាប់ទស្សនៈរបស់ប្រជាពលរដ្ឋម្នាក់ៗ ក្រោយមកបានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់មួយជាមួយ ប្រជាជនដែលទទួលរងផលប៉ះពាល់ និងមន្ត្រីរដ្ឋាភិបាល និងបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលពាក់ព័ន្ធ ដើម្បីពិភាក្សាគ្នារកដំណោះស្រាយឯកភាពគ្នាមួយ។ ក្រោយពីបានពិភាក្សា និងឯកភាពគ្នាហើយ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស ក៏បានតាមដានការអនុវត្តកិច្ចព្រមព្រៀងនោះដែរ។

- សួរអ្នកចូលរួមមើលថា តើដំណោះស្រាយនៅក្នុងករណីសិក្សានេះមានអ្វីខ្លះ និងសួរគាត់មើលថាតើពួកគាត់ គិតថាប្រជាជនពេញចិត្តនឹងដំណោះស្រាយនោះទេ។

- តើពួកគាត់គិតថា ដំណើរការនោះអាចដំណើរការទៅរួចទេក្នុងការរកដំណោះស្រាយចំពោះបញ្ហា ឬក្តីកង្វល់ណាមួយ ដែលពួកគាត់មានជាមួយគម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី និងដែលធ្វើ ឱ្យប៉ះពាល់ដល់ពួកគាត់នោះ?

## ៣. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៩.២និង៩.៣

**ផ្នែកទី៩.២ និង៩.៣:** *វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមទាំងអស់យល់ដឹងថា:*

- ប្រសិនបើ បញ្ហា ឬកង្វល់នានារបស់ពួកគាត់ មិនត្រូវបានដោះស្រាយដោយអ្នកសម្របសម្រួលគម្រោងពិសេសនេះទេ នោះពួកគាត់អាចដាក់ពាក្យបណ្តឹងទៅក្រុមពិនិត្យការប្រតិបត្តិបាន។
- តើក្រុមពិនិត្យការប្រតិបត្តិធ្វើអ្វីខ្លះ។
- យន្តការគណនេយ្យភាព របស់ធនាគារអភិវឌ្ឍន៍អាស៊ីមានគុណវិបត្តិមួយចំនួន។ តើគុណវិបត្តិទាំងនេះមានអ្វីខ្លះ។
- ដោយសារតែគុណវិបត្តិទាំងនេះហើយ ទើបវាមានសារៈសំខាន់ណាស់ដែលប្រជាពលរដ្ឋប្រើទម្រង់ នៃតស៊ូមតិ ឬការស្វែងរកការគាំទ្រផ្សេងៗទៀតដើម្បីធ្វើឱ្យរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ីមានការទទួលខុសត្រូវ។

## ៤. ការពិភាក្សារួមគ្នា

- សួរអ្នកចូលរួមថា តើពួកគាត់យល់ដូចម្តេចចំពោះយន្តការគណនេយ្យភាពរបស់ធនាគារ អភិវឌ្ឍន៍អាស៊ី និងថា ប្រសិនបើពួកគាត់ប្រើវា តើកម្រិតនៃការងារអាចជាបញ្ហាទេ។

- តើពួកគាត់គិតថា ធនាគារអភិវឌ្ឍន៍អាស៊ីត្រូវធ្វើអ្វី ប្រសិនបើ ប្រជាពលរដ្ឋទទួលរងការខូចខាតដោយសារគម្រោង រីឯរដ្ឋាភិបាលវិញមិនព្រមស្វែងរកដំណោះស្រាយជូនពួកគាត់?

- សួរអ្នកចូលរួមមើលតើ ពួកគាត់មានបញ្ហា ឬក្តីកង្វល់ដោយសារគម្រោងទេ? តើពួកគាត់ចង់ធ្វើផែនការដើម្បីប្រើយន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីស្វែងរកដំណោះស្រាយទេ?

## ៥. សង្ខេប

- ស្នើឱ្យអ្នកចូលរួមឈរជារង្វង់នៅជុំវិញអ្នក។ ពន្យល់ពួកគាត់ថា អ្នកនឹងបោះបាល់ទៅអ្នកណាម្នាក់ រួចសួរគាត់មួយសំណួរអំពីអ្វី ដែលគាត់អាចធ្វើ នៅពេលដែលគាត់មានបញ្ហា ដោយសារគម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី។ ក្រោយពីគាត់បានឆ្លើយរួច គាត់ត្រូវបោះបាល់ទៅអ្នកផ្សេងនៅពេលដែល អ្នកនោះចាប់បានបាល់ អ្នកត្រូវសួរគាត់មួយសំណួរដែរ។ (មានសំណួរដែលជាឧទាហរណ៍នៅខាងក្រោមនេះ ប៉ុន្តែ អ្នកអាចសួរសំណួរផ្សេងពីនេះបាន)។

ឧទាហរណ៍:

១. តើ "មានការទទួលខុសត្រូវ" មានន័យដូចម្តេច?

**ចម្លើយអាចទទួលយកបាន:** "មានការទទួលខុសត្រូវ" មានន័យថា ប្រសិនបើអ្នកណាម្នាក់ខកខានមិនបានគោរពច្បាប់ និងធ្វើឱ្យប្រជាពលរដ្ឋមានការខូចខាត អ្នកនោះត្រូវតែទទួលខុសត្រូវ និងស្វែងរកវិធីដោះស្រាយ ឬជួសជុលការខូចខាត ដែលកើតឡើងនោះ។ ចំពោះគម្រោង ដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី "មានការទទួលខុសត្រូវ" ក៏មានន័យដែរថា ធនាគារនេះ និងរដ្ឋាភិបាលត្រូវបញ្ឈប់ការអនុវត្តគម្រោង ប្រសិនបើរដ្ឋាភិបាល និងធនាគារមិនអាចធានាបានថាគោលនយោបាយ នោះត្រូវបានគោរពទេ។

២. សូមរកអ្វីមួយដែលអ្នកអាចធ្វើនៅមូលដ្ឋាន ដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហា ដែលបណ្តាលមកពីគម្រោង ដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី។ (អ្នកអាចសួរសំណួរនេះបីដង)។

**ចម្លើយអាចទទួលយកបាន:** ១) ទាក់ទងគណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុក ការតាំងទីលំនៅថ្មី និងបុគ្គលិកធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំនៅកម្ពុជា។ ២) ប្រើយន្តការដោះស្រាយបណ្តឹងនៅមូលដ្ឋានដែលរដ្ឋាភិបាលរៀបចំឡើង។ ៣) ដាក់បណ្តឹង ទៅតុលាការកម្ពុជា ប្រសិនបើអ្នកគិតថា មានការរំលោភច្បាប់កម្ពុជា។

៣. តើដំណាក់កាលទីមួយនៃយន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ីគឺអ្វី?

**ចម្លើយអាចទទួលយកបាន:** ដំណាក់កាលពិគ្រោះយោបល់ ដោយអ្នកសម្របសម្រួល គម្រោងពិសេស។

៤. តើដំណាក់កាលទីពីរនៃយន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ីគឺអ្វី?

**ចម្លើយអាចទទួលយកបាន:** ពិនិត្យការអនុវត្ត ដោយក្រុមពិនិត្យការប្រតិបត្តិតាម។

៥. តើយន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ីមានគុណវិបត្តិអ្វី?

**ចម្លើយអាចទទួលយកបាន:** យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ីគឺ យន្តការនេះមិនអាចបង្ខំរដ្ឋាភិបាល ឬធនាគារអភិវឌ្ឍន៍អាស៊ីឱ្យធ្វើអ្វីមួយ ដើម្បីដោះស្រាយបញ្ហារបស់អ្នក ឬជួសជុលការខូចខាតរបស់អ្នកបានទេ។

៦. តើអ្នកអាចធ្វើទៀតបាន ដើម្បីធ្វើឱ្យធនាគារអភិវឌ្ឍន៍អាស៊ី និងរដ្ឋាភិបាលមានការទទួលខុសត្រូវ?

**ចម្លើយអាចទទួលយកបាន:** ម្យ៉ាងទៀត វាជាគំនិតល្អដែលអ្នកគប្បីត្រូវប្រើទម្រង់នៃការតស៊ូមតិ ឬការស្វែងរកការគាំទ្រផ្សេងៗទៀត បន្ថែមលើការប្រើប្រាស់ យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

# ៦. ទម្រង់ផ្សេងៗនៃការតស៊ូមតិ

ប្រសិនបើអ្នកសម្រេចចិត្តថា ត្រូវប្រើយន្តការបណ្ដឹងនៅមូលដ្ឋាន ដូចជា តុលាការ ឬយន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ីជាដើម ដូច្នេះ យកល្អអ្នកគប្បីត្រូវប្រើទម្រង់នៃការតស៊ូមតិ ឬ ការស្វែងរកការគាំទ្រផ្សេងៗទៀត។ នេះគឺព្រោះតែពេលខ្លះ រដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ី មិនបានប្រឹងប្រែងអស់លទ្ធភាពក្នុងការដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋទេ ប្រសិនបើ ប្រជាពលរដ្ឋមិនដាក់សម្ពាធលើរដ្ឋាភិបាល និងធនាគារនេះ តាមរយៈទម្រង់ផ្សេងៗនៃការតស៊ូមតិ ឬការស្វែងរកការគាំទ្រផ្សេងៗទេ។

**ការតស៊ូមតិ** មានន័យថា ការបញ្ជូនសារតាមរយៈពាក្យសម្ដី ឬសកម្មភាពនានាដើម្បីធ្វើឱ្យ មានការផ្លាស់ប្ដូរក្នុងការសម្រេចចិត្តដែលមានឥទ្ធិពលលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

យកល្អប្រជាពលរដ្ឋ ដែលទទួលរងផលប៉ះពាល់ដោយសារគម្រោងមូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ីគប្បីត្រូវធ្វើសេចក្ដីសម្រេចចិត្តរួមគ្នាក្នុងការប្រើទម្រង់ផ្សេងៗនៃការតស៊ូមតិ។ ប្រសិនបើអ្នកធ្វើការរួមគ្នាជាសហគមន៍ដូច្នេះ សាររបស់អ្នកនឹងកាន់តែមានអនុភាពខ្លាំង ព្រមទាំងកាន់តែអាចឮដល់រដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ីថែមទៀតផង។

អ្នកក៏អាចទទួលបានការគាំទ្រដែរ ពីអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិនានាដែល ធ្វើការជាមួយសហគមន៍ និងដែលមានបទពិសោធន៍ក្នុងការធ្វើការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី។ នៅផ្នែកខាងក្រោយនៃសៀវភៅនេះមានព័ត៌មានលម្អិតរបស់អង្គការមិនមែនរដ្ឋាភិបាលនានាដែលមាន បទពិសោធន៍ក្នុងការធ្វើការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី។ ដូច្នេះ អ្នកអាចប្រើព័ត៌មានទាំងនោះសម្រាប់ ទាក់ទងការងារបាន។

គំនិតបីទាក់ទងនឹងទម្រង់ផ្សេងៗ ក្នុងការតស៊ូមតិនឹងត្រូវលើកមកពិភាក្សាជាបន្តបន្ទាប់ដូចខាងក្រោមនេះ។ នៅមានកិច្ចការជាច្រើនទៀតដែលសហគមន៍របស់អ្នកអាចធ្វើដើម្បីទាញការចាប់អារម្មណ៍របស់រដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ី។ សូមមានគំនិតច្នៃប្រឌិតទាំងអស់គ្នាឡើង!

## ៦.១. ការប្រើប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានប្រភេទផ្សេងៗគ្នា ជាយុទ្ធសាស្ត្រមួយយ៉ាងសំខាន់ ដើម្បីនិយាយឱ្យសាធារណជនបានដឹងឮអំពីរឿងរបស់អ្នក ព្រមទាំងដើម្បីបញ្ជូនសាររបស់អ្នកទៅរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ី។



មានប្រព័ន្ធផ្សព្វផ្សាយជាច្រើនប្រភេទផ្សេងៗគ្នា។ ឧទាហរណ៍ អ្នកអាចទាក់ទងទៅអ្នកសារព័ត៌មាន ដែលយកព័ត៌មានសម្រាប់កាសែត ទូរទស្សន៍ និងវិទ្យុ ជាដើម។ វាមានសារៈសំខាន់ណាស់ដែលត្រូវ ធ្វើផែនការដោយប្រុងប្រយ័ត្ន មុននឹងទាក់ទងទៅអ្នកសារព័ត៌មានណាម្នាក់ ព្រមទាំងត្រូវសម្រេចចិត្តថា តើអ្នកចង់និយាយប្រាប់អ្នកសារព័ត៌មាននោះ អំពីអ្វី និងសារបែបណាដែលអ្នកចង់ឱ្យគាត់ផ្សាយ ។

អ្នកក៏អាចអញ្ជើញអ្នកសារព័ត៌មានឱ្យមកភូមិរបស់អ្នកបានដែរ។ ប្រសិនបើ អ្នកសារព័ត៌មាននោះមកភូមិរបស់អ្នក ដូច្នេះ អ្នកអាចពន្យល់អំពីស្ថានភាពដែលអ្នកកំពុងប្រឈម រីឯអ្នកសារព័ត៌មាន នោះនឹងអាចឃើញស្ថានភាពនោះជាក់ស្តែងផ្ទាល់នឹងភ្នែក។ ប្រសិនបើ អ្នកសារព័ត៌មាននោះ ជាអ្នកយកព័ត៌មានសម្រាប់កាសែត គាត់ក៏អាចថតរូបមួយចំនួនដែរ។ ប្រសិនបើ គាត់ជាអ្នកយកព័ត៌មានសម្រាប់ បណ្តាញទូរទស្សន៍វិញ នោះគាត់អាចថតវីឌីអូនៅពេលសម្ភាសន៍ជាមួយអ្នក និងប្រជាសហគមន៍ផ្សេងៗទៀត នៅទីតាំងដី ឬនៅផ្ទះរបស់អ្នក។

ប្រសិនបើ អ្នកទាក់ទងទៅស្ថានីយ៍វិទ្យុវិញ នោះគេនឹងអញ្ជើញអ្នកទៅស្ទូឌីយោថតសំឡេង ដើម្បីថតសំឡេងសម្ភាសន៍ ដូច្នេះ អ្នកអាចនិយាយប្រាប់អំពីរឿងរ៉ាវរបស់អ្នកប្រាប់ប្រជាពលរដ្ឋនៅទូទាំងប្រទេសកម្ពុជា។



អ្នកអាចរកបានព័ត៌មានលម្អិតសម្រាប់ទាក់ទងទៅ កាសែតឌឹខេមបូឌាដេលី កាសែតរស្មីកម្ពុជា និង វិទ្យុអាស៊ីសេរី ព្រមទាំងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអន្តរជាតិមួយចំនួនទៀត នៅផ្នែកខាងក្រោយនៃសៀវភៅនេះ។

**ការនិយាយទៅកាន់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន**

ប្រសិនបើ អ្នកនិយាយទៅកាន់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន អំពីបញ្ហារបស់អ្នក វាមានសារៈសំខាន់ណាស់ដែលអ្នកត្រូវ *និយាយអ្វីដែលជាការពិត*។ វានឹងកាន់តែល្អប្រសើរ ប្រសិនបើ អ្នកមានឯកសារ និង ភស្តុតាងសម្រាប់គាំទ្រនូវអ្វីដែលអ្នកនិយាយ។ ឧទាហរណ៍ ប្រសិនបើអ្នកនិយាយថា ដីរបស់អ្នកត្រូវដកហូត សម្រាប់គម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី និងមិនទទួលបានសំណងសមរម្យទេ វាជាគំនិតល្អដែរអ្នកត្រូវផ្តល់ជូនអ្នកសារព័ត៌មាននូវឯកសារណាមួយដែលអ្នកមានទាក់ទងនឹងគម្រោង និង ការសងសំណង។ អ្នកក៏អាចអញ្ជើញអ្នកសារព័ត៌មានឱ្យមកភូមិរបស់អ្នក ដើម្បីថតរូបបានដែរ។

ប្រសិនបើ អ្នកនិយាយខុសពីការពិត ទៅកាន់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន អ្នកនឹងអាចមានគ្រោះថ្នាក់ ព្រោះវាមានទោសព្រហ្មទណ្ឌសម្រាប់ការនិយាយខុសពីការពិតថាអ្នកណាម្នាក់ធ្វើអ្វីមួយខុស។ ជាការល្អ អ្នកត្រូវពិគ្រោះយោបល់ជាមួយអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការផ្នែកច្បាប់ដើម្បីស្វែងយល់ថា តើមានគ្រោះថ្នាក់អ្វីខ្លះក្នុងការនិយាយទៅកាន់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។ អង្គការមិនមែនរដ្ឋាភិបាលទាំងនេះ មានរាយឈ្មោះនៅផ្នែកខាងក្រោយនៃសៀវភៅនេះ។

## ៦.២. ញត្តិតវ៉ា

ទម្រង់មួយទៀតនៃការតស៊ូមតិ គឺធ្វើញត្តិតវ៉ាទៅធនាគារអភិវឌ្ឍន៍អាស៊ី និងរដ្ឋាភិបាល។ **ញត្តិតវ៉ា** ជាការតវ៉ា ឬជាការស្នើសុំ ជាលាយលក្ខណ៍អក្សរ ដោយមានហត្ថលេខា ឬស្នាមមេដៃរបស់ប្រជាពលរដ្ឋ ជាច្រើនទាមទារឱ្យមានការផ្លាស់ប្តូរ ឬទាមទារឱ្យមានការដោះស្រាយបញ្ហាណាមួយ។

ប្រសិនបើ អ្នករៀបចំញត្តិតវ៉ាទាក់ទងនឹងគម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារ អភិវឌ្ឍន៍អាស៊ី ញត្តិតវ៉ានោះអាចទាមទារឱ្យ ធនគារអភិវឌ្ឍន៍អាស៊ី និងរដ្ឋាភិបាលធ្វើអ្វីមួយដើម្បី ដោះស្រាយក្តីកង្វល់ ឬបញ្ហារបស់ប្រជាពលរដ្ឋទាក់ទងនឹងគម្រោង។ វាអាចមានការទាមទារជាក់លាក់ ដើម្បីឱ្យធនាគារអភិវឌ្ឍន៍អាស៊ី និងរដ្ឋាភិបាលអនុវត្ត។ វាអាចជាការទាមទារឱ្យធនាគារអភិវឌ្ឍន៍អាស៊ី បញ្ឈប់ការផ្តល់មូលនិធិទៅគម្រោងនោះ។

កាលណាមានស្នាមផ្តិតមេដៃកាន់តែច្រើន ពេលនោះញត្តិតវ៉ារបស់អ្នកក៏កាន់តែខ្លាំងដែរ។ អ្នកអាចសុំប្រជាពលរដ្ឋនៅក្នុង ឬក្រៅសហគមន៍ឱ្យគាំទ្រ និងចុះហត្ថលេខា ឬផ្តិតមេដៃលើញត្តិតវ៉ានោះ។

វាជាការល្អដែលត្រូវផ្ញើលិខិត ឬញត្តិតវ៉ាទៅមន្ត្រីធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំនៅប្រទេសកម្ពុជា និង ប្រធាននិងក្រុមប្រឹក្សានាយកធនាគារអភិវឌ្ឍន៍អាស៊ី។ អ្នកអាចរកបានព័ត៌មានសម្រាប់ទាក់ទងលម្អិតនៅ ផ្នែកខាងក្រោយនៃសៀវភៅនេះ។ អ្នកក៏អាចផ្ញើលិខិត ឬញត្តិតវ៉ានោះទៅគណៈកម្មាធិការអន្តរក្រសួង ទទួលបន្ទុកការតាំងទីលំនៅថ្មី ឬមន្ត្រីរដ្ឋាភិបាលផ្សេងៗទៀត និងនាយករដ្ឋមន្ត្រី ប្រសិនបើ អ្នកគិតថា នោះជាគំនិតល្អ។



## ឧទាហរណ៍នៃញត្តិតវ៉ា

យើងខ្ញុំជាប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយសារគម្រោងផ្លូវរថភ្លើង។ យើងខ្ញុំសូមគោរព និង ស្នើសុំធនាគារអភិវឌ្ឍន៍អាស៊ី និងគណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុកការតាំងទីលំនៅថ្មី មេត្តាផ្តល់ព័ត៌មាន និង ពិគ្រោះយោបល់ជាមួយយើងខ្ញុំឱ្យបានត្រឹមត្រូវអំពីគម្រោង និងសូមប្រាប់យើងខ្ញុំផងថា តើមានផលប៉ះពាល់យើងខ្ញុំ ដល់កម្រិតណា។

យើងខ្ញុំមានសិទ្ធិទទួលព័ត៌មាន និងពិគ្រោះយោបល់អំពីគម្រោង។

យើងខ្ញុំក៏មានសិទ្ធិទទួលសំណង និងការតាំងទីលំនៅថ្មីសមរម្យទៅតាមច្បាប់របស់ប្រទេសកម្ពុជា និងគោល នយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ស្តីពីការពារការតាំងទីលំនៅថ្មីដោយបង្ខំ។

យើងខ្ញុំសុំឱ្យធនាគារអភិវឌ្ឍន៍អាស៊ី និងគណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុកការតាំងទីលំនៅថ្មី មេត្តាធ្វើ ការពិគ្រោះយោបល់ជាមួយយើងខ្ញុំ ដែលជាក្រុមគ្រួសារទទួលរងផលប៉ះពាល់ ដើម្បីឈានទៅរកកិច្ចព្រមព្រៀង មួយលើ ចំនួនសំណងសមរម្យ។

ភ្នំពេញ ថ្ងៃទី ............. ខែ ................ ឆ្នាំ ...................

អ្នកគាំទ្រញត្តិតវ៉ា

| ល.រ. | នាម និងគោត្តនាម | ភេទ | អាយុ | ភូមិ | ស្នាមមេដៃ |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |

## ៦.៣. ការរៀបចំបាតុកម្ម

**បាតុកម្ម** ជាការបង្ហាញជាសាធារណៈនូវការតវ៉ាប្រឆាំង ឬការបង្ហាញការគាំទ្របញ្ហាណាមួយ សកម្មភាពណាមួយ ឬមនុស្សណាម្នាក់។ បាតុកម្មប្រកបដោយជោគជ័យគឺ បាតុកម្មដោយសន្តិវិធី មានមនុស្សច្រើនចូលរួម និងត្រូវប្រព្រឹត្តទៅនៅពេល ឬនៅកន្លែងដែលទាក់ទាញចំណាប់ អារម្មណ៍ច្រើនពីមនុស្សដែលអ្នកចង់បង្ហាញឱ្យគាត់មានការផ្លាស់ប្តូរ។ ឧទាហរណ៍ អ្នកអាចធ្វើបាតុកម្ម នៅខាងក្រៅ ការិយាល័យរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ឬគណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុកការតាំងទីលំនៅថ្មី។ នៅពេលធ្វើបាតុកម្មនោះ ប្រជាពលរដ្ឋច្រើនតែកាន់បដា ឬរូបភាពដែលពួកគាត់ចង់បង្ហាញសារ។

ប្រទេសកម្ពុជា មានច្បាប់ស្តីពីបាតុកម្មដែលអ្នកគប្បីត្រូវស្វែងយល់ មុននឹងរៀបចំធ្វើបាតុកម្មណាមួយ ដើម្បីឱ្យប្រាកដថា អ្នកយល់ដឹងអំពីគ្រោះថ្នាក់ដែលអាចកើតមានពីការធ្វើបាតុកម្មនោះ។ អ្នកអាចទាក់ទងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការផ្នែកច្បាប់ នៅក្នុងបញ្ជីផ្នែកខាងក្រោយនៃសៀវភៅនេះ ដើម្បីស្វែងយល់ព័ត៌មាននេះ។

| **ការរៀបចំបាតុកម្ម** |
| --- |
| នៅពេលដែលអ្នកសម្រេចចិត្តធ្វើបាតុកម្ម វាមានសារៈសំខាន់ណាស់ដែលត្រូវធ្វើផែនការ ដោយគិតអំពីចំណុចនានាដូចខាងក្រោមនេះ:<br>• តើអ្នកបានរកឃើញនូវគ្រោះថ្នាក់ និងច្បាប់ស្តីពីបាតុកម្ម និងបានធ្វើឱ្យប្រាកដថា អ្នកចូលរួមធ្វើបាតុកម្មបានយល់អំពីគ្រោះថ្នាក់ទេ?<br>• តើការធ្វើបាតុកម្មរបស់អ្នកមានគោលបំណងអ្វី និងចង់បង្ហាញសារអ្វី?<br>• តើអ្នកត្រូវបង្ហាញសាររបស់អ្នកតាមវិធីណា? ឧទាហរណ៍ តើអ្នកប្រើរូបភាពផ្ទាំងធំទេ? តើអ្នកប្រើបដាទេ? អ្នកត្រូវប្រើឧបករណ៍បំពងសំឡេងទេ? ចម្រៀង? ឬប្រើវាទាំងអស់រួមគ្នា?<br>• តើអ្នកនឹងយកអ្វីទៅកន្លែងធ្វើបាតុកម្ម ដើម្បីអាចបង្ហាញសាររបស់អ្នកបាន?<br>• តើបាតុកម្មនោះប្រព្រឹត្តទៅ នៅពេលណា និងនៅកន្លែងណា?<br>• តើអ្នកនឹងអញ្ជើញអ្នកណាខ្លះមកចូលរួមធ្វើបាតុកម្មនេះ?<br>• តើអ្នកចូលរួមគ្រប់រូបមានមធ្យោបាយអ្វីសម្រាប់ធ្វើដំណើរទៅកន្លែងធ្វើបាតុកម្ម?<br>• តើអ្នកត្រូវធ្វើយ៉ាងណាខ្លះ ដើម្បីឱ្យប្រាកដថា វាជាបាតុកម្មដោយសន្តិវិធី?<br>• តើអ្នកបានជូនដំណឹងទៅអាជ្ញាធរ តាមលក្ខខណ្ឌតម្រូវនៃច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី ហើយឬនៅ? |

វាក៏អាចជាគំនិតល្អដែរក្នុងការប្រគល់ញត្តិតវ៉ា និងលិខិតអំពីស្ថានភាពនោះទៅធនាគារអភិវឌ្ឍន៍អាស៊ី និងមន្ត្រីរដ្ឋាភិបាល ក្នុងពេលព្រមគ្នានឹងពេលដែលធ្វើបាតុកម្មនៅខាងក្រៅការិយាល័យរបស់ស្ថាប័នទាំងនោះ។ ប្រជាពលរដ្ឋដែលមកចូលរួមធ្វើបាតុកម្មក៏អាចអញ្ជើញ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានមកចូលរួម និងយកការណ៍អំពីការតវ៉ារបស់ពួកគាត់បានដែរ។




*ការធ្វើបាតុកម្មដោយសន្តិវិធី*

## លំហាត់ទី១៣៖ ការប្រើប្រាស់ទម្រង់ផ្សេងៗនៃការតស៊ូមតិ ដើម្បីធ្វើឱ្យធនាគារអភិវឌ្ឍន៍អាស៊ីមានការទទួលខុសត្រូវ



**គោលបំណង៖** អ្នកចូលរួមទាំងអស់នឹងយល់ដឹងថា តើ "ការតស៊ូមតិ" មានន័យដូចម្ដេច និងថាតើហេតុអ្វីបានជាវា មានសារៈសំខាន់ក្នុងការប្រើប្រាស់ទម្រង់ផ្សេងៗគ្នានៃការតស៊ូមតិ។ អ្នកចូលរួមនឹងដឹងអំពីការប្រើប្រាស់ទម្រង់ទាំងបី នៃការតស៊ូមតិគឺ៖ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ញត្តិតវ៉ា និងបាតុកម្ម។ ពួកគាត់នឹងបានយល់ដឹងថា វានឹងមានគ្រោះថ្នាក់ និងថាពួកគាត់ត្រូវតែស្វែងយល់ព័ត៌មានបន្ថែម និងធ្វើផែនការតស៊ូមតិ រួមគ្នាជាសហគមន៍តែមួយ។

**សម្ភារ៖** ក្ដារខៀន ឬក្រដាសផ្ទាំងធំ ហ្វឺត និងឯកសារសម្រាប់ចែកទី១

**វិធីសាស្ត្រប្រើប្រាស់៖** ការពិភាក្សារួមគ្នា ការបំផុសគំនិត ការងារជាក្រុម និងការសម្ដែងតួ

| ដំណើរការ | រយៈពេល (គិតជានាទី) |
|---|---|
| ១. ការពិភាក្សាខ្លីអំពីការតស៊ូមតិ | ១០ |
| ២. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៦ (តែសេចក្ដីផ្ដើមទេ) | ១០ |
| ៣. ការបំផុសគំនិតអំពីទម្រង់ផ្សេងៗនៃការតស៊ូមតិ | ១០ |
| ៤. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៦.១, ៦.២, និង៦.៣ | ៣០ |
| ៥. ពន្យល់លំហាត់ | ៥ |
| ៦. ការងារជាក្រុម | ២០ |
| ៧. ការសម្ដែងតួ និងការឡើងបង្ហាញ | ១៥ |
| ៨. សង្ខេប | ១០ |
| **សរុប៖** | **១១០** |

## ការណែនាំសម្រាប់អ្នកសម្របសម្រួល

### ១. ការពិភាក្សាខ្លីអំពីការតស៊ូមតិ

- សុំឱ្យអ្នកចូលរួមឡើងពន្យល់ថា ហេតុអ្វីបានជាវាមានសារៈសំខាន់ ក្នុងការពិចារណាអំពីការប្រើប្រាស់ទម្រង់ផ្សេងៗនៃការតស៊ូមតិ ដែលជាការបន្ថែមលើយន្តការបណ្តឹងមូលដ្ឋាន និង យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។

- បន្ទាប់មកទៀត សួរអ្នកចូលរួមថា តើ "ការតស៊ូមតិ" មានន័យដូចម្តេច ។

- ក្រោយពីអ្នកចូលរួមពីរ-បីនាក់មានឱកាសបានឡើងឆ្លើយរួចហើយ អ្នកអាចពន្យល់ថា "ការតស៊ូមតិ" មានន័យថា ជាការបញ្ជូនសារមួយតាមរយៈពាក្យសម្តី ឬសកម្មភាពនានា ដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរការសម្រេចចិត្តដែលមានឥទ្ធិពលលើជីវភាពប្រជាពលរដ្ឋ ។

### ២. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៦ (តែសេចក្តីផ្តើមទេ)

**ផ្នែកទី៦:** *វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ដឹងថា:*

- ជូនកាលរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ី មិនបានខិតខំប្រឹងប្រែងក្នុងការដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋទេ ប្រសិនបើគ្មានការដាក់សម្ពាធដោយទម្រង់ផ្សេងៗនៃការតស៊ូមតិ ។
- ប្រសិនបើ ប្រជាពលរដ្ឋធ្វើការរួមគ្នាជាសហគមន៍តែមួយ និងមានការរួបរួមគ្នាក្នុងការតស៊ូមតិនោះពួកគាត់នឹងកាន់តែមានកម្លាំងខ្លាំង ព្រមទាំងអាចធ្វើឱ្យសាររបស់ពួកគាត់កាន់តែអាចឮដល់រដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ី ។

### ៣. ការបំផុសគំនិតអំពីទម្រង់ផ្សេងៗគ្នានៃការតស៊ូមតិ

- សួរអ្នកចូលរួមមើលថា តើពួកគាត់អាចនឹករកឃើញទម្រង់ផ្សេងៗនៃការតស៊ូមតិទេ។ តើមានវិធីខុសៗគ្នាអ្វីខ្លះដែលពួកគាត់អាចធ្វើឱ្យមានការចាប់អារម្មណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី និងរដ្ឋាភិបាលដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរការសម្រេចចិត្ត ។

- សូមលើកទឹកចិត្តអ្នកចូលរួមឱ្យចែករំលែកគំនិត ឱ្យបានកាន់តែច្រើនកាន់តែល្អ។ សូមលើកទឹកចិត្តពួកគាត់ឱ្យមានគំនិតច្នៃប្រឌិត ។

- សូមកត់ត្រាគំនិតរបស់ពួកគាត់នៅលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ ។

## ៤. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៦.១, ៦.២, និង៦.៣

**ផ្នែកទី៦.១, ៦.២ និង៦.៣ :** *វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ដឹងៈ*

- ថា ការប្រើប្រាស់ប្រភេទផ្សេងៗគ្នានៃប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជាយុទ្ធសាស្ត្រមួយសំខាន់ណាស់ សម្រាប់និយាយរឿងរ៉ាវរបស់ពួកគាត់ទៅឱ្យសាធារណជនដឹងឮ និងសម្រាប់បញ្ជូនសាររបស់គាត់ ទៅរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ី ។
- អំពីប្រភេទផ្សេងៗគ្នានៃប្រព័ន្ធផ្សព្វផ្សាយ និងយល់ដឹងថា តើវាអាចធ្វើអ្វីខ្លះ ។
- តើ ពួកគាត់ត្រូវសម្រេចចិត្តធ្វើអ្វី មុននឹងទាក់ទងទៅអ្នកសារព័ត៌មាន ។
- អំពីរបៀបដែលពួកគាត់អាចទាក់ទងទៅអ្នកសារព័ត៌មាន ។
- តើ ញត្តិតវ៉ាជាអ្វី ។ (អ្នកអាចបង្ហាញអ្នកចូលរួមនូវគំរូញត្តិ)
- របៀបរៀបចំញត្តិ និងត្រូវផ្ញើទៅអ្នកណា ។
- តើបាតុកម្មជាអ្វី ។
- របៀបធ្វើផែនការ និងរៀបចំការធ្វើបាតុកម្ម ។
- ថា មានគ្រោះថ្នាក់ក្នុងការអនុវត្តការតស៊ូមតិ និងថាពួកគាត់ត្រូវស្វែងយល់បន្ថែមអំពីគ្រោះថ្នាក់ទាំងនោះ និងខ្លឹមសារដែលមានចែងនៅក្នុងច្បាប់ ដោយទាក់ទងជាមួយអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការផ្នែកច្បាប់ ។

## ៥. ពន្យល់លំហាត់នេះ

- ពន្យល់ថា អ្នកចូលរួមនឹងត្រូវចែកជាបីក្រុម ។ ក្រុមនីមួយៗនឹងមានឱកាសគិតអំពីរបៀបប្រើទម្រង់ណាមួយនៃការតស៊ូមតិៈ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន, ការផ្ញើញត្តិតវ៉ា និងបាតុកម្ម ។
- ក្រុមនីមួយៗត្រូវគិត និងពិគ្រោះគ្នាអំពីបញ្ហា ឬកង្វល់មួយចំនួន ដែលពួកគាត់មានទាក់ទង នឹងគម្រោងដែលធ្វើឱ្យប៉ះពាល់ដល់ពួកគាត់ ។ ប្រសិនបើ ពួកគាត់គ្មានបញ្ហា ឬក្តីកង្វល់ទាក់ទងនឹងគម្រោង ដែលធ្វើឱ្យប៉ះពាល់ដល់ពួកគាត់ទេ ដូច្នេះពួកគាត់អាចប្រឌិតរឿងឡើង ទាក់ទងនឹងសហគមន៍មួយ ដែលកំពុងត្រូវបង្ខំឱ្យផ្លាស់ប្តូរទីតាំងទៅរស់នៅឆ្ងាយ ដោយគ្មានទូទាត់សំណងសមរម្យ ។ ក្រោយមក ក្រុមនីមួយៗត្រូវធ្វើផែនការថា តើពួកគាត់ចង់បញ្ជូនសារអ្វីខ្លះតាមរយៈការតស៊ូមតិរបស់ពួកគាត់អំពីបញ្ហាទាំងនោះ និងថាតើពួកគាត់ចង់ផ្ញើសារនោះទៅអ្នកណាខ្លះ ។
- ក្រុមនីមួយៗនឹងទទួលបានការណែនាំខុសៗគ្នាអំពីការធ្វើផែនការសកម្មភាពតស៊ូមតិ ។
- ក្រុមនីមួយៗមានរយៈពេល២០នាទី ក្នុងការពិភាក្សានិងរៀបចំការសម្តែងតួខ្លីមួយ ។

- បន្ទាប់មកទៀត ក្រុមនីមួយៗត្រូវឡើងសម្តែងតួ។ សមាជិកក្រុមណាម្នាក់ក៏អាចឡើង ពន្យល់ដែរថា តើមានអ្វីកើតឡើងនៅក្នុងការសម្តែងនោះ ។

## ៦. ការងារជាក្រុម

- ចែកអ្នកចូលរួមជាបីក្រុម ។
- ប្រគល់ទៅក្រុមនីមួយៗនូវសេចក្តីណែនាំដូចមាន នៅក្នុងឯកសារសម្រាប់ចែកទី១ ដើម្បីឱ្យក្រុមទី១ អាចធ្វើផែនការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន, ក្រុមទី២ ធ្វើផែនការសម្រាប់ធ្វើញត្តិតវ៉ា និង ក្រុមទី៣ ធ្វើផែនការធ្វើបាតុកម្ម ។
- សូមដើរមើលក្រុមនីមួយៗ ដើម្បីឱ្យប្រាកដថា អ្នកចូលរួមម្នាក់ៗយល់អំពីកិច្ចការដែលគាត់ត្រូវធ្វើ ។

## ៧. ការសម្តែងតួ និងការឡើងបង្ហាញ

- អញ្ជើញក្រុមឱ្យឡើងសម្តែងតួ។ សុំឱ្យអ្នកណាម្នាក់នៅក្នុងក្រុមនីមួយៗពន្យល់អ្វីដែលកំពុងកើតឡើង នៅក្នុងការសម្តែងតួនោះ ។
- ក្រោយពីក្រុម១ បានសម្តែងចប់ហើយ សូមស្នើអ្នកចូលរួមផ្សេងៗឱ្យពិនិត្យឡើងវិញ ថាតើពួកគាត់គប្បី ត្រូវធ្វើអ្វី នៅពេលពួកគាត់ធ្វើការតស៊ូមតិដោយប្រើប្រព័ន្ធផ្សព្វផ្សាយ ។ ក្រោយពីក្រុម២ បានសម្តែងចប់ សូមស្នើអ្នកចូលរួមផ្សេងៗឱ្យពិនិត្យឡើងវិញថា តើញត្តិ ជាអ្វី និងតើត្រូវមានសារអ្វីខ្លះនៅក្នុងញត្តិនោះ ។ ក្រោយពីក្រុម៣សម្តែងចប់ សូមស្នើ អ្នកចូលរួមផ្សេងៗពិនិត្យឡើងវិញលើ ចំណុចសំខាន់ៗ ដែលត្រូវធ្វើ នៅពេលរៀបចំបាតុកម្ម ។
- សួរអ្នកចូលរួមផ្សេងៗទៀតមើលតើ ពួកគាត់មានសំណួរ ឬមានយោបល់អ្វីទេ ក្រោយពីការសម្តែងតួ នីមួយៗចប់ ។

## ៨. សង្ខេប

- រំលឹកអ្នកចូលរួមថា មានវិធីប្រកបដោយភាពច្នៃប្រឌិតជាច្រើនទៀត ក្នុងការតស៊ូមតិ និង ការបញ្ជូនសារ របស់ពួកគាត់ទៅគ្រប់ទីកន្លែង ។
- អ្នកអាចសួរថា តើពួកគាត់គ្រោងនឹងប្រើៈ
    - យន្តការបណ្តឹងថ្នាក់មូលដ្ឋាន
    - យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី, និង
    - ទម្រង់ផ្សេងៗនៃការតស៊ូមតិ ។

- សួរអ្នកចូលរួមមើលតើ ពួកគាត់មានយោបល់អ្វីបន្ថែម ឬមានសំណួរអ្វីទៀត ទាក់ទងនឹងការធ្វើឱ្យរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ីមានការទទួលខុសត្រូវចំពោះបញ្ហានានា ដែលបណ្តាលមកពីគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។

- លើកទឹកចិត្តអ្នកចូលរួមឱ្យស្វែងរកព័ត៌មានជាប្រចាំ និងតាមដានគម្រោងដែលផ្តល់មូលនិធិ គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ដោយប្រុងប្រយ័ត្ន។ មានកិច្ចការច្រើនដែលពួកគាត់ អាចធ្វើបានដើម្បីធ្វើឱ្យប្រាកដថា គោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីត្រូវបាន គោរព និងថា ពួកគាត់មិនត្រូវទទួលរងការខូចខាតដោយសារគម្រោងនោះឡើយ ។ វាស្រេចតែលើពួកគាត់ដែលត្រូវធ្វើឱ្យធនាគារអភិវឌ្ឍន៍អាស៊ី និងរដ្ឋាភិបាលមានការទទួលខុសត្រូវ ដោយតាមឃ្លាំមើលដោយប្រុងប្រយ័ត្ន មានព័ត៌មានជាប្រចាំចូលរួមក្នុងការពិគ្រោះយោបល់ និងដាក់ពាក្យបណ្តឹង ប្រសិនបើ ពួកគាត់មានក្តីកង្វល់ ។

## ឯកសារសម្រាប់ចែកទី១: លំហាត់ទី១៣

### ការណែនាំសម្រាប់ក្រុម១:

សូមគិត និងពិភាក្សាអំពីបញ្ហានិងក្តីកង្វល់មួយចំនួនរបស់អ្នក ទាក់ទងនឹងគម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី និងដែលកំពុងធ្វើឱ្យប៉ះពាល់ដល់អ្នក។ ប្រសិនបើអ្នកគ្មានបញ្ហា ឬក្តីកង្វល់ណាមួយ ទាក់ទងនឹងគម្រោង ដែលធ្វើឱ្យប៉ះពាល់ដល់អ្នកទេ ដូច្នេះអ្នកអាចប្រឌិតឡើងនូវរឿងមួយអំពីសហគមន៍ ដែលកំពុងប្រឈមនឹងការបង្ខំឱ្យផ្លាស់ប្តូរទីតាំងទៅនៅឆ្ងាយ ដោយគ្មានទូទាត់សំណងសមរម្យ។ សូមពិភាក្សារកលទ្ធភាព ដែលអាចដោះស្រាយបញ្ហាទាំងនេះ។

សូមធ្វើផែនការមួយសម្រាប់ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដើម្បីបញ្ជូនសាររបស់អ្នកអំពីបញ្ហា និងក្តីកង្វល់របស់អ្នក និងអំពីដំណោះស្រាយអ្វីខ្លះដែលអ្នកចង់បាន។

សូមគិតថា តើអ្នកចង់បញ្ជូនសារតាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននេះទៅអ្នកណា។ តើសាររបស់អ្នកមានខ្លឹមសារដូចម្តេច? តើអ្នកនឹងប្រើប្រព័ន្ធផ្សព្វផ្សាយប្រភេទអ្វី។ តើអ្នកនឹងទាក់ទងទៅប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដោយមធ្យោបាយអ្វី? សូមធ្វើកិច្ចការនេះដោយគំនិតច្នៃប្រឌិតរបស់អ្នក!

រៀបចំការសម្តែងតួដោយបង្ហាញអំពី ផែនការរបស់អ្នកក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននោះ។ អ្នកអាចសម្តែងតួជាអ្នកណាម្នាក់ដែលកំពុងទាក់ទង ទៅអ្នកសារព័ត៌មាន និងអំពីអ្វី ដែលកើតឡើងបន្ទាប់ពីទាក់ទង ទៅអ្នកសារព័ត៌មានរួច។ សមាជិកក្នុងក្រុមរបស់អ្នកក៏អាចពន្យល់ដែរ អំពីអ្វីដែលកំពុងកើតឡើងនៅក្នុងការសម្តែង តួនោះ។

ក្រុមរបស់អ្នកមានរយៈពេល៥នាទីសម្រាប់ឡើងសម្តែងតួ។

## ឯកសារសម្រាប់ផ្នែកទី១៖ លំហាត់ទី១៣

### ការណែនាំសម្រាប់ក្រុម២៖

សូមគិត និងពិភាក្សាអំពីបញ្ហានិងក្តីកង្វល់មួយចំនួនរបស់អ្នក ទាក់ទងនឹងគម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី និងដែលកំពុងធ្វើឱ្យប៉ះពាល់ដល់អ្នក។ ប្រសិនបើអ្នកគ្មានបញ្ហា ឬក្តីកង្វល់ណាមួយទាក់ទងនឹងគម្រោងដែលធ្វើឱ្យប៉ះពាល់ដល់អ្នកទេ ដូច្នេះ អ្នកអាចប្រឌិតឡើងនូវរឿងមួយអំពីសហគមន៍ដែលកំពុងប្រឈមនឹង ការបង្ខំឱ្យផ្លាស់ប្តូរទីតាំងទៅនៅឆ្ងាយ ដោយគ្មានទូទាត់សំណងសមរម្យ។ សូមពិភាក្សារកលទ្ធភាពដែលអាច ដោះស្រាយបញ្ហាទាំងនេះ។

សូមធ្វើផែនការមួយសម្រាប់រៀបចំ និងផ្ញើញត្តិតវ៉ា ដើម្បីបញ្ជូនសាររបស់អ្នកអំពីបញ្ហា និងក្តីកង្វល់របស់អ្នក និងអំពីដំណោះស្រាយអ្វីខ្លះដែលអ្នកចង់បាន។

សូមគិតថា តើអ្នកចង់ផ្ញើញត្តិតវ៉ានោះទៅអ្នកណា។ តើសាររបស់អ្នកមានខ្លឹមសារដូចម្តេច? តើអ្នកនឹងសុំឱ្យអ្នកខ្លះចុះហត្ថលេខា ឬផ្តិតមេដៃគាំទ្រញត្តិតវ៉ារបស់អ្នក។ តើអ្នកនឹងព្យាយាមរកអ្នកចុះហត្ថលេខា ឬផ្តិតមេដៃគាំទ្រ ញត្តិតវ៉ារបស់អ្នកចំនួនប៉ុន្មានអ្នក? តើអ្នកនឹងប្រគល់ញត្តិតវ៉ារបស់អ្នកទៅ ធនាគារអភិវឌ្ឍន៍អាស៊ី ឬរដ្ឋាភិបាល ឬ អ្នកពាក់ព័ន្ធផ្សេងៗទៀតដោយវិធីណា? សូមធ្វើកិច្ចការនេះ ដោយគំនិតច្នៃប្រឌិតរបស់អ្នក!

រៀបចំការសម្តែងតួដោយបង្ហាញអំពីផែនការសម្រាប់ញត្តិតវ៉ារបស់អ្នក។ ជាឧទាហរណ៍ ក្រុមរបស់អ្នកអាចធ្វើជាមានញត្តិមួយនៅលើក្រដាសផ្ទាំងធំ រួចសម្តែងតួធ្វើជាពន្យល់ប្រជាពលរដ្ឋអំពីគោលបំណងរបស់ញត្តិតវ៉ានេះ និងសុំឱ្យពួកគាត់ចុះហត្ថលេខា ឬផ្តិតមេដៃគាំទ្រញត្តិតវ៉ារបស់អ្នក។ សមាជិកក្នុងក្រុមរបស់អ្នកក៏អាចពន្យល់ដែរអំពីអ្វី ដែលកំពុងកើតឡើងនៅក្នុងការសម្តែងតួនោះ។

ក្រុមរបស់អ្នកមានរយៈពេល៥នាទីសម្រាប់ឡើងសម្តែងតួ។

# ឯកសារសម្រាប់ផ្នែកទី១: លំហាត់ទី១៣

## ការណែនាំសម្រាប់ក្រុម៣:

សូមគិត និងពិភាក្សាអំពីបញ្ហានិងក្តីកង្វល់មួយចំនួនរបស់អ្នកទាក់ទងនឹងគម្រោង ដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី និងដែលកំពុងធ្វើឱ្យប៉ះពាល់ដល់អ្នក។ ប្រសិនបើ អ្នកគ្មានបញ្ហា ឬក្តីកង្វល់ណាមួយទាក់ទងនឹងគម្រោងដែលធ្វើឱ្យប៉ះពាល់ដល់អ្នកទេ ដូច្នេះអ្នកអាចប្រឌិតឡើងនូវ រឿងមួយអំពីសហគមន៍ដែលកំពុងប្រឈមនឹងការបង្ខំឱ្យផ្លាស់ប្តូរទីតាំងទៅនៅឆ្ងាយ ដោយគ្មានទូទាត់សំណងសមរម្យ។ សូមពិភាក្សារកលទ្ធភាពដែលអាចដោះស្រាយបញ្ហាទាំងនេះ។

សូមធ្វើផែនការមួយសម្រាប់ធ្វើបាតុកម្មមួយ ដើម្បីបញ្ជូនសាររបស់អ្នកអំពីបញ្ហា និងក្តីកង្វល់របស់អ្នក និងអំពី ដំណោះស្រាយអ្វីខ្លះដែលអ្នកចង់បាន។

សូមចងចាំថា អ្នកត្រូវគិតអំពីចំណុចមួយចំនួនដូចខាងក្រោមនេះ:

- តើការធ្វើបាតុកម្មរបស់អ្នកមានគោលបំណងអ្វី និងមានខ្លឹមសារអ្វី?
- តើអ្នកត្រូវបង្ហាញសាររបស់អ្នកតាមវិធីណា? ឧទាហរណ៍ តើអ្នកប្រើរូបភាពផ្ទាំងធំទេ? តើអ្នកប្រើបដាទេ? អ្នកត្រូវប្រើឧបករណ៍បំពងសំឡេងទេ? ចម្រៀង? ឬប្រើវាទាំងអស់ រួមគ្នា?
- តើបាតុកម្មនោះប្រព្រឹត្តទៅ នៅពេលណា និងនៅកន្លែងណា?
- តើអ្នកនឹងអញ្ជើញអ្នកណាខ្លះមកចូលរួមធ្វើបាតុកម្មនេះ?
- តើអ្នកនឹងយកអ្វីទៅកន្លែងធ្វើបាតុកម្ម?
  តើអ្នកចូលរួមគ្រប់រូបមានមធ្យោបាយអ្វីសម្រាប់ធ្វើដំណើរទៅ កន្លែងធ្វើបាតុកម្ម?
- តើអ្នកត្រូវធ្វើយ៉ាងណាខ្លះ ដើម្បីឱ្យប្រាកដថា វាជាបាតុកម្មដោយសន្តិវិធី?
- តើអ្នកបានជូនដំណឹងទៅអាជ្ញាធរ ហើយឬនៅ?

សូមធ្វើកិច្ចការនេះ ដោយគំនិតច្នៃប្រឌិតរបស់អ្នក!

រៀបចំការសម្តែងតួដោយបង្ហាញអំពីផែនការរបស់អ្នក។ ជាឧទាហរណ៍ ក្រុមរបស់អ្នកអាចរៀបចំបដាដោយប្រើក្រដាសផ្ទាំងធំ និងសម្តែងតួអំពីបាតុកម្មនោះដោយបង្ហាញថា បាតុកម្មនេះប្រព្រឹត្ត ទៅនៅកន្លែងណា? តើអ្នកណាខ្លះនៅទីនោះ ព្រមទាំងបង្ហាញ ឬស្រែកខ្លាំងៗអំពីខ្លឹមសារដែលក្រុម របស់អ្នកចង់ឱ្យគេដឹង។ សមាជិកក្នុងក្រុមរបស់អ្នកក៏អាចឡើងពន្យល់ដែរអំពីអ្វីដែលកំពុងកើតឡើង នៅក្នុងការសម្តែងតួនោះ។

ក្រុមរបស់អ្នកមានរយៈពេល៥នាទីសម្រាប់ឡើងសម្តែងតួ។

# សទ្ទានុក្រម

១. **សិទ្ធិទទួលបានឥណទាន:** មានសិទ្ធិទទួលបានប្រាក់ឥណទានមានន័យថា អាចខ្ចីប្រាក់បាន។ ប្រជាពលរដ្ឋតែងតែត្រូវការសិទ្ធិទទួលបានឥណទាន ដើម្បីពួកគាត់អាចយកប្រាក់នេះទៅជួសជុលកែលម្អលំនៅដ្ឋានរបស់គាត់ទិញគ្រាប់ពូជ សម្រាប់ដាំដំណាំ ឬចាប់ផ្តើមការប្រកបអាជីវកម្ម (ការរកស៊ីលក់ដូរកំប៉ិកកំប៉ុក) ជាដើម។ ការធ្វើឱ្យប្រាកដថា ប្រជាពលរដ្ឋមានសិទ្ធិទទួលបានឥណទាន មានន័យថា ពួកគាត់អាចខ្ចីប្រាក់ ដែលពួកគាត់អាចលៃលកសងវិញនៅពេលអនាគត ដោយបូកទាំងការប្រាក់ផង។

២. **ងាយយល់ (ព័ត៌មានងាយយល់):** ជាព័ត៌មានដែលមានការពន្យល់ងាយៗ ដែលប្រជាពលរដ្ឋអាចយល់ និងជាព័ត៌មាន ដែលប្រើភាសាសាមញ្ញៗដែលប្រជាពលរដ្ឋទូទៅនិយាយ។

៣. **ការទទួលខុសត្រូវ:** "មានការទទួលខុសត្រូវ" មានន័យថា នៅពេលដែលអ្នកម្នាក់ខកខានមិនបានគោរពវិធាន ឬច្បាប់ ដូច្នេះអ្នកនោះត្រូវទទួលខុសត្រូវ និងត្រូវរកវិធីជួសជុលការខូចខាតដែលកើត ឡើងពីការការមិនគោរព នោះ។

៤. **ក្រុមប្រឹក្សានាយកធនាគារអភិវឌ្ឍន៍អាស៊ី:** ក្រុមប្រឹក្សាដែលបង្កើតឡើងដោយសមាជិកដែលជាតំណាងប្រទេសជា សមាជិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ក្រុមប្រឹក្សានេះទទួលខុសត្រូវក្នុងការធ្វើសេចក្តីសម្រេចចិត្តធំៗ អំពីធនាគារអភិវឌ្ឍន៍អាស៊ី រួមទាំងការអនុម័តលើអនុសាសន៍នានារបស់ក្រុមពិនិត្យការប្រតិបត្តិផង។

៥. **ការតស៊ូមតិ:** ជាការបញ្ជូនសារតាមរយៈពាក្យសម្តី ឬសកម្មភាពនានា ដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរការសម្រេចចិត្ត ដែលមានឥទ្ធិពលលើជីវភាពរបស់ប្រជាពលរដ្ឋ។

៦. **ធនាគារអភិវឌ្ឍន៍អាស៊ី:** ជាស្ថាប័នអន្តរជាតិមានទីតាំងនៅក្រុងម៉ានីល ប្រទេសហ្វីលីពីន។ ស្ថាប័ននេះត្រូវបានបង្កើត ឡើងនៅឆ្នាំ១៩៦៦ និងមានប្រទេសជាច្រើនជាសមាជិក។ បេសកកម្មដែលបញ្ជាក់យ៉ាងច្បាស់របស់ធនាគារអភិវឌ្ឍន៍ អាស៊ីគឺ "ដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់គុណភាពនៃជីវភាពរបស់ប្រជាពលរដ្ឋនៅតាមបណ្តាប្រទេសកំពុង អភិវឌ្ឍន៍នៅអាស៊ី"។ ធនាគារអភិវឌ្ឍន៍អាស៊ី ធ្វើការនៅតាមប្រទេសទាំងនេះ ដោយផ្តល់ប្រាក់ទៅរដ្ឋាភិបាលសម្រាប់ គម្រោងជាច្រើនប្រភេទផ្សេងៗគ្នា។ ធនាគារអភិវឌ្ឍន៍អាស៊ីក៏ផ្តល់ *ព័ត៌មានការពិគ្រោះយោបល់ និងជំនួយបច្ចេកទេស* ទៅប្រទេស ទាំងនេះដែរ។

៧. **ក្រុមពិនិត្យការប្រតិបត្តិ:** ក្រុមពិនិត្យការប្រតិបត្តិចុះស៊ើបអង្កេតឱ្យដឹងថា តើមានការខូចខាតដែលបានកើតឡើង ឬ ដែលនឹងអាចកើតឡើងដោយសារគម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ីមែនឬមិនមែន។ ប្រសិនបើក្រុមនេះសម្រេចចិត្តថា គោលនយោបាយរបស់ធនាគារនេះត្រូវរំលោភបំពាន ពេលនោះក្រុមនេះនឹងចុះស៊ើបអង្កេតស្ថានភាពនោះ និងសរសេររបាយការណ៍ ដែលអមដោយអនុសាសន៍នានា ដើម្បីធានាថា គោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីត្រូវបានគោរព។

៨. **បាតុកម្ម:** ជាការបង្ហាញសាធារណៈនូវការតវ៉ាប្រឆាំង ឬគាំទ្របញ្ហាណាមួយ សកម្មភាពណាមួយ ឬមនុស្សណាម្នាក់។ បាតុកម្មមានជោគជ័យគឺជាបាតុកម្មដែលធ្វើឡើងដោយសន្តិវិធី មានអ្នកចូលរួមយ៉ាងច្រើន និងត្រូវបានធ្វើឡើងនៅពេល និងនៅកន្លែងដែលនឹងទាក់ទាញចំណាប់អារម្មណ៍ពីមនុស្ស ដែលអ្នកចង់ឱ្យគាត់ផ្លាស់ប្តូរចិត្តតាមអ្នក។

៩. **ការផ្លាស់ប្តូរទីលំនៅដោយបង្ខំ:** ជាការបណ្តេញប្រជាពលរដ្ឋឱ្យចេញពីលំនៅដ្ឋាននិងដីធ្លី ឬធ្វើឱ្យពួកគាត់បាត់បង់ឱកាសប្រើប្រាស់ដីធ្លី និងធនធាននានាដែលពួកគាត់ពឹងផ្អែកទាំងស្រុង សម្រាប់ផលិតស្បៀងអាហារ និងសម្រាប់ប្រកបរបរចិញ្ចឹមជីវិត។

១០. **ប្រាក់ជំនួយឥតសំណង (ពីធនាគារអភិវឌ្ឍន៍អាស៊ី):** ជាប្រាក់ដែលធនាគារនេះផ្តល់ជូនរដ្ឋាភិបាល ដែលមិនចាំបាច់សងប្រាក់នេះវិញទេ។

១១. **គណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុកការតាំងទីលំនៅថ្មី:** ជាអាជ្ញាធរដែលត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាល។ គណៈកម្មាធិការនេះមានការទទួលខុសត្រូវក្នុងការរៀបចំ និងអនុវត្តផែនការសម្រាប់គម្រោងដែលផ្តល់មូលនិធិគាំទ្រ ដោយធនាគារអភិវឌ្ឍន៍អាស៊ី។

១២. **ការប្រាក់ (សម្រាប់កម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី):** ជាប្រាក់ដែលរដ្ឋាភិបាលត្រូវសងបន្ថែមលើចំនួនប្រាក់កម្ចីទៅឱ្យធនាគារអភិវឌ្ឍន៍អាស៊ី។ វាជាប្រាក់បូកបន្ថែមលើប្រាក់កម្ចីដើម ដែលរដ្ឋាភិបាលខ្ចីពីធនាគារនេះ។ ជាទូទៅ **ការប្រាក់** នេះមានកម្រិតទាបណាស់សម្រាប់ប្រាក់កម្ចី ដែលធនាគារអភិវឌ្ឍន៍អាស៊ីផ្តល់ជូនរដ្ឋាភិបាល។

១៣. **ការប្រាក់:** ជាប្រាក់ដែលប្រជាពលរដ្ឋត្រូវសងបន្ថែមលើចំនួនប្រាក់កម្ចីទៅឱ្យធនាគារ។ វាជាប្រាក់បូកបន្ថែមលើប្រាក់កម្ចីដើម ដែលប្រជាពលរដ្ឋខ្ចីពីធនាគារនោះ។ **ការប្រាក់**នេះ ត្រូវតែមានកម្រិតទាបល្មម ដូច្នេះ ការសងប្រាក់កម្ចីទៅធនាគារវិញនោះ មិនធ្វើឱ្យប្រជាពលរដ្ឋធ្លាក់ខ្លួនកាន់តែក្រជាងមុនឡើយ។

១៤. **ការតាំងទីលំនៅថ្មីដោយបង្ខំ (យោងតាមគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី):** ជាស្ថានភាពដែលប្រជាពលរដ្ឋត្រូវតែរុះរើទៅតាំងទីលំនៅថ្មី ដោយគ្មានសិទ្ធិបដិសេធ នៅពេលដែលអ្នកណាម្នាក់សម្រេចចិត្តថា យកដីរបស់គាត់ ឬហាមប្រាមគាត់មិនឱ្យប្រើប្រាស់ដីដែលពួកគាត់កំពុងប្រើប្រាស់ ជាដីលំនៅដ្ឋាន ឬជាដីដែលពួកគាត់ប្រើប្រាស់ ដើម្បីប្រកបរបរចិញ្ចឹមជីវិត។

១៥. **គោលនយោបាយការពារការតាំងទីលំនៅថ្មីដោយបង្ខំ:** ជាវិធានដែលបង្កើតឡើងដោយធនាគារអភិវឌ្ឍន៍អាស៊ី។ គម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ីត្រូវតែគោរព តាមវិធាននេះដើម្បីការពារប្រជាពលរដ្ឋកុំ ឱ្យមានការខូចខាតដោយសារការផ្លាស់ទីលំនៅ។

១៦. **អ្នកកាន់កាប់ស្របច្បាប់:** ប្រជាពលរដ្ឋដែលបានមករស់នៅលើដី មុនថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ (នៅពេលដែលច្បាប់ភូមិបានត្រូវបានអនុម័ត) ឬទិញ ឬទទួលជាមរតកពីអ្នកណាម្នាក់ដែលបានរស់នៅទីនោះ មុនកាលបរិច្ឆេទដែលច្បាប់ ភូមិបាលត្រូវបានអនុម័ត។ ការកាន់កាប់របស់គាត់ត្រូវបំពេញនូវលក្ខខណ្ឌមួយចំនួន គឺពួកគាត់ត្រូវតែកាន់កាប់ដីនោះ ដោយសុខសាន្តនិងដោយស្មោះត្រង់, ពួកគាត់ក៏ត្រូវតែកាន់កាប់ដីនោះដោយគ្មានអាក់ខាន និងច្បាស់លាស់ថាជាអ្នកកាន់កាប់ដីនោះ, ការកាន់កាប់នោះត្រូវតែមានការដឹងឮជាសាធារណៈ។

១៧. **គោលបញ្ជីស្របច្បាប់:** ជាបញ្ជីផ្លូវការ ដែលមានការរៀបរាប់ភិនភាគក្បាលដី និងម្ចាស់ដីនៅកម្ពុជា។

១៨. **ឱកាសនៃការប្រកបរបរចិញ្ចឹមជីវិត:** ប្រជាពលរដ្ឋត្រូវតែអាចរកប្រាក់បានសម្រាប់ចិញ្ចឹមជីវិត និងក្រុមគ្រួសារ ដោយអាចមានអ្វីៗដែលពួកគាត់ត្រូវការដើម្បីរស់ ដូចជាស្បៀងអាហារ ទឹក លំនៅដ្ឋាន ការថែទាំសុខភាព និងការអប់រំ។ ដើម្បីធ្វើដូច្នេះបាន ប្រជាពលរដ្ឋត្រូវតែមានឱកាសទទួលបានការងារធ្វើមានដីស្រែចម្ការ មានទីផ្សារសម្រាប់លក់ដូរ ឬមានមុខរបររកស៊ីផ្សេងៗ។

១៩. **ការគាំទ្រការប្រកបរបរចិញ្ចឹមជីវិត:** មានន័យថាជួយប្រជាពលរដ្ឋ ដើម្បីឱ្យពួកគាត់មានឱកាសអាចប្រកបរបរផ្សេងៗ ដើម្បីផ្គត់ផ្គង់ខ្លួនឯង និងក្រុមគ្រួសារនូវអ្វីៗ ដែលពួកត្រូវការដើម្បីរស់។ គោលនយោបាយធនាគារអភិវឌ្ឍន៍អាស៊ីចែងថា ការគាំទ្រនេះអាចជាអ្វីៗ ដូចជា ការផ្តល់សិទ្ធិទទួលបានឥណទាន ផ្តល់វគ្គបណ្តុះបណ្តាលជំនាញ ឬបង្កើតឱកាសការងារ ជូនប្រជាពលរដ្ឋ ជាដើម។

២០. **ប្រាក់កម្ចី (ពីធនាគារអភិវឌ្ឍន៍អាស៊ី):** ជាប្រាក់ដែលធនាគារអភិវឌ្ឍន៍អាស៊ីផ្តល់ជូនរដ្ឋាភិបាល ហើយរដ្ឋាភិបាលត្រូវ តែសងប្រាក់នេះទៅធនាគារនេះវិញទាំងការប្រាក់ផង។

**២១. យន្តការបណ្តឹងមូលដ្ឋាន:** ជាដំណើរពិសេសមួយដែលត្រូវតែបង្កើងឡើងដោយរដ្ឋាភិបាល ដើម្បីអោយអ្នកអាចដាក់ ពាក្យបណ្តឹងពីក្តីបារម្ភណ៍ ឬបញ្ហាដែលកើតឡើងដោយសារគម្រោងដែលផ្តល់មូលនិធិ ដោយធនាគារអភិវឌ្ឍន៏អាស៊ី ។ ក្តីបារម្ភណ៍របស់អ្នកត្រូវតែយកទៅដោះស្រាយយ៉ាងម៉ត់ចត់ និងរដ្ឋាភិបាលត្រូវតែព្យាយាមស្វែងរកដំណោះស្រាយសមស្រប និងឆាប់រហ័សតាមដែលអាចធ្វើទៅបាន ។

**២២. ការតាមដាន:** ការតាមដានគម្រោងពាក់ព័ន្ធនឹងការប្រមូលព័ត៌មាន ការចូលរួមការពិគ្រោះយោបល់ និងការតាមឃ្លាំមើលអ្វីៗ ដែលកើតឡើងដោយសារគម្រោង ។ ការតាមដាននេះក៏មានពាក់ព័ន្ធដែរនឹងការកត់ត្រា និងសរសេររបាយការណ៍អំពីព័ត៌មានសំខាន់ៗ ។ គោលបំណងនៃការតាមដានលើគម្រោង ដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៏ អាស៊ីគឺដើម្បីចង់ដឹងថា តើគោលនយោបាយនិងផែនការនានា ត្រូវបានអនុវត្តត្រឹមត្រូវដែរឬទេ ។

**២៣. ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស:** ជាការិយាល័យមួយរបស់ធនាគារអភិវឌ្ឍន៏អាស៊ី ដែលត្រូវបាន បង្កើតឡើងជាពិសេសដើម្បីដោះស្រាយក្តីកង្វល់របស់ប្រជាពលរដ្ឋ ។ ការិយាល័យនេះ ព្យាយាមធ្វើបែបនេះ ដោយការចុះស៊ើបអង្កេតស្ថានភាព និងបន្ទាប់មកលើកសំណើមួយចំនួន ដើម្បីដោះស្រាយបញ្ហានានា ។

**២៤. ម្ចាស់ដី:** គឺប្រជាពលរដ្ឋដែលបានចុះបញ្ជីដីរបស់គាត់ជាផ្លូវការ និងមានប័ណ្ណកម្មសិទ្ធិស្របច្បាប់លើដីនោះ ។ កម្មសិទ្ធិ ជាសិទ្ធិរឹងមាំបំផុតដែលមនុស្សគ្រប់រូបមានលើដីធ្លី ។ វាផ្តល់សិទ្ធិទៅម្ចាស់ដី ក្នុងការប្រើប្រាស់ដីនោះទៅតាមមធ្យោបាយ ដែលម្ចាស់ដីចង់ប្រើដរាបការប្រើប្រាស់នោះមិនខុសច្បាប់ណាមួយទេ ។

**២៥. ញត្តិតវ៉ា:** ជាការតវ៉ា ឬសំណូមពរជាលាយលក្ខណ៍អក្សរ ដែលមានហត្ថលេខា ឬស្នាមមេដៃគាំទ្រដោយប្រជាពលរដ្ឋជាច្រើន ដើម្បីទាមទារឱ្យមានការផ្លាស់ប្តូរ ឬមានដំណោះស្រាយចំពោះបញ្ហាអ្វីមួយ ។

**២៦. សិទ្ធិកាន់កាប់ (សិទ្ធិភោគៈ):** ជាសិទ្ធិរបស់អ្នកកាន់កាប់ស្របច្បាប់ ។ សិទ្ធិនេះស្រដៀងគ្នានឹងសិទ្ធិ កម្មសិទ្ធិដែរ ។ អ្នកកាន់កាប់ស្របច្បាប់ក៏មានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិដែរ ។

**២៧. អ្នកតាមដានគម្រោង:**គឺជាអ្នកដែលទទួលខុសត្រូវលើការតាមដានគម្រោង (សូមមើលពាក្យការតាមដានខាងលើ) ។

**២៨. ទីតាំងលំនៅដ្ឋានថ្មី ឬតំបន់តាំងទីលំនៅថ្មី:** ជាកន្លែងរស់នៅថ្មីសម្រាប់ប្រជាពលរដ្ឋដែលរដ្ឋឱ្យផ្លាស់ប្តូរទីលំនៅពីលំនៅដ្ឋានរបស់គាត់ ។ តាមគោលនយោបាយស្តីពីការតាំងទីលំនៅថ្មីដោយបង្ខំរបស់ធនាគារអភិវឌ្ឍន៏អាស៊ី ប្រជាពលរដ្ឋ ត្រូវតែទទួលបានសិទ្ធិកាន់កាប់ដីថ្មីនោះដោយសុវត្ថិភាព ព្រមទាំងត្រូវតែមានលំនៅដ្ឋានល្អប្រសើរជាងលំនៅដ្ឋានចាស់ ។ រដ្ឋាភិបាលក៏ត្រូវតែធ្វើឱ្យប្រាកដថា ប្រជាពលរដ្ឋមានសិទ្ធិ មានឱកាសប្រកបរបរចិញ្ចឹមជីវិត មានហេដ្ឋារចនាសម្ព័ន្ធ និង សេវាកម្មសំខាន់ៗ ដូចជា ទឹក អនាម័យ និងកន្លែងចោលសំរាម ។

២៩. **ផែនការតាំងទីលំនៅថ្មី:** ផែនការតាំងទីលំនៅថ្មីជាផែនការដែលត្រូវរៀបចំដោយរដ្ឋាភិបាល សម្រាប់គម្រោងដែលផ្តល់មូលនិធិគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ដែលធ្វើឱ្យប្រជាពលរដ្ឋផ្លាស់ប្តូរទីលំនៅ។ ផែនការតាំងទីលំនៅថ្មី មានព័ត៌មានសំខាន់ៗអំពីគម្រោងដូចជា ព័ត៌មានអំពីដីដែលគម្រោងត្រូវការយក អំពីការផ្លាស់ប្តូរទីលំនៅ អ្នកដែលត្រូវផ្លាស់ប្តូរទីលំនៅដោយសារគម្រោង និងអំពីផលប៉ះពាល់លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ព័ត៌មានអំពីរបៀបដែលរដ្ឋត្រូវ ធ្វើឱ្យប្រាកដថា ប្រជាពលរដ្ឋបានទទួលព័ត៌មានគ្រប់គ្រាន់ ច្បាស់លាស់ និងមានការពិគ្រោះយោបល់, តើប្រជាពលរដ្ឋ ដែលត្រូវផ្លាស់ប្តូរទីលំនៅត្រូវទទួលបានអ្វីខ្លះ, ជម្រើសសម្រាប់ទីតាំងលំនៅដ្ឋានថ្មី និងតំបន់តាំងទីលំនៅថ្មី, ការគាំទ្រការប្រកបរបរចិញ្ចឹម ជីវិត និងកម្មវិធីជំនួយផ្សេងៗ។

៣០. **គោលនយោបាយការពារ:** គោលនយោបាយទាំងនេះជាវិធានដែលធនាគារអភិវឌ្ឍន៍អាស៊ី និងរដ្ឋាភិបាលត្រូវតែគោរព នៅពេលដែលភាគីទាំងពីរ មានកិច្ចព្រមព្រៀងលើគម្រោងណាមួយ។ វិធានទាំងនេះ មានគោលបំណងទប់ស្កាត់ផលប៉ះ ពាល់លើប្រជាពលរដ្ឋ និងបរិស្ថាន ដែលបណ្តាលមកពីគម្រោងរបស់ធនាគារ។ វិធានទាំងនេះក៏មានគោលបំណងធ្វើឱ្យ ប្រាកដថា ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ ដោយសារគម្រោងនោះ នឹងមានសិទ្ធិទទួលបានព័ត៌មាន និងមានការ ពិគ្រោះយោបល់យ៉ាងត្រឹមត្រូវ។

៣១. **សុវត្ថិភាពនៃការកាន់កាប់ដីធ្លី:** ជាការធានាតាមផ្លូវច្បាប់ថា ប្រជាពលរដ្ឋនឹងមិនត្រូវបង្ខំឱ្យចាកចេញពីលំនៅដ្ឋាន និងដីធ្លីទេ (ប្រសិនបើ វាមិនមែនជាការចាំបាច់ដាច់ខាត និងគ្មានការអនុញ្ញាតដោយច្បាប់ទេ)។

៣២. **ជំនួយបច្ចេកទេស (ដោយធនាគារអភិវឌ្ឍន៍អាស៊ី):** គឺជាការគាំទ្រ និងយោបល់ដែលធនាគារនេះផ្តល់ជូនរដ្ឋាភិបាល។ ឧទាហរណ៍ ធនាគារអភិវឌ្ឍន៍អាស៊ីអាចផ្តល់ជំនួយបច្ចេកទេសដោយជួយរដ្ឋាភិបាល ក្នុងការរៀបចំបង្កើត និង អនុវត្តគម្រោង, បើកវគ្គបណ្តុះបណ្តាលមន្ត្រីរាជការ, ធ្វើការស្រាវជ្រាវ និងប្រមូលព័ត៌មាន, ឬជួយធ្វើសេចក្តីព្រាងគោល នយោបាយ ឬច្បាប់នានា។

៣៣. **ប័ណ្ណកម្មសិទ្ធិ (ដី):** ជាឯកសារផ្លូវការដែលបញ្ជាក់ថា មនុស្សណាម្នាក់ ឬប្រជាពលរដ្ឋ ជាម្ចាស់ដីឡូតិ៍ ដោយស្រប ច្បាប់។

# ព័ត៌មានសម្រាប់ទាក់ទង

## ធនាគារអភិវឌ្ឍន៍អាស៊ី

### ធនាគារអភិវឌ្ឍន៍អាស៊ីៈ

**ការិយាល័យប្រចាំប្រទេសកម្ពុជា**

អគារលេខ២៩ មហាវិថីសុរាមារិត

ប្រអប់សំបុត្រលេខ P.O. Box 2436

សង្កាត់ចតុមុខខណ្ឌដូនពេញ

ភ្នំពេញ កម្ពុជា

ទូរស័ព្ទលេខៈ + ៨៥៥ ២៣ ២១៥ ៨០៥, ២១៥ ៨០៦, ២១៦៤១៧

ទូរសារលេខៈ + ៨៥៥ ២៣ ២១៥ ៨០៧

អ៊ីមែលៈ adbcarm@adb.org

គេហទំព័រៈ www.adb.org/carm

ម៉ោងធ្វើការៈ ០៨:០០ ដល់ ១២:០០, ១៣:០០ ដល់ ១៧:០០ ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ

នាយកប្រចាំប្រទេសៈ Mr. Kamayana

### ការិយាល័យធំរបស់ធនាគារអភិវឌ្ឍន៍អាស៊ី

អគារលេខ៦, មហាវិថីធនាគារអភិវឌ្ឍន៍អាស៊ី

ក្រុងម៉ាន់ដាលូយុង, ១៥៥០

មេត្រូម៉ានីលប្រទេសហ្វីលីពីន

ទូរស័ព្ទលេខៈ + ៦៣២ ៦៣២ ៤៤៤៤

ទូរសារលេខៈ + ៦៣២ ៦៣៦ ២៤៤៤

ប្រធានៈ Haruhiko Kuroda

## យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី

### ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស

Robert C. May

អ្នកសម្របសម្រួលគម្រោងពិសេស, ធនាគារអភិវឌ្ឍន៍អាស៊ី

អគារលេខ៦, មហាវិថីធនាគារអភិវឌ្ឍន៍អាស៊ី

ក្រុងម៉ាន់ដាលូយុង, ១៥៥០

មេត្រូម៉ានីលប្រទេសហ្វីលីពីន

ទូរស័ព្ទលេខ: (៦៣-២) ៦៣២-៤៨២៥

ទូរសារលេខ: (៦៣-២) ៦៣៦-២៤៩០

អ៊ីមែល: spf@adb.org

គេហទំព័រ: http://www.adb.org/SPF/default.asp

## ក្រុមពិនិត្យការប្រតិបត្តិ

លេខា

ក្រុមពិនិត្យការប្រតិបត្តិ, ធនាគារអភិវឌ្ឍន៍អាស៊ី

អគារលេខ៦, មហាវិថីធនាគារអភិវឌ្ឍន៍អាស៊ី

ក្រុងម៉ាន់ដាលូយុង, ១៥៥០

មេត្រូម៉ានីលប្រទេសហ្វីលីពីន

ទូរស័ព្ទលេខ: + ៦៣ ២ ៦៣២ ៤១៤៩

ទូរសារលេខ: +៦៣ ២ ៦៣៦ ២០៨៨

អ៊ីមែល: crp@adb.org

គេហទំព័រ: www.compliance.adb.org

## អង្គការមិនមែនរដ្ឋាភិបាលខ្មែរដែលអាចផ្តល់ជំនួយ

### ក្រុមការងារពិសេសសិទ្ធិលំនៅដ្ឋាន (ក.ព.ស.ល):

អាសយដ្ឋាន: តាមរយៈមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍

អគារលេខ: ៥៤ ផ្លូវលេខ៣០៦ សង្កាត់បឹងកេងកង១ខណ្ឌចំការមនភ្នំពេញ

ទូរស័ព្ទលេខ: ០២៣ ២១៥ ៥៩០

អ៊ីមែល: cam.hrtf@gmail.com

**អង្គការស្ពានទៅកាន់សន្តិភាពកម្ពុជា (BABC):**

អាសយដ្ឋាន: អគារលេខ: ២៦១AB ផ្លូវលេខ: ៣៧១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ ភ្នំពេញ

ទូរស័ព្ទលេខ: ០២៣ ២២០ ៩៣០

អ៊ីមែល: cambodia@babsea.org

គេហទំព័រ: www.babsea.org

**វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (កម្មវិធីដីធ្លី និងជីវភាព):**

អាសយដ្ឋាន: អគារលេខ: ៩-១១ ផ្លូវលេខ: ៤៧៦, សង្កាត់ទួលទំពូង១

ប្រអប់សំបុត្រ:PO. Box 2295, Phnom Penh 3

ទូរស័ព្ទលេខ: ០២៣ ២១៤ ៤២៩, ០២៣ ៩៩៤ ០៦៣

អ៊ីមែល: ngoforum@ngoforum.org.kh

គេហទំព័រ: http://www.ngoforum.org.kh

**សមាគមធាងត្នោត:**

អាសយដ្ឋាន: អគារលេខ: ១៣C ផ្លូវលេខ: ៣៨៤, ១២៣០៩ភ្នំពេញ

ទូរស័ព្ទលេខ: ០២៣ ២២២ ៧៩៤

អ៊ីមែល: info@teangtnaut.org

គេហទំព័រ: www.teangtnaut.org

**អង្គការ លីកាដូ:**

អាសយដ្ឋាន: អគារលេខ: ១៦ ផ្លូវលេខ: ៩៩, បឹងត្របែក ភ្នំពេញ

ប្រអប់សំបុត្រ:PO. Box 499

ទូរស័ព្ទលេខ: ០២៣ ៣៦០ ៩៦៥

អ៊ីមែល: contact@licadho-cambodia.org

គេហទំព័រ: www.licadho-cambodia.org

សូមទូរសព្ទ័ទាក់ទាក់អង្គការលីកាដូសម្រាប់ការិយាល័យតាមបណ្តាខេត្ត

### មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ ( ម.អ.ច.ស)

អាសយដ្ឋានៈ អគារលេខៈ ៥៤ផ្លូវលេខ៣០៦ សង្កាត់បឹងកេងកង១ខណ្ឌចំការមនភ្នំពេញ

ទូរស័ព្ទលេខៈ ០២៣ ២១៥ ៥៩០

អ៊ីមែលៈ admin@clec.org.kh

គេហទំព័រៈ www.clec.org.kh/

## អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិដែលធ្លាប់មានបទពិសោធន៍ធ្វើការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី

**NGO Forum on ADB**
85-A Masikap Extension
Barangay Central, Dilman,
Quezon City, Philippines
Tel: +632 436 1858
Email: secretariat@forum-adb.org
Website: http://www.forum-adb.org/

**Oxfam (Australia)**
132 Leicester Street, Carlton,
Victoria 3053, Australia
Web: http://www.oxfam.org.au/

**Mekong Watch**
2F Maruko Bldg. 1-20-6 HIgahi Ueno, Taito-ku,
Tokyo 110-1-0015, Japan
Email: info@mekongwatch.org
Web: http://mekongwatch.org/english/index.html

**International Accountability Project (IAP)**
221 Pine Street, 5th Floor
San Francisco, CA 94104, USA
Email: iap@accountabilityproject.org
Web: www.accountabilityproject.org

## ព័ត៌មានសម្រាប់ទាក់ទងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

### វិទ្យុអេប៊ីស៊ីអូស្រ្តាលី

អាសយដ្ឋានៈ អគារលេខៈ ១៣A, វត្តកោះ ( ផ្លូវលេខ៨១) បន្ទប់លេខ៥ ជាន់ទី១ Blue Green Office Spaces & Serviced Apartments, 12211 Phnom Penh, P.O Box 414

ទូរស័ព្ទលេខៈ ០២៣ ២២៤ ៦៤០

### ទូរទស្សន៍អប្សរា (ប៉ុស្តិ៍លេខ១១) និងវិទ្យុអេហ្វអឹម ៩៧ MHz

អាសយដ្ឋាន៖ អគារលេខ៖ ៦៩ ផ្លូវលេខ៖ ៣៦០, ភ្នំពេញ

ទូរស័ព្ទលេខ៖ ០២៣ ៩៨៧ ៣៩៥, ទូរសារលេខ៖ ០២៣ ២១៤ ៣០២

អ៊ីមែល៖ info@solaris-mg.com

### វិទ្យុប៊ីប៊ីស៊ីវើលស៊ើវិសត្រាស ១០០ អេហ្វអឹម (ភាសាអង់គ្លេស)

អាសយដ្ឋាន៖ អគារលេខ៖ ៥៨ ផ្លូវលេខ៖ ៣០៦, ១២៣០២ ភ្នំពេញ, P.O Box 155

អ៊ីមែល៖ bbc@bbcwst.org.kh

គេហទំព័រ៖ www.bbcworldservicetrust.org

### កាសែតឌឹខេមបូឌាដេលី (ភាសាអង់គ្លេស)

អាសយដ្ឋាន៖ អគារលេខ៖ ១២៩ ផ្លូវលេខ៖ ២២៨ ភ្នំពេញ

ទូរស័ព្ទលេខ៖ ០២៣ ៤២៦ ៦០២, ០២៣ ៤២៦ ៤៩០

អ៊ីមែល៖ editor@cambodiadaily.com

### ស្ថានីយ៍ទូរទស្សន៍កម្ពុជា ប៉ុស្តិ៍លេខ៩ និងវិទ្យុអេហ្វអឹម ១០៧ MHz

អាសយដ្ឋាន៖ អគារលេខ៖ ១៨ ផ្លូវលេខ៖ ៥៦២, ភ្នំពេញ

ទូរស័ព្ទលេខ៖ ០២៣ ៨៨០ ៨៤៧

អ៊ីមែល៖ tv9cambodia@yahoo.com, info@tv9.com.kh

គេហទំព័រ៖ http://www.tv9.com.kh/

### កាសែតភ្នំពេញប៉ុស្តិ៍ (ភាសាអង់គ្លេស)

ប៉ុស្តិ៍មេឌា ខូអែលធីឌី, អាសយដ្ឋានៈ៨៨៨អគារF, ជាន់ទី៨, មជ្ឈមណ្ឌលភ្នំពេញ (កែងមហាវិថីសុធារសនិងសីហានុ)

សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ

ទូរស័ព្ទលេខ៖ ០២៣ ២១៤ ៣១១,

ទូរសារលេខ៖ ០២៣ ២១៤ ៣១៨

អ៊ីមែល៖ newsroom@phnompenhpost.com

គេហទំព័រ៖ http://www.phnompenhpost.com

## វិទ្យុហ្វ្រង់អ៊ីនធើណេស្យ៊ីនណល់ អេហ្វអឹម ៩២

អាសយដ្ឋាន: អគារលេខ: ២១៨ផ្លូវកែវជា (ផ្លូវលេខ ១៨៤) មជ្ឈមណ្ឌលវប្បធម៌បារាំង ១២២១១ ភ្នំពេញ

ទូរស័ព្ទលេខ: ០២៣ ៧២១ ៣៨៣, ០២៣ ២១១ ១៩៤

## កាសែតរស្មីកម្ពុជាដេលី

អាសយដ្ឋាន: ៤៧៤, មហាវិថីព្រះមុនីវង្ស, ភ្នំពេញ

ទូរស័ព្ទលេខ: ០២៣ ៧២៦ ៦៥៥, ០២៣ ៣៣២ ៨៨១

អ៊ីមែល: rasmei_kampuchea@yahoo.com

## វិទ្យុអាស៊ីសេរី

អាសយដ្ឋាន: ៦៣E0E1 ផ្លូវលេខ: ២៤០ភ្នំពេញប្រអប់សំបុត្រP.O Box 816

ទូរស័ព្ទលេខ: ០២៣ ៩៨២ ៤០៣

អ៊ីមែល: sereyt@pp.rfa.org

គេហទំព័រ: www.rfa.org./khmer

## រ៉យទ័រលីមីតធីត (កម្ពុជា)

អាសយដ្ឋាន: អគារលេខ: ៩ ផ្លូវលេខ: ១៧៤, ១២២១០ ភ្នំពេញ

ទូរស័ព្ទលេខ: ០២៣ ២១៦ ៩៧៧

អ៊ីមែល: reuterpph@yahoo.com

## វិទ្យុសំឡេងសហរដ្ឋអាមេរិក

អាសយដ្ឋាន: អគារលេខ: ២០C, ផ្លូវលេខ: ១០៧, ភ្នំពេញ

ទូរស័ព្ទលេខ: ០៩២ ៣៩២ ៥៣០

គេហទំព័រ: www.voacambodia.com

## វិទ្យុសំឡេងប្រជាធិបតេយ្យ

អាសយដ្ឋាន: អគារលេខ: ១៤A ផ្លូវលេខ: ៣៩២, សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ភ្នំពេញ

ទូរស័ព្ទលេខ: ០២៣ ៧២៦ ៨៤៦, ០២៣ ៧២៦ ៨៤៧

អ៊ីមែល: info@vodradio.org

គេហទំព័រ: www.vodradio.org

## មជ្ឈមណ្ឌលស្ត្រីកម្ពុជាវិទ្យុអេហ្វអឹម ១០២

អាសយដ្ឋាន: អគារលេខ: ៣០ ផ្លូវលេខ: ៤៨៨, ១២៣០៧ភ្នំពេញប្រអប់សំបុត្រP.O Box 497

ទូរស័ព្ទលេខ: ០២៣ ២១២ ២៦៤, ០២៣ ២១៨ ៥៥៦

គេហទំព័រ: www.wmc-cambodia.org

សំណួរស្ទាបស្ទង់ចំណេះដឹងអ្នកចូលរួម មុន និង ក្រោយវគ្គបណ្តុះបណ្តាល

**ការណែនាំ: សូមគូសសញ្ញាខ្វែងនៅប្រអប់ដែលត្រឹមត្រូវ**

**១. បេសកកម្មចម្បងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី គឺដើម្បី**

- ☐ ជួយអោយអ្នកមានកាន់តែមានថែមទៀត
- ☐ កសាងផ្លូវរថភ្លើងឆ្លងកាត់តំបន់អាស៊ី
- ☐ កាត់បន្ថយភាពក្រីក្រ
- ☐ មិនដឹងទេ/ គ្មានយោបល់

**២. គម្រោងដែលគាំទ្រមូលនិធិពីធនាគារអភិវឌ្ឍន៍អាស៊ីបណ្តាលអោយ :**

- ☐ មានតែផលវិជ្ជមាន
- ☐ មានតែផលអវិជ្ជមាន
- ☐ មានផលវិជ្ជមានផង និង ផលអវិជ្ជមានផង
- ☐ មិនដឹងទេ / គ្មានយោបល់

**៣. គោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ីគឺ :**

- ☐ ជាវិធាន/ច្បាប់ដែលការពាររដ្ឋាភិបាលពីការរិះគន់ ពីសំណាក់សហគមន៍
- ☐ ជាវិធាន/ច្បាប់ដែលការពារធនាគារអភិវឌ្ឍន៍អាស៊ី ពីការរិះគន់ពីសំណាក់រដ្ឋាភិបាល
- ☐ ជាវិធាន/ច្បាប់ដែលការពារប្រជាពលរដ្ឋ ពីផលប៉ះពាល់អវិជ្ជមាន ពីគម្រោងធនាគារអភិវឌ្ឍន៍អាស៊ី
- ☐ មិនដឹងទេ /គ្មានយោបល់

**៤. គោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ីចែងថា :**

- ☐ ការផ្លាស់ប្តូរទីលំនៅ គួរតែចៀសវាង និង កាត់បន្ថយអោយនៅតិចបំផុត
- ☐ មានតែប្រជាពលរដ្ឋក្រីក្រទេដែលត្រូវគេបណ្តេញចេញពីទីលំនៅ
- ☐ រដ្ឋាភិបាលអាចបណ្តេញប្រជាពលរដ្ឋច្រើនប៉ុណ្ណាក៏បាន នៅពេលដែលខ្លួនចង់ សាងសង់ផ្លូវរថភ្លើង
- ☐ មិនដឹងទេ /គ្មានយោបល់

**៥. នៅពេលដែលនរណាម្នាក់ត្រូវបានគេផ្លាស់ប្តូរទីលំនៅ ដោយសារគម្រោងដែលគាំទ្រមូលនិធិពីធនាគារអភិវឌ្ឍន៍អាស៊ី :**

- ☐ រដ្ឋាភិបាលមិនមានកាតព្វកិច្ច ផ្តល់សំណង ឬ ជំនួយទេ ប៉ុន្តែរដ្ឋអាចជ្រើសយក ការផ្តល់សំណងដោយខ្លួនឯង
- ☐ រដ្ឋាភិបាលមានកាតព្វកិច្ច ធ្វើអោយប្រាកដថា ប្រជាពលរដ្ឋ មិនមានជីវភាព ដុនដាបជាងមុន ដោយសារការមិនផ្តល់សំណង និង ជំនួយផ្សេងៗ
- ☐ ប្រជាពលរដ្ឋមានសិទ្ធិទទួលសំណងពេញលេញ សំរាប់ដីរបស់ពួកគាត់ ទោះបីជាគាត់មិនមានកម្មសិទ្ធិក៏ដោយ
- ☐ មិនដឹងទេ /គ្មានយោបល់

**៦. នៅពេលដែលប្រជាពលរដ្ឋត្រូវបានគេផ្លាស់ប្តូរទីលំនៅដោយសារគម្រោងដែលផ្តល់មូលនិធិពី ធនាគារអភិវឌ្ឍន៍អាស៊ី :**

- ☐ រដ្ឋាភិបាលត្រូវតែ ធ្វើអោយប្រាកដថា ប្រជាពលរដ្ឋទទួលបានលំនៅដ្ឋាន និងមានសេវាកម្ម សមរម្យ នៅកន្លែងតាំងទីលំនៅថ្មី
- ☐ រដ្ឋាភិបាលអាចស្វែងរកដីនៅកន្លែងណាមួយ នៅក្នុងប្រទេសកម្ពុជា ដើម្បីផ្តល់ជាលំនៅដ្ឋានដល់ពួកគាត់
- ☐ រដ្ឋាភិបាលត្រូវតែផ្តល់តង់មួយដល់ពួកគាត់
- ☐ មិនដឹងទេ /គ្មានយោបល់

**៧. នៅពេលប្រជាពលរដ្ឋបាត់បង់ប្រាក់ចំណូល ដោយសារពួកគាត់ត្រូវផ្លាស់ប្តូរទីលំនៅ ដោយ គម្រោងដែលផ្តល់មូលនិធពីធនាគារអភិវឌ្ឍន៍អាស៊ី:**

- ☐ រដ្ឋាភិបាលគ្មានកាតព្វកិច្ចដើម្បីជួយដល់ពួកគាត់ទេ
- ☐ រដ្ឋាភិបាលត្រូវតែផ្តល់ដល់ពួកគាត់នូវប្រាក់ចំនួន ៥០ ដុល្លារ
- ☐ រដ្ឋាភិបាលមានកាតព្វកិច្ចសងនូវប្រាក់ចំណូលដែលពួកគាត់បានបាត់បង់ទេ
- ☐ មិនដឹងទេ /គ្មានយោបល់

**៨. ក្រោយពេលដែលប្រជាពលរដ្ឋបានផ្លាស់ទីលំនៅ ដោយសារតែគម្រោងផ្តល់មូលនិធិពី ធនាគារអភិវឌ្ឍន៍អាស៊ី :**

- ☐ រដ្ឋាភិបាលគ្មានកាតព្វកិច្ចដើម្បីជួយដល់ពួកគាត់ទេ
- ☐ រដ្ឋាភិបាលត្រូវតែផ្តល់ការគាំទ្រ ដើម្បីឱ្យការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋ និង កំរិតប្រាក់ចំណូលត្រូវបានស្តារឬធ្វើឱ្យប្រសើរឡើងវិញ
- ☐ រដ្ឋាភិបាលអាចផ្លាស់ប្តូរទីលំនៅគាត់ ម្តងទៀតដោយមិនចាំបាច់ជូនដំណឹងជាមុន
- ☐ មិនដឹងទេ /គ្មានយោបល់

**៩. ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ ដោយគម្រោងផ្តល់មូលនិធិពីធនាគារអភិវឌ្ឍន៍អាស៊ី :**

- ☐ មានសិទ្ធិទទួលបានព័ត៌មានអំពីគម្រោង ទំហំនៃផលប៉ះពាល់និង ជម្រើសសំរាប់សំណង និងការតាំងទីលំនៅ
- ☐ មិនចាំបាច់ដឹងច្រើនអំពីគម្រោងទេ គ្រាន់តែដឹងពីចំនួនទឹកប្រាក់ ដែលគាត់ត្រូវទទួលបានហើយ
- ☐ គួរតែធ្វើដំណើទៅរាជធានីភ្នំពេញ ដើម្បីស្វែងរកព័ត៌មាន
- ☐ មិនដឹងទេ /គ្មានយោបល់

**១០. ការពិគ្រោះយោបល់ជាមួយនរណាម្នាក់ មានន័យថា :**

- ☐ ប្រាប់ពីចំនួនទឹកប្រាក់ដែលពួកគាត់ត្រូវទទួលបាន
- ☐ ផ្តល់ឱ្យពួកគាត់នូវសៀវភៅព័ត៌មានមួយ
- ☐ ផ្តល់ជម្រើសជូនប្រជាពលរដ្ឋ និងឱកាសដើម្បីសម្តែងនូវទស្សនៈ និងក្តីបារម្ភរបស់គាត់ និងយកបញ្ហាទាំងអស់នេះទៅពិចារណា ដើម្បីធ្វើការសម្រេចចិត្ត
- ☐ មិនដឹងទេ /គ្មានយោបល់

**១១. បើសិនជាខ្ញុំមានបញ្ហា ឬ ក្តីបារម្ភណ៍អំពីគម្រោងផ្លូវរថភ្លើង :**

- ☐ ខ្ញុំអាចត្រឹមតែប្តឹងទៅសង្កាត់របស់ខ្ញុំ
- ☐ មានយន្តការបណ្តឹងសារទុក្ខពិសេសមួយដែលបង្កើតឡើងសម្រាប់គម្រោង
- ☐ ខ្ញុំគួរតែស្វែងរកមេធាវីម្នាក់ និងធ្វើពាក្យបណ្តឹងទៅតុលាការភ្លាម
- ☐ មិនដឹងទេ/ គ្មានយោបល់